**រាជរដ្ឋាភិបាលកម្ពុជា**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

# កម្មវិធីជាតិ
# សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
# នៅថ្នាក់ក្រោមជាតិ
# ដំណាក់កាលទី២ (២០២១-២០៣០)

**បានទទួលការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា**

**នាថ្ងៃព្រហស្បតិ៍ ៥កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥**

**ត្រូវនឹងថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៣០.សណខ....

# សារលិខិត
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

- ជនរួមជាតិជាទីស្នេហា!

សន្តិភាព ស្ថេរភាពនយោបាយ ការឯកភាពជាតិ និងឯកភាពទឹកដីដែលកើតចេញពីកិច្ចខិតខំប្រឹងប្រែងរបស់យើងទាំងអស់គ្នាប្រកបដោយស្មារតីសាមគ្គីភាព និងការគិតដល់ប្រយោជន៍ជាតិជាធំ គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការស្តារ និងការអភិវឌ្ឍប្រទេសជាតិដែលធ្លាប់ទទួលរងនូវការបំផ្លិចបំផ្លាញយ៉ាងខ្ទេចខ្ទីដោយសង្គ្រាមស៊ីវិលរ៉ាំរ៉ៃជាច្រើនទសវត្សរ៍កន្លងមក។

បន្ទាប់ពីទទួលបានសន្តិភាព ស្ថេរភាពនយោបាយ ការឯកភាពជាតិ និងឯកភាពទឹកដីពេញលេញនាចុងទសវត្សរ៍ទី៩០តាមរយៈការអនុវត្តនយោបាយឈ្នះ-ឈ្នះ បានផ្តល់ឱកាសដ៏កម្រ និងមិនអាចកាត់ថ្លៃបានឱ្យយើងបានខិតខំប្រឹងប្រែងរួមគ្នាក្នុងការកសាងប្រទេសជាតិឡើងវិញ តាមរយៈការរៀបចំ និងដាក់ឱ្យអនុវត្តនូវគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីកំណែទម្រង់លើគ្រប់វិស័យ ដើម្បីធានាដល់ការបន្តថែរក្សាឱ្យបានគង់វង្សនូវសន្តិភាពពេញលេញទូទាំងប្រទេស ព្រមទាំងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឱ្យមានភាពរុងរឿង និងសម្បូរណ៍សប្បាយ ប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គមដែលជាបំណងប្រាថ្នារបស់ប្រជាជនកម្ពុជាគ្រប់រូប។

ផ្អែកលើឆន្ទៈដ៏មោះមុត និងកិច្ចខិតខំប្រឹងប្រែងដោយមិនគិតពីភាពនឿយហត់របស់យើងទាំងអស់គ្នាក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះបានជំរុញឱ្យប្រទេសជាតិយើងឆ្លងផុតនូវដំណាក់កាលអន្តរកាលដ៏សែនលំបាកមួយ។ អត្រានៃភាពក្រីក្ររបស់ប្រជាជនយើងត្រូវបានកាត់បន្ថយយ៉ាងឆាប់រហ័ស។ យោងតាមការវាយតម្លៃចុងក្រោយរបស់គណៈកម្មាធិការសម្រាប់គោលនយោបាយអភិវឌ្ឍនៃអង្គការសហប្រជាជាតិដែលធ្វើឡើងនៅរៀងរាល់៣ឆ្នាំម្តងបានបង្ហាញឱ្យឃើញថា ក្នុងឆ្នាំ២០២១នេះ គឺជាលើកដំបូងក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជាចាប់តាំងពីឆ្នាំ១៩៧៥មក ដែលយើងបានបំពេញតាមលក្ខខណ្ឌគ្រប់គ្រាន់ឱ្យពិភពលោកដកឈ្មោះប្រទេសកម្ពុជាយើងចេញពីឋានៈនៃក្រុមប្រទេសមានការអភិវឌ្ឍតិចតួចបំផុត។

យើងទាំងអស់គ្នាត្រូវទទួលស្គាល់ថា នេះគឺជាសមិទ្ធផលដ៏ធំធេង និងជាប្រវត្តិសាស្ត្រដែលយើងទាំងអស់គ្នាទទួលបានពីកិច្ចខិតខំប្រឹងប្រែងក្រោមម្លប់សន្តិភាពអស់រយៈពេលជាងពីរទសវត្សរ៍មកនេះ។

ក្នុងនាមប្រមុខរាជរដ្ឋាភិបាល ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងប្រជាពលរដ្ឋស្រីប្រុសគ្រប់រូប ដែលបានចូលរួម និងគាំទ្រដល់ការរៀបចំ និងការអនុវត្តនូវគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រជាតិ និងកម្មវិធីកំណែទម្រង់លើគ្រប់វិស័យនានារបស់រាជរដ្ឋាភិបាលរហូតទទួលបាននូវសមិទ្ធផលដ៏ធំធេង និងជាប្រវត្តិសាស្ត្រនេះ។

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ឬហៅថា កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាកំណែទម្រង់អភិបាលកិច្ចដ៏មានសារៈសំខាន់មួយរបស់រាជរដ្ឋាភិបាលដែលបានកំណត់ក្នុងគោលនយោបាយជាតិ និងយុទ្ធសាស្ត្រចតុកោណតាមដំណាក់កាលនីមួយៗជាបន្តបន្ទាប់។ កំណែទម្រង់នេះផ្តោតទៅលើការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិដោយឈរលើគោលការណ៍គន្លឹះនានានៃអភិបាលកិច្ចល្អ គឺភាពជាតំណាង ការចូលរួម ការឆ្លើយតប ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព នីតិរដ្ឋ បរិយាប័ន្ន និងសមធម៌សង្គម។

គោលបំណងដ៏ទូលំទូលាយនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការគឺការបង្កើតនូវវប្បធម៌ប្រជាធិបតេយ្យនៅមូលដ្ឋានដោយមានការចូលរួមពីប្រជាពលរដ្ឋ ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ លើកស្ទួយគុណភាពជីវិត និងចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គម។

ផ្អែកតាមប្រវត្តិសាស្ត្រនៃប្រព័ន្ធគ្រប់គ្រងសាធារណៈ និងស្ថានភាពនៃការផ្លាស់ប្តូររបបនយោបាយនៅកម្ពុជានាពេលកន្លងមក រាជរដ្ឋាភិបាលបានប្រមើលឃើញថា ការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាកិច្ចដំណើរការដែលមានលក្ខណៈសាំញ៉ាំ ស្មុគស្មាញដែលទាមទារឱ្យមានការអនុវត្តក្នុងរយៈពេលយូរអង្វែងមួយ។ ទោះយ៉ាងនេះក្តី រាជរដ្ឋាភិបាលនៅតែមានឆន្ទៈមោះមុត និងច្បាស់លាស់ក្នុងការសម្រេចជ្រើសរើសយកកំណែទម្រង់នេះមករៀបចំ និងអនុវត្តដើម្បីធានាដល់ការលើកកម្ពស់អភិបាលកិច្ច និងការអភិវឌ្ឍមូលដ្ឋានដោយមានការចូលរួមយ៉ាងទូលំទូលាយពីប្រជាពលរដ្ឋ ដែលជាមូលដ្ឋានគ្រឹះយ៉ាងសំខាន់ក្នុងការចូលរួមចំណែកដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិប្រកបដោយនិរន្តរភាពដោយប្រជាពលរដ្ឋគ្រប់រូបទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍនេះប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គម។

ជាការពិតណាស់ យើងបានរៀបចំ និងអនុវត្តកំណែទម្រង់នេះផ្អែកលើបរិបទជាក់ស្តែងនៃស្ថានភាពនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់កម្ពុជាដោយមានការប្រុងប្រយ័ត្នជាទីបំផុត ព្រមទាំងបាន

ប្រកាន់ខ្ជាប់នូវវិធីសាស្ត្រសម្រាប់ការអនុវត្តតាមការរៀនសូត្រផង និងអនុវត្តផងជាជំហានៗដែលត្រូវបានគិតគូរ និងកំណត់យ៉ាងច្បាស់លាស់។ ជាក់ស្តែង យើងបានចាប់ផ្តើមរៀបចំ និងអនុវត្តកំណែទម្រង់នេះពីជំហានដំបូងនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានស្ថិតនៅកៀកជិតប្រជាពលរដ្ឋជាងគេ នោះគឺរដ្ឋបាលឃុំ សង្កាត់។ ផ្អែកលើមេរៀន បទពិសោធន៍ និងជោគជ័យនៃការអនុវត្តនៅថ្នាក់ឃុំ សង្កាត់ យើងបានពង្រីកការរៀបចំ និងការអនុវត្តកំណែទម្រង់នេះនៅរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត នោះគឺរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌជាបន្តបន្ទាប់រហូតមកដល់បច្ចុប្បន្ននេះ។ តាមរយៈការអនុវត្តកំណែទម្រង់នេះ សិទ្ធិអំណាច ការទទួលខុសត្រូវ មុខងារ និងធនធានត្រូវបានផ្ទេរជាបណ្តើរៗពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងន័យ "**បង្វិតការធ្វើសេចក្តីសម្រេចចិត្តលើការផ្តល់សេវាសាធារណៈឱ្យទៅកៀកជិតប្រជាពលរដ្ឋ**" សំដៅជានាដល់ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈចាំបាច់នានាជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរថែមទៀត។

រហូតមកដល់ឆ្នាំ២០២០កន្លងមកនេះ យើងបានអនុវត្តបញ្ចប់នូវកម្មវិធីជាតិរយៈពេល១០ឆ្នាំ ជំណាក់កាលទី១ (ឆ្នាំ២០១០-២០២០) ដោយសម្រេចបាននូវសមិទ្ធផលធំៗជាច្រើនពាក់ព័ន្ធនឹងការរៀបចំដាក់ឱ្យដំណើរការស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ទន្ទឹមគ្នានេះ មុខងារ និងធនធានចាំបាច់នានាក៏ត្រូវបានផ្ទេរជាបណ្តើរៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់សម្រាប់ការអនុវត្តមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ចក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយភាពម្ចាស់ការ ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម។

ការវិវឌ្ឍនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមដំណាក់កាលនីមួយៗបានជំរុញឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានសមត្ថភាពក្នុងការទទួលខុសត្រូវលើការផ្តល់សេវាសាធារណៈ ក៏ដូចជាការដោះស្រាយបញ្ហាប្រឈមនានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយភាពម្ចាស់ការ។ ជាក់ស្តែង ក្នុងពេលដែលប្រទេសយើងជួបស្ថានភាពដ៏លំបាកនៃការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ដែលទាមទារឱ្យរាជរដ្ឋាភិបាលត្រូវមានវិធានការចាំបាច់នានា និងជាបន្ទាន់ ក៏ដូចជាករណីដែលមានគ្រោះមហន្តរាយផ្សេងទៀត ដូចជាគ្រោះទឹកជំនន់ ភាពរាំងស្ងួតដែលបានកើតឡើងនៅតាមតំបន់មួយចំនួន យើងបានកត់សម្គាល់ឃើញថា រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗបានម្ចាស់ការក្នុងការចូលរួមចាត់វិធានការការពារ ទប់ស្កាត់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីជួយសង្គ្រោះប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ទាំងនោះបានយ៉ាងឆាប់រហ័ស ទាន់ពេលវេលា និងមានប្រសិទ្ធភាព។

ក្នុងគោលបំណងជំរុញការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត រាជរដ្ឋាភិបាលបានសម្រេចរៀបចំ និងដាក់ឱ្យអនុវត្តនូវ "**កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាម**

បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២” រយៈពេល១០ឆ្នាំបន្ថែមទៀត គឺចាប់ពីឆ្នាំ ២០២១ដល់ឆ្នាំ២០៣០ សំដៅបន្តពង្រឹងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានសក្តានុពលក្នុង ការចូលរួមចំណែកសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ពោលគឺ “**ការប្រែក្លាយកម្ពុជាឱ្យទៅជា ប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០**”។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** (គ.ជ.អ.ប.) ដែល បានដឹកនាំ សម្របសម្រួលកិច្ចដំណើរការកំណែទម្រង់ដ៏មានសារៈសំខាន់នេះឱ្យមានការវិវឌ្ឍជាជំហានៗ ស្របតាមគោលនយោបាយជាតិ និងឆន្ទៈរបស់រាជរដ្ឋាភិបាល។

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២នេះ គឺ ជាអាទិភាពដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាល អាស្រ័យហេតុនេះ ខ្ញុំស្នើឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធនានា ទាំងនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបន្តការគាំទ្រ និងចូលរួមអនុវត្តឱ្យកាន់តែសកម្មបន្ថែម ទៀតក្នុងកិច្ចដំណើរការនៃកំណែទម្រង់នេះស្របតាមតួនាទី និងការទទួលខុសត្រូវដែលបានកំណត់។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមអំពាវនាវដល់សាធារណជន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ ផ្នែក ឯកជន និងអ្នកពាក់ព័ន្ធទាំងអស់ផ្តល់ការគាំទ្រ និងចូលរួមអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២នេះឱ្យទទួលបានជោគជ័យតាមការរំពឹងទុក សំដៅ ចូលរួមចំណែកក្នុងការលើកកម្ពស់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិ និងគុណភាពជីវិតរបស់ប្រជាពលរដ្ឋ គ្រប់រូបឱ្យមានភាពកាន់តែប្រសើរឡើង។

*ថ្ងៃ..ព្រហស្បតិ៍..៥..កើត.. ខែ..មិគសិរ.. ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥*

*រាជធានីភ្នំពេញ ថ្ងៃទី.......៩....... ខែ.....ធ្នូ.......... ឆ្នាំ ២០២១*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# អារម្ភកថា

ឯកសារកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ គឺជាឯកសារដែលត្រូវបានរៀបចំតាក់តែងឡើង ដើម្បីផ្តល់ផែនទីបង្ហាញផ្លូវសម្រាប់ការបន្តអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរយៈពេលវែងមួយបន្ថែមទៀត ពោលគឺពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ បន្ទាប់ពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី១ត្រូវបានបញ្ចប់នាចុងឆ្នាំ២០២០។

ឯកសារកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ នេះត្រូវបានរៀបចំតាក់តែងឡើងដោយផ្អែកលើសមិទ្ធផលដែលបានបង្កើតឡើង និងបញ្ហាប្រឈមដែលនៅសេសសល់ពីការអនុវត្តកម្មវិធីជាតិដំណាក់កាលទី១ ព្រមទាំងផ្អែកលើគោលការណ៍ណែនាំតម្រង់ទិសពីប្រមុខរាជរដ្ឋាភិបាលអំពីចក្ខុវិស័យនៃការធ្វើវិមជ្ឈការ និងវិសហមជ្ឈការសម្រាប់រយៈពេល១០ឆ្នាំបន្ទាប់។

ឯកសារកម្មវិធីជាតិដំណាក់កាលទី២នេះត្រូវបានរៀបចំតាក់តែងឡើងក្រោមការដឹកនាំ សម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) ដោយមានការគាំទ្របច្ចេកទេសពីក្រុមទីប្រឹក្សាជំនាញបច្ចេកទេសជាតិ និងអន្តរជាតិ ព្រមទាំងដោយមានការចូលរួម និងពិគ្រោះយោបល់យ៉ាងទូលំទូលាយពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា។ ឯកសារកម្មវិធីជាតិដំណាក់កាលទី២នេះបានដាក់ឆ្លងកិច្ចប្រជុំលើកទី១៩របស់ គ.ជ.អ.ប. នាថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ មុននឹងទទួលបានការពិនិត្យ និងអនុម័តពីប្រមុខរាជរដ្ឋាភិបាល។

ឯកសារកម្មវិធីជាតិដំណាក់កាលទី២បានបរិយាយអំពីចក្ខុវិស័យ គោលបំណង គោលដៅ និងសមិទ្ធផលរំពឹងទុកសំខាន់ៗនៃការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរយៈពេល១០ឆ្នាំខាងមុខ ព្រមទាំងកំណត់នូវសមាសភាគសំខាន់ៗចំនួន៥ ដែលក្នុងសមាសភាគនីមួយៗបានរៀបរាប់អំពីលទ្ធផលរំពឹងទុក យុទ្ធសាស្ត្រ និងសកម្មភាពជាអាទិភាពនានាដែលត្រូវអនុវត្តដើម្បីឈានទៅសម្រេចបាននូវសមិទ្ធផលរំពឹងទុក គោលដៅ គោលបំណង និងចក្ខុវិស័យនៃកំណែទម្រង់នេះ ពោលគឺ "**ការពង្រឹងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានសមត្ថភាពក្នុងការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គម ដើម្បីចូលរួមចំណែកអភិវឌ្ឍកម្ពុជាឱ្យក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០**"។

ឯកសារកម្មវិធីជាតិដំណាក់កាលទី២ក៏បានរៀបរាប់អំពីភាពចាំបាច់នៃការរៀបចំ និងអនុវត្តសកម្មភាពអាទិភាពតាមសមាសភាគនីមួយៗប្រកបដោយភាពប្រទាក់ក្រឡា និងស៊ីសង្វាក់គ្នាជាមួយកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងកំណែទម្រង់តាមវិស័យពាក់ព័ន្ធនានា ព្រមទាំងកំណត់អំពីកិច្ចការអន្តរវិស័យនានា រួមមាន ការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ននិងសមធម៌សង្គម និងការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា

ដែលត្រូវបញ្ជ្រាបទៅក្នុងសកម្មភាពជាអាទិភាពនានានៃសមាសភាគទាំង៥ផងដែរ។

ទន្ទឹមគ្នានេះ ឯកសារកម្មវិធីជាតិដំណាក់កាលទី២បានផ្ដល់គោលការណ៍តម្រង់ទិសអំពីបែបផែននៃការអនុវត្តដែលរួមមានការរៀបចំជាផែនការអនុវត្ត៥ឆ្នាំចំនួនពីរដំណាក់កាល ផែនការយុទ្ធសាស្ត្រថវិកា និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ ព្រមទាំងការកំណត់អំពីតួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នមិនមែនរដ្ឋដែលត្រូវមានភាពចាំបាច់ក្នុងការគាំទ្រ និងចូលរួមអនុវត្តសកម្មភាពជាអាទិភាពនានានៃកម្មវិធីជាតិដំណាក់កាលទី២។

ក្នុងនាម គ.ជ.អ.ប. ខ្ញុំសង្ឃឹមជឿជាក់ថា ឯកសារកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២នេះនឹងផ្ដល់សារៈប្រយោជន៍យ៉ាងច្រើនដល់ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំ មន្ត្រីរាជការនៃស្ថាប័នរដ្ឋទាំងនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្ថាប័នមិនមែនរដ្ឋ អ្នកសិក្សាស្រាវជ្រាវ និងសាធារណជនក្នុងការស្វែងយល់អំពីដំណើរការវិវឌ្ឍនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនាពេលកន្លងមក និងទិសដៅនៃកំណែទម្រង់ដ៏មានសារៈសំខាន់នេះសម្រាប់រយៈពេល១០ឆ្នាំខាងមុខ ព្រមទាំងទទួលបានការគាំទ្រពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់នៃរាជរដ្ឋាភិបាល គណបក្សនយោបាយ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងប្រជាពលរដ្ឋគ្រប់រូប។

ខ្ញុំសូមសម្ដែងនូវឧបការគុណ និងវាយតម្លៃខ្ពស់ចំពោះរាល់អនុសាសន៍នានារបស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលតែងផ្ដល់ជាគោលការណ៍ដឹកនាំសំខាន់ៗសម្រាប់ជំរុញកិច្ចដំណើរការកំណែទម្រង់នេះ។

ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាថ្នាក់ដឹកនាំ ជាមន្ត្រីរាជការនៃក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ គណបក្សនយោបាយ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងសាធារណជនទាំងអស់ដែលបានផ្ដល់ការគាំទ្រ និងចូលរួមក្នុងការរៀបចំ និងអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងរយៈពេលជាង២ទសវត្សរ៍កន្លងមកនេះ និងសូមអំពាវនាវឱ្យបន្តផ្ដល់ការគាំទ្រ និងចូលរួមអនុវត្តឱ្យកាន់តែមានភាពសកម្មបន្ថែមទៀត ដើម្បីជានាជំរុញឱ្យកំណែទម្រង់នេះទទួលបានជោគជ័យតាមការរំពឹងទុក៕

*ថ្ងៃ...ពុធ ១២រោច...... ខែ...កត្តិក.... ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥*

*រាជធានីភ្នំពេញ ថ្ងៃទី...០១........ ខែ......ធ្នូ.......... ឆ្នាំ ២០២១*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប.**

**សម្ដេចក្រឡាហោម ស ខេង**

# មាតិកា


**ជំពូកទី១** ...................... ១

**សេចក្តីផ្តើម** ...................... ១

១.១. សារតារ ...................... ១

១.២. សនិទានភាព ...................... ២

១.៣. សមិទ្ធផល ...................... ៦

១.៤. បញ្ហាប្រឈម ...................... ៩

១.៥. ដំណើរការនៃការរៀបចំតាក់តែងកម្មវិធីជាតិជំណាក់កាលទី២ ...................... ១២

១.៦. រចនាសម្ព័ន្ធនៃកម្មវិធីជាតិ ...................... ១៣

**ជំពូកទី២** ...................... ១៥

**ទិដ្ឋភាពទូទៅនៃកម្មវិធីជាតិ** ...................... ១៥

២.១. ចក្ខុវិស័យ ...................... ១៥

២.២. គោលបំណង ...................... ១៦

២.៣. គោលដៅ ...................... ១៦

២.៤. សមាសភាគ កិច្ចការអន្តរវិស័យ និងសមិទ្ធផលរំពឹងទុកនៃកម្មវិធីជាតិ ...................... ១៧

២.៥. យុទ្ធសាស្ត្រនៃការអនុវត្តកម្មវិធីជាតិ ...................... ១៨

**ជំពូកទី៣** ...................... ២០

**សមាសភាគនៃកម្មវិធីជាតិ** ...................... ២០

៣.១. សមាសភាគទី១៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់ ...................... ២០

៣.១.១. សនិទានភាព ...................... ២០

៣.១.២. ទិដ្ឋភាពទូទៅនៃសមាសភាគទី១ ...................... ២៤

៣.២. សមាសភាគទី២៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ...................... ៤៤

៣.២.១. សនិទានភាព ...................... ៤៤

៣.២.២. ទិដ្ឋភាពទូទៅនៃសមាសភាគទី២ ...................... ៤៥

៣.៣. សមាសភាគទី៣៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ...................... ៧៤

៣.៣.១. សនិទានភាព ...................... ៧៤

៣.៣.២. ទិដ្ឋភាពទូទៅនៃសមាសភាគទី៣ ........................................ ៧៥
៣.៤. សមាសភាគទី៤៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ........................................ ១០៤
៣.៤.១. សនិទានភាព ........................................ ១០៤
៣.៤.២. ទិដ្ឋភាពទូទៅនៃសមាសភាគទីបួន ........................................ ១០៦
៣.៥. សមាសភាគទី៥៖ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ........................................ ១៤៣
៣.៥.១. សនិទានភាព ........................................ ១៤៣
៣.៥.២. ទិដ្ឋភាពទូទៅនៃសមាសភាគទី៥ ........................................ ១៤៤
៣.៦. កិច្ចការអន្តរវិស័យ ........................................ ១៦១
៣.៦.១. ការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ........................................ ១៦១
៣.៦.២. ការគ្រប់គ្រងការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយ ហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា ........................................ ១៦៣
**ជំពូកទី៤** ........................................ ១៦៧
**ការគ្រប់គ្រង និងការអនុវត្តកម្មវិធីជាតិ** ........................................ ១៦៧
៤.១. ក្របខ័ណ្ឌសម្រាប់អនុវត្តកម្មវិធីជាតិជំណាក់កាលទី២ ........................................ ១៦៧
៤.១.១. ស្ថាប័នអនុវត្តកម្មវិធីជាតិជំណាក់កាលទី២ ........................................ ១៦៧
៤.១.២. កិច្ចដំណើរការរៀបចំផែនការ និងថវិកា ........................................ ១៧២
៤.២. ការតាមដាន និងការវាយតម្លៃកម្មវិធីជាតិជំណាក់កាលទី២ ........................................ ១៧៧
៤.២.១. វិសាលភាពនៃការតាមដាន និងការវាយតម្លៃកម្មវិធី ........................................ ១៧៧
៤.២.២. សូចនាករ និងវិធីសាស្ត្រសម្រាប់ការវាស់វែងការផ្លាស់ប្តូរ ........................................ ១៧៧
៤.២.៣. ក្របខ័ណ្ឌលទ្ធផលកម្មវិធីជាតិ ........................................ ១៧៩
៤.២.៤. ប្រព័ន្ធទិន្នន័យសម្រាប់ការតាមដាន និងការវាយតម្លៃ ........................................ ១៨០
៤.២.៥. ផែនការសកម្មភាព និងថវិកាសម្រាប់ការតាមដាន និងការវាយតម្លៃ ........................................ ១៨១
៤.២.៦. ការវាយតម្លៃការអនុវត្ត កជទី២ ........................................ ១៨១
៤.២.៧. ការសិក្សាដែលមានលក្ខណៈជាការវាយតម្លៃ និងការស្រាវជ្រាវ ........................................ ១៨៤
៤.២.៨. ការរៀបចំរបាយការណ៍ស្តីពីការអនុវត្ត កជទី២ ........................................ ១៨៥
៤.៣. ការគ្រប់គ្រងហានិភ័យ ........................................ ១៨៥
៤.៣.១. ចំណាត់ថ្នាក់ហានិភ័យនានា ........................................ ១៨៦

៤.៣.២. ការគ្រប់គ្រងហានិភ័យ..................................................................................១៨៨
**ជំពូកទី ៥** ..................................................................................................... ១៩០
**ការចំណាយនានា និងការផ្តល់ហិរញ្ញប្បទាននៃកម្មវិធី** ................................................ ១៩០
**ជំពូកទី ៦** ..................................................................................................... ១៩២
**សេចក្តីសន្និដ្ឋាន** ............................................................................................. ១៩២
**សន្ទានុក្រម** ..................................................................................................១៩៤

# បញ្ជីតារាង

តារាងទី ១ ៖ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពនានាសម្រាប់សមាសភាគទី១ ............... ៣៩

តារាងទី ២ ៖ ការគ្រប់គ្រងហានិភ័យសំខាន់ៗសម្រាប់សមាសភាគទី១ ........................................ ៤៣

តារាងទី ៣ ៖ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពនានាសម្រាប់សមាសភាគទី២ ............... ៦៦

តារាងទី ៤ ៖ ការគ្រប់គ្រងហានិភ័យសំខាន់ៗសម្រាប់សមាសភាគទី២ ........................................ ៧១

តារាងទី ៥ ៖ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពនានាសម្រាប់សមាសភាគទី៣ ............... ៩៧

តារាងទី ៦ ៖ ការគ្រប់គ្រងហានិភ័យសំខាន់ៗសម្រាប់សមាសភាគទី៣ ..................................... ១០២

តារាងទី ៧ ៖ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពនានាសម្រាប់សមាសភាគទី៤ ............ ១៣៦

តារាងទី ៨ ៖ ការគ្រប់គ្រងហានិភ័យសំខាន់ៗសម្រាប់សមាសភាគទី៤ ..................................... ១៤១

តារាងទី ៩ ៖ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពនានាសម្រាប់សមាសភាគទី៥ ............ ១៥៧

តារាងទី ១០ ៖ ការគ្រប់គ្រងហានិភ័យសំខាន់ៗសម្រាប់សមាសភាគទី៥ ..................................... ១៦០

តារាងទី ១១ ៖ ការគ្រប់គ្រងហានិភ័យសំខាន់ៗសម្រាប់កិច្ចការអន្តរវិស័យ ................................... ១៦៥

តារាងទី ១២ ៖ ការគ្រប់គ្រងហានិភ័យដែលមានលក្ខណៈទូទៅ (កម្រិតកម្មវិធី) ............................ ១៨៨

តារាងទី ១៣ ៖ ការគ្រប់គ្រងហានិភ័យតាមការកំណត់ជាពណ៌ ................................................... ១៨៩

តារាងទី ១៤ ៖ ការប៉ាន់ស្មានតាមប្រភេទចំណាយនៃកម្មវិធីជាតិ ................................................... ១៩០

# ជំពូកទី១

## សេចក្តីផ្តើម

### ១.១. សាវតារ

រាជរដ្ឋាភិបាលបានចាត់ទុកកំណែទម្រង់អភិបាលកិច្ច គឺជាកិច្ចការដ៏មានសារៈសំខាន់ក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដើម្បីឈានឆ្ពោះទៅសម្រេចឱ្យបាននូវឋានៈជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលបាននិងកំពុងធ្វើទំនើបកម្មយ៉ាងទូលំទូលាយ និងស៊ីជម្រៅនូវប្រព័ន្ធអភិបាលកិច្ចតាមរយៈកម្មវិធីកំណែទម្រង់នានារួមមាន កម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឬហៅថាកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងកម្មវិធីកំណែទម្រង់តាមវិស័យនានា។

កម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានចាប់ផ្តើមក្នុងដំណាក់កាលដំបូងជាប្រវត្តិសាស្ត្រតាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស និងការដាក់ឱ្យដំណើរការនូវប្រព័ន្ធគ្រប់គ្រងតាមបែបវិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់នាឆ្នាំ២០០២ ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ផ្អែកតាមបទពិសោធន៍ និងភាពជោគជ័យនៃការអនុវត្តកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់ រាជរដ្ឋាភិបាលបានពង្រីកវិសាលភាពនៃកំណែទម្រង់នេះទៅគ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការបោះឆ្នោតអសកលជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទូទាំងប្រទេស និងការដាក់ឱ្យដំណើរការនូវប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបវិមជ្ឈការ និងវិសហមជ្ឈការនាឆ្នាំ២០០៩ ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

កម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងដំណាក់កាលនៃការពង្រីកនេះគឺមានវិសាលភាពកាន់តែទូលំទូលាយពាក់ព័ន្ធគ្រប់ក្រសួង ស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងមានលក្ខណៈសាំញ៉ាំស្មុគស្មាញដែលទាមទារឱ្យរាជរដ្ឋាភិបាលត្រូវរៀបចំ និងដាក់ឱ្យអនុវត្តនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំ គឺចាប់ពីឆ្នាំ២០១០-២០២០ (ហៅកាត់ថា កជទី១) ដើម្បីផ្តល់ជាផែនទីបង្ហាញផ្លូវសម្រាប់អនុវត្តច្បាប់រៀបចំអង្គការពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។ កម្មវិធីជាតិនេះ ត្រូវបានបញ្ចប់នៅចុងឆ្នាំ២០២០ ដោយសម្រេចបានសមិទ្ធផលសំខាន់ៗជាច្រើនពាក់ព័ន្ធនឹងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ការលើកកម្ពស់សិទ្ធិអំណាចនិងការចូលរួមរបស់ប្រជាពលរដ្ឋ ការលើកកម្ពស់គុណភាពនៃ

ការផ្តល់សេវាសាធារណៈ និងការទទួលបាននូវផលប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋានប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គម តាមរយៈការបង្កើតឡើងនូវរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការផ្ទេរមុខងារក្នុងការផ្តល់សេវាសាធារណៈនិងការអភិវឌ្ឍមូលដ្ឋាន ការធ្វើវិមជ្ឈការហិរញ្ញវត្ថុ ការផ្ទេរបុគ្គលិកនិងការកសាងសមត្ថភាពដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ការលើកកម្ពស់តួនាទីស្ត្រីក្នុងដំណើរការអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ ព្រមទាំងការផ្តល់សេវាសាធារណៈមានការឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងក្រុមជនងាយរងគ្រោះនានា។ ទោះជាយ៉ាងនេះក្តី ក្នុងការអនុវត្តកម្មវិធីជាតិនេះបានជួបនូវបញ្ហាប្រឈមជាគន្លឹះមួយចំនួន។

ក្នុងគោលបំណងបន្តដោះស្រាយនូវបញ្ហាប្រឈមទាំងនេះ បន្តអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការឱ្យកាន់តែស៊ីជម្រៅ និងបន្តចូលរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ រាជរដ្ឋាភិបាលសម្រេចរៀបចំតាក់តែងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (ហៅកាត់ថា កជទី២) សម្រាប់រយៈពេល១០ឆ្នាំ គឺចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០។

កជទី២នេះ បានរៀបចំតាក់តែងដោយផ្អែកលើឯកសារទស្សនទាន ដែលបានរៀបចំឡើងដោយមានការចូលរួម និងការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ព្រមទាំងទទួលបានការឯកភាព និងគោលការណ៍ណែនាំតម្រង់ទិសពី **សម្តេចអគ្គមហាសេនាបតី តេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០។

កជទី២នេះ ពិពណ៌នាអំពីសនិទានភាពនៃការរៀបចំ និងការអនុវត្តកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សមិទ្ធផលសំខាន់ៗដែលសម្រេចបានក្នុងអំឡុងពេលនៃការអនុវត្តកជទី១ និងបញ្ហាប្រឈមជាគន្លឹះនានាដែលត្រូវបន្តដោះស្រាយក្នុងកជទី២ ព្រមទាំងកំណត់អំពីចក្ខុវិស័យ គោលបំណង គោលដៅ សមិទ្ធផលរំពឹងទុក សមាសភាគសំខាន់ៗ យុទ្ធសាស្ត្រសម្រាប់ការអនុវត្ត ក្របខ័ណ្ឌលទ្ធផលសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រងហានិភ័យ និងការប៉ាន់ប្រមាណធនធានដែលត្រូវការសម្រាប់គាំទ្រដល់ការអនុវត្តកជទី២។

កជទី២នេះ នឹងត្រូវរៀបចំ និងអនុវត្តជាពីរដំណាក់កាល។ ផែនការអនុវត្តដំណាក់កាលទី១មានរយៈពេល៥ឆ្នាំ គឺចាប់ពីឆ្នាំ២០២១-២០២៥ (ហៅកាត់ថា ផអ៥ទី១) និងផែនការអនុវត្តដំណាក់កាលទី២មានរយៈពេល៥ឆ្នាំ គឺចាប់ពីឆ្នាំ២០២៦-២០៣០ (ហៅកាត់ថា ផអ៥ទី២) នឹងត្រូវរៀបចំជាឯកសារដាច់ដោយឡែកពីឯកសារកជទី២ នេះ។

### ១.២. សនិទានភាព

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលបានអនុម័តក្នុងឆ្នាំ១៩៩៣ បានកំណត់ប្រទេសកម្ពុជាគឺជារដ្ឋទោល ហើយរដ្ឋធម្មនុញ្ញដែលបានធ្វើវិសោធនកម្មនៅក្នុងឆ្នាំ២០០៨ ដែលក្នុងនោះ មាត្រា ១៤៥ ថ្មី

បានចែងថា ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ត្រូវគ្រប់គ្រងតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការ ដែលបច្ចុប្បន្ននេះរួមមានដូចជា ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

រដ្ឋបាលថ្នាក់ក្រោមជាតិនៃព្រះរាជាណាចក្រកម្ពុជារួមមាន៣កម្រិត គឺ ១). រដ្ឋបាលរាជធានី ខេត្ត ២). រដ្ឋបាលក្រុង ស្រុក ខណ្ឌ និង ៣). រដ្ឋបាលឃុំ សង្កាត់។

នាពេលបច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជាមានរាជធានីចំនួន០១ និងខេត្តចំនួន២៤។ រាជធានីត្រូវបានបែងចែកជា១៤ខណ្ឌ និង១០៥សង្កាត់។ រដ្ឋបាលនៅទីប្រជុំជននៃខេត្តនីមួយៗ និងតំបន់ទីប្រជុំជនសំខាន់ៗចំនួន៤ទៀតត្រូវបានកំណត់ជារដ្ឋបាលក្រុង។ រដ្ឋបាលក្រុងទាំង២៨នេះ ត្រូវបានបែងចែកជា២៤៦សង្កាត់។ ក្រៅពីរដ្ឋបាលក្រុង ទឹកដីដែលនៅសល់ក្នុងខេត្តទាំងអស់ត្រូវបានបែងចែកជា១៦២ស្រុក ដែលចែកជា១.៤០៦ឃុំ។ ដូច្នេះ ចំនួនសរុបនៃរដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន រដ្ឋបាលរាជធានី ខេត្តចំនួន២៥ រដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន២០៤ និងរដ្ឋបាលឃុំ សង្កាត់ចំនួន១.៦៥២។

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិក។ ក្រុមប្រឹក្សានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបានជ្រើសរើសតាមការបោះឆ្នោតជាអសកលដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។ គណៈអភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបានតែងតាំងដោយថ្នាក់ជាតិ។ បុគ្គលិកភាគច្រើនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវតែងតាំងដោយរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ចសាមីនីមួយៗ។

រដ្ឋបាលឃុំ សង្កាត់គ្រប់គ្រងដោយក្រុមប្រឹក្សា ដែលត្រូវបានជ្រើសរើសឡើងតាមការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋ។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់គឺជាមេឃុំ ចៅសង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានស្មៀន០១រូប ដែលបានតែងតាំងឱ្យជួយក្រុមប្រឹក្សាក្នុងការបំពេញការងាររបស់ខ្លួន។ ក្រៅពីស្មៀន ក្រុមប្រឹក្សាឃុំ សង្កាត់អាចជ្រើសរើសជំនួយការរដ្ឋបាល ដើម្បីជួយបំពេញការងារតាមការចាំបាច់។ មេភូមិ និងជំនួយការភូមិ (ភូមិមិនមែនជាថ្នាក់រដ្ឋបាលឡើយ) ក៏មានតួនាទីជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ផងដែរ។

រដ្ឋបាលថ្នាក់ក្រោមជាតិបំពេញតួនាទីជាតំណាងឱ្យប្រជាពលរដ្ឋ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងការផ្តល់សេវាសាធារណៈចាំបាច់នានាជូនប្រជាពលរដ្ឋ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមមូលដ្ឋាន។ ជាមួយគ្នានេះដែរ រដ្ឋបាលថ្នាក់ក្រោមជាតិក៏មានតួនាទី និងការទទួលខុសត្រូវក្នុងការអនុវត្តនូវមុខងារនានាក្នុងនាមជាតំណាងឱ្យថ្នាក់ជាតិផងដែរ។ ចាប់ពីឆ្នាំ១៩៩៣ រហូតដល់មុនឆ្នាំ២០០២ មុខងារផ្តល់សេវាសាធារណៈភាគច្រើននៅថ្នាក់ក្រោមជាតិត្រូវបានគ្រប់គ្រង និងចាត់ចែងតាមបែបមជ្ឈការដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន ដោយមានមន្ទីរ អង្គភាព និងការិយាល័យជំនាញខ្សែបណ្តោយរបស់ខ្លួននៅថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ។ មន្ទីរ អង្គភាព និងការិយាល័យជំនាញទាំងនេះត្រូវ

មានគណនេយ្យភាពផ្ទាល់ជាមួយក្រសួង ស្ថាប័នសាមីនៅថ្នាក់ជាតិ។ ក្នុងអំឡុងពេលនៃការអនុវត្តកដទី១ មុខងារផ្តល់សេវាសាធារណៈចាំបាច់មួយចំនួនត្រូវបានផ្ទេរឱ្យទៅស្ថិតក្រោមការគ្រប់គ្រង និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ នៅចុងឆ្នាំ២០១៩ ការិយាល័យជំនាញនៃក្រសួង ស្ថាប័ននៅថ្នាក់ក្រុង ស្រុក ខណ្ឌត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌតាមគោលការណ៍នៃរដ្ឋបាលឯកភាព។

ទោះបីជារចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីបំពេញការងារត្រូវបានរៀបចំ និងកែលម្អជាបណ្តើរៗក៏ដោយ ក៏កិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅមិនទាន់សម្រេចបាននូវគោលបំណងជាចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការប្រែក្លាយរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យក្លាយជាស្ថាប័នដែលមានភាពរឹងមាំ មានសមត្ថភាព មានសិទ្ធិអំណាច មានមុខងារ ធនធាន និងការទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយប្រសិទ្ធភាព និងនវានុវត្តន៍ ដើម្បីលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ និងរួមចំណែកដល់ការសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ២០៣០។

ដើម្បីធានាសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលបានកំណត់យក**ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច**ធ្វើជាស្នូលនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយផ្តោតលើការធ្វើទំនើបកម្មស្ថាប័នរដ្ឋ និងការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គមតាមរយៈការអនុវត្តសិទ្ធិអំណាចរដ្ឋខាងផ្នែកនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាលក្នុងការដឹកនាំ ការគ្រប់គ្រង និងការចាត់ចែងកិច្ចការរបស់ប្រទេសជាតិ ជាពិសេសការធានានិរន្តរភាពនៃតួនាទី និងដំណើរការរដ្ឋបាលសាធារណៈដោយយកចិត្តទុកដាក់លើអត្ថប្រយោជន៍ប្រជាពលរដ្ឋជាស្នូល និងការអភិវឌ្ឍជាតិ។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលចាំបាច់ត្រូវរៀបចំប្រព័ន្ធរដ្ឋបាលសាធារណៈដ៏មានប្រសិទ្ធភាព ជាពិសេសនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងគុណភាពខ្ពស់ ព្រមទាំងបង្កបរិយាកាសសមស្រប ដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋប្រកបដោយនវានុវត្តន៍នៅក្នុងប្រព័ន្ធនេះ។

គោលនយោបាយ និងកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិគឺជាសមាសធាតុសំខាន់មួយនៃកំណែទម្រង់អភិបាលកិច្ចរបស់រាជរដ្ឋាភិបាល។ កំណែទម្រង់នេះមានគោលបំណងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពនានារបស់ប្រជាពលរដ្ឋផ្អែកតាមស្ថានភាពជាក់ស្តែងនៅតាមមូលដ្ឋាននីមួយៗ តាមរយៈការផ្ទេរមុខងារ និងធនធានកាន់តែច្រើនឡើងទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

ការផ្ទេរមុខងារទាំងនេះត្រូវផ្អែកលើគោលការណ៍ "សាប់ស៊ីឌីយ៉ារីធី" ដែលគោលការណ៍នេះរួមមានចំណុចជាគន្លឹះៗចំនួន៣ ពោលគឺ៖ ១). ការទទួលខុសត្រូវក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារនានានឹងត្រូវផ្តល់អាទិភាពទៅឱ្យរដ្ឋបាលដែលនៅកៀកជិតប្រជាពលរដ្ឋជាងគេ និងអាច

គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារនោះប្រកបដោយប្រសិទ្ធភាព ២). ក្នុងករណីដែលរដ្ឋបាលនៅកៀកជិតប្រជាពលរដ្ឋមិនអាចគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារណាមួយបាន នោះរដ្ឋបាលថ្នាក់លើបន្ទាប់ត្រូវជួយគាំទ្រដល់រដ្ឋបាល ដែលនៅកៀកជិតប្រជាពលរដ្ឋក្នុងការគ្រប់គ្រងចាត់ចែង និងអនុវត្តមុខងារនោះ និង ៣). លើកលែងតែក្នុងករណីដែលមានការជួយគាំទ្ររួចហើយ ក៏នៅតែមិនអាចទទួលបានលទ្ធផលល្អសមស្រប នោះទើបអនុញ្ញាតឱ្យរដ្ឋបាលថ្នាក់លើបន្ទាប់នោះយកមុខងារនោះមកគ្រប់គ្រង ចាត់ចែង និងអនុវត្តក្រោមការទទួលខុសត្រូវរបស់ខ្លួន។

ក្នុងក្របខ័ណ្ឌនៃការអនុវត្តកជទី១ រាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នបានរៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្ត និងយន្តការនានាជាច្រើនផ្អែកតាមច្បាប់រៀបចំអង្គការពាក់ព័ន្ធក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ តាមរយៈការបង្កិតការផ្តល់សេវាឱ្យទៅកៀកជិតប្រជាពលរដ្ឋ និងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្តនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះយ៉ាងនេះក្តី ដំណើរការនេះនៅពុំទាន់បានសម្រេចតាមគោលបំណងខាងលើនៅឡើយដែលទាមទារឱ្យមានការពិនិត្យ និងកែសម្រួលឱ្យបានសមស្រប។ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាតំណាងឱ្យប្រជាពលរដ្ឋនៅពុំទាន់បានអនុវត្តពេញលេញនូវសិទ្ធិអំណាចស្របតាមច្បាប់រៀបចំអង្គការក្នុងការធ្វើសេចក្តីសម្រេចចិត្តទៅលើផែនការ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការត្រួតពិនិត្យមើលលើការអនុវត្តការងាររបស់គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំចៅសង្កាត់។ ការប្រើប្រាស់នូវសិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់នូវធនធានធន្ធានុសិទ្ធិរបស់ខ្លួននៅមិនទាន់មានភាពពេញលេញ ដោយសារការធ្វើសេចក្តីសម្រេចចិត្តក្នុងការប្រើប្រាស់ធនធានទាំងនេះ ត្រូវបានកម្រិតដោយលិខិតបទដ្ឋានគតិយុត្តជាធរមានមួយចំនួន។

កម្ពុជានឹងក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់តាមរយៈការធ្វើទំនើបកម្ម និងធ្វើពិពិធកម្មគ្រប់ផ្នែកក្នុងវិស័យសេដ្ឋកិច្ច និងសង្គម។ ការលើកកម្ពស់សេដ្ឋកិច្ចជាតិដែលមានការចូលរួមចំណែកយ៉ាងសំខាន់ពីវិស័យឯកជនដែលផ្តោតលើវិស័យឧស្សាហកម្ម និងសេវាកម្ម រួមទាំងការធ្វើបដិវត្តឧស្សាហកម្មទី៤ត្រូវការជាចាំបាច់នូវការដឹកនាំ ការសម្របសម្រួល និងការគាំទ្រពីរដ្ឋបាលសាធារណៈទំនើប និងមានសមត្ថភាពខ្ពស់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ធនធានមនុស្ស និងវិធីសាស្ត្រនៃការអនុវត្តការងារនាពេលបច្ចុប្បន្ន នៅមិនទាន់អាចធានាដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៅឆ្នាំ២០៣០បានឡើយ។ អាស្រ័យហេតុនេះ ជាមួយគ្នានឹងការផ្ទេរសិទ្ធិអំណាច មុខងារ ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុកាន់តែច្រើនឡើងទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ចាំបាច់ត្រូវយកចិត្តទុកដាក់ក្នុងការពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យក្លាយទៅជាស្ថាប័នដែលមានសមត្ថភាព និងមានលក្ខណៈទំនើប។ ដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវគិតគូរទាំងការពង្រឹងប្រព័ន្ធគ្រប់គ្រងបុគ្គលិក ការធ្វើឱ្យប្រសើរឡើងនូវជំនាញវិជ្ជាជីវៈរបស់បុគ្គលិក និងការបញ្ចូលនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពេញលេញទៅក្នុងប្រព័ន្ធអភិបាលកិច្ចនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

ប្រទេសកម្ពុជាក៏ដូចជាប្រទេសដទៃទៀត បាននិងកំពុងជួបប្រទះនូវបញ្ហាប្រឈមជាសកលនៃការប្រែប្រួលអាកាសធាតុដែលចាំបាច់ត្រូវចូលរួមដោះស្រាយទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែរ ការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមក៏ជាបញ្ហាប្រឈមដ៏សំខាន់ដែលត្រូវដោះស្រាយមានលក្ខណៈជាពហុវិស័យទាំងក្នុងក្របខ័ណ្ឌថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផងដែរ។

អាស្រ័យហេតុនេះ ការរៀបចំកជទី២ ក៏បានយកចិត្តទុកដាក់ក្នុងការដាក់បញ្ចូលនូវបញ្ហាទាំង២ខាងលើនេះ ជាផ្នែកអន្តរវិស័យនៃកម្មវិធីជាតិ។

## ១.៣. សមិទ្ធផល

ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដំណាក់កាលទី១ រាជរដ្ឋាភិបាលសម្រេចបានលទ្ធផលធំៗដូចខាងក្រោម ៖

– បង្កើតបាននូវមូលដ្ឋានគ្រឹះសំខាន់ៗនៃរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងតាមបែបប្រជាធិបតេយ្យនៅគ្រប់កម្រិតនៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងនោះរួមមាន ការបង្កើតក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗតាមរយៈការបោះឆ្នោត ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធគ្រប់គ្រង ព្រមទាំងនីតិវិធីអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗរួមមាន នីតិវិធីរៀបចំកិច្ចប្រជុំនិងការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា នីតិវិធីនៃការរៀបចំវេទិកាពិគ្រោះយោបល់សាធារណៈរបស់ក្រុមប្រឹក្សា និងនីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីបង្កលក្ខណៈឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងសមធម៌។ រចនាសម្ព័ន្ធនានានៃមន្ទីរសុខាភិបាលរាជធានី ខេត្ត និងមណ្ឌលថែទាំកុមាររដ្ឋត្រូវបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលរាជធានី ខេត្ត។ ជាមួយគ្នានេះដែរ រចនាសម្ព័ន្ធគ្រប់គ្រងនៅថ្នាក់ក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំឡើងវិញដោយផ្អែកតាមគោលការណ៍រដ្ឋបាលឯកភាព តាមរយៈការធ្វើសមាហរណកម្មការិយាល័យជំនាញនានារបស់ក្រសួងចំនួន២០ ទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងថ្មីនេះនាឆ្នាំ២០១៩។

– បានរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់ខ្លួនដែលត្រូវបានផ្ទេរទៅឱ្យចំនួនប្រមាណជាង ៤០.០០០នាក់។ ការអភិវឌ្ឍសមត្ថភាពដល់បុគ្គលិកទាំងនោះអំពីការទទួលខុសត្រូវ តួនាទី ភារកិច្ច និងនីតិវិធីអនុវត្តការងារក៏ត្រូវបានផ្តល់តាមរយៈវគ្គបណ្តុះបណ្តាលខ្លីៗ សិក្ខាសាលា និងការហ្វឹកហាត់ការងារជាក់ស្តែង។ ទន្ទឹមនោះ សាលាជាតិរដ្ឋបាលមូលដ្ឋានក៏ត្រូវបានបង្កើតឡើងដើម្បីផ្តល់សេវាអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

– បានផ្ទេរមុខងារចំនួន៥៥ ក្នុងវិស័យចំនួន២០ ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងបានផ្ទេរមុខងារក្នុងវិស័យសង្គមកិច្ច និងសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ស្របតាមគោលការណ៍វិមជ្ឈការ ដើម្បីបង្ខិតការផ្តល់សេវាឱ្យកៀកជិតប្រជាពលរដ្ឋនៅមូលដ្ឋាន និងឆ្លើយតបទាន់ពេលវេលា

ទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ យន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានបង្កើតឡើង ដើម្បីបង្កលក្ខណៈងាយស្រួលឱ្យប្រជាពលរដ្ឋមកទទួលសេវារដ្ឋបាលចាំបាច់មួយចំនួនពីរដ្ឋបាលថ្នាក់ក្រោមជាតិ។

– បង្កើតបាននូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមគោលការណ៍វិមជ្ឈការហិរញ្ញវត្ថុដូចជា ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក ដើម្បីគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ ប្រព័ន្ធផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានបង្កើតឡើងដែលរួមមាន ប្រព័ន្ធផ្ទេរធនធានហិរញ្ញវត្ថុគ្មានភ្ជាប់លក្ខខណ្ឌដូចជា មូលនិធិឃុំ សង្កាត់ មូលនិធិក្រុង ស្រុក និងប្រព័ន្ធផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌដូចជា ប្រព័ន្ធផ្ទេរមូលនិធិវិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រព័ន្ធផ្ទេរធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារដែលបានផ្ទេរ ព្រមទាំងប្រព័ន្ធចែករំលែកចំណូលសារពើពន្ធរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងក្របខ័ណ្ឌនៃការធ្វើវិមជ្ឈការហិរញ្ញវត្ថុ និងភាពជោគជ័យនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលបានបង្កើនការផ្ទេរថវិការដ្ឋជារៀងរាល់ឆ្នាំទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរហូតមកទល់ឆ្នាំ២០២០នេះថវិកានេះមានចំនួនសរុបប្រមាណជាង **៣.៨០០លានដុល្លារអាមេរិក** សម្រាប់ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ក្រោមឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ។

– បង្កើតបាននូវប្រព័ន្ធកសាងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន ផែនការអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល ស្របទៅតាមចរិតលក្ខណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដើម្បីធានាដល់ការប្រើប្រាស់ធនធាននានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម។

– បង្កើតបាននូវយន្តការគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ដែលរួមមានដូចជាការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទូទាំងប្រទេស ដើម្បីទទួល និងសម្រុះសម្រួលដោះស្រាយបណ្ដឹងតវ៉ានានាក្រៅប្រព័ន្ធតុលាការពាក់ព័ន្ធនឹងការបំពេញមុខងារ និងការផ្ដល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការបង្កើតក្របខ័ណ្ឌការងារគណនេយ្យភាពសង្គមក្នុងភាពជាដៃគូយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិល ដើម្បីផ្ដល់ព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងការប្រើប្រាស់ថវិកាឃុំ សង្កាត់ និងអង្គភាពជំនាញនានានៅតាមមូលដ្ឋាន ព្រមទាំងដើម្បីបង្កលក្ខណៈងាយស្រួលជូនប្រជាពលរដ្ឋក្នុងការចូលរួមតាមដាន ត្រួតពិនិត្យ និងផ្ដល់យោបល់កែលម្អលើការបំពេញការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងការផ្ដល់សេវារបស់អង្គភាពផ្ដល់សេវានៅមូលដ្ឋានមួយចំនួនរួមមានដូចជា សាលាបឋមសិក្សា និងមណ្ឌលសុខភាពជាដើម ព្រមទាំងបានអនុវត្តសាកល្បងនូវការងារគណនេយ្យភាពសង្គមនៅក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌគោលដៅមួយចំនួន។

– បាននិងកំពុងផ្តល់សេវារដ្ឋបាលប្រមាណជាង ៦០០ប្រភេទ ព្រមទាំងបានសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងអនុវត្តគម្រោងសេវាសង្គមប្រមាណជាង ២.០០០គម្រោងក្នុងមួយឆ្នាំៗដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងក្នុងមូលដ្ឋាន ដែលជាការរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

– បានបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិសម្រាប់ដឹកនាំ សម្របសម្រួល និងគាំទ្រដល់ការរៀបចំ និងអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ក្រោមក្របខ័ណ្ឌនៃយន្តការនេះ គ.ជ.អ.ប. បានកៀរគរការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានាដល់ការអនុវត្តកម្មវិធីកំណែទម្រង់នេះ។ ក្រោមការដឹកនាំ និងការសម្របសម្រួលរបស់គ.ជ.អ.ប. ក្រសួង ស្ថាប័នថ្នាក់ជាតិពាក់ព័ន្ធចំនួន ២៣ និងរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេសបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលមានសមាជិកសរុបចំនួន ១៥.៦៨៦រូប ត្រូវបានបង្កើតឡើងដើម្បីធ្វើជាយន្តការតំណាងឱ្យក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេសសម្រាប់ការពារ គាំទ្រ និងបម្រើផលប្រយោជន៍ស្របច្បាប់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

– បានរៀបចំលិខិតបទដ្ឋានគតិយុត្តនានាដែលឆ្លើយតបទៅនឹងសមភាពយេនឌ័រ និងការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅថ្នាក់ក្រោមជាតិ ជាពិសេសបានបង្កើតនូវគោលនយោបាយស្តីពីការលើកកម្ពស់សមភាពយេនឌ័រសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងផែនការយុទ្ធសាស្ត្រក្នុងការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងបានធ្វើសវនកម្មយេនឌ័រក្នុងប្រព័ន្ធគ្រប់គ្រងការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងផ្តល់ការអភិវឌ្ឍសមត្ថភាពពាក់ព័ន្ធនឹងការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមតាមរយៈវគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចជូនថ្នាក់ដឹកនាំរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗបានបង្កើតនូវគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (គ.ក.ស.ក.) និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ (គ.ក.ន.ក.) ដែលជាយន្តការដ៏មានសារៈសំខាន់ក្នុងការឆ្លើយតបទៅនឹងតម្រូវការ និងបញ្ហាអាទិភាពរបស់ស្ត្រី កុមារ និងក្រុមជនងាយរងគ្រោះ។

– ដើម្បីចូលរួមចំណែកក្នុងការលើកកម្ពស់សមត្ថភាពបន្សាំរបស់ប្រជាពលរដ្ឋទប់ទល់ទៅនឹងគ្រោះមហន្តរាយស្របទៅតាមស្ថានភាពរងគ្រោះរបស់មូលដ្ឋាននីមួយៗ ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយត្រូវបានដាក់បញ្ចូលទៅក្នុងកិច្ចដំណើរការនៃការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ រដ្ឋបាលក្រុង ស្រុកចំនួន ៥០ ដែលស្ថិតក្នុងតំបន់ងាយរងគ្រោះពីគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានាបានទទួលការគាំទ្រហិរញ្ញប្បទានអាកាសធាតុតាមរយៈមូលនិធិធន់ទៅនឹងការប្រែប្រួលអាកាសធាតុផ្អែកលើលទ្ធផលនៃការអនុវត្ត សម្រាប់វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធធន់នឹងការប្រែប្រួលអាកាសធាតុ ការបណ្តុះបណ្តាល

កសាងសមត្ថភាព និងពង្រឹងស្ថាប័ន។ លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវបានទទួលស្គាល់ជាស្ថាប័នអនុវត្តជាតិសម្រាប់មូលនិធិអាកាសធាតុបៃតងក្នុងការកៀរគរធនធានហិរញ្ញប្បទានអាកាសធាតុគាំទ្រដល់ការអនុវត្តសកម្មភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាស។

- បានរៀបចំ និងដាក់ឱ្យអនុវត្តនូវគោលនយោបាយ និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធនឹងសុវត្ថិភាពបរិស្ថាន និងសង្គម ដើម្បីជាមូលដ្ឋានដល់ការរៀបចំ និងការអនុវត្តគម្រោងវិនិយោគសាធារណៈនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិសំដៅធានាដល់ការចៀសវាងនូវផលប៉ះពាល់អវិជ្ជមានជាអតិបរមា ការគំរាមកំហែងទៅលើនិរន្តរភាពនៃលំនឹងបរិស្ថាន ប្រព័ន្ធអេកូឡូស៊ី សង្គម វប្បធម៌ ប្រពៃណី ជនជាតិដើមភាគតិច ក៏ដូចជាផលប៉ះពាល់ជាអវិជ្ជមានទៅលើសុខភាព សេដ្ឋកិច្ច សមភាពយេនឌ័រ និងការរំលោភបំពានផ្សេងៗដែលបណ្តាលមកពីកិច្ចការអភិវឌ្ឍន៍ទាំងនេះ។

## ១.៤. បញ្ហាប្រឈម

ទន្ទឹមនឹងការសម្រេចបាននូវសមិទ្ធផលធំៗខាងលើនេះ ក៏នៅមានបញ្ហាប្រឈមជាគន្លឹះមួយចំនួនដែលត្រូវបន្តដោះស្រាយ រួមមាន៖

- កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការគឺជាគោលនយោបាយដ៏មានសារៈសំខាន់របស់រាជរដ្ឋាភិបាលដែលបានដាក់ឱ្យអនុវត្តជិតពីរទសវត្សរ៍មកហើយ ក៏ប៉ុន្តែការយល់ដឹងរបស់អ្នកពាក់ព័ន្ធនានាទាំងស្ថាប័នសាធារណៈ សង្គមស៊ីវិល និងសាធារណជនអំពីកំណែទម្រង់នេះនៅមានកម្រិត និងមានការយល់ឃើញ និងបកស្រាយផ្សេងគ្នាៗអំពីចក្ខុវិស័យ និងគោលបំណងនៃកំណែទម្រង់នេះ។

- កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាកំណែទម្រង់ដែលមានលក្ខណៈស្មុគស្មាញសាំញ៉ាំ ដែលទាមទារឱ្យមានការប្តេជ្ញាចិត្តយ៉ាងមុតមាំទាំងកម្រិតនយោបាយ និងកម្រិតបច្ចេកទេសរបស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងការចូលរួមរបស់អ្នកពាក់ព័ន្ធនានា។ ក្នុងអំឡុងពេលនៃការអនុវត្តកជទី១ ក្រសួង ស្ថាប័នមួយចំនួននៅមានភាពស្ទាក់ស្ទើរក្នុងការផ្ទេរអំណាច និងការទទួលខុសត្រូវក្នុងការអនុវត្តមុខងារ និងធនធាននានារួមមានធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងធនធានមនុស្សទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ ពាក់ព័ន្ធនឹងបញ្ហាប្រឈមដ៏សំខាន់នេះ ចាំបាច់ត្រូវបន្តពង្រឹងការតាំងចិត្តទាំងកម្រិតនយោបាយ និងកម្រិតបច្ចេកទេសរបស់ក្រសួង ស្ថាប័ននានាក្នុងកិច្ចដំណើរការកំណែទម្រង់នេះឱ្យកាន់តែស៊ីជម្រៅ និងមានប្រសិទ្ធភាព។

- រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវបានរៀបចំឡើងវិញ និងកែសម្រួលជាបណ្តើរៗនាពេលកន្លងមក ក៏ប៉ុន្តែរចនាសម្ព័ន្ធ និងប្រព័ន្ធទាំងនេះនៅមិនទាន់មានលក្ខណៈសមស្របពេញលេញតាមចរិតលក្ខណៈផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដែលមានលក្ខណៈ

ជាទីក្រុងធំ លក្ខណៈទីប្រជុំជន និងលក្ខណៈតំបន់ជនបទ ព្រមទាំងផ្អែកទៅតាមលក្ខណៈភូមិសាស្ត្រ ប្រជាសាស្ត្រ និងសក្តានុពលសេដ្ឋកិច្ចសង្គមខុសៗគ្នារបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំង៣កម្រិត។

– ផ្អែកតាមកជទី១ រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ត្រូវបានរៀបចំឱ្យក្លាយទៅជារដ្ឋបាលមូលដ្ឋាន ដែលមានតួនាទីសំខាន់ក្នុងការផ្តល់សេវាសាធារណៈចាំបាច់មួយចំនួនដោយផ្ទាល់ជូនប្រជាពលរដ្ឋ និងរដ្ឋបាលខេត្តជារដ្ឋបាលថ្នាក់តំបន់ដែលមានតួនាទីសំខាន់ក្នុងការអនុវត្តមុខងារមួយចំនួនក្នុងនាមជាតំណាងឱ្យរាជរដ្ឋាភិបាល និងក្រសួងស្ថាប័ន និងការគាំទ្រ ការតាមដាន ការត្រួតពិនិត្យ ការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលមូលដ្ឋាន ព្រមទាំងការផ្តល់សេវាសាធារណៈនិងគម្រោងវិនិយោគធំៗដែលរដ្ឋបាលមូលដ្ឋានពុំមានលទ្ធភាពអនុវត្ត។ ទោះបីយ៉ាងនេះក្តី ការសិក្សាអំពីការរៀបចំរដ្ឋបាលខេត្តឱ្យមានចរិតលក្ខណៈជារដ្ឋបាលតំបន់នៅមិនទាន់បានអនុវត្តនៅឡើយ។

– ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ នៅពុំទាន់បំពេញតួនាទីពេញលេញជាអង្គធ្វើសេចក្តីសម្រេចចិត្តលើផែនការ និងថវិការបស់ខ្លួន ព្រមទាំងបំពេញតួនាទីជាតំណាងប្រជាពលរដ្ឋក្នុងការឆ្លើយតបទៅនឹងតម្រូវការនានារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ពាក់ព័ន្ធនឹងបញ្ហានេះ ទាមទារឱ្យមានការកែលម្អកិច្ចដំណើរការពិនិត្យ អនុម័ត និងការតាមដានត្រួតពិនិត្យលើការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សា ព្រមទាំងការកសាងសមត្ថភាពរបស់ក្រុមប្រឹក្សាក្នុងការអនុវត្តតួនាទីទាំងនេះឱ្យកាន់តែមានប្រសិទ្ធភាព។ ទោះបីជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម និងការបង្កើតការិយាល័យប្រជាពលរដ្ឋក៏ដោយ ក៏ប្រជាពលរដ្ឋនៅមិនទាន់យល់ដឹងច្បាស់លាស់អំពីសិទ្ធិរបស់ខ្លួនក្នុងការជំរុញឱ្យក្រុមប្រឹក្សាមានគណនេយ្យភាពចំពោះខ្លួនឡើយ។

– បើទោះបីជាមានការផ្ទេរមុខងារមួយចំនួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិហើយក៏ដោយ ក៏ការបែងចែកសិទ្ធិអំណាច តួនាទី ភារកិច្ច និងការទទួលខុសត្រូវលើការអនុវត្តមុខងារផ្តល់សេវាសាធារណៈចាំបាច់មួយចំនួនរវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិនៅមានភាពមិនទាន់ច្បាស់លាស់ ព្រមទាំងមិនទាន់មានភាពសមស្របទៅនឹងគោលនយោបាយវិមជ្ឈការក្នុងការបង្វិតការផ្តល់សេវាសាធារណៈទៅកៀកជិតជាមួយប្រជាពលរដ្ឋ។ ប្រការនេះ ធ្វើឱ្យប្រជាពលរដ្ឋនៅតែជួបការលំបាកក្នុងការទទួលបាននូវសេវាសាធារណៈចាំបាច់មួយចំនួន។

– ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាពិសេស រដ្ឋបាលក្រុង ស្រុកនៅពុំទាន់មានប្រសិទ្ធភាពពេញលេញនៅឡើយ ដោយហេតុថាសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់រដ្ឋបាលទាំងនេះ នៅមានកម្រិតដែលបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ ចាំបាច់ត្រូវមានការពិនិត្យ និងការកែសម្រួលនូវលិខិតបទដ្ឋានគតិយុត្តទាំងនេះ ដើម្បីផ្តល់សិទ្ធិអំណាចច្បាស់លាស់ និងកាន់តែច្រើនឡើងទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងពង្រឹងសមត្ថភាព និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

– ទោះបីជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ក្នុងការផ្ទេរមុខងារមួយចំនួនទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក៏ដោយក៏ការផ្ទេរធនធាននានាទាំងធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ សម្រាប់អនុវត្តមុខងារទាំងនេះពុំទាន់មានលក្ខណៈសមស្របតាមចំនួនមុខងារ និងទំហំមុខងារនីមួយៗ ដែលផ្ទេរទៅឱ្យ ព្រមទាំងពុំទាន់មានដំណើរការដោយរលូននៅឡើយ។

– ការគ្រប់គ្រង និងការអនុវត្តមុខងារផ្តល់សេវាដែលត្រូវរ៉ាប់រងចំណាយជាសំខាន់ពីកម្រៃសេវា ដែលប្រមូលបានពីអ្នកប្រើប្រាស់ក៏នៅជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួន។ ជាក់ស្តែង មុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុកនៅមិនទាន់អាចអនុវត្តបានល្អនៅឡើយទេ ដែលតម្រូវឱ្យមានការពង្រឹងយន្តការគាំទ្រ ការពង្រឹងសមត្ថភាពនិងការទទួលខុសត្រូវរបស់រដ្ឋបាលទាំងនោះបន្ថែមទៀត។

– ទោះបីធនធានហិរញ្ញវត្ថុដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ មានការកើនឡើងជាបន្តបន្ទាប់ក៏ដោយ ក៏ទំហំធនធាននេះនៅមិនទាន់មានលក្ខណៈសមស្របទៅនឹងមុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការឆ្លើយតបទៅនឹងតម្រូវការចាំបាច់ និងជាអាទិភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានឡើយ។ ប្រការនេះ ចាំបាច់ត្រូវពិនិត្យមើលឡើងវិញ ដើម្បីបង្កើនការផ្ទេរធនធានហិរញ្ញវត្ថុឱ្យមានទំហំសមស្រប ព្រមទាំងពិនិត្យ និងកែសម្រួលឡើងវិញនូវរូបមន្ត និងលក្ខណៈវិនិច្ឆ័យសម្រាប់ការវិភាជធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយសមធម៌ សំដៅកាត់បន្ថយគម្លាតនៃការអភិវឌ្ឍរវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ។

– ទោះបីប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជាបណ្តើរៗក៏ដោយ ក៏ការអនុវត្តជាក់ស្តែងនៅពុំទាន់មានប្រសិទ្ធភាព និងអនុវត្តពេញលេញតាមប្រព័ន្ធនោះនៅឡើយ ហើយសមត្ថភាពបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិតផងដែរ។ មន្ត្រីសាធារណៈមួយចំនួនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់យល់ដឹងច្បាស់លាស់អំពីមុខងារ និងការទទួលខុសត្រូវរបស់ខ្លួន មិនទាន់ទទួលបានការបណ្តុះបណ្តាលជំនាញជាក់លាក់ និងពុំទាន់មានការជំរុញលើកទឹកចិត្ត ឬចាត់វិធានការខាងវិន័យឱ្យបានម៉ឺងម៉ាត់ក្នុងការបំពេញការងាររបស់បុគ្គលិក។

– បច្ចុប្បន្ននេះ បញ្ហាប្រឈមសំខាន់ៗមានលក្ខណៈជាអន្តរវិស័យមួយចំនួនដូចជា ការរៀបចំប្រព័ន្ធអភិបាលកិច្ចឌីជីថល ការប្រែប្រួលអាកាសធាតុ ការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម នៅពុំទាន់បានបញ្ជ្រាបនិងអនុវត្តបានពេញលេញនៅក្នុងការបំពេញការងារជាទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ។ ប្រការនេះ ការរៀបចំនិងអនុវត្តនូវកជទី២ ចាំបាច់ត្រូវយកចិត្តទុកដាក់ដោះស្រាយឱ្យមានប្រសិទ្ធភាព។

## ១.៥. ដំណើរការនៃការរៀបចំតាក់តែងកម្មវិធីជាតិដំណាក់កាលទី២

ការរៀបចំតាក់តែងកជទី២ (២០២១-២០៣០) ស្ថិតក្រោមការដឹកនាំ និងសម្របសម្រួលរបស់ គ.ជ.អ.ប. ដោយមានជំនួយបច្ចេកទេសពីក្រុមទីប្រឹក្សាជាតិ និងអន្តរជាតិដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍មួយចំនួន។

កិច្ចដំណើរការរៀបចំតាក់តែងកម្មវិធីនេះ បានចាប់ផ្តើមនៅក្នុងខែឧសភា ឆ្នាំ២០២០ និងបានបញ្ចប់នូវសេចក្តីព្រាងនៅក្នុងខែសីហា ឆ្នាំ២០២១ ដោយមានការពិភាក្សា និងការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយក្រសួង ស្ថាប័នជាសមាជិក គ.ជ.អ.ប. ក្រសួង ស្ថាប័នពាក់ព័ន្ធនានា រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ព្រមទាំងបានដាក់ឱ្យពិភាក្សា និងពិគ្រោះយោបល់ក្នុងសិក្ខាសាលាជាតិ និងបានឆ្លងកិច្ចប្រជុំ គ.ជ.អ.ប. មុននឹងដាក់ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។ ឯកសារកម្មវិធីនេះត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១។ កិច្ចដំណើរការរៀបចំកម្មវិធីនេះ បានចំណាយពេលច្រើនជាងការគ្រោងទុកដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩។

កិច្ចដំណើរការរៀបចំតាក់តែងកជទី២ ត្រូវអនុវត្តតាមលំដាប់លំដោយជាជំហានៗដូចខាងក្រោម៖

- **ជំហានទី១ ៖** ការរៀបចំសេចក្តីព្រាងបឋមនៃឯកសារទស្សនទានសម្រាប់ការរៀបចំតាក់តែងកជទី២ ដែលត្រូវបានចាប់ផ្តើមក្នុងខែឧសភា ឆ្នាំ២០២០
- **ជំហានទី២ ៖** ការរៀបចំប្រជុំកម្រិតបច្ចេកទេសជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានាក្នុងអំឡុងខែកញ្ញា-វិច្ឆិកា ឆ្នាំ២០២០ និងការរៀបចំសិក្ខាសាលាជាតិ ដើម្បីពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយនឹងអ្នកពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនាថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២០
- **ជំហានទី៣ ៖** ការពិនិត្យ និងអនុម័តលើសេចក្តីព្រាងឯកសារទស្សនទានដោយរាជរដ្ឋាភិបាលនាថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០
- **ជំហានទី៤ ៖** ការរៀបចំសេចក្តីព្រាងលម្អិតបឋមនៃឯកសារកជទី២ ចាប់ពីខែធ្នូ ឆ្នាំ២០២០ ដល់ខែសីហា ឆ្នាំ២០២១
- **ជំហានទី៥ ៖** ការរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងឯកសារកជទី២ជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១
- **ជំហានទី៦ ៖** ការរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១
- **ជំហានទី៧ ៖** ការដាក់ឆ្លងសេចក្តីព្រាងឯកសារកជទី២ ក្នុងកិច្ចប្រជុំ គ.ជ.អ.ប. នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១។

➢ **ជំហានទី៨ ៖** ការដាក់សេចក្ដីព្រាងចុងក្រោយនៃឯកសារកជទី២ ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១។

ឯកសារកជទី២ ត្រូវបានរៀបចំតាក់តែងឡើងដោយផ្អែកលើមូលដ្ឋាននៃឯកសារទស្សនទានសម្រាប់ការរៀបចំតាក់តែងកជទី២ ដែលបានអនុម័តដោយរាជរដ្ឋាភិបាលនាថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០។

ជាមួយគ្នានេះ កជទី២ ក៏ត្រូវបានរៀបចំតាក់តែងឡើងដោយផ្អែកលើច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

- ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (២០០១)
- ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២០០៨)
- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល (២០១៨-២០២៣)
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (២០១៩-២០២៣)
- ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (២០១៦-២០៣០)
- គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត យុទ្ធសាស្ត្រ ផែនការ និងរបាយការណ៍វាយតម្លៃ និងការអង្កេតនានាដែលបានរៀបចំក្នុងអំឡុងពេលការអនុវត្ត កជទី១ ពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ
- កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

បន្ថែមលើនេះទៀត ការរៀបចំកជទី២ ក៏ផ្អែកទៅលើវឌ្ឍនភាព មេរៀន និងបទពិសោធន៍នៃការអនុវត្តកជទី១ (២០១០-២០២០) ព្រមទាំងផ្ដោតទៅលើការបន្តដោះស្រាយនូវបញ្ហាជាអាទិភាពនានាដែលមានកំណត់នៅក្នុង កជទី១ តែនៅមិនទាន់បានអនុវត្ត។ ទន្ទឹមនោះ ក៏បានយកចិត្តទុកដាក់ទៅលើការដោះស្រាយនូវបញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលនៅសេសសល់ក្នុងការអនុវត្តកជទី១ ក៏ដូចជាបញ្ហាប្រឈមនានាដែលប្រមើលមើលឃើញទៅអនាគត។ ជាមួយគ្នានេះដែរ ការរៀបចំឯកសារកម្មវិធីនេះក៏បានយកចិត្តទុកដាក់ទៅលើមេរៀន និងបទពិសោធន៍នៃបណ្ដាប្រទេសនានាផងដែរ។

## ១.៦. រចនាសម្ព័ន្ធនៃកម្មវិធីជាតិ

ឯកសារកជទី២ បែងចែកជា៦ជំពូក និងរួមមានឧបសម្ព័ន្ធចំនួន៦ ដូចខាងក្រោម ៖

**ជំពូកទី១ ៖ អំពីសេចក្ដីផ្ដើម** ដែលរៀបរាប់ពីសាវតារកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ សមិទ្ធផលជាគន្លឹះ និងបញ្ហាប្រឈមនៃការអនុវត្តកជទី១ ព្រមទាំងកិច្ចដំណើររៀបចំតាក់តែងកជទី២ និងរចនាសម្ព័ន្ធកម្មវិធីជាតិ។

**ជំពូកទី២ ៖ អំពីទិដ្ឋភាពទូទៅនៃកម្មវិធីជាតិ** ដែលរៀបរាប់អំពីចក្ខុវិស័យ គោលបំណង គោលដៅដំណាក់កាលនានានៃកម្មវិធីជាតិ និងសមិទ្ធផលរំពឹងទុក។

**ជំពូកទី៣ ៖** ជាផ្នែកមួយដ៏សំខាន់នៃឯកសារកម្មវិធីជាតិដែលរៀបរាប់យ៉ាងលម្អិតអំពីសមាសភាគទាំង៥នៃកម្មវិធីជាតិ និងកិច្ចការអន្តរវិស័យ។ ក្នុងសមាសភាគនីមួយៗមានរៀបរាប់អំពីសនិទានភាព សមិទ្ធផលរំពឹងទុក លទ្ធផលរំពឹងទុក យុទ្ធសាស្ត្រអនុវត្តដើម្បីសម្រេចបានលទ្ធផលរំពឹងទុក ក្របខ័ណ្ឌលទ្ធផល និងការគ្រប់គ្រងហានិភ័យរួមបញ្ចូលទាំងវិធានការកាត់បន្ថយហានិភ័យ។ លទ្ធផលរំពឹងទុក និងយុទ្ធសាស្ត្រអនុវត្តគឺជាមូលដ្ឋានសម្រាប់ការរៀបចំផែនការអនុវត្តរយៈពេលប្រាំឆ្នាំនៃកម្មវិធី។ កិច្ចការអន្តរវិស័យរួមមាន សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម និងការគ្រប់គ្រងការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានាដែលបានបញ្ជ្រាបក្នុងសមាសភាគទាំងអស់។

**ជំពូកទី៤ ៖** បរិយាយអំពីបែបផែននៃការគ្រប់គ្រង និងការអនុវត្ត ការត្រួតពិនិត្យនិងការវាយតម្លៃ និងក្របខ័ណ្ឌលទ្ធផលរួមនៃកម្មវិធី។

**ជំពូកទី៥ ៖** សង្ខេបអំពីថវិកាប៉ាន់ស្មាននៃកម្មវិធីជាតិ និងប្រភពផ្តល់មូលនិធិ។

**ជំពូកទី៦ ៖** ជាសេចក្តីសន្និដ្ឋាន ដែលផ្តោតលើសារៈសំខាន់នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងការលើកកម្ពស់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ សេចក្តីសន្និដ្ឋាននេះក៏គូសបញ្ជាក់អំពីតម្រូវការនៃកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន ដើម្បីជានាភាពជោគជ័យនៃកម្មវិធី។

ឯកសារកម្មវិធីជាតិមានភ្ជាប់ជាមួយនូវឧបសម្ព័ន្ធចំនួន៦ ដែលធ្វើយុត្តិកម្ម និងពន្យល់លម្អិតអំពីយុទ្ធសាស្ត្រនានាសម្រាប់ជានាការសម្រេចបាននូវលទ្ធផលរំពឹងទុកជាគន្លឹះនានា និងការងារអន្តរវិស័យដូចបានកំណត់នៅក្នុងឯកសារកម្មវិធីជាតិ។ ឧបសម្ព័ន្ធទាំង៦រួមមាន ៖

- ឧបសម្ព័ន្ធ "ក" ៖ ក្របខ័ណ្ឌលទ្ធផលនៃកជទី២
- ឧបសម្ព័ន្ធ "ខ" ៖ ការគ្រប់គ្រងហានិភ័យនៃកជទី២
- ឧបសម្ព័ន្ធ "គ" ៖ យុទ្ធសាស្ត្របញ្ជ្រាបសមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម
- ឧបសម្ព័ន្ធ "ឃ" ៖ យុទ្ធសាស្ត្រការកាត់បន្ថយភាពងាយរងគ្រោះពីប្រែប្រួលអាកាសធាតុ ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា
- ឧបសម្ព័ន្ធ "ង" ៖ យុទ្ធសាស្ត្រអភិបាលកិច្ចឌីជីថល
- ឧបសម្ព័ន្ធ "ច" ៖ សន្ទានុក្រមនៃកជទី២។

# ជំពូកទី២

# ទិដ្ឋភាពទូទៅនៃកម្មវិធីជាតិ

## ២.១. ចក្ខុវិស័យ

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលសម្រាប់កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងរយៈពេល១០ឆ្នាំខាងមុខ (ឆ្នាំ២០២១ ដល់ឆ្នាំ២០៣០) គឺ *"ប្រជាពលរដ្ឋទទួលបានសេវាសាធារណៈ និងផលប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គម ដែលរួមចំណែកសម្រេចឱ្យបាននូវគោលបំណងដ៏ទូលំទូលាយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ និងប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០"*។

ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើនេះ កជទី២ ត្រូវផ្តោតជាសំខាន់ទៅលើការពង្រឹង និងការកែលម្អរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលរួមមានដូចខាងក្រោម៖

- ការកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របទៅនឹងចរិតលក្ខណៈនៃរដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទនីមួយៗ រួមមានការកែសម្រួលរដ្ឋបាលរាជធានីភ្នំពេញឱ្យមានរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងារតាមចរិតលក្ខណៈជារដ្ឋបាលក្រុងមេត្រូប៉ូលីតែន រដ្ឋបាលខេត្តឱ្យមានរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងារតាមចរិតលក្ខណៈជារដ្ឋបាលតំបន់ និងរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ឱ្យមានរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងារតាមចរិតលក្ខណៈជារដ្ឋបាលមូលដ្ឋាន
- ការលើកកម្ពស់សមត្ថភាពគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការពង្រឹង និងការកែលម្អប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការរៀបចំ និងការដាក់ឱ្យអនុវត្តតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (អភិបាលកិច្ចឌីជីថល)
- រដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានហិរញ្ញវត្ថុកាន់តែច្រើន តាមរយៈការបង្កើនប្រភពចំណូលមូលដ្ឋាន និងការផ្ទេរធនធានបន្ថែមពីថ្នាក់ជាតិប្រកបដោយតម្លាភាព អាចព្យាករណ៍បាន និងកាត់បន្ថយនូវគម្លាតនៃការអភិវឌ្ឍរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ ជាមួយគ្នានេះដែររដ្ឋបាលថ្នាក់ក្រោមជាតិក៏មានសិទ្ធិអំណាច និងការទទួលខុសត្រូវកាន់តែច្រើនក្នុងការរៀបចំ និងការអនុវត្តផែនការនិងថវិការបស់ខ្លួន

- ការរៀបចំ ការកែសម្រួល និងការពង្រឹងយន្តការ នីតិវិធី និងស្តង់ដារសម្រាប់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម
- រដ្ឋបាលថ្នាក់ក្រោមជាតិអាចវាយតម្លៃ គ្រប់គ្រង និងឆ្លើយតបដោយប្រសិទ្ធភាពទៅនឹងភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា ដើម្បីគាំទ្រដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋ ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ននៅក្នុងមូលដ្ឋានរបស់ខ្លួន
- ការលើកកម្ពស់សិទ្ធិអំណាចរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការដាក់ចេញនូវគោលនយោបាយ ការពិនិត្យ និងអនុម័តលើផែនការ ថវិកា និងកិច្ចការចម្បងៗជាអាទិភាពដទៃទៀតរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការដោះស្រាយនូវសំណើសំណូមពរនានារបស់ប្រជាពលរដ្ឋ ដើម្បីធានាដល់ប្រសិទ្ធភាពនៃការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ២.២. គោលបំណង

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ មានគោលបំណង *"លើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យប្រកបដោយបរិយាប័ន្ន សមធម៌ និងយុត្តិធម៌តាមរយៈការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ចថ្នាក់ក្រោមជាតិ និងការកែលម្អនូវដំណើរការផ្តល់សេវា និងគុណភាពសេវា ដើម្បីរួមចំណែកក្នុងការលុបបំបាត់ភាពក្រីក្រ និងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង"។*

គោលបំណងនេះបានឆ្លុះបញ្ចាំង និងធ្វើបច្ចុប្បន្នភាពនូវគោលបំណងនៃកជទី១ និងការដាក់បញ្ចូលនូវគោលដៅជាយុទ្ធសាស្ត្រសម្រាប់អភិបាលកិច្ចនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលដែលបានសង្កត់ធ្ងន់លើការធ្វើទំនើបកម្មនៃប្រព័ន្ធអភិបាលកិច្ចថ្នាក់ក្រោមជាតិ ឱ្យស្របទៅតាមការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៅក្នុងសង្គមកម្ពុជា និងសេចក្តីត្រូវការរបស់ប្រទេសជាតិនាពេលអនាគត ជាពិសេសនៅពេលដែលកម្ពុជាក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

## ២.៣. គោលដៅ

គោលដៅនៃកជទី២ នៅឆ្នាំ២០៣០គឺ *"រចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានលក្ខណៈទំនើប ស្វ័យភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គម ក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានសិទ្ធិអំណាចសមស្រប និងសមត្ថភាពគ្រប់គ្រាន់សម្រាប់អនុវត្តមុខងារទាំងឡាយក្រោមការត្រួតពិនិត្យពីក្រុមប្រឹក្សារបស់ខ្លួន ដើម្បីធានាដល់ការពង្រឹងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ"។*

## ២.៤. សមាសភាគ កិច្ចការអន្តរវិស័យ និងសមិទ្ធផលរំពឹងទុកនៃកម្មវិធីជាតិ

កជទី២ រួមមានសមាសភាគចំនួន៥ ដូចខាងក្រោម ៖

**សមាសភាគទី១៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់៖** សមិទ្ធផលរំពឹងទុកនៃសមាសភាគនេះគឺ *យន្តការដឹកនាំ សម្របសម្រួល និងគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានពង្រឹង ដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននានានៅក្នុងការរៀបចំតាក់តែង និងអនុវត្តនូវកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។*

**សមាសភាគទី២៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ៖** សមិទ្ធផលរំពឹងទុកនៃសមាសភាគនេះគឺ *រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល សិទ្ធិអំណាច និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកំណត់យ៉ាងច្បាស់លាស់តាមកម្រិត និងតាមប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ស្របតាមចរិតលក្ខណៈជារដ្ឋបាលនៃតំបន់ទីក្រុងធំ រដ្ឋបាលនៃតំបន់ទីប្រជុំជន និងរដ្ឋបាលនៃតំបន់ជនបទ ដោយជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងការផ្តល់សេវាសាធារណៈ និងការប្រាស្រ័យទាក់ទងសាធារណៈ។*

**សមាសភាគទី៣៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស៖** សមិទ្ធផលរំពឹងទុកនៃសមាសភាគនេះគឺ *រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិជ្រើសរើស គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិករបស់ខ្លួនផ្អែកលើទំហំការងារ និងលទ្ធភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងមានបុគ្គលិកដែលប្រកបដោយឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការជំនាញវិជ្ជាជីវៈស្របតាមតួនាទី ការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងទទួលបានការអភិវឌ្ឍសមត្ថភាព និងជំនាញវិជ្ជាជីវៈជាប្រចាំ។*

**សមាសភាគទី៤៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖** សមិទ្ធផលរំពឹងទុកនៃសមាសភាគនេះគឺ *រដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានថវិកាដែលអាចព្យាករណ៍បាន និងមានទំហំសមស្របទៅនឹងមុខងារ និងអាទិភាពគោលនយោបាយជាតិ ហើយត្រូវបានវិភាជសម្រាប់ការប្រើប្រាស់ប្រកបដោយភាពបត់បែនក្នុងការឆ្លើយតបទៅនឹងតម្រូវការនានា ដូចមានកំណត់នៅក្នុងផែនការអភិវឌ្ឍកម្មវិធីវិនិយោគ និងផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។*

**សមាសភាគទី៥៖ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន៖** សមិទ្ធផលរំពឹងទុកនៃសមាសភាគនេះគឺ *រដ្ឋបាលថ្នាក់ក្រោមជាតិមានយន្តការ នីតិវិធី និងស្តង់ដារសម្រាប់ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការប្រាស្រ័យទាក់ទងសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន*

*និងសមធម៌សង្គមតាមរយៈការអនុវត្តមុខងារជាអាណត្តិទូទៅ ឬមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។*

បន្ថែមលើសមាសភាគទាំង៥ខាងលើនេះ កជទី២ ក៏នឹងផ្ដោតលើកិច្ចការអន្តរវិស័យចំនួន២ ដែលរួមមាន ៖

– **ការលើកកម្ពស់សមតាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម៖** កិច្ចការនេះគឺ *រដ្ឋបាលថ្នាក់ក្រោមជាតិជ្រើសរើស និងគ្រប់គ្រងបុគ្គលិក រៀបចំផែនការ និងធនធាន ព្រមទាំងចាត់ចែងការផ្ដល់សេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋានដោយគ្មានការរើសអើង និងមិនប្រកាន់ជាតិសាសន៍ សាសនា ភេទ ជនពិការ និងឆ្លើយតបដល់ក្រុមជនងាយរងគ្រោះនានាក្នុងសង្គមប្រកបដោយបរិយាប័ន្ន និងសមធម៌។*

– **ការគ្រប់គ្រងការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា៖** កិច្ចការនេះគឺ *រដ្ឋបាលថ្នាក់ក្រោមជាតិអាចវាយតម្លៃ គ្រប់គ្រង និងឆ្លើយតបដោយប្រសិទ្ធភាពនឹងភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា ដើម្បីគាំទ្រដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋ និងអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងមូលដ្ឋានរបស់ខ្លួន។*

## ២.៥. យុទ្ធសាស្ត្រនៃការអនុវត្តកម្មវិធីជាតិ

មូលដ្ឋានគ្រឹះដ៏សំខាន់នៃការអនុវត្តកជទី២ គឺការចូលរួមគាំទ្រយ៉ាងសកម្មពីក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល និងសាធារណជនទូទៅក្នុងការអនុវត្តឱ្យបានសម្រេចនូវចក្ខុវិស័យ គោលបំណង គោលដៅ និងសមាសភាគនានាដែលត្រូវបានកំណត់យ៉ាងច្បាស់លាស់នៅក្នុងឯកសារកម្មវិធីជាតិនេះ។

ផ្អែកលើការស្រុះស្រួលមតិគ្នាយ៉ាងទូលំទូលាយលើចក្ខុវិស័យ គោលបំណង និងគោលដៅនៃកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិនេះ កជទី២ នឹងកំណត់អំពីលទ្ធផលរំពឹងទុកជាក់លាក់ និងអាចសម្រេចបានសម្រាប់រយៈពេលមធ្យម និងរយៈពេលវែង និងត្រូវរៀបចំផែនការសកម្មភាពលម្អិត ដើម្បីធានាដល់ការសម្រេចបាននូវលទ្ធផលរំពឹងទុកទាំងនោះ។

សមាសភាគនានានៃកជទី២នេះ ត្រូវមានទំនាក់ទំនងគ្នា និងត្រូវអនុវត្តដោយមានកិច្ចសហការគ្នាយ៉ាងជិតស្និទ្ធ។ លទ្ធផលជាយុទ្ធសាស្ត្រនៃសមាសភាគនីមួយៗអាចសម្រេចបាន លុះត្រាតែសមាសភាគពាក់ព័ន្ធផ្សេងទៀតបានចូលរួមអនុវត្តក្នុងការបំពេញឱ្យគ្នាទៅវិញទៅមក។ ការកំណត់សមាសភាគទាំងនេះត្រូវបានរៀបចំឱ្យមានលក្ខណៈសមស្របជាមួយនឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នដឹកនាំអនុវត្តសមាសភាគនីមួយៗ។

កជទី២ នឹងត្រូវអនុវត្តជាដំណាក់កាលៗតាមរយៈផែនការអនុវត្តពហុឆ្នាំ។ កជទី២ ត្រូវរៀបចំជាពីរដំណាក់កាល ដែលដំណាក់កាលនីមួយៗមានរយៈពេល៥ឆ្នាំ។

ឯកសារកជទី២ ត្រូវកំណត់នូវលទ្ធផលចម្បងៗសម្រាប់ការត្រួតពិនិត្យ និងការវាយតម្លៃនៅក្នុងរយៈពេលនៃកម្មវិធីជាតិទាំងមូល។ ក្របខ័ណ្ឌលទ្ធផលនៃកម្មវិធីជាតិត្រូវរៀបចំ ត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាពតាមការចាំបាច់។ ផែនការអនុវត្ត៥ឆ្នាំនីមួយៗត្រូវរៀបចំឱ្យស្របជាមួយក្របខ័ណ្ឌលទ្ធផលនេះ។ ចំពោះផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំត្រូវរៀបចំផ្អែកលើផែនការអនុវត្ត៥ឆ្នាំនីមួយៗ។

ការរៀបចំបែបផែននៃការអនុវត្តកជទី២ អាចមានការប្រែប្រួលក្នុងអំឡុងពេលនៃការអនុវត្តកម្មវិធីជាតិទាំងមូល។ អាស្រ័យហេតុនេះ ឯកសារកជទី២ ត្រូវកំណត់នូវគោលការណ៍តម្រង់ទិសមួយចំនួន ព្រមទាំងត្រូវគ្រោងនូវលទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពនានាសម្រាប់ការរៀបចំ ផអ៥ទី១ និង ផអ៥ទី២។

កជទី២ គឺជារបៀបវារៈនយោបាយមួយនៃការកែទម្រង់វិស័យសាធារណៈដ៏ទូលំទូលាយមួយរបស់រាជរដ្ឋាភិបាល។ ភាពជោគជ័យនៃកជទី២នេះ មានភាពពាក់ព័ន្ធទៅនឹងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ព្រមទាំងកំណែទម្រង់តាមវិស័យនីមួយៗ។ អាស្រ័យហេតុនេះ កជទី២ ត្រូវរៀបចំតាក់តែងដើម្បីជានាដល់ការសម្របសម្រួល និងកិច្ចសហការជាមួយនឹងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។

# ជំពូកទី៣

# សមាសភាគនៃកម្មវិធីជាតិ

## ៣.១. សមាសភាគទី១៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់

### ៣.១.១. សនិទានភាព

កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅកម្ពុជា គឺជាកំណែទម្រង់ដែលមានភាពសាំញ៉ាំ ស្មុគស្មាញ និងមានបញ្ហាប្រឈមជាច្រើន អាស្រ័យហេតុនេះ ចិរវេលា១០ឆ្នាំសម្រាប់ កជទី២ ស្ដីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺនៅតែជារយៈពេលខ្លីមួយដែលមានការលំបាកក្នុងការសម្រេចបានទាំងស្រុងនូវគោលបំណងនានានៃកំណែទម្រង់នេះ។ ក្រសួងស្ថាប័នពាក់ព័ន្ធនានានឹងត្រូវបន្តធ្វើកំណែទម្រង់របស់ខ្លួនតាមបែបផែនខុសៗគ្នា ស្របតាមតួនាទី ភារកិច្ចការទទួលខុសត្រូវ និងកិច្ចការអាទិភាពរបស់ខ្លួន ប៉ុន្តែដោយសារសកម្មភាពនៃកំណែទម្រង់របស់ក្រសួងស្ថាប័ននីមួយៗ មានការជះឥទ្ធិពលគ្នាទៅវិញទៅមកជាមួយនឹងការកែទម្រង់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ អាស្រ័យហេតុនេះ ការអនុវត្តនូវកំណែទម្រង់របស់ក្រសួង ស្ថាប័ននីមួយៗត្រូវមានភាពប្រទាក់ក្រឡាគ្នា គាំទ្រគ្នាទៅវិញទៅមក គឺជាកត្តាដ៏មានសារៈសំខាន់មួយ។ ជាមួយគ្នានេះដែរ កម្មវិធីកំណែទម្រង់សំខាន់ៗដទៃទៀតរបស់រាជរដ្ឋាភិបាលរួមមាន៖ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក៏ចាំបាច់ត្រូវសម្របសម្រួលគ្នាទៅវិញទៅមកជាមួយកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីរួមគ្នាសម្រេចនូវទស្សនវិស័យ គោលនយោបាយ និងយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងការអភិវឌ្ឍប្រទេសជាតិទាំងមូល។ ក្រៅពីនេះ ដោយសារកំណែទម្រង់នេះត្រូវប្រើប្រាស់ពេលវេលាយូរអង្វែង ព្រមទាំងត្រូវដោះស្រាយស្របទៅតាមស្ថានភាពដែលកំពុងវិវត្តនានាដូចជា ការវិវត្តនៃបច្ចេកវិទ្យាព័ត៌មាន និងការផ្លាស់ប្ដូរនៃវិសាលភាព រចនាសម្ព័ន្ធ និងការរីកចម្រើនសេដ្ឋកិច្ចរបស់ទីក្រុង និងទីប្រជុំជននានា ហេតុដូច្នេះ កំណែទម្រង់នេះចាំបាច់ត្រូវរៀបចំឱ្យមានការគ្រប់គ្រងតាមអភិក្រមថ្មីមួយ។

ជាមួយគ្នានឹងភាពស្មុគស្មាញខាងលើនេះ រាជរដ្ឋាភិបាលបានប្ដេជ្ញាចិត្តក្នុងការបន្តអនុវត្តកំណែទម្រង់ឱ្យកាន់តែស៊ីជម្រៅ ក៏ប៉ុន្តែដើម្បីធានាឱ្យសកម្មភាពនានានៃកម្មវិធីជាតិត្រូវបានអនុវត្តប្រកបដោយកិច្ចសហការគ្នា និងសម្រេចបានតាមគោលដៅ ចាំបាច់ត្រូវមានការចូលរួមអនុវត្តប្រកបដោយការតាំងចិត្ត និងភាពជាម្ចាស់របស់ក្រសួង ស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ ការគ្រប់គ្រងកំណែទម្រង់ ពុំមែនផ្អែកទាំងស្រុងតែទៅលើថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែក៏អាស្រ័យទៅលើថ្នាក់ដឹកនាំរបស់ក្រសួង ស្ថាប័ននានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផងដែរ។ ថ្នាក់ដឹកនាំនៃក្រសួង ស្ថាប័ននានាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ដូចជាអ្នកពាក់ព័ន្ធដទៃទៀត ព្រមទាំងប្រជាពលរដ្ឋទូទៅ ចាំបាច់ត្រូវមានការយល់ដឹងយ៉ាងច្បាស់លាស់អំពីចក្ខុវិស័យជាយុទ្ធសាស្ត្រ និង

គោលបំណងនៃកំណែទម្រង់ អាស្រ័យហេតុនេះ ការពង្រឹងនូវការប្រាស្រ័យទាក់ទងដើម្បីលើកម្ពស់ការយល់ដឹងអំពីកំណែទម្រង់ឱ្យបានទូលំទូលាយ គឺជាកត្តាជាគន្លឹះមួយនៃការដឹកនាំកំណែទម្រង់។

ការគ្រប់គ្រងកម្មវិធីកំណែទម្រង់តម្រូវឱ្យមានការដឹកនាំ សម្របសម្រួលដោយគណៈកម្មាធិការជាតិមួយក្នុងនាមរាជរដ្ឋាភិបាល ជាមួយនឹងការចូលរួមយ៉ាងសកម្មរបស់ក្រសួង ស្ថាប័នអនុវត្តនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

នៅពេលដែលកំណែទម្រង់កាន់តែស៊ីជម្រៅ ចាំបាច់ត្រូវគិតគូរពីជម្រើសនានានៃការរៀបចំនូវរចនាសម្ព័ន្ធស្ថាប័នថ្នាក់ជាតិដែលមានការទទួលខុសត្រូវយ៉ាងច្បាស់លាស់ទាំងការដឹកនាំ ការសម្របសម្រួល ព្រមទាំងការតាមដានត្រួតពិនិត្យ និងការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ មុខងារមួយចំនួនដែលត្រូវបានអនុវត្តនៅក្នុងកម្មវិធីជាតិ នឹងក្លាយជាមុខងារអចិន្ត្រៃយ៍របស់ក្រសួង ស្ថាប័នពាក់ព័ន្ធមួយឬច្រើន។ ក្រសួងជំនាញមួយចំនួនដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈតាមវិស័យនីមួយៗ ត្រូវពិនិត្យកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធ និងមុខងារបច្ចុប្បន្នរបស់ខ្លួន ដើម្បីធានាដល់ការដឹកនាំ និងការទទួលខុសត្រូវលើការរៀបចំគោលនយោបាយក្នុងវិស័យរបស់ខ្លួន ផ្តល់នូវគោលការណ៍ណែនាំនានា កំណត់ស្តង់ដារសេវា គាំទ្របច្ចេកទេស និងពង្រឹងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការត្រួតពិនិត្យវាយតម្លៃលើការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយរក្សាទុកនូវមុខងារជាយុទ្ធសាស្ត្រសំខាន់ៗដែលមិនអាចធ្វើវិមជ្ឈការបាន។

ដើម្បីឱ្យកំណែទម្រង់នេះកាន់តែមានប្រសិទ្ធភាព ចាំបាច់ត្រូវមានការចូលរួមយ៉ាងសកម្ម និងការយល់ដឹងច្បាស់លាស់ពីប្រជាពលរដ្ឋ។ ផ្អែកតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានជាប់ឆ្នោតគឺជាតួអង្គដ៏សំខាន់ក្នុងការធានានូវការប្រាស្រ័យទាក់ទងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ។ ជាមួយគ្នានេះដែរ សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទីយ៉ាងសំខាន់ក្នុងការកសាងសមត្ថភាពរបស់ក្រុមប្រឹក្សា និងការចូលរួមចំណែកក្នុងការគាំទ្រដល់ការពង្រឹងសិទ្ធិអំណាច ការទទួលខុសត្រូវលើតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សា។

អង្គការសង្គមស៊ីវិលមានតួនាទីយ៉ាងសំខាន់ ក្នុងការរួមចំណែកពាំនាំនូវកង្វល់របស់ប្រជាពលរដ្ឋជូនរដ្ឋបាលថ្នាក់ក្រោមជាតិពិនិត្យ និងដោះស្រាយ ព្រមទាំងចូលរួមលើកកម្ពស់សិទ្ធិទទួលព័ត៌មានចាំបាច់នានារបស់ប្រជាពលរដ្ឋ ក៏ដូចជាចូលរួមក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានផងដែរ។ កន្លងមកមានបទពិសោធន៍ល្អៗជាច្រើនដែលអង្គការសង្គមស៊ីវិលបានបំពេញតួនាទី និងភារកិច្ចប្រកបដោយប្រសិទ្ធភាពដូចជាការអនុវត្តនៅក្នុងការងារគណនេយ្យភាពសង្គម ក៏ប៉ុន្តែនៅមានភាពមិនទាន់រលូនល្អក្នុងកិច្ចសហការគ្នារវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលផងដែរ។

ផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) ត្រូវបានបង្កើតឡើងនៅចុងឆ្នាំ២០០៨ ក្នុងនាមជាស្ថាប័នទទួលខុសត្រូវក្នុងការដឹកនាំ និងការសម្របសម្រួលកិច្ចដំណើរការជាទូទៅ

នៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ គ.ជ.អ.ប. បានបង្កើតឡើងនូវអនុគណៈកម្មាធិការនានាដែលមានតួនាទីជួយ គ.ជ.អ.ប. ក្នុងការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងកំណែទម្រង់។ លេខាធិការដ្ឋាន គ.ជ.អ.ប. ក៏បានបំពេញតួនាទីយ៉ាងសំខាន់នៅក្នុងកិច្ចដំណើរការរៀបចំសេចក្តីព្រាងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ក៏ដូចជាបានបំពេញតួនាទី ក្នុងការសម្របសម្រួល និងការអនុវត្តដោយផ្ទាល់នូវសកម្មភាពប្រចាំថ្ងៃនៃកម្មវិធីកំណែទម្រង់ផងដែរ។ ដោយឡែក គណៈកម្មាធិការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ និងនៅតាមរដ្ឋបាលរាជធានី ខេត្ត ក្រុង និងស្រុក ក៏បានបំពេញតួនាទីរបស់ខ្លួនយ៉ាងសកម្មក្នុងការអនុវត្តការងារកំណែទម្រង់ផងដែរ។

ការអនុវត្តសមាសភាគ ឬសកម្មភាពនានានៃកជទី១ ត្រូវបានបែងចែកឱ្យមានការទទួលខុសត្រូវផ្សេងៗគ្នារវាងក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា។ ដោយឡែក ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធមួយចំនួនក៏បានចូលរួមផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងការពិភាក្សាផ្នែកគោលនយោបាយ ដោយប្រើប្រាស់ជាសំខាន់នូវយន្តការនៃក្រុមការងារបច្ចេកទេសស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ជារួម តាមរយៈការអនុវត្តកជទី១ កំណែទម្រង់នេះបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដែលធ្វើឱ្យមានការរាំងស្ទះ និងអូសបន្លាយរយៈពេលក្នុងការអនុវត្តនូវកិច្ចការអាទិភាពមួយចំនួន។ ភាពយឺតយ៉ាវនេះ បានឆ្លុះបញ្ចាំងឱ្យឃើញពីភាពស្មុគស្មាញនៃកំណែទម្រង់ និងការខ្វះបទពិសោធន៍ក្នុងការអនុវត្តកំណែទម្រង់នៅកម្ពុជានាពេលកន្លងមក។ នៅក្នុងការអនុវត្តកជទី១ ក្រសួង ស្ថាប័នអនុវត្តនានាបានរៀនសូត្រនូវមេរៀន បទពិសោធន៍ជាបណ្តើរៗ និងបានកែសម្រួលនូវវិធីសាស្ត្រនៃការអនុវត្តរបស់ខ្លួនឱ្យស្របទៅតាមការវិវឌ្ឍនៃកម្មវិធីជាតិ។ ទោះយ៉ាងណាក៏ដោយ ភាពយឺតយ៉ាវនៃការអនុវត្តកិច្ចការអាទិភាពមួយចំនួន ក៏ផ្តើមចេញជាសំខាន់ពីកង្វះខាតនៃការតាំងចិត្ត ឬភាពស្ទាក់ស្ទើររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនក្នុងការអនុវត្តសកម្មភាព ឬលទ្ធផលរំពឹងទុកជាក់លាក់មួយចំនួន ក៏ដូចជាការចូលរួមក្នុងការសម្រេចនូវគោលដៅជាយុទ្ធសាស្ត្ររួមនៃកំណែទម្រង់ផងដែរ។ ដោយឡែក ក្រសួង ស្ថាប័នមួយចំនួនដែលគាំទ្រកិច្ចដំណើរការកំណែទម្រង់ ក៏នៅពុំទាន់មានទិសដៅច្បាស់លាស់ក្នុងការអនុវត្តកំណែទម្រង់នេះ ឬពុំទាន់បានចាត់ទុកការងារកំណែទម្រង់នេះ ជាកិច្ចការអាទិភាពសំខាន់មួយក្នុងចំណោមកិច្ចការស្នូលដែលក្រសួង ស្ថាប័ននោះទទួលខុសត្រូវ។

ជាទូទៅ កង្វះខាតនៃការតាំងចិត្ត និងការពុំបានផ្តល់អាទិភាពទៅលើការងារកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន គឺជាបញ្ហាប្រឈមដ៏សំខាន់មួយនៅក្នុងការសម្រេចឱ្យបាននូវជោគជ័យនៃគោលបំណង និងគោលដៅនៃកជទី១។

ជាមួយគ្នានេះដែរ អនុគណៈកម្មាធិការនានារបស់គ.ជ.អ.ប. បានដំណើរការយ៉ាងសកម្មនូវកិច្ចការរបស់ខ្លួនក្នុងពេលចាប់ផ្តើមអនុវត្តកជទី១ ក៏ប៉ុន្តែបន្ទាប់មកកិច្ចដំណើរការនេះហាក់លែងមានភាពសកម្ម

ដូចពេលមុនដែលជាហេតុធ្វើឱ្យ គ.ជ.អ.ប. ចាំបាច់ត្រូវកែសម្រួលសមាសភាពនៃគណៈកម្មាធិការទាំងនេះឡើងវិញ ដើម្បីធានាដល់ប្រសិទ្ធភាពនៃកិច្ចដំណើរការរបស់អនុគណៈកម្មាធិការនានារបស់គ.ជ.អ.ប.។

កជទី១ ក៏បានជួបប្រទះនូវបញ្ហាប្រឈមអំពីហិរញ្ញវត្ថុក្នុងពេលដែលមូលនិធិរបស់ដៃគូអភិវឌ្ឍន៍ភាគច្រើនត្រូវបានផ្អាកនៅដើមឆ្នាំ២០១៨។ បញ្ហានេះ នាំឱ្យមានការកាត់បន្ថយនូវការគាំទ្រជំនួយបច្ចេកទេសដល់ការងារកំណែទម្រង់ និងខ្វះខាតថវិកាសម្រាប់អនុវត្តសកម្មភាពមួយចំនួន។ ទោះបីយ៉ាងនេះក៏ដោយ រាជរដ្ឋាភិបាលបានខិតខំពង្រឹងភាពជាម្ចាស់នៃការអនុវត្តកំណែទម្រង់ តាមរយៈការកំណត់ឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធនានាប្រើប្រាស់នូវថវិការបស់ខ្លួនក្នុងការអនុវត្តនូវកិច្ចការជាអាទិភាពនានានៃកម្មវិធីកំណែទម្រង់។

ភាពយឺតយ៉ាវនៃកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅក្នុងកជទី១ ក៏ពាក់ព័ន្ធទៅនឹងប្រជាពលរដ្ឋដែលភាគច្រើននៅតែមិនទាន់បានយល់ដឹងច្បាស់លាស់អំពីគោលបំណងជាយុទ្ធសាស្ត្រនៃកំណែទម្រង់ ក៏ដូចជាមិនទាន់មើលឃើញអំពីអត្ថប្រយោជន៍នៃកំណែទម្រង់ទៅលើការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវានានានៅឡើយ។ អាស្រ័យហេតុនេះ ប្រសិនបើប្រជាពលរដ្ឋទូទៅបានយល់ដឹងច្បាស់លាស់អំពីគោលបំណង និងអត្ថប្រយោជន៍នៃកំណែទម្រង់នោះនឹងបង្កលក្ខណៈងាយស្រួលដល់ការកៀរគរការគាំទ្របានយ៉ាងទូលំទូលាយលើកំណែទម្រង់នេះ។

ទោះបីជាយ៉ាងនេះក៏ដោយ សមិទ្ធផលជាសំខាន់នៃការអនុវត្តកជទី១ បានឆ្លុះបញ្ចាំងឱ្យឃើញអំពីការស្រុះស្រួលមូលមតិគ្នា និងកៀរគរការគាំទ្រកាន់តែច្រើនឡើងជាពិសេសនៅថ្នាក់មូលដ្ឋានតាមរយៈការបង្កើតឱ្យមានក្របខ័ណ្ឌច្បាស់លាស់សម្រាប់ការចូលរួមរបស់អង្គការសង្គមស៊ីវិល និងវិស័យឯកជននៅក្នុងដំណើរការកំណែទម្រង់ និងប្រតិបត្តិការនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

នៅក្នុងផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទី៣ ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ (ផអ៣ទី៣) នៃកជទី១ រួមមាននូវសមាសភាគស្តីពី "ការគ្រប់គ្រង និងការដឹកនាំកំណែទម្រង់" ដែលមានវិសាលភាព និងទម្រង់ប្រហាក់ប្រហែលនឹងសមាសភាគទី១ ដែលបានគ្រោងឡើងនៅក្នុងកជទី២ផងដែរ។ អាស្រ័យហេតុនេះ កិច្ចការអាទិភាពសំខាន់ៗមួយចំនួននៃសមាសភាគទី១នៅក្នុងផអ៣ទី៣ ដែលមិនទាន់បានសម្រេចទាំងស្រុងនឹងត្រូវបន្តអនុវត្តនៅក្នុងកជទី២ទៀត ដែលកិច្ចការទាំងនោះរួមមាន៖

- ការពិនិត្យ និងការកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធនៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និងអង្គភាពពាក់ព័ន្ធនានារបស់ក្រសួង ស្ថាប័នមួយចំនួនដែលបានផ្ទេរមុខងារ
- ការពង្រឹងភាពជាម្ចាស់លើការងារកំណែទម្រង់ និងការរៀបចំវេទិកាសម្រាប់ការពិភាក្សាគ្នាក្នុងកម្រិតថ្នាក់ដឹកនាំអំពីបញ្ហាប្រឈមនានានៃកំណែទម្រង់តាមរយៈការរៀបចំកិច្ចប្រជុំប្រចាំឆ្នាំចំនួន៣ ដាច់ដោយឡែកពីគ្នា ពោលគឺការរៀបចំកិច្ចប្រជុំកម្រិតអភិបាលក្រុង ស្រុក

កិច្ចប្រជុំកម្រិតអភិបាលរាជធានី ខេត្ត និងកិច្ចប្រជុំកម្រិតរដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធនានា

- ការពង្រឹងយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងដែលរួមមាន ការរៀបចំសកម្មភាពជាការផ្តួចផ្តើមនានា ដើម្បីជានាឱ្យមានការផ្លាស់ប្តូរឥរិយាបថ ការរៀបចំវេទិកាផ្សព្វផ្សាយព័ត៌មានយ៉ាងតិចចំនួន៣ដងក្នុងមួយឆ្នាំ ការពង្រឹងប្រព័ន្ធផ្សព្វផ្សាយតាមបណ្តាញព័ត៌មានសង្គម និងគេហទំព័ររបស់គ.ជ.អ.ប. ព្រមទាំងការបោះពុម្ពផ្សព្វផ្សាយជាដើម
- ការរៀបចំនូវយុទ្ធសាស្ត្រមួយ ស្តីពីការអនុវត្តសាកល្បងនូវសកម្មភាពមួយចំនួនដែលធានាដល់ការអនុវត្តនូវគោលនយោបាយនៃកំណែទម្រង់ និងការប្រមូលចងក្រងនូវមេរៀនបទពិសោធន៍ល្អៗ ដើម្បីធ្វើជាមូលដ្ឋានក្នុងការពិនិត្យ និងកែសម្រួលនូវគោលនយោបាយនានាដែលកំពុងអនុវត្ត
- ការពង្រឹងនូវតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការគាំទ្រដល់សមាជិករបស់ខ្លួន ព្រមទាំងការលើកកម្ពស់នូវភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល។

### ៣.១.២. និជ្ជាភាពនូវខៅនៃសមាសភាគនី១

#### ៣.១.២.១. សមិទ្ធផលរំពឹងទុក

សមិទ្ធផលរំពឹងទុកនៃសមាសភាគទី១ គឺ *"យន្តការដឹកនាំ សម្របសម្រួល និងគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានពង្រឹង ដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននានានៅក្នុងការរៀបចំតាក់តែង និងអនុវត្តនូវកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព"*។

#### ៣.១.២.២. យុទ្ធសាស្ត្រដើម្បីសម្រេចសមិទ្ធផលរំពឹងទុក

សមាសភាគទី១ ស្តីពីការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់នៃកជទី២ត្រូវបានរៀបចំឡើងដោយផ្អែកលើសមិទ្ធផលនានា ព្រមទាំងមេរៀនបទពិសោធន៍នៃការដោះស្រាយបញ្ហាប្រឈមនានាដែលបានអនុវត្តនៅក្នុងកជទី១។ ជាមួយគ្នានេះដែរ ការរៀបចំតាក់តែងសមាសភាគទី១នៃកជទី២ត្រូវបានយកចិត្តទុកដាក់ និងពិចារណាទៅលើបរិបទនៃការវិវត្តយ៉ាងឆាប់រហ័សនៃកំណែទម្រង់វិមជ្ឈការ និងការអភិវឌ្ឍរបស់ប្រទេសជាតិ ក៏ដូចជាផ្អែកទៅលើតួនាទីនៃការដឹកនាំ និងគ្រប់គ្រងដែលបានកំណត់យ៉ាងជាក់លាក់ នៅក្នុងសមាសភាគផ្សេងៗទៀតនៃកជទី២។

តួនាទីដឹកនាំរបស់ គ.ជ.អ.ប. ត្រូវបានពង្រឹងឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត ជាពិសេសតាមរយៈការជំរុញឱ្យអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. កាន់តែមានសកម្មភាពយ៉ាងសកម្ម។ កជទី២ នឹងជំរុញឱ្យមានការខិតខំប្រឹងប្រែងប្រកបដោយលក្ខណៈជាប្រព័ន្ធ និងរឹងមាំ ដើម្បីលើកកម្ពស់

ការយល់ដឹងយ៉ាងទូលំទូលាយអំពីគោលបំណង យុទ្ធសាស្ត្រ និងទិសដៅនានានៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងគោលបំណងលើកកម្ពស់នូវការស្រុះស្រួលមូលមតិគ្នាក្នុងការអនុវត្តកំណែទម្រង់នេះ។ ការដឹកនាំ និងការគ្រប់គ្រងកំណែទម្រង់នឹងត្រូវបានបន្តពង្រឹង ដោយផ្តោតជាសំខាន់លើការលើកកម្ពស់ការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំនានាទៅលើលទ្ធផលរំពឹងទុក។ ក្នុងអំឡុងពេល១០ឆ្នាំទៅមុខនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធនានានឹងត្រូវបានកែសម្រួលរចនាសម្ព័ន្ធរបស់ខ្លួនជាបណ្តើរៗ ដើម្បីធានាដល់ការគាំទ្រដល់ការអភិវឌ្ឍនៃអភិបាលកិច្ចល្អនៅថ្នាក់ក្រោមជាតិ។ ភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ និងជាមួយអង្គការសង្គមស៊ីវិលនឹងត្រូវបានពង្រឹងបន្ថែមទៀតដែលក្នុងនោះ សមាគមក្រុមប្រឹក្សាថ្នាក់ក្រោមជាតិនឹងកាន់តែចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងការពង្រឹងភាពជាដៃគូទាំងនេះ។

ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់សម្រាប់ការអនុវត្តកជទី២ នឹងមិនដូចគ្នាទាំងស្រុងជាមួយនឹងការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់នៅក្នុងកជទី១ នោះទេ។ ទន្ទឹមនឹងការបន្តផ្តោតការយកចិត្តទុកដាក់ទៅលើការរៀបចំក្របខ័ណ្ឌគតិយុត្តនានា កជទី២ ក៏ត្រូវយកចិត្តទុកដាក់ទៅលើការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវានៅថ្នាក់មូលដ្ឋានផងដែរ។ ក្នុងរយៈពេលជាង ១០ឆ្នាំកន្លងមកនេះ ប្រទេសកម្ពុជាមានការអភិវឌ្ឍលើគ្រប់វិស័យយ៉ាងឆាប់រហ័ស ហើយរំពឹងថានឹងមានការវិវត្តយ៉ាងលឿនបន្ថែមទៀតនៅពេលអនាគត។ ទន្ទឹមគ្នានឹងការអភិវឌ្ឍជាទូទៅនេះ បច្ចេកវិទ្យាព័ត៌មានក៏មានការរីកចម្រើនយ៉ាងឆាប់រហ័ស ហើយនឹងដើរតួនាទីកាន់តែទូលំទូលាយនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាល និងក្នុងការប្រាស្រ័យទាក់ទងនានារវាងរដ្ឋបាលសាធារណៈគ្រប់ថ្នាក់ជាមួយនឹងប្រជាពលរដ្ឋ។

ទិសដៅសំខាន់បំផុតនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺការផ្ទេរសិទ្ធិអំណាច និងការទទួលខុសត្រូវទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យរដ្ឋបាលទាំងនោះអាចបម្រើប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព។ ជាមួយគ្នានេះ ថ្នាក់ដឹកនាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវមានសមត្ថភាព និងទំនុកចិត្តខ្លួនឯងក្នុងការធ្វើសេចក្តីសម្រេចចិត្តនានាដោយការទទួលខុសត្រូវក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋប្រកបដោយភាពបត់បែន។ ក្នុងន័យនេះ ការអភិវឌ្ឍសមត្ថភាពសម្រាប់ការដឹកនាំ និងការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកិច្ចការចាំបាច់មួយក្នុងចំណោមកិច្ចការសំខាន់នានាក្នុងកជទី២។

លើសពីនេះទៀត កជទី២ ត្រូវបន្តសហការយ៉ាងជិតស្និទ្ធជាមួយកម្មវិធីកំណែទម្រង់ដទៃទៀតរបស់រាជរដ្ឋាភិបាលទាំងកម្រិតថ្នាក់ដឹកនាំ និងកម្រិតបច្ចេកទេស រួមមានកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងកម្មវិធីកំណែទម្រង់តាមវិស័យផ្សេងៗទៀត។

### ៣.១.២.៣. លទ្ធផលរំពឹងទុក

សមិទ្ធផលរំពឹងទុកនៃសមាសភាគទី១នេះ នឹងត្រូវសម្រេចបានតាមរយៈការអនុវត្តឱ្យបានជោគជ័យនូវលទ្ធផលរំពឹងទុកជាយុទ្ធសាស្ត្រចំនួន ៥ ដែលរួមមានដូចខាងក្រោម៖

- **លទ្ធផលរំពឹងទុកទី១ ៖** យន្តការដឹកនាំកំណែទម្រង់ត្រូវបានពង្រឹងយ៉ាងរឹងមាំ ដើម្បីបន្តជំរុញកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យកាន់តែមានការវិវឌ្ឍទៅមុខប្រកបដោយសមធម៌ និងបរិយាប័ន្ន
- **លទ្ធផលរំពឹងទុកទី២ ៖** ចក្ខុវិស័យ គោលបំណង គោលដៅ និងសមិទ្ធផលនានានៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានផ្សព្វផ្សាយ សំដៅបង្កើនការយល់ដឹង និងការគាំទ្រយ៉ាងទូលំទូលាយដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា
- **លទ្ធផលរំពឹងទុកទី៣៖** កម្មវិធីជាតិដំណាក់កាលទី២ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព
- **លទ្ធផលរំពឹងទុកទី៤ ៖** រចនាសម្ព័ន្ធស្ថាប័ននៅថ្នាក់ជាតិសម្រាប់ធានាការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង
- **លទ្ធផលរំពឹងទុកទី៥ ៖** ការចូលរួមរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការកំណែទម្រង់ត្រូវបានលើកកម្ពស់។

#### ៣.១.២.៤. យុទ្ធសាស្ត្រ និងសកម្មភាពជាអាទិភាពសម្រាប់អនុវត្តលទ្ធផលរំពឹងទុកនានា

*លទ្ធផលរំពឹងទុក ១.១៖ យន្តការដឹកនាំកំណែទម្រង់ត្រូវបានពង្រឹងយ៉ាងរឹងមាំ ដើម្បីបន្តជំរុញកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យកាន់តែមានការវិវឌ្ឍទៅមុខប្រកបដោយសមធម៌ និងបរិយាប័ន្ន*

ដោយសារកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កាន់តែមានលក្ខណៈស្មុគស្មាញ សាំញ៉ាំ ទូលំទូលាយ និងមានការពាក់ព័ន្ធជាមួយក្រសួង ស្ថាប័នជាច្រើនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហេតុដូច្នេះភាពរឹងមាំនៃការដឹកនាំ និងការសម្របសម្រួលកំណែទម្រង់ គឺជាកត្តាកំណត់ភាពជោគជ័យនៃការអនុវត្តកម្មវិធីកំណែទម្រង់នេះ។ ក្នុងន័យនេះ កជទី២ ត្រូវផ្តោតជាសំខាន់ទៅលើការពង្រឹងការដឹកនាំ និងការសម្របសម្រួលរបស់ គ.ជ.អ.ប. ដែលជាស្ថាប័នដឹកនាំថ្នាក់ខ្ពស់តំណាងឱ្យរាជរដ្ឋាភិបាល ការពង្រឹងយន្តការនានារបស់ គ.ជ.អ.ប. និងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយកម្មវិធីកំណែទម្រង់ និងដៃគូនានា។

ដើម្បីធានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី១ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៨ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ១.១.១៖ ការបន្តពង្រឹងតួនាទី ភារកិច្ចរបស់ គ.ជ.អ.ប. ក្នុងការដឹកនាំ សម្របសម្រួលកម្មវិធីកំណែទម្រង់

សកម្មភាពនេះត្រូវផ្តោតទៅលើការរៀបចំកិច្ចប្រជុំរបស់ គ.ជ.អ.ប. ឱ្យបានទៀងទាត់តាមច្បាប់កំណត់ ដើម្បីធានាដល់ការដឹកនាំនិងសម្របសម្រួលរបស់ គ.ជ.អ.ប. លើការរៀបចំ និងការកែលម្អក្របខ័ណ្ឌគតិយុត្តិស្របតាមស្ថានភាពវិវត្តនៃកំណែទម្រង់ ការតាមដានត្រួតពិនិត្យការអនុវត្តកជទី២ និងការផ្តល់ការណែនាំ និងការតម្រង់ទិសដល់អនុគណៈកម្មាធិការនានា និងលេខាធិការដ្ឋានរបស់ គ.ជ.អ.ប. ព្រមទាំងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគាំទ្រ និងចូលរួមអនុវត្តកម្មវិធីកំណែទម្រង់នេះ។ ទន្ទឹមនោះ គ.ជ.អ.ប. ត្រូវធ្វើសេចក្តីរាយការណ៍ជាទៀងទាត់ជូនរាជរដ្ឋាភិបាលអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

### សកម្មភាពអាទិភាព ១.១.២៖ ការបន្តពង្រឹងអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. ក្នុងការបំពេញភារកិច្ចឱ្យមានប្រសិទ្ធភាព

អនុគណៈកម្មាធិការនីមួយៗរបស់ គ.ជ.អ.ប. ត្រូវជួបប្រជុំគ្នាយ៉ាងតិចចំនួនបីដងក្នុងមួយឆ្នាំ។ ក្រៅពីរបៀបវារៈនានាដែលផ្តួចផ្តើមដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីដាក់ជូនអនុគណៈកម្មាធិការនីមួយៗក្នុងការពិនិត្យ និងពិភាក្សាមុនដាក់ជូន គ.ជ.អ.ប. ពិនិត្យ និងអនុម័ត អនុគណៈកម្មាធិការនីមួយៗត្រូវរៀបចំឱ្យមានការសិក្សាស្រាវជ្រាវ តាមដានត្រួតពិនិត្យ និងវាយតម្លៃអំពីវឌ្ឍនភាពនិងបញ្ហាប្រឈមនានាក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងលើកឡើងនូវរបៀបវារៈសម្រាប់កិច្ចប្រជុំរបស់ខ្លួន ដើម្បីរៀបចំនូវសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិចាំបាច់នានា ក៏ដូចជាជម្រើសនៃការដោះស្រាយនូវបញ្ហាប្រឈមនានាដែលអនុគណៈកម្មាធិការបានរកឃើញ ដើម្បីដាក់ជូន គ.ជ.អ.ប. ពិនិត្យ និងសម្រេច។ អនុគណៈកម្មាធិការនីមួយៗត្រូវធ្វើរបាយការណ៍ជាទៀងទាត់អំពីវឌ្ឍនភាពនៃកិច្ចការរបស់ខ្លួនជូន គ.ជ.អ.ប.។

ក្នុងករណីចាំបាច់ អនុគណៈកម្មាធិការចំនួនពីរ ឬច្រើនអាចរៀបចំកិច្ចប្រជុំរួមគ្នា ដើម្បីសម្របសម្រួល និងពិភាក្សាការងារដែលពាក់ព័ន្ធនឹងអនុគណៈកម្មាធិការទាំងនោះ។

អនុគណៈកម្មាធិការនីមួយៗត្រូវបង្កើត ឬចាត់តាំងឱ្យមានអង្គភាព ឬក្រុមការងារមួយដើម្បីជួយដល់អនុគណៈកម្មាធិការសាមីនីមួយៗក្នុងការបំពេញការងារប្រចាំថ្ងៃ។ អង្គភាព ឬក្រុមការងារនេះត្រូវមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីធានាបាននូវការបំពេញតួនាទីជាសេនាធិការរួមគ្នារបស់អនុគណៈកម្មាធិការនីមួយៗ។

### សកម្មភាពអាទិភាព ១.១.៣៖ ការពង្រឹងសមត្ថភាព តួនាទី និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.

ដើម្បីធានាឱ្យការងាររបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការជួយគាំទ្រដល់ គ.ជ.អ.ប. និងអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. ក្នុងការដឹកនាំ និងសម្របសម្រួលការងារកំណែទម្រង់ប្រចាំថ្ងៃឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត ផ្នែកខ្លះនៃរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ចាំបាច់ត្រូវ

ពិនិត្យ និងកែសម្រួលឡើងវិញ។ ការពិនិត្យមើលឡើងវិញនូវរចនាសម្ព័ន្ធ និងមុខងាររបស់លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងត្រូវអនុវត្តឱ្យបានរួចរាល់នៅក្នុងឆ្នាំដំបូងៗនៃកជទី២។ ទន្ទឹមនឹងនោះ ក៏ចាំបាច់ត្រូវយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍសមត្ថភាពដល់បុគ្គលិករបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ជាពិសេសសមត្ថភាពពាក់ព័ន្ធនឹងការវិភាគនិងរៀបចំគោលនយោបាយនានា ការងារគ្រប់គ្រងការអនុវត្តកម្មវិធីកំណែទម្រង់ និងការបំពេញតួនាទីជាសេនាធិការឱ្យ គ.ជ.អ.ប. និងអនុគណៈកម្មាធិការនានារបស់គ.ជ.អ.ប.។

### សកម្មភាពអាទិភាព១.១.៤៖ ការលើកកម្ពស់ប្រសិទ្ធភាពដឹកនាំរបស់គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

ដើម្បីធានាដល់ការអនុវត្តកជទី២ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ចាំបាច់ត្រូវពង្រឹងតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់គណៈកម្មាធិការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅតាមស្ថាប័នរបស់ខ្លួន។ ក្នុងការរៀបចំ និងអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការងារកំណែទម្រង់នេះនៅក្នុងស្ថាប័ននីមួយៗ ចាំបាច់ត្រូវកំណត់ឱ្យបានច្បាស់លាស់នូវលទ្ធផលរំពឹងទុក ក្របខ័ណ្ឌពេលវេលា និងអ្នកទទួលខុសត្រូវ ព្រមទាំងត្រូវវិភាជថវិការបស់ស្ថាប័នសាមីឱ្យបានសមស្របសម្រាប់ការអនុវត្តផែនការសកម្មភាពទាំងនេះ។ ផែនការនេះ ចាំបាច់ត្រូវមានការឯកភាព និងចុះកិច្ចព្រមព្រៀងជាមួយ គ.ជ.អ.ប. ដើម្បីធានាដល់ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ។ ជាមួយគ្នានេះដែរ គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅតាមស្ថាប័ននីមួយៗក៏ត្រូវពិនិត្យមើលឡើងវិញ និងពង្រឹងសមត្ថភាពនូវអង្គភាព ឬក្រុមការងារដែលបានបង្កើតឡើងជាសេនាធិការរបស់ខ្លួន ដើម្បីពង្រឹងការទទួលខុសត្រូវលើកិច្ចការប្រចាំថ្ងៃ។ គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៃរដ្ឋបាលថ្នាក់ក្រោមជាតិពិនិត្យ និងកែសម្រួលសមាសភាពរបស់ខ្លួនដោយដាក់បញ្ចូលនូវមន្ទីរ អង្គភាពពាក់ព័ន្ធនានា។ គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ស្ថាប័ននីមួយៗត្រូវធ្វើរបាយការណ៍ជាទៀងទាត់អំពីវឌ្ឍនភាព និងបញ្ហាប្រឈមជូន គ.ជ.អ.ប.។

### សកម្មភាពអាទិភាព ១.១.៥៖ ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានា

ដើម្បីធានាដល់ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិជាមួយកម្មវិធីកំណែទម្រង់សំខាន់ៗផ្សេងទៀតរបស់រាជរដ្ឋាភិបាល ពោលគឺកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ យន្តការនៃការជួបប្រជុំគ្នាជាប្រចាំរវាងលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំកំណែទម្រង់ទាំងនេះត្រូវបន្តអនុវត្តកិច្ចប្រជុំតាមការឆ្លាស់វេនគ្នាឱ្យបានទៀងទាត់ ដើម្បីធានាដល់ភាពប្រទាក់ក្រឡាគ្នា និងគាំទ្រគ្នាទៅវិញទៅមករវាងកម្មវិធីកំណែទម្រង់នីមួយៗ ព្រមទាំងសម្រេចបាននូវគោលដៅនានានៃកំណែទម្រង់ទាំងនេះ។

ផែនការសកម្មភាពរួមមួយ (ដែលរួមមាននូវសកម្មភាពទាំងឡាយដែលមានភាពប្រទាក់ក្រឡាគ្នារវាងកំណែទម្រង់ពីរឬច្រើន) រវាងលេខាធិការដ្ឋាននៃកំណែទម្រង់ទាំងនេះចាំបាច់ត្រូវបានរៀបចំ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំដោយមានការកំណត់នូវសូចនាករ ក្របខ័ណ្ឌពេលវេលា និងស្ថាប័នទទួលខុសត្រូវច្បាស់លាស់ ព្រមទាំងត្រូវធានាថាផែនការនេះត្រូវបានទទួលការឯកភាពពីប្រធានគណៈកម្មការកំណែទម្រង់នីមួយៗ និងត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅក្នុងស្ថាប័នសាមីនីមួយៗដែលទទួលបន្ទុកកំណែទម្រង់នោះ ដើម្បីធានាដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាព។ ជាមួយគ្នានេះដែរ ចាំបាច់ត្រូវរៀបចំឱ្យមានឯកសារទស្សនទានស្ដីពីចក្ខុវិស័យ និងយុទ្ធសាស្ត្រនៃកម្មវិធីកំណែទម្រង់សំខាន់ៗទាំងបួនរបស់រាជរដ្ឋាភិបាល ពោលគឺកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដើម្បីជាមូលដ្ឋានមួយបន្ថែមទៀតក្នុងការរួមចំណែកបន្សុីគ្នាយ៉ាងជិតស្និទ្ធនូវការអនុវត្តកំណែទម្រង់ទាំងនេះក្នុងការសម្រេចនូវគោលដៅ និងគោលបំណងនៃកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល។

## សកម្មភាពអាទិភាព ១.១.៦៖ ការរៀបចំវេទិកា ឬកិច្ចប្រជុំប្រធានក្រុមប្រឹក្សា និងអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវសហការជាមួយក្រសួងមហាផ្ទៃ និងសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការសម្របសម្រួល និងគាំទ្រឱ្យមានវេទិកា ឬកិច្ចប្រជុំរវាងថ្នាក់ដឹកនាំរាជធានី ខេត្ត និងកិច្ចប្រជុំរវាងថ្នាក់ដឹកនាំក្រុង ស្រុក ខណ្ឌ ដើម្បីពិភាក្សាផ្លាស់ប្ដូរយោបល់គ្នាលើការអនុវត្តគោលនយោបាយនានា ក៏ដូចជាការដឹកនាំ និងការគ្រប់គ្រងកម្មវិធីកំណែទម្រង់នៃថ្នាក់រដ្ឋបាលនីមួយៗ។ កិច្ចប្រជុំនេះត្រូវមានការចូលរួមដោយផ្ទាល់ពីប្រធានក្រុមប្រឹក្សា និងអភិបាលនៃថ្នាក់រដ្ឋបាលនីមួយៗ ព្រមទាំងត្រូវរៀបចំយ៉ាងហោចណាស់ចំនួនពីរឆ្នាំម្ដង។

## សកម្មភាពអាទិភាព ១.១.៧៖ ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានាប្រកបដោយភាពស្ថាបនា

សកម្មភាពនេះផ្ដោតលើការពង្រឹងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធជាមួយដៃគូអភិវឌ្ឍន៍នានា តាមរយៈយន្តការនៃកិច្ចប្រជុំក្រុមការងារបច្ចេកទេស ស្ដីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យបានទៀងទាត់ និងប្រកបដោយប្រសិទ្ធភាព ក្នុងគោលបំណងធានាដល់ការចែករំលែកព័ត៌មានគ្នាទៅវិញទៅមក និងការប្រមូលធាតុចូលនានាពាក់ព័ន្ធទៅនឹងកិច្ចដំណើរការកំណែទម្រង់ ក៏ដូចជាដើម្បីកៀរគរការគាំទ្រទាំងធនធាន និងជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ដល់ការអនុវត្តកម្មវិធីជាតិ។

### សកម្មភាពអាទិភាព ១.១.៨៖ ការពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

សកម្មភាពនេះ ផ្តោតលើការពង្រឹងយន្តការអន្តរវិស័យ ជាពិសេសដើម្បីការឆ្លើយតបទៅនឹងបញ្ហា និងតម្រូវការនានារបស់ស្ត្រី កុមារ និងក្រុមជនងាយរងគ្រោះនៅក្នុងដំណើរការអនុវត្តកម្មវិធីជាតិ។ គោលនយោបាយ ស្តីពីការលើកកម្ពស់សមភាពយេនឌ័រសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបន្តពង្រឹង និងពង្រីកវិសាលភាពនៅក្នុងការអនុវត្តកម្មវិធីជាតិទាំងមូល។ ក្នុងន័យនេះ ក្រុមការងារយេនឌ័រដែលមានសមាសភាពពីក្រសួងកិច្ចការនារី និងលេខាធិការដ្ឋាន គ.ជ.អ.ប. នឹងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការឆ្លើយតបនិងបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមនៅក្នុងដំណើរការតាក់តែង អនុវត្ត តាមដាន និងវាយតម្លៃកម្មវិធីជាតិ និងផអ៥នីមួយៗ រួមទាំងការបញ្ចូលការយកចិត្តទុកដាក់កិច្ចការអន្តរវិស័យនេះ នៅក្នុងរបៀបវារៈកិច្ចប្រជុំរបស់ គ.ជ.អ.ប. ក្នុងការអនុវត្តការងារស្នូលរបស់ក្រសួង ស្ថាប័នវិស័យនានា លេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

### *លទ្ធផលរំពឹងទុក ១.២៖ ចក្ខុវិស័យ គោលបំណង គោលដៅ និងសមិទ្ធផលនានានៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានផ្សព្វផ្សាយ សំដៅបង្កើនការយល់ដឹង និងការគាំទ្រយ៉ាងទូលំទូលាយដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា*

ដើម្បីលើកកម្ពស់ការយល់ដឹងឱ្យបានទូលំទូលាយអំពីកំណែទម្រង់ យុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនៅក្នុងអំឡុងពេលនៃកជទី១។ ទោះបីយ៉ាងនេះក៏ដោយ យុទ្ធសាស្ត្រនេះនៅពុំទាន់មានភាពគ្រប់ជ្រុងជ្រោយ និងពុំទាន់ត្រូវបានអនុវត្តពេញលេញនៅឡើយ។ អាស្រ័យហេតុនេះ ក្នុងអំឡុងពេលនៃកជទី២ យុទ្ធសាស្ត្រនេះចាំបាច់ត្រូវពង្រឹងក្នុងការអនុវត្ត ព្រមទាំងត្រូវពិនិត្យ និងកែលម្អឱ្យមានលក្ខណៈសមស្របជាមួយនឹង ផអ៥នីមួយៗ។ យុទ្ធសាស្ត្រនេះនឹងត្រូវបានអនុវត្តដោយប្រើប្រាស់នូវមន្ត្រីដែលមានជំនាញវិជ្ជាជីវៈ និងគ្រប់មធ្យោបាយក្នុងការងារប្រាស្រ័យទាក់ទង។ លទ្ធផលរំពឹងទុកនៃការអនុវត្តយុទ្ធសាស្ត្រនេះ ត្រូវវាស់វែងដោយផ្អែកជាសំខាន់លើការផ្លាស់ប្តូរនូវការយល់ដឹង ឥរិយាបថ និងអាកប្បកិរិយារបស់ក្រុមជនគោលដៅនានា ពោលគឺមិនមែនតែទៅលើចំនួននៃការផ្សព្វផ្សាយព័ត៌មានប៉ុណ្ណោះនោះទេ។

ដើម្បីធានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី២ ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៣ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ១.២.១៖ ការកែលម្អ និងការពង្រឹងយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង

ការកែលម្អ និងពង្រឹងយុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទងត្រូវធានាដល់ការសម្រេចនូវលទ្ធផលរំពឹងទុកមួយចំនួន ដូចខាងក្រោម ៖

- ចក្ខុវិស័យ និងគោលបំណងនៃកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានយល់ដឹង និងទទួលបានការគាំទ្រយ៉ាងទូលំទូលាយពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា
- គោលដៅនៃកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានយល់ដឹង និងទទួលបានការគាំទ្រយ៉ាងទូលំទូលាយពីតួអង្គប្រតិបត្តិពាក់ព័ន្ធនានា ជាពិសេសក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- មុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមថ្នាក់នីមួយៗត្រូវបានយល់ដឹងយ៉ាងទូលំទូលាយពីប្រជាពលរដ្ឋ ពោលគឺប្រជាពលរដ្ឋអាចដឹងថា តើសេវាប្រភេទណាដែលខ្លួនអាចទទួលបានពីរដ្ឋបាលថ្នាក់ណា ហើយតើត្រូវធ្វើដូចម្តេចដើម្បីទទួលបាននូវសេវាទាំងនោះ
- អ្នកពាក់ព័ន្ធនានា រួមបញ្ចូលទាំងប្រជាពលរដ្ឋបានយល់ដឹងអំពីវិធីសាស្ត្រក្នុងការចូលរួមដោយផ្ទាល់ ឬដោយប្រយោលនូវមតិយោបល់ និងសកម្មភាពអាទិភាពនានារបស់ខ្លួនស្តីពីការងារកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ការរៀបចំឱ្យមានយន្តការប្រកបដោយប្រសិទ្ធភាពមួយសម្រាប់ការទទួលយក និងការឆ្លើយតបចំពោះមតិយោបល់ សំណូមពរ និងបណ្តឹងនានាពាក់ព័ន្ធនឹងការអនុវត្តកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

យុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងត្រូវរៀបចំឱ្យមាននូវសារជាគន្លឹះ និងវិធីសាស្ត្រនានាសម្រាប់ការផ្សព្វផ្សាយដល់ក្រុមគោលដៅជាក់លាក់នីមួយៗ ដូចខាងក្រោម ៖

- មន្ត្រីនៅក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សមាជិកក្រុមប្រឹក្សា
- អង្គការសង្គមស៊ីវិល
- វិស័យឯកជន
- ដៃគូអភិវឌ្ឍន៍
- គ្រូបង្រៀន និងសិស្សនិស្សិត
- ប្រជាពលរដ្ឋទូទៅ។

យុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងត្រូវប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននានា រួមមានការបោះពុម្ព សារព័ត៌មានអេឡិចត្រូនិច ការផ្សព្វផ្សាយតាមរលកធាតុអាកាស និងការរៀបចំវេទិកាចែករំលែកព័ត៌មានផ្សេងៗ។ ប្រព័ន្ធផ្សព្វផ្សាយត្រូវបានប្រើប្រាស់ផ្សេងៗគ្នា ដើម្បីជានាការផ្សព្វផ្សាយឱ្យបានដល់

ក្រុមគោលដៅនីមួយៗ។ ជាទូទៅ សារព័ត៌មានអេឡិចត្រូនិចដែលជាប្រព័ន្ធផ្សព្វផ្សាយទំនើប គឺជាប្រព័ន្ធផ្សព្វផ្សាយមានសារៈសំខាន់ ដោយសារប្រព័ន្ធនេះចំណាយតិចជាងប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី។ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយនានាដែលមានចំណាយខ្ពស់ដូចជា ការបោះពុម្ព និងការរៀបចំសិក្ខាសាលានានាអាចប្រើប្រាស់បានក្នុងករណីដែលពុំមានលទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដែលមានចំណាយតិច។

## សកម្មភាពអាទិភាព ១.២.២៖ ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង

យុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងនៅក្នុងកជទី២ ត្រូវអនុវត្ត និងទទួលខុសត្រូវដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ដែលមានអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មានជាសេនាធិការ។ លេខាធិការដ្ឋាន គ.ជ.អ.ប. អាចសហការ ឬផ្តល់កិច្ចសន្យាដល់ស្ថាប័នជំនាញផ្សព្វផ្សាយព័ត៌មាន ឬអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា ដើម្បីចូលរួមការផ្សព្វផ្សាយ។ ជាមួយគ្នានេះដែរ លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវខិតខំបន្តពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកការងារប្រាស្រ័យទាក់ទងជាសាធារណៈ ព្រមទាំងប្រើប្រាស់នូវមធ្យោបាយផ្សព្វផ្សាយនានាឱ្យបានគ្រប់រូបភាព។

## សកម្មភាពអាទិភាព ១.២.៣៖ ការវាស់វែងលទ្ធផលនៃការប្រាស្រ័យទាក់ទង

កជទី២ ត្រូវរៀបចំឱ្យមានការអង្កេតនានា ដើម្បីវាស់វែងអំពីប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង ដោយប្រើប្រាស់នូវវិធីសាស្ត្រដ៏មានប្រសិទ្ធភាពនានា រាប់បញ្ចូលទាំងវិធីសាស្ត្រដែលបានប្រើប្រាស់ដោយក្រុមហ៊ុនឯកជន ក្នុងការវាស់វែងពីប្រសិទ្ធភាពនៃការផ្សព្វផ្សាយរបស់ខ្លួន។ ប្រសិទ្ធភាពនៃការប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នានៃការប្រាស្រ័យទាក់ទង នឹងត្រូវបានវាស់វែងដោយប្រើប្រាស់លទ្ធផលនានានៃការអង្កេត ដើម្បីជាមូលដ្ឋានក្នុងការកែសម្រួលសកម្មភាពនានានៃការផ្សព្វផ្សាយដែលធានាដល់ការសម្រេចលទ្ធផលឱ្យកាន់តែល្អប្រសើរឡើង។

## *លទ្ធផលរំពឹងទុក ១.៣៖ កម្មវិធីជាតិដំណាក់កាលទី២ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព*

ឯកសារជាគន្លឹះសម្រាប់ការអនុវត្តកជទី២ រួមមាន ៖

- ផែនការអនុវត្តរយៈពេលប្រាំឆ្នាំ (ផអ៥) ដំណាក់កាលទី១ និងដំណាក់កាលទី២
- ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ (ផ.ស.ថ.) របស់គ.ជ.អ.ប.
- កិច្ចការ ឬគម្រោងនានាដែលកំណត់នៅក្នុងផអ៥ ដែលក្នុងនោះកិច្ចការ ឬគម្រោងនីមួយៗត្រូវកំណត់នូវលទ្ធផលរំពឹងទុក ក្របខ័ណ្ឌពេលវេលា និងស្ថាប័នអនុវត្តយ៉ាងច្បាស់លាស់។

ផអ៥ គឺជាផែនការរយៈពេលមធ្យមមួយដែលបែងចែក និងរៀបចំសកម្មភាពនានានៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (ដែលរួមមាននៅក្នុងកជទី២) ឱ្យទៅជា

បញ្ជីមួយនៃគម្រោង ឬកិច្ចការជាក់លាក់នានាដែលត្រូវអនុវត្តឱ្យបានសម្រេចក្នុងអំឡុងពេលនៃ ផអ៥ នីមួយៗ។

ផ.ស.ថ.ប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ត្រូវរៀបចំដោយផ្អែកលើកជទី២ និងជាពិសេស ផអ៥ ដែលរួមបញ្ចូលនូវកិច្ចការ ឬគម្រោងនានារបស់ក្រសួង ស្ថាប័នអនុវត្តទាំងអស់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងគម្រោង ឬកម្មវិធីនានាដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាដែលពាក់ព័ន្ធនឹងការងារកំណែទម្រង់។

កិច្ចការ ឬគម្រោងនានាស្តីពីការងារកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់បណ្តាស្ថាប័នអនុវត្តនីមួយៗទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានរៀបចំដោយស្ថាប័នសាមីនីមួយៗ ឱ្យទៅជាផ្នែកមួយនៃផែនការយុទ្ធសាស្ត្រថវិការបស់ស្ថាប័ននោះ។ កិច្ចការ ឬគម្រោងទាំងនោះត្រូវរៀបចំដោយផ្អែកលើបញ្ជីកិច្ចការ ឬគម្រោងនានាដែលបានកំណត់នៅក្នុង ផអ៥ ហើយដែលត្រូវអនុវត្តឱ្យបានសម្រេចក្នុងឆ្នាំនីមួយៗ ព្រមទាំងផ្អែកលើអាណត្តិ និងការទទួលខុសត្រូវរបស់ស្ថាប័នអនុវត្តនីមួយៗ។ លទ្ធផលរំពឹងទុក សកម្មភាពជាអាទិភាព សូចនាករ ពេលវេលា ថវិកា និងអង្គភាពទទួលខុសត្រូវត្រូវបានកំណត់យ៉ាងច្បាស់លាស់ ដើម្បីធានាដល់ការសម្រេចនូវកិច្ចការ ឬគម្រោងនីមួយៗ។

កិច្ចការ ឬគម្រោងនានានឹងត្រូវរៀបចំជាចង្កោមសកម្មភាព ឬសកម្មភាពនៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ស្ថាប័នអនុវត្តនីមួយៗ (ដូចជាលេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ)។ អាស្រ័យហេតុនេះ ការរៀបចំផែនការប្រចាំឆ្នាំសម្រាប់អនុវត្តកិច្ចការ ឬគម្រោងនានានៃកជទី២ ត្រូវបន្សុីគ្នាជាមួយនឹងវដ្តនៃការរៀបចំថវិកាប្រចាំឆ្នាំរបស់ស្ថាប័នអនុវត្តនានាដែលត្រូវចាប់ផ្តើមនៅរៀងរាល់ត្រីមាសទី២នៃឆ្នាំមុន។

គម្រោងនានាដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ត្រូវឆ្លុះបញ្ចាំងនៅក្នុង ផ.ស.ថ.ប្រចាំឆ្នាំរបស់គ.ជ.អ.ប. ដើម្បីបង្ហាញពីការរួមចំណែករបស់ដៃគូអភិវឌ្ឍន៍ ក្នុងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងឆ្នាំនីមួយៗ។ ជាទូទៅ ការគ្រប់គ្រងហិរញ្ញវត្ថុដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ភាគច្រើនត្រូវបានអនុវត្តតាមនីតិវិធីដោយឡែកៗរបស់ដៃគូអភិវឌ្ឍន៍នីមួយៗ និងមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ការរៀបចំនូវបញ្ជីកិច្ចការនានានៅក្នុងផអ៥ ក្នុងគោលបំណងដើម្បីបង្កលក្ខណៈងាយស្រួលដល់ដៃគូអភិវឌ្ឍន៍ក្នុងការរៀបចំនូវគម្រោង ឬកម្មវិធីគាំទ្រនានាដែលពាក់ព័ន្ធទៅនឹងកិច្ចការទាំងនោះ។ អាស្រ័យហេតុនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. ដែលមានអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធីជាសេនាធិការ ត្រូវទទួលខុសត្រូវក្នុងការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍នានាក្នុងការធានាឱ្យរាល់ការរៀបចំគម្រោង ឬកម្មវិធីនានាដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ត្រូវបន្សុីគ្នាជាមួយនឹងកិច្ចការជាអាទិភាពនានានៅក្នុងផអ៥។

ការរៀបចំ ការអនុវត្ត និងការគ្រប់គ្រងកិច្ចការ ឬគម្រោងនានារបស់ស្ថាប័នអនុវត្តនីមួយៗ ត្រូវអនុវត្តតាមនីតិវិធីនានានៃសៀវភៅណែនាំស្តីពីការគ្រប់គ្រងគម្រោងរបស់គ.ជ.អ.ប.។ អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធីនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវទទួលខុសត្រូវក្នុងការគាំទ្រស្ថាប័នអនុវត្តនានាក្នុងការអនុវត្តតាមនីតិវិធីនៃសៀវភៅណែនាំស្តីពីការគ្រប់គ្រងគម្រោង ព្រមទាំងទទួលខុសត្រូវក្នុងការតាមដាន និងត្រួតពិនិត្យការអនុវត្តកិច្ចការ ឬគម្រោងនានាដែលបានកំណត់នៅក្នុងផអ៥ ផងដែរ។

ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំត្រូវបញ្ចូលនូវសកម្មភាព និងថវិកាពីប្រភពផ្តល់មូលនិធិទាំងអស់ដែលគាំទ្រការអនុវត្តកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ព្រមទាំងកំណត់នូវចំណុចដៅនានាដែលត្រូវសម្រេចតាមឆ្នាំនីមួយៗ។

ទន្ទឹមនឹងនេះ គ.ជ.អ.ប. ចាំបាច់ត្រូវពង្រឹងនូវយន្តការត្រួតពិនិត្យ និងតាមដានលទ្ធផលនៃការអនុវត្តកិច្ចការ ឬគម្រោងនានារបស់ស្ថាប័នអនុវត្តនីមួយៗតាមរយៈការធានាឱ្យមាននូវរបាយការណ៍ជាទៀងទាត់និងការពិនិត្យ និងវាយតម្លៃអំពីលទ្ធផលនៃការអនុវត្តរបស់ស្ថាប័នអនុវត្តនីមួយៗនូវរាល់កិច្ចប្រជុំរបស់គ.ជ.អ.ប.។ ជារួម ការវាយតម្លៃអំពីសមិទ្ធផលនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាកិច្ចការដោយឡែកផ្សេងពីការត្រួតពិនិត្យការអនុវត្តកិច្ចការ ឬគម្រោងនានាដែលបានកំណត់នៅក្នុងផអ៥ ហើយក៏ចាំបាច់ត្រូវប្រើប្រាស់វិធីសាស្រ្ត និងជំនាញបច្ចេកទេសផ្សេងៗគ្នាផងដែរ។

ដើម្បីធានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៣ ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៦ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ១.៣.១៖ ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការអនុវត្តដំណាក់កាលនីមួយៗនៃកជទី២

សកម្មភាពអាទិភាពនេះនឹងផ្តោតទៅលើការរៀបចំផែនការអនុវត្តនៃកជទី២ តាមដំណាក់កាលនីមួយៗដែលដំណាក់កាលនីមួយៗមានរយៈពេល៥ឆ្នាំ ពោលគឺផែនការអនុវត្តដំណាក់កាលទី១ ចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥ (ផអ៥ទី១) និងផែនការអនុវត្តដំណាក់កាលទី២ ចាប់ពីឆ្នាំ២០២៦ ដល់ឆ្នាំ២០៣០ (ផអ៥ទី២)។ ផអ៥នីមួយៗត្រូវពិនិត្យ និងអនុម័តដោយគ.ជ.អ.ប.។

### សកម្មភាពអាទិភាព ១.៣.២៖ ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គ.ជ.អ.ប.

សកម្មភាពអាទិភាពនេះ ផ្តោតលើការរៀបចំ ផ.ស.ថ.ប្រចាំឆ្នាំរបស់គ.ជ.អ.ប. ដោយផ្អែកលើផអ៥នីមួយៗ។ ផ.ស.ថ.ប្រចាំឆ្នាំរបស់គ.ជ.អ.ប. ត្រូវរៀបចំឡើងដោយការបូកសរុបនូវផ.ស.ថ.ប្រចាំឆ្នាំរបស់ស្ថាប័នអនុវត្តនីមួយៗនៃកជទី២ដែលពាក់ព័ន្ធទៅនឹងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ផ.ស.ថ.ប្រចាំឆ្នាំនីមួយៗត្រូវពិនិត្យ និងអនុម័តដោយគ.ជ.អ.ប.។

### សកម្មភាពអាទិភាព ១.៣.៣៖ ការរៀបចំ និងដាក់បញ្ចូលកិច្ចការ ឬគម្រោងនានានៃកជទី២ ទៅក្នុងផែនការយុទ្ធសាស្រ្តថវិការបស់ស្ថាប័នអនុវត្តនីមួយៗ

សកម្មភាពអាទិភាពនេះ ផ្តោតទៅលើការរៀបចំ និងការដាក់បញ្ចូលកិច្ចការ ឬគម្រោងនានានៃកជទី២ ទៅក្នុងផែនការយុទ្ធសាស្រ្តថវិការបស់ស្ថាប័នអនុវត្តនីមួយៗ។

### សកម្មភាពអាទិភាព ១.៣.៤៖ ការរៀបចំគម្រោងនានាដែលគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍ ឬ អង្គការសង្គមស៊ីវិលនានាដោយបន្សុីជាមួយកជទី២

សកម្មភាពអាទិភាពនេះ ផ្តោតទៅលើការរៀបចំគម្រោងនានាដែលគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍ ឬ អង្គការសង្គមស៊ីវិលនានាដោយបន្សុីជាមួយកជទី២ ដើម្បីធានាឱ្យគម្រោងទាំងនោះបានចូលរួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅនៃកជទី២។

### សកម្មភាពអាទិភាព ១.៣.៥៖ ការរៀបចំ និងការអនុវត្តសាកល្បងនូវគំនិតផ្តួចផ្តើមថ្មីៗ

សកម្មភាពនេះ ផ្តោតទៅលើការរៀបចំ និងការអនុវត្តសាកល្បងនូវយន្តការ និងគោលនយោបាយដែលជាគំនិតផ្តួចផ្តើមថ្មីៗមួយចំនួនពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ លទ្ធផលនៃការអនុវត្តសាកល្បងទាំងនេះត្រូវបានវាយតម្លៃ ចងក្រងសម្រាប់ជាមូលដ្ឋានក្នុងការរៀបចំជាគោលនយោបាយលិខិតបទដ្ឋានគតិយុត្ត និងយន្តការផ្លូវការនៅក្នុងរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងសាធារណៈ។

### សកម្មភាពអាទិភាព ១.៣.៦៖ ការសម្របសម្រួល ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តកជទី២

ដើម្បីធានាដល់ការអនុវត្តកជទី២ឱ្យមានប្រសិទ្ធភាព និងសម្រេចបាននូវលទ្ធផលនានានៃកជទី២ លេខាធិការដ្ឋាន គ.ជ.អ.ប. ដែលជាសេនាធិការឱ្យគ.ជ.អ.ប. ត្រូវធ្វើការសម្របសម្រួល គាំទ្រ តាមដានត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំលើការអនុវត្តសកម្មភាពជាអាទិភាព និងលទ្ធផលនានានៃកជទី២ រួមបញ្ចូលទាំងលទ្ធផល និងសកម្មភាពជាអាទិភាពនានានៃផអ៥ និងផ.ស.ថ.ប្រចាំឆ្នាំ។

### *លទ្ធផលរំពឹងទុក ១.៤៖ រចនាសម្ព័ន្ធស្ថាប័ននៅថ្នាក់ជាតិសម្រាប់ធានាការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង*

លទ្ធផលរំពឹងទុកនេះ ពាក់ព័ន្ធនឹងការពង្រឹងក្របខ័ណ្ឌស្ថាប័ននៅថ្នាក់ជាតិដើម្បីគាំទ្រ និងត្រួតពិនិត្យលើរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់រយៈពេលវែង។

កិច្ចការនេះពាក់ព័ន្ធនឹងការពិនិត្យមើលឡើងវិញនូវតួនាទី និងភារកិច្ចដែលបច្ចុប្បន្នត្រូវបានប្រគល់ឱ្យអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. ក៏ដូចជាតួនាទី និងភារកិច្ច ដែលត្រូវរៀបចំឡើងសម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធនានាដែលបានផ្ទេរមុខងារមួយចំនួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

ដើម្បីជានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៤ ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៤ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ១.៤.១៖ ការសិក្សាអំពីជម្រើសជាយុទ្ធសាស្ត្រនានាត្រូវបានបញ្ចប់

ក្នុងអំឡុងពេលផអ៥ទី១ ការសិក្សាជាយុទ្ធសាស្ត្រដ៏សំខាន់មួយត្រូវបានរៀបចំ និងអនុវត្ត ដើម្បីកំណត់អំពីជម្រើសនានាសម្រាប់ការពង្រឹងនូវរចនាសម្ព័ន្ធ និងប្រព័ន្ធនៃស្ថាប័នថ្នាក់ជាតិដែលជានាដល់ភាពច្បាស់លាស់ និងប្រសិទ្ធភាពនៃកិច្ចដំណើរការជាទូទៅសម្រាប់ការគាំទ្រ និងការត្រួតពិនិត្យមើលពីលើរដ្ឋបាលថ្នាក់ក្រោមជាតិ។

### សកម្មភាពអាទិភាព ១.៤.២៖ រចនាសម្ព័ន្ធ និងប្រព័ន្ធនៃស្ថាប័ននៅថ្នាក់ជាតិសម្រាប់ការគាំទ្រដល់កិច្ចដំណើរការជាទូទៅនៃអភិបាលកិច្ចសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែសម្រួល

ផ្អែកលើលទ្ធផលនៃការសិក្សាខាងលើដែលបានទទួលការពិនិត្យ និងឯកភាពពីរាជរដ្ឋាភិបាល ចាំបាច់ត្រូវពិនិត្យ កែសម្រួល និងពង្រឹងនូវរចនាសម្ព័ន្ធ និងប្រព័ន្ធនៃក្រសួង ស្ថាប័នពាក់ព័ន្ធនានានៅក្នុងអំឡុងផអ៥ទី២។

### សកម្មភាពអាទិភាព ១.៤.៣៖ រចនាសម្ព័ន្ធ និងប្រព័ន្ធនៃក្រសួង ស្ថាប័នពាក់ព័ន្ធនានាត្រូវបានកែសម្រួល ដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវា

ក្រសួង ស្ថាប័ននីមួយៗដែលបានផ្ទេរមុខងារក្នុងការផ្តល់សេវាឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំឱ្យមានការវិភាគអំពីតួនាទីរបស់ស្ថាប័នខ្លួន ដើម្បីជានាដល់ការបន្តការប្រាស្រ័យទាក់ទងរវាងស្ថាប័ននីមួយៗជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ (ដូចជា ការរៀបចំ និងការត្រួតពិនិត្យ តាមដាននូវការអនុវត្តស្តង់ដារនានានៃការផ្តល់សេវា ការអភិវឌ្ឍសមត្ថភាព...)។ ផ្អែកលើលទ្ធផលនៃការវិភាគនេះ ក្រសួង ស្ថាប័ននីមួយៗត្រូវរៀបចំកែសម្រួលរចនាសម្ព័ន្ធ និងប្រព័ន្ធរបស់ក្រសួង ស្ថាប័នសាមីឱ្យបានសមស្របដើម្បីជានាដល់ការបន្តប្រាស្រ័យទាក់ទងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានច្បាស់លាស់ និងមានប្រសិទ្ធភាព។

### សកម្មភាពអាទិភាព ១.៤.៤៖ ការសិក្សាអំពីជម្រើសនានាអំពីអនាគតនៃ គ.ជ.អ.ប. និងលេខាធិការដ្ឋាន គ.ជ.អ.ប.

នៅក្នុងអំឡុងពេលផអ៥ទី២ ត្រូវរៀបចំឱ្យមានការសិក្សាបន្ថែមអំពីជម្រើសនានាសម្រាប់អនាគតនៃគ.ជ.អ.ប. និងលេខាធិការដ្ឋានគ.ជ.អ.ប. នៅក្នុងអំឡុងពេលបន្ទាប់ពីកជទី២ ត្រូវបានបញ្ចប់។

## *លទ្ធផលរំពឹងទុក ១.៥.៖ ការចូលរួមរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការកំណែទម្រង់ត្រូវបានលើកកម្ពស់*

កជទី២ ត្រូវពង្រឹងនិងគាំទ្រដល់ការរៀបចំរចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនានា ដើម្បីធានាឱ្យសមាគមទាំងនេះកាន់តែមានសមត្ថភាពក្នុងការចូលរួមលើកកម្ពស់កិច្ចដំណើរកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាពិសេសការបំពេញតួនាទីជាតំណាងឱ្យផលប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការចូលរួមក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយនានាពាក់ព័ន្ធនឹងកំណែទម្រង់នេះ និងការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ។ អាស្រ័យហេតុនេះ ដើម្បីធានាដល់ការលើកកម្ពស់សមត្ថភាពរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការចូលរួមកិច្ចដំណើរការកំណែទម្រង់នេះឱ្យកាន់តែមានប្រសិទ្ធភាពចាំបាច់ត្រូវរៀបចំឱ្យមានការសិក្សា ដើម្បីផ្តល់នូវជម្រើសនានាក្នុងការកែលម្អ និងពង្រឹងនូវរចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យស្របតាមស្ថានភាពវិវត្តនៃកំណែទម្រង់។

ជាមួយគ្នានេះដែរ ភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលក៏ត្រូវបានពង្រឹងបន្ថែមទៀតសំដៅលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងកិច្ចដំណើរការកំណែទម្រង់ប្រកបដោយប្រសិទ្ធភាព និងក្នុងន័យស្ថាបនា។

ដើម្បីធានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៥ ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៤ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព១.៥.១៖ ការពង្រឹងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

ក្នុងអំឡុងពេលនៃការអនុវត្តកជទី២ ចាំបាច់ត្រូវបន្តពង្រឹងការអនុវត្តតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិដែលបានបង្កើតឡើងកន្លងមក ទាំងក្នុងតួនាទីជាតំណាងឱ្យសំឡេង និងផលប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់យោបល់លើកិច្ចដំណើរការរៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងតួនាទីជាស្ថាប័នផ្តល់ការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### សកម្មភាពអាទិភាព ១.៥.២៖ ការសិក្សាអំពីជម្រើសនៃការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

ទន្ទឹមនឹងការពង្រឹងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិបច្ចុប្បន្ន ក៏ចាំបាច់ត្រូវរៀបចំឱ្យមានការសិក្សា វាយតម្លៃ និងកំណត់អំពីជម្រើសសមស្របនានាសម្រាប់កែសម្រួលរចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវរបស់សមាគមនេះ។ ការសិក្សានេះ ត្រូវផ្តោតជាសំខាន់ទៅលើជម្រើសនៃការរៀបចំទៅអនាគតសម្រាប់សមាគមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអាចបង្កើតដាច់ដោយឡែកពីគ្នា

រវាងក្រុមប្រឹក្សា និងគណៈអភិបាល ឬជាសមាគមរួមគ្នារវាងក្រុមប្រឹក្សា និងគណៈអភិបាល ដើម្បីជានាដល់ភាពជាតំណាងឱ្យសំឡេង និងផលប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិយ៉ាងពេញលេញ។

### សកម្មភាពអាទិភាព ១.៥.៣៖ ការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

ផ្អែកលើលទ្ធផលនៃការសិក្សា សន្និបាតរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនឹងធ្វើការពិនិត្យ និងអនុម័តទៅលើជម្រើសនានានៃការរៀបចំរចនាសម្ព័ន្ធ តួនាទីរបស់សមាគមនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ រចនាសម្ព័ន្ធថ្មីនេះនឹងត្រូវបានកែសម្រួលឬរៀបចំ ដាក់ឱ្យអនុវត្តនៅក្នុងអំឡុងនៃ ផអ៥ ទី១ នៃ កជទី២។

### សកម្មភាពអាទិភាព ១.៥.៤៖ ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយនានាពាក់ព័ន្ធនឹងកំណែទម្រង់

ក្នុងអំឡុងពេលនៃការអនុវត្តកជទី២ គ.ជ.អ.ប. ត្រូវបន្តពង្រឹងយន្តការនានា ដែលជានាដល់ការបង្កបរិយាកាសល្អប្រសើរ និងមានការលើកទឹកចិត្តដល់អង្គការសង្គមស៊ីវិលនានា ក្នុងការចូលរួមប្រកបដោយលក្ខណៈស្ថាបនាក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានាដែលជាផ្នែកមួយដ៏សំខាន់ក្នុងការពង្រឹងការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

## តារាងទី ១៖ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពនានាសម្រាប់សមាសភាគទី១

<table>
<tr><td colspan="2">សមិទ្ធផលរំពឹងទុកនៃសមាសភាគទី១៖<br>យន្តការដឹកនាំ សម្របសម្រួល និងគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានពង្រឹង ដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននានានៅក្នុងការរៀបចំតាក់តែង និងអនុវត្តនូវកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។</td></tr>
<tr><td colspan="2">លទ្ធផលរំពឹងទុក ១.១៖ យន្តការដឹកនាំកំណែទម្រង់ត្រូវបានពង្រឹងយ៉ាងរឹងមាំ ដើម្បីបន្តជំរុញកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យកាន់តែមានការវិវឌ្ឍទៅមុខប្រកបដោយសមធម៌ និងបរិយាប័ន្ន។</td></tr>
<tr><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</td><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</td></tr>
<tr><td>✓ ១.១.១៖ ការបន្តពង្រឹងតួនាទី ភារកិច្ចរបស់ គ.ជ.អ.ប. ក្នុងការដឹកនាំសម្របសម្រួលកម្មវិធីកំណែទម្រង់<br>✓ ១.១.២៖ ការបន្តពង្រឹងអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. ក្នុងការបំពេញភារកិច្ចឱ្យមានប្រសិទ្ធភាព<br>✓ ១.១.៣៖ ការពង្រឹងសមត្ថភាព តួនាទី និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.<br>✓ ១.១.៤៖ ការលើកកម្ពស់ប្រសិទ្ធភាពដឹកនាំរបស់គណៈកម្មការដឹកនាំកំណែទម្រង់រដ្ឋការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ១.១.៥៖ ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានា</td><td>✓ ១.១.១៖ ការបន្តពង្រឹងតួនាទី ភារកិច្ចរបស់ គ.ជ.អ.ប. ក្នុងការដឹកនាំសម្របសម្រួលកម្មវិធីកំណែទម្រង់<br>✓ ១.១.២៖ ការបន្តពង្រឹងអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. ក្នុងការបំពេញភារកិច្ចឱ្យមានប្រសិទ្ធភាព<br>✓ ១.១.៣៖ ការពង្រឹងសមត្ថភាព តួនាទី និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.<br>✓ ១.១.៤៖ ការលើកកម្ពស់ប្រសិទ្ធភាពដឹកនាំរបស់គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ១.១.៥៖ ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានា</td></tr>
</table>

| | |
|---|---|
| ✓ **១.១.៦៖** ការរៀបចំវេទិកា ឬកិច្ចប្រជុំប្រធានក្រុមប្រឹក្សា និងអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ **១.១.៧៖** ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានាប្រកបដោយភាពស្ថាបនា<br>✓ **១.១.៨៖** ការពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | ✓ **១.១.៦៖** ការរៀបចំវេទិកា ឬកិច្ចប្រជុំប្រធានក្រុមប្រឹក្សា និងអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ **១.១.៧៖** ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានាប្រកបដោយភាពស្ថាបនា<br>✓ **១.១.៨៖** ការពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ |
| **លទ្ធផលរំពឹងទុក ១.២៖ ចក្ខុវិស័យ គោលបំណង គោលដៅ និងសមិទ្ធផលនានានៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានផ្សព្វផ្សាយសំដៅបង្កើនការយល់ដឹង និងការគាំទ្រយ៉ាងទូលំទូលាយដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា។** | |
| **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១** | **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២** |
| ✓ **១.២.១៖** ការកែលម្អ និងការពង្រឹងយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង<br>✓ **១.២.២៖** ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង<br>✓ **១.២.៣៖** ការវាស់វែងលទ្ធផលនៃការប្រាស្រ័យទាក់ទង | ✓ **១.២.១៖** ការកែលម្អ និងការពង្រឹងយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង<br>✓ **១.២.២៖** ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង<br>✓ **១.២.៣៖** ការវាស់វែងលទ្ធផលនៃការប្រាស្រ័យទាក់ទង |
| **លទ្ធផលរំពឹងទុក ១.៣៖ កម្មវិធីជាតិដំណាក់កាលទី២ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។** | |
| **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១** | **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២** |
| ✓ **១.៣.១៖** ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការអនុវត្តដំណាក់កាលនីមួយៗនៃកជទី២ | ✓ **១.៣.១៖** ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការអនុវត្តដំណាក់កាលនីមួយៗនៃកជទី២ |

| | |
|---|---|
| ✓ **១.៣.២៖** ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គ.ជ.អ.ប. | ✓ **១.៣.២៖** ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គ.ជ.អ.ប. |
| ✓ **១.៣.៣៖** ការរៀបចំ និងដាក់បញ្ចូលកិច្ចការ ឬគម្រោងនានានៃកជទី២ ទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ស្ថាប័នអនុវត្តនីមួយៗ | ✓ **១.៣.៣៖** ការរៀបចំ និងដាក់បញ្ចូលកិច្ចការ ឬគម្រោងនានានៃកជទី២ ទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ស្ថាប័នអនុវត្តនីមួយៗ |
| ✓ **១.៣.៤៖** ការរៀបចំគម្រោងនានាដែលគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍ ឬអង្គការសង្គមស៊ីវិលនានាដោយបន្ស៊ីជាមួយកជទី២ | ✓ **១.៣.៤៖** ការរៀបចំគម្រោងនានាដែលគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍ ឬអង្គការសង្គមស៊ីវិលនានាដោយបន្ស៊ីជាមួយកជទី២ |
| ✓ **១.៣.៥៖** ការរៀបចំ និងការអនុវត្តសាកល្បងនូវគំនិតផ្តួចផ្តើមថ្មីៗ | ✓ **១.៣.៥៖** ការរៀបចំ និងការអនុវត្តសាកល្បងនូវគំនិតផ្តួចផ្តើមថ្មីៗ |
| ✓ **១.៣.៦៖** ការសម្របសម្រួល ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តកជទី២ | ✓ **១.៣.៦៖** ការសម្របសម្រួល ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តកជទី២ |
| **លទ្ធផលរំពឹងទុក ១.៤៖ រចនាសម្ព័ន្ធស្ថាប័ននៅថ្នាក់ជាតិសម្រាប់ធានាការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង។** | |
| **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១** | **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២** |
| ✓ **១.៤.១៖** ការសិក្សាអំពីជម្រើសជាយុទ្ធសាស្ត្រនានាត្រូវបានបញ្ចប់ | ✓ **១.៤.១៖** ការសិក្សាអំពីជម្រើសជាយុទ្ធសាស្ត្រនានាត្រូវបានបញ្ចប់ |
| ✓ **១.៤.២៖** រចនាសម្ព័ន្ធ និងប្រព័ន្ធនៃស្ថាប័ននៅថ្នាក់ជាតិសម្រាប់ការគាំទ្រដល់កិច្ចដំណើរការជាទូទៅនៃអភិបាលកិច្ចសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែសម្រួល | ✓ **១.៤.២៖** រចនាសម្ព័ន្ធ និងប្រព័ន្ធនៃស្ថាប័ននៅថ្នាក់ជាតិសម្រាប់ការគាំទ្រដល់កិច្ចដំណើរការជាទូទៅនៃអភិបាលកិច្ចសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែសម្រួល |
| ✓ **១.៤.៣៖** រចនាសម្ព័ន្ធ និងប្រព័ន្ធនៃក្រសួង ស្ថាប័នពាក់ព័ន្ធនានាត្រូវបានកែសម្រួល ដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវា | ✓ **១.៤.៣៖** រចនាសម្ព័ន្ធ និងប្រព័ន្ធនៃក្រសួង ស្ថាប័នពាក់ព័ន្ធនានាត្រូវបានកែសម្រួល ដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវា |

| | |
|---|---|
| ✓ **១.៤.៤៖** ការសិក្សាអំពីជម្រើសនានាអំពីអនាគតនៃ គ.ជ.អ.ប. និងលេខាធិការដ្ឋាន គ.ជ.អ.ប. | ✓ **១.៤.៤៖** ការសិក្សាអំពីជម្រើសនានាអំពីអនាគតនៃ គ.ជ.អ.ប. និងលេខាធិការដ្ឋាន គ.ជ.អ.ប. |
| **លទ្ធផលរំពឹងទុក ១.៥.៖ ការចូលរួមរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការកំណែទម្រង់ត្រូវបានលើកកម្ពស់។** | |
| **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១** | **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២** |
| ✓ **១.៥.១៖** ការពង្រឹងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ **១.៥.២៖** ការសិក្សាអំពីជម្រើសនៃការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទី របស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ **១.៥.៣៖** ការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ **១.៥.៤៖** ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើររៀបចំគោលនយោបាយនានាពាក់ព័ន្ធនឹងកំណែទម្រង់ | ✓ **១.៥.១៖** ការពង្រឹងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ **១.៥.២៖** ការសិក្សាអំពីជម្រើសនៃការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទី របស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ **១.៥.៣៖** ការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ **១.៥.៤៖** ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើររៀបចំគោលនយោបាយនានាពាក់ព័ន្ធនឹងកំណែទម្រង់ |

## តារាងទី ២៖ ការគ្រប់គ្រងហានិភ័យសំខាន់ៗសម្រាប់សមាសភាគទី១

| ល.រ | ហានិភ័យ | ផលប៉ះពាល់ | លទ្ធភាពកើតមាន | វិធានការកាត់បន្ថយហានិភ័យ |
|---|---|---|---|---|
| ១ | ការផ្លាស់ប្តូរដ៏សំខាន់នូវទិសដៅផ្នែកនយោបាយរបស់រាជរដ្ឋាភិបាល ដូចជាក្នុងកាលៈទេសៈដែលត្រូវឆ្លើយតបជាបន្ទាន់ចំពោះការជះឥទ្ធិពលដ៏ធ្ងន់ធ្ងរពីកត្តាខាងក្រៅប្រទេស (ឧទាហរណ៍ ជំងឺរាតត្បាត) | ខ្ពស់ | ទាប | - សម្របតាមការផ្លាស់ប្តូរគោលនយោបាយថ្មីរបស់រាជរដ្ឋាភិបាលដោយបន្តអនុវត្តនូវលទ្ធផលរំពឹងទុកណាដែលអាចអនុវត្តបាន |
| ២ | ការពុំទាន់ស្រុះស្រួលគ្នារបស់ស្ថាប័នអនុវត្តមួយចំនួនជាមួយនឹងការងារមួយចំនួននៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (ឧទាហរណ៍ ដូចជាក្នុងកិច្ចដំណើរការផ្ទេរមុខងាររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ) | មធ្យម | មធ្យម | - បន្តពង្រឹងការសម្របសម្រួលក្នុងក្របខ័ណ្ឌនៃការដឹកនាំរបស់ គ.ជ.អ.ប.<br>- គោលបំណង និងទិសដៅនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ<br>- បន្តពង្រឹងការពិគ្រោះយោបល់ តាមរយៈវេទិកានានា<br>- កំណត់បញ្ហាប្រឈមជាក់លាក់នីមួយៗ ដើម្បីដោះស្រាយឱ្យបានទាន់ពេលវេលា |
| ៣ | ធនធានថវិកាមិនត្រូវបានផ្តល់គ្រប់គ្រាន់សម្រាប់អនុវត្តនូវសកម្មភាពជាអាទិភាពនៃការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់ | មធ្យម | មធ្យម | - បញ្ចូលគម្រោងចំណាយថវិកាដែលមានទំហំសមស្របសម្រាប់ការងារកំណែទម្រង់ទៅក្នុងថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័នសាមី<br>- បន្តកៀរគរធនធានពីដៃគូអភិវឌ្ឍន៍សម្រាប់គាំទ្រដល់កិច្ចការ ឬគម្រោងដែលមានការលំបាកក្នុងការប្រើប្រាស់ថវិការដ្ឋ។ |
| ៤ | ការប្រាស្រ័យទាក់ទងពុំទាន់មានប្រសិទ្ធភាពក្នុងការបង្កើនការយល់ដឹង និងការគាំទ្រឱ្យបានយ៉ាងទូលំទូលាយ | មធ្យម | មធ្យម | - បន្តពង្រីកការផ្សព្វផ្សាយតាមគ្រប់រូបភាព និងទូលំទូលាយជាងមុន ព្រមទាំងបន្តពង្រឹងសមត្ថភាពមន្ត្រីជំនាញផ្នែកប្រាស្រ័យទាក់ទង<br>- បន្តពង្រឹងការតាមដានស្វែងយល់អំពីបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទង<br>- ពិនិត្យ និងកែសម្រួលយុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទង |

## ៣.២.សមាសភាគទី២៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

### ៣.២.១. សនិទានភាព

រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈដ៏រឹងមាំដែលធានាដល់ការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព គឺជាកត្តាដ៏សំខាន់ក្នុងការចូលរួមចំណែកធ្វើឱ្យសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍប្រទេសកម្ពុជាឱ្យក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

អាស្រ័យហេតុនេះ ការកែលម្អ និងការធ្វើទំនើបកម្មរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈដែលធានាដល់ការលើកកម្ពស់សមត្ថភាពស្ថាប័ន ពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ ពង្រឹងប្រសិទ្ធភាព និងនវានុវត្តន៍ក្នុងការបំពេញការងារ និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ គឺជាកិច្ចការដ៏សំខាន់ដែលត្រូវផ្តល់អាទិភាពក្នុងអំឡុងពេលនៃកជទី២ (២០២១-២០៣០)។ ទន្ទឹមនឹងនេះ ចាំបាច់ត្រូវកំណត់ឱ្យបានច្បាស់លាស់នូវមុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលតាមថ្នាក់នីមួយៗ ដើម្បីចៀសវាងនូវភាពមិនច្បាស់លាស់ និងភាពត្រួតស៊ីគ្នានៃមុខងារនិងការទទួលខុសត្រូវក្នុងចំណោមរដ្ឋបាលតាមថ្នាក់នីមួយៗ។ ដើម្បីធានាដល់ការអនុវត្តមុខងារ និងការផ្តល់សេវាធារណៈប្រកបដោយគុណភាពជូនប្រជាពលរដ្ឋ ចាំបាច់ត្រូវបង្កបរិយាកាសឱ្យបានសមស្របក្នុងការលើកកម្ពស់គំនិតផ្តួចផ្តើមដ៏ទូលំទូលាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងកិច្ចដំណើរការនេះ។

ក្នុងក្របខ័ណ្ឌនៃការអនុវត្តកជទី១ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងបីថ្នាក់ត្រូវបានរៀបចំជាថ្មីតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងត្រូវបានកែសម្រួលជាបណ្តើរៗ ក្នុងគោលបំណងលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ ទោះយ៉ាងនេះក្តី រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវមានការសិក្សា និងកែសម្រួលបន្ថែមទៀតឱ្យស្របទៅតាមចរិតលក្ខណៈនៃរដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទនីមួយៗ ព្រមទាំងឱ្យស្របទៅតាមលក្ខណៈភូមិសាស្ត្រ ប្រជាសាស្ត្រ និងសក្តានុពលផ្នែកសេដ្ឋកិច្ច និងសង្គមនៅតាមតំបន់នីមួយៗ។ ជាទូទៅ តម្រូវការ និងបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋដែលត្រូវដោះស្រាយគឺមានលក្ខណៈខុសៗគ្នារវាងតំបន់ជនបទ តំបន់ទីប្រជុំជន និងតំបន់ទីក្រុងធំ។ អាស្រ័យហេតុនេះ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងារនៃរដ្ឋបាលទាំងនេះត្រូវតែមានលក្ខណៈដោយឡែកៗពីគ្នា ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងបញ្ហាប្រឈមដែលមានលក្ខណៈផ្សេងៗគ្នានៅតាមតំបន់នីមួយៗ។

ការបែងចែកសិទ្ធិអំណាច តួនាទី និងការទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈ រវាងក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតែមានភាពច្បាស់លាស់ស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ពោលគឺ "**ការបង្វិតការធ្វើសេចក្តីសម្រេចចិត្តលើការផ្តល់សេវាសាធារណៈឱ្យទៅកៀកជិតប្រជាពលរដ្ឋ**"។ ការផ្ទេរធនធានមនុស្ស

ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យសមស្របទៅនឹងមុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗក៏ចាំបាច់ត្រូវរៀបចំឱ្យសមស្របទៅតាមចរិតលក្ខណៈរបស់រចនាសម្ព័ន្ធ និងប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិដែលនឹងត្រូវបានកែលម្អបន្ថែមទៀតនេះដែរ។

ជាមួយគ្នានេះ យន្តការនានាសម្រាប់គាំទ្រដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជាគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាក៏ចាំបាច់ត្រូវមានការកែលម្អបន្ថែមទៀត ដើម្បីធានាឱ្យក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះកាន់តែមានសមត្ថភាពនៅក្នុងការបំពេញតួនាទីជាតំណាងឱ្យសំឡេង និងផលប្រយោជន៍របស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ស្របតាមកម្រិតនិងប្រភេទនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម។

ក្នុងន័យនេះ ការពិនិត្យ ការកែសម្រួលឡើងវិញ និងការធ្វើទំនើបកម្មនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមគោលនយោបាយវិមជ្ឈការ ត្រូវផ្អែកលើគោលការណ៍ដែលកំណត់ថា "មុខងារត្រូវប្រគល់ទៅឱ្យរដ្ឋបាលថ្នាក់ណាដែលកៀកជិតប្រជាពលរដ្ឋបំផុត និងដែលអនុវត្តមានប្រសិទ្ធភាពបំផុត ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋបានយ៉ាងឆាប់រហ័សបំផុត"។

**៣.២.២. និន្នាការទូទៅនៃសមាសភាគទី២**

**៣.២.២.១. សមិទ្ធផលរំពឹងទុក**

សមិទ្ធផលរំពឹងទុកនៃសមាសភាគនេះគឺ ***"រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល សិទ្ធិអំណាច និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកំណត់យ៉ាងច្បាស់លាស់តាមកម្រិត និងតាមប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗស្របតាមចរិតលក្ខណៈជារដ្ឋបាលនៃតំបន់ទីក្រុងធំ រដ្ឋបាលនៃតំបន់ទីប្រជុំជន និងរដ្ឋបាលតំបន់ជនបទដោយជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការផ្ដល់សេវាសាធារណៈ និងការប្រាស្រ័យទាក់ទងសាធារណៈ"។***

**៣.២.២.២. យុទ្ធសាស្ត្រដើម្បីសម្រេចបានសមិទ្ធផលរំពឹងទុក**

ដើម្បីធានាដល់ការសម្រេចបាននូវសមិទ្ធផលរំពឹងទុកនេះ ក្នុងអំឡុងពេលនៃការអនុវត្តកជទី២ ចាំបាច់ត្រូវផ្ដោតលើការពិនិត្យកែសម្រួលឡើងវិញ និងការធ្វើទំនើបកម្មនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងនៃរដ្ឋបាលសាធារណៈ ដោយកំណត់ឱ្យបានច្បាស់លាស់នូវសិទ្ធិអំណាច មុខងារ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ផ្អែកតាមគោលនយោបាយវិមជ្ឈការ និងគោលការណ៍នៃរដ្ឋបាលឯកភាព។ ការរៀបចំបែបនេះនឹងជំរុញឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្លាយជាស្ថាប័នដ៏មានប្រសិទ្ធភាព ក្នុងការចូលរួមការអភិវឌ្ឍសេដ្ឋកិច្ចសង្គមតាមបែបប្រជាធិបតេយ្យនៅកម្ពុជា។ កិច្ចការដ៏មានសារៈសំខាន់នេះ នឹងផ្ដោតលើការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងារសម្រាប់រដ្ឋបាលតាមថ្នាក់នីមួយៗដូចខាងក្រោម ៖

- **ក្រសួង ស្ថាប័នថ្នាក់ជាតិ**នឹងមានមុខងារស្នូលសំខាន់ៗពាក់ព័ន្ធនឹង ១). ការសិក្សាស្រាវជ្រាវដើម្បីជំរុញការអភិវឌ្ឍ និងនវានុវត្តន៍តាមវិស័យជំនាញរបស់ខ្លួន ២). ការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត បទដ្ឋានបច្ចេកទេសសម្រាប់កំណត់ស្តង់ដារសេវា ៣). ការគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និង៤). ការអនុវត្តមុខងារជាយុទ្ធសាស្ត្រធំៗមួយចំនួន។
- **រដ្ឋបាលខេត្ត**ត្រូវរៀបចំប្រែក្លាយជារដ្ឋបាលដែលមានរចនាសម្ព័ន្ធគ្រប់គ្រងតាមចរិតលក្ខណៈជា**រដ្ឋបាលតំបន់**ផ្អែកតាមគោលការណ៍នៃរដ្ឋបាលឯកភាព និងមានមុខងារសំខាន់ៗពាក់ព័ន្ធនឹង ១). ការបំពេញមុខងារជាតំណាងឱ្យរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នក្នុងការថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងអនុវត្តមុខងារនានាដែលរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នបានធ្វើប្រតិភូកម្មឱ្យ ២). ការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលមូលដ្ឋានក្នុងការអនុវត្តមុខងារផ្តល់សេវាសាធារណៈ ការត្រួតពិនិត្យនីត្យានុកូលភាព ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងាររបស់រដ្ឋបាលមូលដ្ឋានស្របតាមគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដារសេវាដែលបានកំណត់ ការសម្របសម្រួលជាមួយរដ្ឋបាលមូលដ្ឋាន ក្នុងការរៀបចំផែនការអភិវឌ្ឍតំបន់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និង ៣). ការអនុវត្តមុខងារ ឬគម្រោងក្នុងវិស័យសាធារណៈសំខាន់ៗមួយចំនួនដែលមានលក្ខណៈបច្ចេកទេសខ្ពស់ និងឬមានវិសាលភាពគ្របដណ្តប់លើភូមិសាស្ត្រទូទាំងខេត្តដែលរដ្ឋបាលក្រុង ស្រុកពុំអាចអនុវត្តបាន។
- **រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់**នឹងត្រូវរៀបចំប្រែក្លាយជា**រដ្ឋបាលមូលដ្ឋាន**ដែលមានស្វ័យភាព សមត្ថភាព និងការទទួលខុសត្រូវលើការផ្តល់សេវាសាធារណៈនានាដោយផ្ទាល់ជូនប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ រដ្ឋបាលមូលដ្ឋានទាំងនេះនឹងត្រូវរៀបចំឱ្យមានមុខងារ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងដែលមានលក្ខណៈពិសេសផ្សេងៗគ្នាស្របតាមសក្តានុពល និងស្ថានភាពផ្សេងៗគ្នារវាងទីប្រជុំជន និងតំបន់ជនបទ។ រដ្ឋបាលមូលដ្ឋានទាំងនេះមានមុខងារសំខាន់ៗពាក់ព័ន្ធនឹង ១). ការកំណត់តម្រូវការ និងបញ្ហាប្រឈមនានានៅតាមមូលដ្ឋានតាមរយៈដំណើរការកសាងផែនការ ដោយមានការចូលរួមដោយផ្ទាល់ពីប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាន និងការពង្រឹងអនុវត្តការងារគណនេយ្យភាពសង្គម ២). ការរៀបចំ និងអនុវត្តគម្រោងអភិវឌ្ឍន៍មូលដ្ឋាន និងផ្តល់សេវាសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមបទដ្ឋានបច្ចេកទេស និងស្តង់ដារសេវាដែលបានកំណត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងដោះស្រាយបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋ និង ៣). ការរៀបចំ និងអនុវត្តការងារគណនេយ្យភាពជាមួយប្រជាពលរដ្ឋ តាមរយៈយន្តការទទួលសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ានានារបស់ប្រជាពលរដ្ឋ។

- **រដ្ឋបាលរាជធានី** ត្រូវរៀបចំឱ្យមានរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងជា**រដ្ឋបាលក្រុងមេត្រូប៉ូលីតែន** ដែលមានលក្ខណៈពិសេសដោយឡែកពីរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុងដទៃទៀត។ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរាជធានីភ្នំពេញ ត្រូវរៀបចំស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដែលបង្កលទ្ធភាពឱ្យរដ្ឋបាលនេះអាចបំពេញមុខងារជារដ្ឋបាលតំបន់ និងរដ្ឋបាលមូលដ្ឋានផងដែរ។ ជាមួយគ្នានេះដែរ រដ្ឋបាលនេះក៏មានលទ្ធភាពក្នុងការពង្រីកការអភិវឌ្ឍក្នុងក្របខ័ណ្ឌនៃដែនសមត្ថកិច្ចរបស់ខ្លួន ដែលបច្ចុប្បន្ននេះ រាជធានីភ្នំពេញរួមមានតំបន់រណបជាច្រើន ដែលត្រូវបានកាត់ចេញពីខេត្តជាប់ព្រំប្រទល់នានា ដាក់បញ្ចូលឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលរាជធានី (ដែលតំបន់រណបទាំងនេះពុំទាន់មានការអភិវឌ្ឍដូចគ្នានឹងខណ្ឌនានាដែលស្ថិតនៅតំបន់កណ្តាលនៃរាជធានី) ប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ ការទទួលខុសត្រូវជាចម្បងរបស់រដ្ឋបាលរាជធានីរួមមានដូចជា ការរៀបចំផែនការទីក្រុង ការរៀបចំហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ការរៀបចំនិងការផ្តល់សេវាដឹកជញ្ជូនសាធារណៈ ការគ្រប់គ្រងចរាចរណ៍ ការគ្រប់គ្រងសំណល់រឹងនិងរាវ ការងារបរិស្ថាននិងអនាម័យ ការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់និងសុវត្ថិភាពសាធារណៈ និងមុខងារមួយចំនួនទៀត។

ទន្ទឹមនឹងការកំណត់ឱ្យបានច្បាស់លាស់នូវសិទ្ធិអំណាច មុខងារ តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលតាមថ្នាក់នីមួយៗ ក៏តម្រូវឱ្យមានការគិតគូរទៅលើកិច្ចការជាអាទិភាពមួយចំនួនរួមមាន ១). ការពិនិត្យនិងការកែលម្អនូវទំនាក់ទំនងការងាររវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងក្រសួង ស្ថាប័នថ្នាក់ជាតិ ២). ការកំណត់ឱ្យបានច្បាស់លាស់នូវមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ៣). ការពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ៤). ការបន្តលើកកម្ពស់ខ្សែគណនេយ្យភាពទាំងបីពោលគឺ គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានកម្រិតខ្ពស់ជាង និងចំពោះថ្នាក់ជាតិ គណនេយ្យភាពផ្ទៃក្នុងនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងជាពិសេសគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ និង ៥). ការកែលម្អយន្តការអធិការកិច្ចលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

#### ៣.២.២.៣. លទ្ធផលរំពឹងទុក

សមិទ្ធផលរំពឹងខាងលើនឹងត្រូវសម្រេចបាន តាមរយៈលទ្ធផលរំពឹងទុកចំនួន ៨ ដូចខាងក្រោម៖

- **លទ្ធផលរំពឹងទុកទី១**៖ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ត្រូវបានពង្រឹង កែសម្រួល និងប្រតិបត្តិការជារដ្ឋបាលមូលដ្ឋាន និងស្របតាមចរិតលក្ខណៈរដ្ឋបាលតំបន់ទីប្រជុំជន និងរដ្ឋបាលតំបន់ជនបទ

- **លទ្ធផលរំពឹងទុកទី២៖** រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ និងធនធានរបស់រដ្ឋបាលខេត្ត ត្រូវបានពិនិត្យ កែសម្រួល និងប្រតិបត្តិការតាមចរិតលក្ខណៈជារដ្ឋបាលតំបន់ និងស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព
- **លទ្ធផលរំពឹងទុកទី៣៖** រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលរាជធានីត្រូវបានពិនិត្យ កែសម្រួល និងដាក់ឱ្យប្រតិបត្តិការតាមចរិតលក្ខណៈជារដ្ឋបាលក្រុងមេត្រូប៉ូលីតែន និងស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព
- **លទ្ធផលរំពឹងទុកទី៤៖** ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានពង្រឹង កែសម្រួល និងដាក់ឱ្យអនុវត្ត
- **លទ្ធផលរំពឹងទុកទី៥៖** សមត្ថភាពដឹកនាំរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង
- **លទ្ធផលរំពឹងទុកទី៦៖** ការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ ដើម្បីធានាដល់ជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ
- **លទ្ធផលរំពឹងទុកទី៧៖** ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើទំនើបកម្មតាមរយៈការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថល
- **លទ្ធផលរំពឹងទុកទី៨៖** ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងយន្តការអធិការកិច្ចផ្ទៃក្រៅដែលមានលក្ខណៈជាប្រព័ន្ធមួយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ កែសម្រួល និងដាក់ឱ្យអនុវត្ត។

#### ៣.២.២.៤. យុទ្ធសាស្ត្រ និងសកម្មភាពជាអាទិភាពសម្រាប់អនុវត្តលទ្ធផលរំពឹងទុកនានា

***លទ្ធផលរំពឹងទុក ២.១៖ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ត្រូវបានពង្រឹង កែសម្រួល និងប្រតិបត្តិការជារដ្ឋបាលមូលដ្ឋាន និងស្របតាមចរិតលក្ខណៈរដ្ឋបាលតំបន់ទីប្រជុំជន និងរដ្ឋបាលតំបន់ជនបទ***

ដើម្បីធានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី១ ខាងលើនេះចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៤ ដូចខាងក្រោម៖

##### សកម្មភាពអាទិភាព ២.១.១៖ ការពង្រឹងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់រដ្ឋបាលក្រុង ស្រុក

កជទី២ នឹងបន្តផ្តោតលើការពង្រឹងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ដែលបានរៀបចំ និងដាក់ឱ្យអនុវត្តក្នុងអំឡុងពេលនៃការអនុវត្តកជទី១ តាមរយៈ៖

- ការពង្រឹងយន្តការជាក់លាក់នានានៅថ្នាក់ជាតិ ដើម្បីចុះគាំទ្រជាប្រចាំដល់រដ្ឋបាលក្រុង ស្រុក ក្នុងការដឹកនាំ ការគ្រប់គ្រង និងការចាត់ចែងការអនុវត្តការងារស្របតាមមុខងារ និងរចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក និងដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខនានា
- ការពិនិត្យលើមុខងារនានារបស់រដ្ឋបាលក្រុង ស្រុកដើម្បីកំណត់ឱ្យបានច្បាស់នូវមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើស។ ទន្ទឹមគ្នានេះ សេចក្តីណែនាំបច្ចេកទេសសម្រាប់ការអនុវត្តមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសរបស់រដ្ឋបាលក្រុង ស្រុក ក៏ចាំបាច់ត្រូវពិនិត្យ កែលម្អ និងជំរុញការអនុវត្តផងដែរ
- ការបន្តពង្រឹងការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលអំពីគោលការណ៍ នីតិវិធី និងបែបបទនៃការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក
- ការរៀបចំ ប្រមូល និងចងក្រងទិន្នន័យដើមគ្រានៃការអនុវត្តមុខងារតាមវិស័យសំខាន់ៗមួយចំនួនដើម្បីធ្វើជាមូលដ្ឋានសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើប្រសិទ្ធភាពនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារនានារបស់រដ្ឋបាលក្រុង ស្រុក
- ការបន្តរៀបចំផ្ទេរធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ មធ្យោបាយ ឧបករណ៍ សម្ភារ បរិក្ខារឱ្យបានសមស្របទៅនឹងមុខងាររបស់រដ្ឋបាលក្រុង ស្រុក
- ការបន្តពង្រឹងការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុកឱ្យបានត្រឹមត្រូវតាមគោលការណ៍កំណត់ និងចាត់ចែងប្រើប្រាស់បុគ្គលិកឱ្យបានសមស្របតាមសមត្ថភាព និងជំនាញវិជ្ជាជីវៈដើម្បីជានានិរន្តរភាព និងប្រសិទ្ធភាពនៃការបំពេញការងារ និងការផ្តល់សេវាសាធារណៈ
- ការសិក្សា និងវាយតម្លៃលើការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក ដើម្បីជាមូលដ្ឋានសម្រាប់ការពង្រីកការផ្ទេរមុខងារនានាបន្ថែមទៀតទៅឱ្យរដ្ឋបាលនេះ
- ការបន្តផ្ទេរមុខងារផ្តល់សេវាសាធារណៈដែលចាំបាច់នានាទៅឱ្យរដ្ឋបាលក្រុង ស្រុក ផ្អែកតាមលទ្ធផលនៃការសិក្សា និងវាយតម្លៃ
- ការសិក្សាអំពីលទ្ធភាពនៃការផ្ទេរមុខងារសុខាភិបាលមួយចំនួនពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក ក៏ដូចជាលទ្ធភាពក្នុងការបង្កើតការិយាល័យសុខាភិបាលនៃរដ្ឋបាលក្រុង ស្រុក ដើម្បីផ្តល់សេវាសុខាភិបាលជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព
- ការពង្រឹងនូវការប្រាស្រ័យទាក់ទងរវាងរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ក្នុងកិច្ចសហការរួមគ្នានៃការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាជូនប្រជាពលរដ្ឋ ជាពិសេសការពង្រឹងតួនាទីរបស់រដ្ឋបាលក្រុង ស្រុក ក្នុងការគាំទ្រដល់រដ្ឋបាលឃុំ សង្កាត់។

### សកម្មភាពអាទិភាព ២.១.២៖ ការពង្រឹងការអនុវត្តមុខងារបច្ចុប្បន្នរបស់រដ្ឋបាលឃុំ សង្កាត់

កជទី២ នឹងបន្តពង្រឹងការគាំទ្រ និងការតាមដានវាយតម្លៃលើការអនុវត្តមុខងាររបស់រដ្ឋបាលឃុំ សង្កាត់តាមរយៈការផ្តល់ការគាំទ្រសមត្ថភាព គាំទ្របច្ចេកទេស មធ្យោបាយ សម្ភារៈ និងធនធានផ្សេងទៀត ព្រមទាំងការពិនិត្យកែលម្អនូវលិខិតបទដ្ឋាន និងសេចក្តីណែនាំបច្ចេកទេសនានាពាក់ព័ន្ធនឹងការអនុវត្តមុខងាររបស់រដ្ឋបាលឃុំ សង្កាត់។

### សកម្មភាពអាទិភាព ២.១.៣៖ ការពិនិត្យ និងការកែសម្រួលរចនាសម្ព័ន្ធ មុខងារ និងធនធានរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ដែលស្ថិតក្នុងតំបន់ទីប្រជុំជន

កជទី២ នឹងធ្វើការសិក្សា និងវាយតម្លៃដើម្បីកែសម្រួលរចនាសម្ព័ន្ធ និងមុខងារ របស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ដែលស្ថិតក្នុងតំបន់ទីប្រជុំជន ដើម្បីធានាឱ្យរដ្ឋបាលទាំងនោះមានរចនាសម្ព័ន្ធ មុខងារ និងធនធាន (ហិរញ្ញវត្ថុ និងបុគ្គលិក) សមស្របក្នុងការផ្តល់សេវាទីប្រជុំជនប្រកបដោយប្រសិទ្ធភាព ព្រមទាំងក្លាយជាមជ្ឈមណ្ឌលអភិវឌ្ឍសេដ្ឋកិច្ច សង្គម ដើម្បីជួយអភិវឌ្ឍតំបន់ជនបទក្បែរខាង។ ការសិក្សា និងវាយតម្លៃដើម្បីកែសម្រួលរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ទាំងនេះត្រូវផ្អែកលើកត្តាភូមិសាស្ត្រ ប្រជាសាស្ត្រ និងសក្តានុពលផ្នែកសេដ្ឋកិច្ច និងសង្គមរបស់រដ្ឋបាលនីមួយៗ។

ទន្ទឹមនេះ ដើម្បីកំណត់បានស្រុក និងឃុំណាមួយជាតំបន់ទីប្រជុំជន តម្រូវឱ្យមានការសិក្សា និងកំណត់លក្ខណៈវិនិច្ឆ័យជាក់លាក់មួយ។ ជាមួយគ្នានេះ ក៏ត្រូវសិក្សា និងកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ប្រែក្លាយស្រុកទៅជាក្រុង និងឃុំទៅជាសង្កាត់។

### សកម្មភាពអាទិភាព ២.១.៤៖ ការពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ មុខងារ និងធនធានរបស់រដ្ឋបាលស្រុក និងឃុំដែលស្ថិតក្នុងតំបន់ជនបទ

កជទី២ នឹងរៀបចំឱ្យមានការសិក្សា និងការវាយតម្លៃដើម្បីកែសម្រួលរចនាសម្ព័ន្ធ និងមុខងាររដ្ឋបាលស្រុក និងរដ្ឋបាលឃុំនៅតាមតំបន់ជនបទ ដើម្បីធានាឱ្យរដ្ឋបាលទាំងនោះមានរចនាសម្ព័ន្ធ មុខងារ និងធនធាន (ហិរញ្ញវត្ថុ និងបុគ្គលិក) សមស្របក្នុងការផ្តល់សេវាសាធារណៈនានាពាក់ព័ន្ធវិស័យអភិវឌ្ឍជនបទ កសិកម្ម ធនធានធម្មជាតិ និងការផ្តល់សេវាជាមូលដ្ឋានចាំបាច់ជូនប្រជាពលរដ្ឋដែលរស់នៅតាមភូមិ ឬតំបន់ឆ្ងាយៗពីសាលាស្រុក និងសាលាឃុំ។

### *លទ្ធផលរំពឹងទុក ២.២៖ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ និងធនធានរបស់រដ្ឋបាលខេត្តត្រូវបានពិនិត្យ កែសម្រួល និងប្រតិបត្តិការតាមចរិតលក្ខណៈជារដ្ឋបាលតំបន់ និងស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព*

ដើម្បីធានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី២ ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៣ ដូចខាងក្រោម ៖

### សកម្មភាពអាទិភាព ២.២.១៖ ការសិក្សាជម្រើសនានាសម្រាប់ការរៀបចំរដ្ឋបាលខេត្តក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់

កជទី២ ត្រូវរៀបចំការសិក្សា និងវាយតម្លៃលើរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈនៅថ្នាក់ខេត្ត ព្រមទាំងប្រមូលមេរៀន បទពិសោធន៍អំពីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតំបន់ដែលបាននិងកំពុងអនុវត្តនៅក្នុងបណ្តាប្រទេសនានា ព្រមទាំងមានការពិភាក្សា និងពិគ្រោះយោបល់ឱ្យបានគ្រប់ជ្រុងជ្រោយជាមួយក្រសួង ស្ថាប័ននានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា ដើម្បីកំណត់នូវជម្រើសសម្រាប់កែសម្រួលរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលខេត្តឱ្យមានចរិតលក្ខណៈជារដ្ឋបាលតំបន់។ ការកំណត់នូវជម្រើសត្រូវឆ្លុះបញ្ចាំងនូវបរិបទ តម្រូវការ និងស្ថានភាពជាក់ស្តែងនៅកម្ពុជា និងត្រូវផ្តោតលើចំណុចសំខាន់ៗដូចខាងក្រោម ៖

- ការរៀបចំរចនាសម្ព័ន្ធរដ្ឋបាលខេត្តឱ្យមានចរិតលក្ខណៈជារដ្ឋបាលតំបន់ដោយផ្អែកលើស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ និងសក្តានុពលសេដ្ឋកិច្ច សង្គម របស់ខេត្តនីមួយៗ
- ការបែងចែកឡើងវិញនូវមុខងារតាមគោលការណ៍សាប់ស៊ីឌីយ៉ារីធី ដែលក្នុងនោះមុខងារមួយចំនួនត្រូវបន្តផ្ទេរពីក្រសួង ស្ថាប័នថ្នាក់ជាតិទៅឱ្យរដ្ឋបាលខេត្ត និងមុខងារមួយចំនួនត្រូវផ្ទេរពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលមូលដ្ឋាន (រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់)
- តួនាទីចម្បងៗរបស់រដ្ឋបាលខេត្តក្នុងការជួយគាំទ្រផ្នែកបច្ចេកទេស ការអភិវឌ្ឍសមត្ថភាព ការតាមដានត្រួតពិនិត្យនីត្យានុកូលភាពលើការបំពេញការងាររបស់រដ្ឋបាលមូលដ្ឋាន និងការសម្របសម្រួលការរៀបចំផែនការអភិវឌ្ឍក្នុងតំបន់របស់ខ្លួន។

### សកម្មភាពអាទិភាព ២.២.២៖ ការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការរៀបចំរដ្ឋបាលខេត្តឱ្យមានចរិតលក្ខណៈជារដ្ឋបាលតំបន់

បន្ទាប់ពីជម្រើសនានាត្រូវបានឯកភាពដោយរាជរដ្ឋាភិបាល ចាំបាច់ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលខេត្តឱ្យមានចរិតលក្ខណៈជារដ្ឋបាលតំបន់។ ក្នុងដំណើរការនៃការរៀបចំលិខិតបទដ្ឋានគតិយុត្តនេះចាំបាច់ត្រូវមានការពិភាក្សា និងពិគ្រោះយោបល់ឱ្យបានគ្រប់ជ្រុងជ្រោយជាមួយក្រសួង ស្ថាប័ននានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា មុននឹងដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

### សកម្មភាពអាទិភាព ២.២.៣៖ ដំណើរការដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងារនៃរដ្ឋបាលខេត្តដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់

ក្នុងដំណាក់កាលនៃការអនុវត្តតាមរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងារនៃរដ្ឋបាលខេត្តដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់ រាជរដ្ឋាភិបាលអាចដាក់ឱ្យអនុវត្តនូវគ្រប់ខេត្តទាំងអស់ ឬជ្រើសរើសយកខេត្តមួយចំនួនដើម្បីចាប់ផ្តើមអនុវត្តជាជំហានដំបូង និងបន្តពង្រីកការអនុវត្តនេះទៅបណ្តាខេត្តនានា

ជាដំណាក់កាលៗដោយផ្អែកលើលទ្ធផលនៃការសិក្សា និងការវាយតម្លៃជាក់លាក់មួយលើដំណើរការអនុវត្តដំហានដំបូង។

ក្នុងដំណើរការអនុវត្តចាំបាច់ត្រូវរៀបចំឱ្យមានផែនការ និងកម្មវិធីជាក់លាក់សម្រាប់ការគាំទ្រដល់កិច្ចប្រតិបត្តិការតាមរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលខេត្ត។

### *លទ្ធផលរំពឹងទុក ២.៣៖ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលរាជធានីភ្នំពេញត្រូវបានពិនិត្យ កែសម្រួល និងដាក់ឱ្យប្រតិបត្តិការតាមចរិតលក្ខណៈជារដ្ឋបាលក្រុងមេត្រូប៉ូលីតែន និងស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព*

នាពេលបច្ចុប្បន្ន រាជធានីភ្នំពេញគឺជារដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈពិសេសជាងរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុងដទៃទៀត ដោយសារតែរដ្ឋបាលនេះមានប្រជាពលរដ្ឋរស់នៅយ៉ាងច្រើនកុះករ (ច្រើនជាង២.០០០.០០០នាក់ មានដង់ស៊ីតេប្រមាណជាង៣.០០០នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ) ហើយក៏ជាមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ច វប្បធម៌ និងការគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័នសាធារណៈថ្នាក់ជាតិដ៏សំខាន់មួយរបស់ប្រទេសជាតិ។ ទន្ទឹមនេះ តំបន់ជាយរាជធានីភ្នំពេញបាន និងកំពុងមានការអភិវឌ្ឍយ៉ាងលឿនទៅជាទីក្រុងរណបដែលមានប្រជាពលរដ្ឋមករស់នៅកាន់តែច្រើនឡើងៗ។ ការកើនឡើងនូវចំនួនប្រជាពលរដ្ឋយ៉ាងលឿនបែបនេះ បានបង្កឱ្យរដ្ឋបាលរាជធានីភ្នំពេញជួបប្រទះនូវបញ្ហាប្រឈមជាច្រើនរួមមានដូចជា បញ្ហាសណ្តាប់ធ្នាប់សាធារណៈ បញ្ហាប្រព័ន្ធដឹកជញ្ជូនទីក្រុងនិងការកកស្ទះចរាចរណ៍ បញ្ហាសំរាមសំណល់រឹងនិងរាវ បញ្ហាបំពុលបរិស្ថាននិងអនាម័យ និងបញ្ហាពាក់ព័ន្ធនឹងការរៀបចំផែនការជាយុទ្ធសាស្ត្រ ដែលជានាដល់ការគ្រប់គ្រងដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានីភ្នំពេញទាំងមូល ដោយរាប់បញ្ចូលទាំងទីក្រុងរណបនានាដែលនៅមានការអភិវឌ្ឍពុំទាន់ដូចតំបន់កណ្តាលនៃរាជធានីភ្នំពេញ។ ជាទូទៅ បញ្ហាប្រឈមទាំងនេះនឹងបន្តកើនឡើងកាន់តែខ្លាំងឡើងៗដែលជាឧបសគ្គ និងក្លាយទៅជាបន្ទុកដ៏ធ្ងន់ធ្ងរដល់ប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ក្រសួង ស្ថាប័ន និងរាជរដ្ឋាភិបាល។ ដើម្បីជានាដល់ការដោះស្រាយបញ្ហាប្រឈមទាំងនេះ ចាំបាច់ត្រូវពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌ និងរដ្ឋបាលសង្កាត់ក្នុងរាជធានីភ្នំពេញឱ្យស្របតាមប្រព័ន្ធគ្រប់គ្រងរដ្ឋបាលក្រុងមេត្រូប៉ូលីតែន និងតាមគោលការណ៍នៃរដ្ឋបាលឯកភាព។

ដើម្បីជានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៣ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៣ ដូចខាងក្រោម៖

#### សកម្មភាពអាទិភាព ២.៣.១៖ ការសិក្សាជម្រើសនានាសម្រាប់រៀបចំរដ្ឋបាលរាជធានីក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលក្រុងមេត្រូប៉ូលីតែន

កជទី២ នឹងរៀបចំឱ្យមានការសិក្សា និងវាយតម្លៃលើស្ថានភាពបច្ចុប្បន្ននៃរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានីភ្នំពេញ ដោយមានការស្រាវជ្រាវ និងស្វែងយល់អំពីមេរៀន និងបទពិសោធន៍អំពីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងនៃរដ្ឋបាលក្រុងមេត្រូប៉ូលីតែនដែលបាននឹងកំពុងអនុវត្តនៅក្នុងបណ្តា

ប្រទេសនានា ព្រមទាំងមានការពិភាក្សា និងពិគ្រោះយោបល់ឱ្យបានទូលំទូលាយជាមួយក្រសួង ស្ថាប័ននានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា ដើម្បីកំណត់ជម្រើសសមស្របនានាសម្រាប់កែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររដ្ឋបាលរាជធានីភ្នំពេញឱ្យក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលក្រុងមេត្រូប៉ូលីតែន។ ការសិក្សាលើជម្រើសនានាត្រូវផ្តោតលើ ៖

- ការបែងចែកសិទ្ធិអំណាច មុខងារ ធនធាន ការទទួលខុសត្រូវ និងការប្រាស្រ័យទាក់ទងរវាងក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលរាជធានីភ្នំពេញ
- ការបែងចែងមុខងារ តួនាទី ការទទួលខុសត្រូវ ការប្រាស្រ័យទាក់ទង និងខ្សែគណនេយ្យភាពរវាងរដ្ឋបាលរាជធានីភ្នំពេញជាមួយរដ្ឋបាលខណ្ឌ និងរដ្ឋបាលសង្កាត់ក្នុងរាជធានីភ្នំពេញតាមគោលការណ៍សាប់ស៊ីឌែរីធី និងធានាបាននូវការផ្តល់សេវា និងការអភិវឌ្ឍរាជធានីភ្នំពេញទាំងមូលប្រកបដោយប្រសិទ្ធភាព សមធម៌ និងនិរន្តរភាព
- ការផ្តល់សិទ្ធិសម្រេចទៅឱ្យរដ្ឋបាលរាជធានីក្នុងការកសាងផែនការជាយុទ្ធសាស្ត្រគ្របដណ្តប់លើដែនដីនៃរដ្ឋបាលរាជធានីភ្នំពេញទាំងមូល
- ការរៀបចំ និងការជ្រើសរើសក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌ និងការជ្រើសរើសក្រុមប្រឹក្សា និងចៅសង្កាត់ក្នុងរាជធានីភ្នំពេញដែលធានាដល់ការលើកកម្ពស់ភាពជាតំណាងសាធារណៈ គណនេយ្យភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ
- ការរៀបចំប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងការកំណត់ប្រភពធនធានរបស់រដ្ឋបាលរាជធានី រដ្ឋបាលខណ្ឌ និងរដ្ឋបាលសង្កាត់ក្នុងរាជធានីភ្នំពេញដែលធានាដល់ការលើកកម្ពស់ការប្រមូលចំណូលមូលដ្ឋានប្រកបដោយតម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ថវិការបស់ខ្លួន
- ការបង្កើតយន្តការនៃកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលរាជធានីភ្នំពេញជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានព្រំប្រទល់ជាប់ជាមួយរាជធានីភ្នំពេញ ដើម្បីធានាដល់ការសម្របសម្រួលការរៀបចំផែនការយុទ្ធសាស្ត្រ និងសហការដោះស្រាយបញ្ហាប្រឈមនានា។

### សកម្មភាពអាទិភាព ២.៣.២៖ ការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរាជធានីភ្នំពេញឱ្យមានចរិតលក្ខណៈជារដ្ឋបាលក្រុងមេត្រូប៉ូលីតែន

បន្ទាប់ពីជម្រើសនានាត្រូវបានឯកភាពដោយរាជរដ្ឋាភិបាល ចាំបាច់ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលរាជធានីភ្នំពេញឱ្យក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលក្រុងមេត្រូប៉ូលីតែន។ ក្នុងដំណើរការនៃការរៀបចំលិខិត

បទដ្ឋានគតិយុត្តនេះចាំបាច់ត្រូវមានការពិភាក្សា និងពិគ្រោះយោបល់ឱ្យបានទូលំទូលាយជាមួយក្រសួង ស្ថាប័ននានាទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធ។

### សកម្មភាពអាទិភាព ២.៣.៣៖ ការដាក់ឱ្យអនុវត្តរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងារនៃរដ្ឋបាលក្រុងមេត្រូប៉ូលីតែន

ក្នុងដំណើរការដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលក្រុងមេត្រូប៉ូលីតែនចាំបាច់ត្រូវរៀបចំឱ្យមានផែនការ និងកម្មវិធីជាក់លាក់សម្រាប់គាំទ្រដល់កិច្ចប្រតិបត្តិការនៃរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងនេះ។

### *លទ្ធផលរំពឹងទុក ២.៤៖ ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង កែសម្រួល និងដាក់ឱ្យអនុវត្ត*

ក្នុងអំឡុងពេលនៃការអនុវត្តកជទី២ ទោះបីរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែសម្រួលផ្អែកតាមលទ្ធផលរំពឹកទុក ២.១ លទ្ធផលរំពឹងទុក ២.២ និងលទ្ធផលរំពឹងទុក ២.៣ នៃកជទី២នេះ ក៏បែបផែននៃការប្រាស្រ័យទាក់ទងការងារ និងខ្សែគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវពិនិត្យ កែសម្រួល និងពង្រឹងឡើងវិញឱ្យបានសមស្របទៅតាមរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានកែសម្រួល។ បែបផែននៃការប្រាស្រ័យទាក់ទង និងខ្សែគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន៖ ទំនាក់ទំនងការងារ និងគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនិងថ្នាក់ជាតិ ទំនាក់ទំនងការងារ និងគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានកម្រិតខុសគ្នា ទំនាក់ទំនងការងារ និងគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងជាពិសេសទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ។

ដើម្បីជានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៤ ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៤ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ២.៤.១៖ ការពិនិត្យ កែសម្រួល និងពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនិងរដ្ឋបាលថ្នាក់ជាតិ

កជទី២ ត្រូវបន្តពិនិត្យ កែសម្រួល និងពង្រឹងទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយថ្នាក់ជាតិ ដើម្បីជានាបាននូវការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមគោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់ និងលិខិតបទដ្ឋាននានារបស់ថ្នាក់ជាតិ ព្រមទាំងមានការកំណត់យ៉ាងច្បាស់លាស់ អំពីក្របខ័ណ្ឌនៃការប្រាស្រ័យទាក់ទងការងារពាក់ព័ន្ធនឹងការគាំទ្រកិច្ចសហប្រតិបត្តិការ ការធ្វើអន្តរាគមន៍ និងការតាមដានត្រួតពិនិត្យលើការបំពេញមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### សកម្មភាពអាទិភាព ២.៤.២៖ ការពិនិត្យ កែសម្រួល និងពង្រឹងទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិមានកម្រិតខុសគ្នា

ស្របពេលដែលមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខេត្តត្រូវបានពិនិត្យ និងកែសម្រួលឱ្យក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់ និងរដ្ឋបាលរាជធានីភ្នំពេញត្រូវបានកែសម្រួលជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលក្រុងមេត្រូប៉ូលីតែន និងរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលមូលដ្ឋាន ចាំបាច់កដទី២ ត្រូវបន្តពិនិត្យ កែសម្រួល និងពង្រឹងទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានកម្រិតខុសគ្នា ដើម្បីធានាដល់ស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងកម្រិតនីមួយៗ ក្នុងការអនុវត្តមុខងារដែលត្រូវបានប្រគល់ឱ្យ និងធានាដល់ការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មពីរដ្ឋបាលកម្រិតខ្ពស់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកម្រិតទាបជាងណាមួយ។

### សកម្មភាពអាទិភាព ២.៤.៣៖ ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ

ក្នុងអំឡុងពេលនៃការអនុវត្តកដទី១ ទោះបីរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលក្រុង ស្រុកត្រូវបានកែសម្រួលដោយបានធ្វើសមាហរណកម្មការិយាល័យជំនាញទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុកស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព និងការធ្វើសមាហរណកម្មមន្ទីរសុខាភិបាល និងមណ្ឌលថែទាំកុមាររដ្ឋទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលរាជធានីខេត្តក៏ដោយ ក៏ទំនាក់ទំនងការងារ និងការអនុវត្តខ្សែគណនេយ្យភាពផ្ទៃក្នុងនៃរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងថ្មីនេះនៅមានបញ្ហាប្រឈមជាច្រើន ជាពិសេសទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងមន្ទីរ និងការិយាល័យជំនាញនានាជាមួយក្រុមប្រឹក្សា និងគណៈអភិបាល។ ជាមួយគ្នានឹងការកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកតាមលទ្ធផលរំពឹងទុក ២.១ លទ្ធផលរំពឹងទុក ២.២ និងលទ្ធផលរំពឹងទុក ២.៣ ក៏ជាហេតុផលចាំបាច់បន្ថែមទៀតក្នុងការពង្រឹង និងកែសម្រួលនូវទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

ការពង្រឹងទំនាក់ទំនង និងគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសំដៅដល់ទំនាក់ទំនង និងគណនេយ្យភាពរបស់អភិបាល គណៈអភិបាល នាយករដ្ឋបាល ប្រធានអង្គភាព/ការិយាល័យ និងបុគ្គលិកនានាតាមឋានានុក្រម និងជាពិសេសចំពោះក្រុមប្រឹក្សារបស់ខ្លួន។

### សកម្មភាពអាទិភាព ២.៤.៤៖ ការពង្រឹងទំនាក់ទំនងការងារនិងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ

ការពង្រឹងទំនាក់ទំនង និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ គឺជាទំនាក់ទំនងដ៏សំខាន់ជាងគេក្នុងចំណោមខ្សែគណនេយ្យភាពទាំងអស់ ដែលកិច្ចការនេះត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើ ៖

- ការពង្រឹងទំនាក់ទំនងជាមួយប្រជាពលរដ្ឋតាមរយៈការរៀបចំវេទិកាសាធារណៈនានា និងការចុះជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋដោយផ្ទាល់ ក៏ដូចជាការប្រើប្រាស់នូវបណ្តាញផ្សព្វផ្សាយព័ត៌មាននានា ដើម្បីធានាដល់ការជូនព័ត៌មានជូនប្រជាពលរដ្ឋអំពីការបំពេញការងាររបស់ខ្លួន និងទទួលបាននូវសំណើសំណូមពរនានារបស់ប្រជាពលរដ្ឋ។
- ការពង្រឹងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ ផ្តោតជាសំខាន់ទៅលើការរៀបចំ និងការអនុម័តលើគោលនយោបាយ សេចក្តីសម្រេចនានារបស់រដ្ឋបាលមូលដ្ឋាន ការផ្តល់សេវា និងការអនុវត្តគម្រោងសំខាន់ៗរបស់រដ្ឋបាលមូលដ្ឋាន និងការដោះស្រាយនូវសំណើសំណូមពររបស់ប្រជាពលរដ្ឋ ព្រមទាំងការលើកកម្ពស់សិទ្ធិអំណាចប្រជាពលរដ្ឋក្នុងការត្រួតពិនិត្យតាមដានលើការបំពេញការងារ ដើម្បីធានាដល់ការយកចិត្តទុកដាក់របស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបំពេញការងាររបស់ខ្លួន ដើម្បីផលប្រយោជន៍សាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព និងសមធម៌។

### *លទ្ធផលរំពឹងទុក ២.៥៖ សមត្ថភាពដឹកនាំរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង*

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបានបង្កើតឡើងតាមការបោះឆ្នោតមានកាតព្វកិច្ចបំពេញមុខងារជាតំណាងឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សានីមួយៗមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចទៅលើគោលនយោបាយ ផែនការ និងគម្រោងថវិកា និងការតាមដានត្រួតពិនិត្យនិងវាយតម្លៃលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយត្រូវមានគណនេយ្យភាពដោយផ្ទាល់ និងមានភាពច្បាស់លាស់ចំពោះប្រជាពលរដ្ឋក្នុងការធានាដល់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ដើម្បីធានាដល់ការអនុវត្តនូវសិទ្ធិអំណាច និងការធ្វើគណនេយ្យភាពចំពោះប្រជាពលរដ្ឋនេះ ជាគោលការណ៍ច្បាប់តម្រូវឱ្យគណៈអភិបាល និងបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួន។

ក្នុងពេលដែលសិទ្ធិអំណាច មុខងារ ធនធាន និងការទទួលខុសត្រូវកាន់តែច្រើនត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ កិច្ចការចាំបាច់នៅក្នុងការអនុវត្តកជទី២ ត្រូវបន្តពង្រឹងការអនុវត្តនូវសិទ្ធិអំណាចតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការលើកកម្ពស់ការដឹកនាំ ការធ្វើសេចក្តីសម្រេចចិត្តក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម។

ដើម្បីធានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៥ ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៣ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ២.៥.១៖ ការកែសម្រួល និងការបង្កើតគណៈកម្មាធិការនានាបន្ថែមទៀត របស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ

ការកែសម្រួល និងការបង្កើតគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រភេទ និងកម្រិតនីមួយៗត្រូវផ្ដោតការយកចិត្តទុកដាក់ទៅលើ ៖

- សមាសភាព តួនាទី ភារកិច្ចនៃគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យស្របតាមវិសាលភាពមុខងារ និងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការបង្កើតបន្ថែមនូវគណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងាររបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជួយផ្ដល់យោបល់ដល់ក្រុមប្រឹក្សាក្នុងការបំពេញតួនាទីរបស់ខ្លួនឱ្យបានពេញលេញ និងមានប្រសិទ្ធភាពក្នុងការធ្វើសេចក្ដីសម្រេចលើការរៀបចំ ការអនុម័តផែនការ គម្រោងថវិកា កម្មវិធីផ្ដល់សេវាសាធារណៈ និងកិច្ចការសំខាន់ៗដទៃទៀត ព្រមទាំងក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការងារទាំងនោះ
- គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាអាចបង្កើតនូវអនុគណៈកម្មការ ឬក្រុមការងារចាំបាច់មួយចំនួន ដើម្បីជួយផ្ដល់យោបល់ ដែលក្រុមការងារនេះអាចរួមមាននូវតំណាងអង្គការសង្គមស៊ីវិល និងវិស័យឯកជនផងដែរ ដើម្បីធានាថា ទស្សនៈ និងយោបល់របស់សង្គមស៊ីវិល ផ្នែកឯកជន និងប្រជាពលរដ្ឋត្រូវបានពិចារណាដោយក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។

### សកម្មភាពអាទិភាព ២.៥.២៖ ការពង្រឹងលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ មានលេខាធិការដ្ឋានរបស់ខ្លួនដែលត្រូវបំពេញកិច្ចការប្រចាំថ្ងៃ ដើម្បីជួយគាំទ្រដល់ក្រុមប្រឹក្សាក្នុងការរៀបចំកិច្ចប្រជុំ កំណត់ហេតុកិច្ចប្រជុំ វេទិកាសាធារណៈ ការផ្សព្វផ្សាយសេចក្ដីសម្រេចនានារបស់ក្រុមប្រឹក្សា និងកិច្ចការរដ្ឋបាលនានា។ អាស្រ័យហេតុនេះ កជទី២ ត្រូវផ្ដោតការយកចិត្តទុកដាក់ទៅលើការរៀបចំ និងការពង្រឹងលេខាធិការដ្ឋានក្រុមប្រឹក្សាមួយច្បាស់លាស់ ដែលមានការទទួលខុសត្រូវ និងគណនេយ្យភាពដោយផ្ទាល់ចំពោះក្រុមប្រឹក្សា ព្រមទាំងត្រូវមានបុគ្គលិកគ្រប់គ្រាន់ប្រកបដោយសមត្ថភាព និងមានទីកន្លែងបំពេញការងារ មធ្យោបាយ សម្ភារ ថវិកាសមស្រប ដើម្បីបំពេញការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

### សកម្មភាពអាទិភាព ២.៥.៣៖ ការរៀបចំកញ្ចប់ថវិកាដាក់លាក់សម្រាប់គាំទ្រដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

ដើម្បីធានាដល់ការពង្រឹងសមត្ថភាពដឹកនាំរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវរៀបចំឱ្យមានគម្រោងចំណាយដាក់លាក់សម្រាប់ក្រុមប្រឹក្សា ដែលជាចំណែកមួយនៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រដល់ការបំពេញការងាររបស់ក្រុមប្រឹក្សា គណៈកម្មាធិការ អនុគណៈកម្មាធិការ

ក្រុមការងារ និងលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សា។ ក្នុងនាមក្រុមប្រឹក្សា អភិបាលដែលជាអាណាប័កថវិកាត្រូវធានាថាថវិកានេះ ត្រូវបានប្រើប្រាស់ដោយក្រុមប្រឹក្សាស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

### *លទ្ធផលរំពឹងទុក២.៦៖ ការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ ដើម្បីធានាដល់ជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ*

ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងរាល់ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាផ្នែកមួយដ៏សំខាន់ក្នុងការបង្កើនជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងអំឡុងពេលនៃការអនុវត្តកជទី១ យន្តការមួយចំនួនពាក់ព័ន្ធនឹងការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ក៏ប៉ុន្តែយន្តការទាំងនេះនៅពុំទាន់បានអនុវត្តឱ្យបានទូលំទូលាយ មានប្រសិទ្ធភាព និងបង្កលក្ខណៈងាយស្រួលដល់ការចូលរួមរបស់ប្រជាពលរដ្ឋនៅឡើយ។ អាស្រ័យហេតុនេះ ដើម្បីធានាដល់ការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋប្រកបដោយបរិយាប័ន្ន និងសមធម៌កជទី២ ត្រូវផ្ដោតជាសំខាន់ទៅលើការពិនិត្យ កែសម្រួល និងពង្រឹងយន្តការនៃការចូលរួមរបស់ប្រជាពលរដ្ឋឱ្យមានលក្ខណៈជាស្ថាប័នរឹងមាំ និងមានការទទួលខុសត្រូវជាក់លាក់ ព្រមទាំងមាននីតិវិធីច្បាស់លាស់ដែលបង្កលក្ខណៈងាយស្រួល និងមានការលើកទឹកចិត្តដែលក្នុងនោះរួមមាន យន្តការនៃការផ្ដល់ព័ត៌មានជូនប្រជាពលរដ្ឋ យន្តការនៃការទទួលនិងដោះស្រាយសំណើរបស់ប្រជាពលរដ្ឋ ដោយមានការចូលរួមពីអង្គការសង្គមស៊ីវិល និងវិស័យឯកជន។

ដើម្បីធានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៦ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៣ ដូចខាងក្រោម៖

#### សកម្មភាពអាទិភាព ២.៦.១៖ ការពង្រឹងយន្តការផ្ដល់ព័ត៌មានជូនប្រជាពលរដ្ឋ

ការទទួលបានព័ត៌មានយ៉ាងច្បាស់លាស់ និងគ្រប់គ្រាន់ គឺជាមូលដ្ឋានដ៏សំខាន់នៃការចូលរួមផ្ដល់មតិយោបល់នានាទៅលើបញ្ហាអ្វីមួយ។ អាស្រ័យហេតុនេះ ការផ្ដល់ព័ត៌មានជូនប្រជាពលរដ្ឋយ៉ាងច្បាស់លាស់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ពិតជាមានសារៈសំខាន់បំផុតក្នុងការជំរុញ និងលើកទឹកចិត្តដល់ការចូលរួមជាទូទៅរបស់ប្រជាពលរដ្ឋក្នុងការផ្ដល់យោបល់ និងការដាក់សំណើសំណូមពរនានាចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ។ កជទី២ ត្រូវផ្ដោតការយកចិត្តទុកដាក់លើការបន្តពង្រឹង និងរៀបចំឱ្យមានអង្គភាព និង/ឬយន្តការជាក់លាក់របស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗសម្រាប់ការផ្ដល់ព័ត៌មានជូនប្រជាពលរដ្ឋអំពីកិច្ចដំណើរការនានា ជាពិសេសពាក់ព័ន្ធទៅនឹងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ ការអនុវត្តការងារគណនេយ្យភាពសង្គមត្រូវបន្តពង្រឹង ពង្រីក និងរៀបចំឱ្យទៅជាយន្តការស្ថាប័នច្បាស់លាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងគោលបំណងបង្កភាពងាយស្រួលផ្ដល់ព័ត៌មានជូនប្រជាពលរដ្ឋអំពីថវិកា ការផ្ដល់សេវា និងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាការលើកកម្ពស់តម្លាភាពគណនេយ្យភាពសំដៅលើកកម្ពស់អភិបាលកិច្ចល្អនៅតាមមូលដ្ឋាននីមួយៗ។

### សកម្មភាពអាទិភាព ២.៦.២៖ ការពង្រឹងនូវយន្តការសម្រាប់ទទួលការដាក់សំណើសំណូមពរនានារបស់ប្រជាពលរដ្ឋ

ក្នុងការពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការទទួល និងដោះស្រាយនូវសំណើសំណូមពរ និងបណ្តឹងតវ៉ានានារបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន កជទី១ បានរៀបចំ និងដាក់ឱ្យអនុវត្តនូវយន្តការមួយចំនួនដូចជា ក្រុមការងារគណនេយ្យភាព ការបង្កើតការិយាល័យប្រជាពលរដ្ឋ និងការរៀបចំឱ្យមាននូវអង្គភាពទទួលខុសត្រូវលើការដោះស្រាយបណ្តឹងរបស់ប្រជាពលរដ្ឋនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះបីយ៉ាងនេះក្តី កជទី២ ត្រូវបន្តផ្តោតការយកចិត្តទុកដាក់ទៅលើការពង្រឹង និងកែលម្អយន្តការទាំងនេះឱ្យមានលក្ខណៈជាស្ថាប័នច្បាស់លាស់ និងមាននីតិវិធីអនុវត្តជាក់លាក់ ដើម្បីធានានូវប្រសិទ្ធភាពនៃការទទួល និងការដោះស្រាយ សំណើ សំណូមពរ និងបណ្តឹងតវ៉ានានារបស់ប្រជាពលរដ្ឋ។ ការដាក់សំណើសំខាន់ៗរបស់ប្រជាពលរដ្ឋរួមមានដូចជា សំណើសុំឱ្យធ្វើសវនកម្ម ឬអធិការកិច្ចលើការបំពេញការងារណាមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សំណើលើការផ្តួចផ្តើមគំនិត ឬការកែតម្រូវ ឬការលុបចោលនូវដីកា ឬសេចក្តីសម្រេចណាមួយរបស់ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ល។ ការរៀបចំនូវយន្តការទាំងនេះនឹងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានគណនេយ្យភាពច្បាស់លាស់ចំពោះប្រជាពលរដ្ឋ។

### សកម្មភាពអាទិភាព ២.៦.៣៖ ការលើកកម្ពស់ការចូលរួមរបស់អង្គការស៊ីវិលនៅក្នុងកិច្ចដំណើរការចូលរួមរបស់ប្រជាពលរដ្ឋ

ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលត្រូវផ្តោតលើ៖

- តួនាទីរបស់អង្គការសង្គមស៊ីវិលក្នុងការចូលរួមលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិទទួលបានព័ត៌មាននានារបស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាព័ត៌មាននានាពាក់ព័ន្ធនឹងថវិកា ផែនការ គម្រោង/កម្មវិធី និងសេវាសាធារណៈ ដើម្បីជំរុញ និងលើកទឹកចិត្តដល់ការចូលរួមរបស់ប្រជាពលរដ្ឋ ជាពិសេសក្រុមជនងាយរងគ្រោះ ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- តួនាទីរបស់អង្គការសង្គមស៊ីវិលក្នុងការប្រមូលមតិយោបល់របស់ប្រជាពលរដ្ឋ និងការផ្តួចផ្តើមគំនិតថ្មីៗ ដើម្បីផ្តល់យោបល់ក្នុងនាមក្រុមប្រជាពលរដ្ឋនានាដែលតំណាងឱ្យផលប្រយោជន៍ផ្សេងៗជូនរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំគោលនយោបាយ និងការធ្វើសេចក្តីសម្រេចចិត្តនានាពាក់ព័ន្ធការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការបង្កបរិយាកាសកាន់តែប្រសើរឡើងនៃការប្រាស្រ័យទាក់ទងការងាររវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គការសង្គមស៊ីវិលនានា ដើម្បីធានាដល់ការលើកកម្ពស់ការចូលរួមការអនុវត្តសកម្មភាព និងការផ្តល់យោបល់របស់អង្គការសង្គមស៊ីវិលនៅក្នុងការបំពេញការងារ

របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះ ដើម្បីងាយស្រួលក្នុងការប្រាស្រ័យទាក់ទងនេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំ និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអង្គការសង្គមស៊ីវិលដែលកំពុងប្រតិបត្តិការក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដូចជា អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ អង្គការសហគមន៍មូលដ្ឋាន សមាគមមូលដ្ឋាន គណៈកម្មការវត្ត គណៈកម្មការសាលារៀន គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព និងក្រុមយុវជននានាជាដើម។

- ការរៀបចំឱ្យមានកិច្ចប្រជុំជាទៀងទាត់រវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គការសង្គមស៊ីវិល ឬកិច្ចសហការគ្នាក្នុងការរៀបចំឱ្យមានព្រឹត្តិការណ៍នានា ដើម្បីផ្សព្វផ្សាយ និងចែករំលែកព័ត៌មាន និងការពិគ្រោះយោបល់ជាសាធារណៈ។

### *លទ្ធផលរំពឹងទុក ២.៧៖ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើទំនើបកម្មតាមរយៈការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថល*

នាពេលបច្ចុប្បន្ននេះ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័សដែលត្រូវបាន និងកំពុងប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងប្រព័ន្ធគ្រប់គ្រងការងារ ការចែករំលែកព័ត៌មាន និងការប្រាស្រ័យទាក់ទងជាសាធារណៈ។ ទោះយ៉ាងនេះក្តី រដ្ឋបាលថ្នាក់ក្រោមជាតិបំពេញការងារភាគច្រើនរបស់ខ្លួននៅតែផ្អែកលើប្រព័ន្ធរដ្ឋបាលប្រើប្រាស់ក្រដាសស្នាម និងធ្វើការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋដោយការជួបមុខគ្នាដោយផ្ទាល់ ដែលជាហេតុធ្វើឱ្យការទទួលសេវា និងការប្រាស្រ័យទាក់ទងរបស់ប្រជាពលរដ្ឋនៅមានភាពយឺតយ៉ាវ និងមានការលំបាក។ ប្រការនេះ ចាំបាច់ត្រូវជំរុញការរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ យុទ្ធសាស្ត្រស្តីពីអភិបាលកិច្ចតាមប្រព័ន្ធអេឡិចត្រូនិចនៃកជទី២ មានចែងនៅក្នុងឧបសម្ព័ន្ធ "ង" ៖ យុទ្ធសាស្ត្រអភិបាលកិច្ចឌីជីថល។

ដើម្បីធានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៧ ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៤ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ២.៧.១៖ ការពង្រឹង និងពង្រីកលទ្ធភាពក្នុងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិត

មកទល់បច្ចុប្បន្ននេះ រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ឃុំ សង្កាត់ដែលមានលក្ខណៈជាទីប្រជុំជនអាចរៀបចំជាបណ្តាញតភ្ជាប់សេវាអ៊ីនធឺណិត បើទោះបីជាតំបន់ទីប្រជុំជនខ្លះនៅពុំទាន់មានលទ្ធភាពប្រើប្រាស់នូវប្រព័ន្ធអ៊ីនធឺណិតល្បឿនលឿនក៏ដោយ។ ដោយឡែក ក៏នៅមានរដ្ឋបាលស្រុក និងរដ្ឋបាលឃុំដែលមានលក្ខណៈជាតំបន់ជនបទមួយចំនួនមានលទ្ធភាពប្រើប្រាស់អ៊ីនធឺណិត តែតាមរយៈក្រុមហ៊ុនទូរស័ព្ទចល័តប៉ុណ្ណោះ។ អាស្រ័យហេតុនេះ កជទី២ ត្រូវបន្តជំរុញឱ្យមានការវិនិយោគទៅលើការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិតឱ្យបានដល់តំបន់ជនបទ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅតំបន់ជនបទទាំងនោះមានលទ្ធភាពក្នុងការតភ្ជាប់សេវាអ៊ីនធឺណិត ក្នុងការរៀបចំជារដ្ឋបាលរបស់ខ្លួនឱ្យទៅជារដ្ឋបាលឌីជីថល។

## សកម្មភាពអាទិភាព ២.៧.២៖ ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

កជទី២ ត្រូវរៀបចំឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានលទ្ធភាពកាន់តែច្រើនក្នុងការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់គ្រប់គ្រងការងាររបស់ខ្លួន។ កិច្ចការនេះរួមបញ្ចូលទាំងការយកចិត្តទុកដាក់លើការគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធឌីជីថល ដែលធានាដល់ការចូលរួមចំណែកលើកកម្ពស់ការបំពេញការងារនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធឌីជីថលនេះ ត្រូវបានពង្រឹងតាមរយៈការរៀបចំ និងដាក់ឱ្យអនុវត្តជាជំហានៗតាមរយៈប្រព័ន្ធអនឡាញនៃប្រព័ន្ធទិន្នន័យនានា ដូចជាប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងធនធានមនុស្ស ប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ ប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់  និងប្រព័ន្ធគ្រប់គ្រងទិន្នន័យសំខាន់ៗផ្សេងទៀតដែលប្រើប្រាស់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងប្រើប្រាស់ឯកសារផ្លូវការតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានកាន់តែច្រើនឡើងៗ ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងកាត់បន្ថយចំណាយថវិកា និងពេលវេលា ជាពិសេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដែលស្ថិតនៅតំបន់ឆ្ងាយ។ អាស្រ័យហេតុនេះ ក្នុងដំណាក់កាលដំបូងនៃការរៀបចំប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅក្នុងការគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវពង្រឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការប្រាស្រ័យទាក់ទងការងាររដ្ឋបាលជាប្រចាំមួយចំនួន ដែលកន្លងមកធ្លាប់ប្រើដោយក្រដាសស្នាម (ឧទាហរណ៍ លិខិតអញ្ជើញ លិខិតបេសកកម្ម ការជូនដំណឹង...)។ ដំណាក់កាលជាបន្តបន្ទាប់ទៀត ប្រព័ន្ធនេះចាំបាច់ត្រូវប្រើប្រាស់សម្រាប់ឯកសារទំនាក់ទំនងការងារដែលមានលក្ខណៈសំខាន់ៗ (ឧទាហរណ៍ ឯកសារពាក់ព័ន្ធទៅនឹងការស្នើសុំ និងការពិនិត្យឯកភាពលើកិច្ចការហិរញ្ញវត្ថុ ផែនការ...)។ ជាមួយគ្នានេះដែរ កម្មវិធីកុំព្យូទ័រសម្រាប់កិច្ចការជាក់លាក់ណាមួយនៃការគ្រប់គ្រងដែលមានលក្ខណៈសមស្របសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងបង្កើតឡើង។

ការរៀបចំប្រព័ន្ធគ្រប់គ្រងការងាររដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវបានអភិវឌ្ឍជាបណ្តើរៗពីបែបផែននៃរដ្ឋបាលអេឡិចត្រូនិចទៅជារដ្ឋបាលឌីជីថល អាស្រ័យទៅតាមស្ថានភាពនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

ជាមួយគ្នានឹងការរៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធរដ្ឋបាលឌីជីថលនេះចាំបាច់ត្រូវយកចិត្តទុកដាក់ក្នុងការធានាដល់ការបំពាក់សម្ភារៈ ឧបករណ៍ ក៏ដូចជាការលើកកម្ពស់សមត្ថភាពផ្នែកព័ត៌មានវិទ្យាដល់មន្ត្រីសាធារណៈនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

### សកម្មភាពអាទិភាព ២.៧.៣៖ ការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

កជទី២ ត្រូវលើកកម្ពស់ការប្រាស្រ័យទាក់ទងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីធានាដល់ការធ្វើឱ្យប្រសើរឡើងនូវការផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយ និងឆាប់រហ័ស ព្រមទាំងការកាត់បន្ថយការចំណាយនិងពេលវេលារបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មាន។ កិច្ចការទាំងនេះរួមបញ្ចូលទាំងការផ្សព្វផ្សាយព័ត៌មានអំពីដីកា លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ផែនការអភិវឌ្ឍន៍ គម្រោងថវិកា គម្រោង/កម្មវិធីអភិវឌ្ឍន៍ លទ្ធកម្មសាធារណៈ សេវាសាធារណៈនានា និងព័ត៌មានពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា ព្រមទាំងព័ត៌មានសំខាន់ៗដទៃទៀត។ ការរៀបចំប្រព័ន្ធផ្តល់ និងទទួលព័ត៌មានតាមរយៈប្រព័ន្ធព័ត៌មានវិទ្យា ក៏ចាំបាច់ត្រូវរៀបចំឱ្យមានគេហទំព័រសម្រាប់ព័ត៌មានពាក់ព័ន្ធនឹងបញ្ហានីមួយៗឱ្យបានច្បាស់លាស់ និងរៀបចំឱ្យមាននូវប្រព័ន្ធផ្តល់ព័ត៌មានទាន់ហេតុការណ៍ ដើម្បីធានាដល់ការទទួល និងបកស្រាយនូវសំណើសំណូមពរនានាឱ្យបានទាន់ពេលវេលាជូនប្រជាពលរដ្ឋ។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននឹងត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់កាន់តែច្រើននៅក្នុងការិយាល័យប្រជាពលរដ្ឋ និងក្នុងក្របខ័ណ្ឌការងារគណនេយ្យភាពសង្គម ដើម្បីផ្តល់ព័ត៌មានឱ្យបានទូលំទូលាយជូនប្រជាពលរដ្ឋ និងទទួលព័ត៌មានត្រឡប់ ឬបណ្តឹងតវ៉ានានាពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលសាមីនីមួយៗ។

### សកម្មភាពអាទិភាព ២.៧.៤៖ ការបង្កើត និងការដាក់ឱ្យប្រើប្រាស់ថ្នាលឌីជីថលសម្រាប់ការផ្តល់សេវាសាធារណៈ

កជទី២ ត្រូវគាំទ្រដល់ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់នូវថ្នាលឌីជីថលសម្រាប់ការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ថ្នាលឌីជីថលសម្រាប់ការផ្តល់សេវា រួមមានពាក់ព័ន្ធនឹងសេវានានាដូចជា ៖

- ការចុះបញ្ជីអត្រានុកូលដ្ឋាន និងលិខិត/ឯកសារបញ្ជាក់អត្តសញ្ញាណបុគ្គល
- ការចុះបញ្ជី ឬការស្នើសុំសេវារដ្ឋបាលនានា
- ការទូទាត់ថ្លៃសេវា
- ការទទួលសំណូមពរ និងពាក្យបណ្តឹងតវ៉ានានាពាក់ព័ន្ធនឹងការផ្តល់សេវា។

### *លទ្ធផលរំពឹងទុក ២.៨៖ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងយន្តការអធិការកិច្ចផ្ទៃក្រៅដែលមានលក្ខណៈជាប្រព័ន្ធមួយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ កែសម្រួល និងដាក់ឱ្យអនុវត្ត*

ក្នុងពេលដែលមុខងារ និងធនធានត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមគោលការណ៍វិមជ្ឈការចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវយន្តការត្រួតពិនិត្យផ្ទៃក្នុង និងយន្តការអធិការកិច្ចផ្ទៃក្រៅ ដើម្បីធានា

ដល់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការបំពេញការងារនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើអធិការកិច្ចផ្ទៃក្រៅលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរួមបញ្ចូលទាំងការត្រួតពិនិត្យលើការប្រើប្រាស់ធនធាននានា រួមទាំងធនធានហិរញ្ញវត្ថុ និងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ យន្តការអធិការកិច្ចសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើអធិការកិច្ចផ្ទៃក្រៅដែលសំដៅទៅលើការធ្វើអធិការកិច្ចពីរដ្ឋបាលថ្នាក់ខ្ពស់ជាង។ ទោះយ៉ាងនេះក្តី ការធ្វើអធិការកិច្ចពីខាងក្រៅ ឬពីរដ្ឋបាលថ្នាក់ខ្ពស់ជាងត្រូវតែធានាដល់ការរក្សាបាននូវស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។

បច្ចុប្បន្ននេះ នៅក្នុងរចនាសម្ព័ន្ធនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រួមមាននូវអង្គភាពដែលទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលមានតួនាទីពាក់ព័ន្ធនឹងការធ្វើអធិការកិច្ចផ្ទៃក្នុងរបស់ខ្លួន។ ដោយឡែកផ្អែកតាមអនុក្រឹត្យស្តីពីក្របខ័ណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ចក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានតួនាទីជាសេនាធិការឱ្យរាជរដ្ឋាភិបាលក្នុងការធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រសួងមុខងារសាធារណៈមានតួនាទីជាសេនាធិការឱ្យរាជរដ្ឋាភិបាល ក្នុងការធ្វើអធិការកិច្ចលើកិច្ចការមុខងារសាធារណៈ (ការគ្រប់គ្រងបុគ្គលិក) របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រសួង ស្ថាប័នវិស័យជំនាញមានតួនាទីធ្វើអធិការកិច្ចលើការអនុវត្តមុខងារតាមវិស័យជំនាញនានាដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងអំឡុងពេលនៃការអនុវត្តកជទី១ មុខងារថ្មីៗជាច្រើនត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធនឹងវិស័យខុសៗគ្នាប្រមាណចំនួន២០។ ជារួម ការត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅលើមុខងារទាំងនោះ នៅពុំទាន់មានប្រសិទ្ធភាពនៅឡើយ ដោយសារការរៀបចំឱ្យមានអង្គភាពទទួលខុសត្រូវច្បាស់លាស់ ក្នុងការងារត្រួតពិនិត្យផ្ទៃក្នុងនេះនៅមានភាពមិនច្បាស់លាស់នៅឡើយ។ ជាមួយគ្នានេះដែរ ក៏រួមមាននូវការធ្វើអធិការកិច្ចពីរដ្ឋបាលថ្នាក់ខ្ពស់ដែលភាគច្រើនត្រូវបានអនុវត្តដោយក្រសួង ស្ថាប័នថ្នាក់ជាតិផ្ទាល់ទៅលើការអនុវត្តមុខងារទាំងនេះ ដែលត្រូវបានអនុវត្តដាច់ដោយឡែកៗពីក្រសួងវិស័យនីមួយៗ។ ប្រការនេះបានធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវចំណាយពេលវេលា និងមានបន្ទុកការងារយ៉ាងច្រើនក្នុងការរៀបចំទទួលការចុះធ្វើអធិការកិច្ចទាំងនេះ។ អាស្រ័យហេតុនេះ ដើម្បីធានាដល់ការដោះស្រាយបញ្ហាប្រឈមនេះ កជទី២ ចាំបាច់ត្រូវរៀបចំកែសម្រួល និងពង្រឹងនូវយន្តការត្រួតពិនិត្យ ផ្ទៃក្នុង និងយន្តការអធិការកិច្ចផ្ទៃក្រៅស្របតាមគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ និងមានលក្ខណៈជាប្រព័ន្ធ និងនីតិវិធីច្បាស់លាស់មួយលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសត្រូវធានាថាការធ្វើអធិការកិច្ចពីរដ្ឋបាលថ្នាក់ខ្ពស់នឹងពុំមានការរំខានច្រើនពេកក្នុងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ដើម្បីធានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៨ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៤ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ២.៨.១៖ ការពង្រឹងយន្តការត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ជាទូទៅ ការត្រួតពិនិត្យផ្ទៃក្នុងគឺជាយន្តការដ៏មានសារៈសំខាន់បំផុតរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗក្នុងការធានាដល់ភាពត្រឹមត្រូវ និងប្រសិទ្ធភាពនៃការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ អាស្រ័យហេតុនេះ កជទី២ ចាំបាច់ត្រូវយកចិត្តទុកដាក់ក្នុងការពង្រឹងយន្តការត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដើម្បីសហការជាមួយការធ្វើអធិការកិច្ចផ្ទៃក្រៅក្នុងការលើកកម្ពស់ប្រសិទ្ធភាព តម្លាភាពនៃការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### សកម្មភាពអាទិភាព ២.៨.២៖ ការសិក្សាលើជម្រើសសម្រាប់ការបង្កើតយន្តការអធិការកិច្ចពីខាងក្រៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

កជទី២ ត្រូវរៀបចំការសិក្សាស្រាវជ្រាវលើយន្តការ នីតិវិធី និងបញ្ហាប្រឈមនានានៃការធ្វើអធិការកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធទៅលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិនាពេលបច្ចុប្បន្ននេះ ព្រមទាំងសិក្សាស្រាវជ្រាវទៅលើមេរៀន និងបទពិសោធន៍អំពីយន្តការអធិការកិច្ចពីរដ្ឋបាលថ្នាក់លើ ទៅលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបាននិងកំពុងអនុវត្តនៅតាមបណ្តាប្រទេសនានា ដើម្បីកំណត់នូវជម្រើសសមស្របសម្រាប់ការរៀបចំ និងដាក់ឱ្យអនុវត្តនូវយន្តការអធិការកិច្ចទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលធានាដល់សុខដុមនីយកម្មនៃយន្តការអធិការកិច្ចតាមវិស័យនានារបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនីមួយៗ។ ការកំណត់នូវជម្រើសនានាត្រូវផ្តោតលើ ៖

- លទ្ធភាពនៃការពង្រឹងប្រព័ន្ធអធិការកិច្ចរបស់ថ្នាក់ជាតិទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងធានាដល់ការមិនរំខានច្រើនដល់ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- លទ្ធភាពនៃការបង្កើតយន្តការនៅថ្នាក់រាជធានី ខេត្តដើម្បីទទួលខុសត្រូវលើការធ្វើអធិការកិច្ចការលើការអនុវត្តការងាររបស់រដ្ឋបាលមូលដ្ឋាន (ក្រុង ស្រុក និងឃុំ សង្កាត់)
- កិច្ចដំណើរការអធិការកិច្ច (វិធីសាស្ត្រ ឧបករណ៍ និងរបាយការណ៍)
- ការរៀបចំប្រព័ន្ធលើកទឹកចិត្ត និងដាក់ទណ្ឌកម្ម ពិន័យចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកតាមលទ្ធផលនៃការអធិការកិច្ច។

### សកម្មភាពអាទិភាព ២.៨.៣៖ ការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងឯកសារណែនាំបច្ចេកទេស

ផ្អែកលើជម្រើសនានា ដែលមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងទទួលបានការឯកភាពពីរាជរដ្ឋាភិបាលតាមរយៈគ.ជ.អ.ប. ចាំបាច់ត្រូវកែសម្រួល ឬរៀបចំលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់រៀបចំយន្តការអធិការកិច្ចដែលមានលក្ខណៈជាប្រព័ន្ធមួយរបស់ថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត និងរៀបចំឯកសារណែនាំបច្ចេកទេសលម្អិតសម្រាប់ការធ្វើអធិការកិច្ចនេះ។

## សកម្មភាពអាទិភាព ២.៨.៤៖ ការធ្វើអធិការកិច្ចលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ផ្អែកលើលិខិតបទដ្ឋានគតិយុត្ត និងឯកសារណែនាំបច្ចេកទេសដែលបានអនុម័ត យន្តការអធិការកិច្ចរបស់ថ្នាក់ជាតិដែលបានរៀបចំកែសម្រួលឡើងវិញ ត្រូវចាប់ផ្តើមអនុវត្តការធ្វើអធិការកិច្ចប្រចាំឆ្នាំលើការបំពេញការងាររបស់រដ្ឋបាលរាជធានី និងរដ្ឋបាលខេត្ត។ ក្នុងនាមថ្នាក់ជាតិ យន្តការអធិការកិច្ចរបស់ថ្នាក់រាជធានី ខេត្តត្រូវសម្របសម្រួល និងចុះធ្វើអធិការកិច្ចប្រចាំឆ្នាំលើការបំពេញការងាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

## តារាងទី ៣៖ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពនានាសម្រាប់សមាសភាគទី២

| | |
|---|---|
| **សមិទ្ធផលរំពឹងទុកនៃសមាសភាគទី២៖** *រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល សិទ្ធិអំណាច និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកំណត់យ៉ាងច្បាស់លាស់ តាមកម្រិត និងតាមប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗស្របតាមចរិតលក្ខណៈជារដ្ឋបាលនៃតំបន់ទីក្រុងធំ រដ្ឋបាលនៃតំបន់ទីប្រជុំជន និងរដ្ឋបាលនៃតំបន់ជនបទ ដោយជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការផ្តល់សេវាសាធារណៈ និងការប្រាស្រ័យទាក់ទងសាធារណៈ។* | |
| លទ្ធផលរំពឹងទុក ២.១៖ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ត្រូវបានពង្រឹង កែសម្រួល និងប្រតិបត្តិការជារដ្ឋបាលមូលដ្ឋាន និងស្របតាមចរិតលក្ខណៈរដ្ឋបាលតំបន់ទីប្រជុំជន និងរដ្ឋបាលតំបន់ជនបទ។ | |
| សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១ | សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២ |
| ✓ ២.១.១៖ ការពង្រឹងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់រដ្ឋបាលក្រុង ស្រុក<br>✓ ២.១.២៖ ការពង្រឹងការអនុវត្តមុខងារបច្ចុប្បន្នរបស់រដ្ឋបាលឃុំ សង្កាត់<br>✓ ២.១.៣៖ ការពិនិត្យ និងការកែសម្រួលរចនាសម្ព័ន្ធ មុខងារ និងធនធានរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ដែលស្ថិតក្នុងតំបន់ទីប្រជុំជន<br>✓ ២.១.៤៖ ការពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ មុខងារ និងធនធានរបស់រដ្ឋបាលស្រុក និងឃុំដែលស្ថិតក្នុងតំបន់ជនបទ | |
| លទ្ធផលរំពឹងទុក ២.២៖ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ និងធនធានរបស់រដ្ឋបាលខេត្តត្រូវបានពិនិត្យ កែសម្រួល និងប្រតិបត្តិការតាមចរិតលក្ខណៈជារដ្ឋបាលតំបន់ និងស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព។ | |
| សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១ | សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២ |
| ✓ ២.២.១៖ ការសិក្សាជម្រើសនានាសម្រាប់ការរៀបចំរដ្ឋបាលខេត្តក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់ | |

<table>
<tr><td>✓ ២.២.២៖ ការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការរៀបចំរដ្ឋបាលខេត្តឱ្យមានចរិតលក្ខណៈជារដ្ឋបាលតំបន់</td><td>✓ ២.២.២៖ ការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការរៀបចំរដ្ឋបាលខេត្តឱ្យមានចរិតលក្ខណៈជារដ្ឋបាលតំបន់<br>✓ ២.២.៣៖ ដំណើរការដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងារនៃរដ្ឋបាលខេត្តដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់</td></tr>
<tr><td colspan="2">លទ្ធផលរំពឹងទុក ២.៣៖ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលរាជធានីត្រូវបានពិនិត្យ កែសម្រួល និងដាក់ឱ្យប្រតិបត្តិការតាមចរិតលក្ខណៈជារដ្ឋបាលក្រុងមេត្រូប៉ូលីតែន និងស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព។</td></tr>
<tr><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</td><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</td></tr>
<tr><td>✓ ២.៣.១៖ ការសិក្សាជម្រើសនានាសម្រាប់រៀបចំរដ្ឋបាលរាជធានីក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលក្រុងមេត្រូប៉ូលីតែន<br>✓ ២.៣.២៖ ការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរាជធានីភ្នំពេញរដ្ឋបាលក្រុងមេត្រូប៉ូលីតែន</td><td>✓ ២.៣.២៖ ការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរាជធានីភ្នំពេញរដ្ឋបាលក្រុងមេត្រូប៉ូលីតែន<br>✓ ២.៣.៣៖ ការដាក់ឱ្យអនុវត្តរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងារនៃរដ្ឋបាលក្រុងមេត្រូប៉ូលីតែន</td></tr>
<tr><td colspan="2">លទ្ធផលរំពឹងទុក ២.៤៖ ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង កែសម្រួល និងដាក់ឱ្យអនុវត្ត។</td></tr>
<tr><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</td><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</td></tr>
<tr><td>✓ ២.៤.១៖ ការពិនិត្យ កែសម្រួល និងពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនិងរដ្ឋបាលថ្នាក់ជាតិ<br>✓ ២.៤.២៖ ការពិនិត្យ កែសម្រួល និងពង្រឹងទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិមានកម្រិតខុសគ្នា</td><td></td></tr>
</table>

| | |
|---|---|
| ✓ **២.៤.៣៖** ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ<br>✓ **២.៤.៤៖** ការពង្រឹងទំនាក់ទំនងការងារនិងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ | ✓ **២.៤.៣៖** ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ<br>✓ **២.៤.៤៖** ការពង្រឹងទំនាក់ទំនងការងារនិងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ |
| **លទ្ធផលរំពឹងទុក ២.៥៖ សមត្ថភាពដឹកនាំរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង។** | |
| **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១** | **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២** |
| ✓ **២.៥.១៖** ការកែសម្រួល និងការបង្កើតគណៈកម្មាធិការនានាបន្ថែមទៀតរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ **២.៥.២៖** ការពង្រឹងលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ **២.៥.៣៖** ការរៀបចំកញ្ចប់ថវិកាដាក់លាក់សម្រាប់គាំទ្រដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | ✓ **២.៥.២៖** ការពង្រឹងលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ **២.៥.៣៖** ការរៀបចំកញ្ចប់ថវិកាដាក់លាក់សម្រាប់គាំទ្រដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ |
| **លទ្ធផលរំពឹងទុក ២.៦៖ ការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ ដើម្បីធានាដល់ជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ។** | |
| **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១** | **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២** |
| ✓ **២.៦.១៖** ការពង្រឹងយន្តការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ<br>✓ **២.៦.២៖** ការពង្រឹងនូវយន្តការសម្រាប់ទទួលការដាក់សំណើសំណូមពរនានារបស់ប្រជាពលរដ្ឋ | ✓ **២.៦.១៖** ការពង្រឹងយន្តការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ<br>✓ **២.៦.២៖** ការពង្រឹងនូវយន្តការសម្រាប់ទទួលការដាក់សំណើសំណូមពរនានារបស់ប្រជាពលរដ្ឋ |

| | |
|---|---|
| ✓ **២.៦.៣៖** ការលើកកម្ពស់ការចូលរួមរបស់អង្គការស៊ីវិលនៅក្នុងកិច្ចដំណើរការចូលរួមរបស់ប្រជាពលរដ្ឋ | ✓ **២.៦.៣៖** ការលើកកម្ពស់ការចូលរួមរបស់អង្គការស៊ីវិលនៅក្នុងកិច្ចដំណើរការចូលរួមរបស់ប្រជាពលរដ្ឋ |
| **លទ្ធផលរំពឹងទុក ២.៧៖ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើទំនើបកម្មតាមរយៈការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថល។** | |
| **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១** | **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២** |
| ✓ **២.៧.១៖** ការពង្រឹង និងពង្រីកលទ្ធភាពក្នុងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបណ្ដាញអ៊ីនធឺណិត<br>✓ **២.៧.២៖** ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ **២.៧.៣៖** ការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន<br>✓ **២.៧.៤៖** ការបង្កើត និងការដាក់ឱ្យប្រើប្រាស់ថ្នាលឌីជីថលសម្រាប់ការផ្ដល់សេវាសាធារណៈ | ✓ **២.៧.១៖** ការពង្រឹង និងពង្រីកលទ្ធភាពក្នុងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបណ្ដាញអ៊ីនធឺណិត<br>✓ **២.៧.២៖** ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ **២.៧.៣៖** ការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន<br>✓ **២.៧.៤៖** ការបង្កើត និងការដាក់ឱ្យប្រើប្រាស់ថ្នាលឌីជីថលសម្រាប់ការផ្ដល់សេវាសាធារណៈ |
| **លទ្ធផលរំពឹងទុក ២.៨៖ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងយន្តការអធិការកិច្ចផ្ទៃក្រៅដែលមានលក្ខណៈជាប្រព័ន្ធមួយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ កែសម្រួល និងដាក់ឱ្យអនុវត្ត។** | |
| **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១** | **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២** |
| ✓ **២.៨.១៖** ការពង្រឹងយន្តការត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ✓ **២.៨.១៖** ការពង្រឹងយន្តការត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |

| | |
|---|---|
| ✓ **២.៨.២៖** ការសិក្សាលើជម្រើសសម្រាប់ការបង្កើតយន្តការអធិការកិច្ចពីខាងក្រៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ **២.៨.៣៖** ការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងឯកសារណែនាំបច្ចេកទេស<br>✓ **២.៨.៤៖** ការធ្វើអធិការកិច្ចលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ✓ **២.៨.៣៖** ការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងឯកសារណែនាំបច្ចេកទេស<br>✓ **២.៨.៤៖** ការធ្វើអធិការកិច្ចលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |

## តារាងទី ៤៖ ការគ្រប់គ្រងហានិភ័យសំខាន់ៗសម្រាប់សមាសភាគទី២

| ល.រ | ហានិភ័យ | ផលប៉ះពាល់ | លទ្ធភាពកើតមាន | វិធានការកាត់បន្ថយហានិភ័យ |
|---|---|---|---|---|
| ១ | មុខងារជាកាតព្វកិច្ចដែលបានប្រគល់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមិនត្រូវបានកំណត់ច្បាស់លាស់ ដែលធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមិនអាចគ្រប់គ្រងចាត់ចែង និងអនុវត្តមុខងារទាំងនោះឱ្យមានប្រសិទ្ធភាព | ខ្ពស់ | មធ្យម | - ការកំណត់ឱ្យបានច្បាស់លាស់នូវមុខងារជាកាតព្វកិច្ច និងការរៀបចំសេចក្តីណែនាំលម្អិតស្តីពីនីតិវិធីនៃការអនុវត្តមុខងារជាកាតព្វកិច្ចនីមួយៗ រួមទាំងបទដ្ឋានពាក់ព័ន្ធសម្រាប់ការផ្តល់សេវាកម្ម |
| ២ | ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុកមិនអាចបំពេញតួនាទីរបស់ខ្លួនបានពេញលេញក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងត្រួតពិនិត្យលើការអនុវត្តការងាររបស់គណៈអភិបាល និងបុគ្គលិករបស់ខ្លួន | ខ្ពស់ | ខ្ពស់ | - ផ្តល់ការណែនាំអំពីការរៀបចំបង្កើតយន្តការគាំទ្រដល់ក្រុមប្រឹក្សា រួមមានដូចជាការកែសម្រួល ឬការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការបន្ថែមរបស់ក្រុមប្រឹក្សា និងនីតិវិធីប្រតិបត្តិការរបស់គណៈកម្មាធិការទាំងនោះ<br>- រៀបចំវគ្គបណ្តុះបណ្តាលដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីបង្កើនការយល់ដឹងបន្ថែមទៅក្នុងការអនុវត្តតួនាទី និងអាណត្តិការងាររបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ<br>- ការរៀបចំឱ្យមានគម្រោងចំណាយច្បាស់លាស់របស់ក្រុមប្រឹក្សា នៅក្នុងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៣ | មន្ត្រីរដ្ឋបាលខេត្តមិនផ្លាស់ប្តូរទម្លាប់ក្នុងការគ្រប់គ្រង និងអន្តរាគមន៍លើការអនុវត្តការងាររបស់រដ្ឋបាលមូលដ្ឋាន ឱ្យទៅជាការជួយគាំទ្រផ្នែកបច្ចេកទេស និងការប្រឹក្សាយោបល់ | មធ្យម | ខ្ពស់ | - ផ្តល់គោលការណ៍ណែនាំ និងការបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៃរដ្ឋបាលខេត្ត អំពីទំនាក់ទំនងការងាររវាងរដ្ឋបាលខេត្ត និងរដ្ឋបាលមូលដ្ឋាន<br>- ជំរុញ និងពង្រឹងការតាមដានត្រួតពិនិត្យ និងផ្តល់អន្តរាគមន៍ពីក្រសួងមហាផ្ទៃ ក្នុងករណីដែលមានអាកប្បកិរិយា និងសកម្មភាពមិនសមស្របរបស់មន្ត្រីនៃរដ្ឋបាលខេត្ត |

| ល.រ | ហានិភ័យ | ផលប៉ះពាល់ | លទ្ធភាពកើតមាន | វិធានការកាត់បន្ថយហានិភ័យ |
|---|---|---|---|---|
| ៤ | ស្វ័យភាពរបស់រដ្ឋបាលមូលដ្ឋានក្នុងការផ្តល់អាទិភាព និងការប្រើប្រាស់ធនធានធន្ទានុសិទ្ធិរបស់ខ្លួនសម្រាប់សកម្មភាព និងគម្រោងក្នុងក្របខ័ណ្ឌនៃមុខងារជាអាណត្តិទូទៅ/មុខងារជាជម្រើសរបស់ខ្លួន មិនត្រូវបានគោរពដោយអង្គភាពពាក់ព័ន្ធនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ។ | ខ្ពស់ | មធ្យម | -ក្រោមការសម្របសម្រួលរបស់ គ.ជ.អ.ប. ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវរៀបចំ និងដាក់ចេញនូវសៀវភៅណែនាំស្តីពីការរៀបចំ និងអនុវត្តគម្រោងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្រោមក្របខ័ណ្ឌនៃការអនុវត្តមុខងារជាអាណត្តិទូទៅ/មុខងារជាជម្រើស។ |
| ៥ | ប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមិនត្រូវបានរៀបចំឱ្យស្របទៅតាមប្រភេទ និងចរិតលក្ខណៈនៃរដ្ឋបាលទីក្រុងធំ ទីប្រជុំជន និងតំបន់ជនបទ និងមិនត្រូវបានបែងចែកមុខងារ តួនាទី និងការទទួលខុសត្រូវខុសៗគ្នា។ | មធ្យម | មធ្យម | -គ.ជ.អ.ប. ដឹកនាំ សម្របសម្រួល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងស្នើសុំការពិនិត្យសម្រេចពីប្រមុខរាជរដ្ឋាភិបាល។ |
| ៦ | ភាពមិនជោគជ័យនៃយុទ្ធសាស្ត្រឌីជីថលដោយសារការកំណត់ នីតិវិធីរដ្ឋបាលមិនច្បាស់លាស់ និងការខ្វះបុគ្គលិកដែលមានសមត្ថភាពសមស្របរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | មធ្យម | មធ្យម | -ការពិនិត្យ និងកែសម្រួលនីតិវិធីរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានច្បាស់លាស់<br>-រៀបចំការបណ្តុះបណ្តាលដែលមានលក្ខណៈជាប្រព័ន្ធដល់មន្ត្រីនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការបញ្ជ្រាបចំណេះដឹងអំពីបច្ចេកវិទ្យាព័ត៌មាន និងអភិបាលកិច្ចឌីជីថលទៅក្នុងការបណ្តុះបណ្តាលដំបូងចំពោះបុគ្គលិកដែលចូលបម្រើការងារថ្មី |
| ៧ | យន្តការអធិការកិច្ចទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈជាប្រព័ន្ធមួយមិនត្រូវបានរៀបចំឡើង និងដាក់ឱ្យអនុវត្តដោយសារពុំមានការគាំទ្រពីក្រសួង ស្ថាប័នមួយចំនួន | មធ្យម | មធ្យម | -គ.ជ.អ.ប. ដឹកនាំ សម្របសម្រួល និងពិភាក្សាអំពីជម្រើសសមស្របសម្រាប់ការរៀបចំយន្តការអធិការកិច្ចទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ និងសុំការពិនិត្យសម្រេចពីរដ្ឋាភិបាល |
| ៨ | ការបន្តពង្រឹងរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងតាមបែបមជ្ឈការរបស់ក្រសួង ស្ថាប័នជំនាញមួយចំនួនអាចធ្វើឱ្យប៉ះពាល់ដល់ស្វ័យភាពរបស់រដ្ឋបាលមូលដ្ឋាន | មធ្យម | ខ្ពស់ | -គ.ជ.អ.ប. ត្រូវធានាថាការកែសម្រួលរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័ននីមួយៗត្រូវស្របតាមគោលនយោបាយវិមជ្ឈការ |

| ល.រ | ហានិភ័យ | ផលប៉ះពាល់ | លទ្ធភាពកើតមាន | វិធានការកាត់បន្ថយហានិភ័យ |
|---|---|---|---|---|
| | | | | -គ.ជ.អ.ប. ត្រូវរៀបចំឱ្យមានការវាយតម្លៃទៅលើស្ថានភាពជាអវិជ្ជមាននៃរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័នមួយចំនួនដែលនៅតែបន្តពង្រឹងក្នុងបែបផែនមជ្ឈការ ដើម្បីស្នើសុំគោលការណ៍អនុម័តពីរាជរដ្ឋាភិបាល |
| ៩ | គោលនយោបាយជាអាទិភាពថ្មីៗមួយចំនួននៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមិនស្របជាមួយចក្ខុវិស័យ និងគោលបំណងរួមនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ | ខ្ពស់ | មធ្យម | -គ.ជ.អ.ប. ត្រូវធានាឱ្យមានការពិភាក្សា ពិគ្រោះយោបល់ឱ្យមានការឯកភាពគ្នាក្នុងការដាក់ចេញនូវគោលនយោបាយជាអាទិភាពថ្មីៗនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស្របជាមួយគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ |

## ៣.៣. សមាសភាគទី៣៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

### ៣.៣.១. សនិទានភាព

គោលបំណងជាចម្បងនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺការលើកកម្ពស់ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។ ដើម្បីរួមចំណែកសម្រេចបាននូវគោលបំណងនេះ តម្រូវឱ្យមានការរៀបចំធនធានមនុស្សឱ្យបានសមស្របប្រកបដោយឆន្ទៈម្ចាស់ការ សមត្ថភាព ជំនាញ និងក្រមសីលធម៌វិជ្ជាជីវៈ។ ពាក់ព័ន្ធនឹងបញ្ហានេះ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សប្រកបដោយប្រសិទ្ធភាពគឺជាកត្តាមួយដ៏មានសារៈសំខាន់ក្នុងការធានាសម្រេចបាននូវសមិទ្ធផលនានា និងការផ្តល់សេវានិងការអភិវឌ្ឍមូលដ្ឋានដែលមានគុណភាពខ្ពស់ជូនប្រជាពលរដ្ឋ។ អាស្រ័យហេតុនេះ ចាំបាច់ត្រូវរៀបចំឱ្យមានយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព។

ក្នុងអំឡុង កជទី១ សមិទ្ធផលសំខាន់ៗមួយចំនួនដែលសម្រេចបានរួមមាន ១). ការរៀបចំ និងដាក់ឱ្យអនុវត្តនូវគោលនយោបាយ លក្ខន្តិកៈដោយឡែក និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងគោលការណ៍នីតិវិធីនៃការគ្រប់គ្រងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ២). ការផ្ទេរសិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ ៣). ការផ្ទេរបុគ្គលិកពីក្រសួង ស្ថាប័នពាក់ព័ន្ធនានាស្របតាមមុខងារ និងធនធានដែលបានផ្ទេរ និង ៤). ការរៀបចំ និងអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពនានាដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

បើទោះបីជាប្រព័ន្ធគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តក៏ដោយ ក៏នៅមានបញ្ហាប្រឈមមួយចំនួន និងនៅមានភាពមិនទាន់ច្បាស់លាស់ពាក់ព័ន្ធនឹងការជ្រើសរើសការរៀបចំបុគ្គលិកឱ្យបានសមស្របទៅតាមជំនាញវិជ្ជាជីវៈ ការរៀបចំឱ្យមានការពិពណ៌នាមុខតំណែងវិជ្ជាជីវៈនិងលក្ខខណ្ឌការងារសម្រាប់បុគ្គលិកម្នាក់ៗ ប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផលនៃការបំពេញការងារ (ប្រព័ន្ធគ្រប់គ្រងគុណផល) ប្រព័ន្ធលើកទឹកចិត្តដល់បុគ្គលិកក្នុងការបំពេញការងារ ក្រមសីលធម៌វិជ្ជាជីវៈ និងវិន័យការងារ និងការរៀបចំកែលម្អអង្គវិជ្ជាជីវៈរបស់មន្ត្រីរាជការ (ក្នុងពេលដែលមុខតំណែងមួយចំនួននៃមន្ត្រីក្នុងអង្គវិជ្ជាជីវៈនីមួយៗត្រូវបានផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ) ព្រមទាំងបញ្ហាពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងបច្ចុប្បន្នដែលផ្អែកជាសំខាន់ទៅលើប្រព័ន្ធវិជ្ជាជីវៈក្របខ័ណ្ឌ (ឬហៅថា ប្រព័ន្ធអាជីព)។

ជាមួយគ្នានេះ ការអភិវឌ្ឍសមត្ថភាពដែលបានផ្តល់ក្នុងអំឡុងកជទី១ បានផ្តោតទៅលើ ១). ការអភិវឌ្ឍសមត្ថភាពដែលតម្រូវនិងផ្តល់ដោយថ្នាក់ជាតិ ហើយភាគច្រើនផ្តោតលើការយល់ដឹងអំពីលិខិតបទដ្ឋានគតិយុត្តនានាដែលបានដាក់ចេញ ២). ការរៀបចំ និងដាក់ឱ្យដំណើរការនូវមណ្ឌលអភិវឌ្ឍធនធានមនុស្សនៅថ្នាក់រាជធានី ខេត្តក្នុងគោលបំណងពង្រឹងយន្តការអភិវឌ្ឍសមត្ថភាពនៅតាមរាជធានី ខេត្តនីមួយៗ ក៏ដូចជាការកាត់បន្ថយជាបណ្តើរៗនូវការពឹងផ្អែកលើជំនួយបច្ចេកទេសរបស់ទីប្រឹក្សា ក្នុងការអភិវឌ្ឍសមត្ថភាព និង ៣). ការបង្កើតឡើងនូវសាលាជាតិរដ្ឋបាលមូលដ្ឋានដើម្បីទទួលខុសត្រូវ និងជានា

នូវនិរន្តរភាពនៃការផ្តល់សេវាអភិវឌ្ឍសមត្ថភាពដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះបីជាមានការរៀបចំបែបនេះក៏ដោយ ក៏ការអភិវឌ្ឍសមត្ថភាពដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៅមិនទាន់ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសមត្ថភាពជាក់ស្តែង ដែលចាំបាច់តម្រូវឱ្យមានការពង្រឹង និងកែលម្អនូវយន្តការផ្តល់សេវាអភិវឌ្ឍសមត្ថភាពទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ដើម្បីពង្រឹង និងកែលម្អនូវប្រព័ន្ធគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ កជទី២ ត្រូវផ្តោតជាសំខាន់លើការពិនិត្យ ការកែសម្រួល ការរៀបចំ និងការពង្រឹងការអនុវត្តនូវគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានមនុស្សដែលក្នុងនោះរួមមានដូចជា ការជ្រើសរើសនិងការរៀបចំបុគ្គលិកសមស្របតាមតម្រូវការជាក់លាក់នៃចំនួន និងជំនាញវិជ្ជាជីវៈ ការវាយតម្លៃផ្អែកលើលទ្ធផលនៃការបំពេញការងារ ការផ្តល់ការលើកទឹកចិត្តដល់បុគ្គលិកដែលបម្រើការងារនៅតំបន់ដាច់ស្រយាលនិងតំបន់ជួបការលំបាក ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបុគ្គលិក ការរៀបចំផែនការអភិវឌ្ឍសមត្ថភាពស្ថាប័ន ការពង្រឹងកិច្ចដំណើរការរបស់សាលាជាតិរដ្ឋបាលមូលដ្ឋានរួមបញ្ចូលទាំងការរៀបចំបែបផែននានាសម្រាប់ការអភិវឌ្ឍសមត្ថភាពនៅថ្នាក់តំបន់ ការរៀបចំកម្មវិធីនិងសម្ភារៈបណ្តុះបណ្តាល ការរៀបចំវិធីសាស្ត្រសម្រាប់ការបណ្តុះបណ្តាល និងការអភិវឌ្ឍវិជ្ជាជីវៈអាជីពសម្រាប់បុគ្គលិក។ល។

### ៣.៣.២. និន្នាការទូទៅនៃសមាសភាគទី៣

#### ៣.៣.២.១. សមិទ្ធផលរំពឹងទុក

សមិទ្ធផលរំពឹងទុករបស់សមាសភាគនេះគឺ *"រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិជ្រើសរើស គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិករបស់ខ្លួនផ្អែកលើទំហំការងារ និងលទ្ធភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងមានបុគ្គលិកដែលប្រកបដោយឆន្ទៈម្ចាស់ការ កក្តីភាព និងមនសិការជំនាញវិជ្ជាជីវៈស្របតាមតួនាទី ការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងទទួលបានការអភិវឌ្ឍសមត្ថភាពនិងជំនាញវិជ្ជាជីវៈជាប្រចាំ"*។

#### ៣.៣.២.២. យុទ្ធសាស្ត្រសម្រាប់ការសម្រេចបានសមិទ្ធផលរំពឹងទុក

កជទី២ ត្រូវផ្តោតលើការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាការពង្រឹងនូវសមិទ្ធផលនានាដែលសម្រេចបានក្នុងកជទី១។ ក្នុងន័យនេះ កជទី២ ត្រូវធ្វើការពិនិត្យមើលអំពីភាពខ្វះចន្លោះ និងចំណុចខ្សោយនានាពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលកើតមានឡើងក្នុងអំឡុងកជទី១ ដើម្បីធ្វើការកែលម្អ និងដោះស្រាយ។

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវពេញលេញក្នុងការជ្រើសរើស ការគ្រប់គ្រង និងការរៀបចំបុគ្គលិករបស់ខ្លួនស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ក្នុងន័យនេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានបុគ្គលិកក្នុងចំនួនសមស្របដែលមានសមត្ថភាព ជំនាញវិជ្ជាជីវៈ និងបទពិសោធន៍សមស្រប ដើម្បី

អនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ បុគ្គលិកម្នាក់ៗត្រូវមានលក្ខខណ្ឌការងារច្បាស់លាស់ដែលជាមូលដ្ឋានសម្រាប់ការវាយតម្លៃប្រចាំឆ្នាំដែលនឹងត្រូវអនុវត្តជាប្រចាំ។ ជាងនេះទៀត កជទី២ ត្រូវរៀបចំឱ្យមានប្រព័ន្ធលើកទឹកចិត្តសមស្របដល់បុគ្គលិក ដូចជាការលើកទឹកចិត្តផ្នែកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ មុខតំណែង និងការលើកទឹកចិត្តផ្សេងទៀត ដើម្បីលើកកម្ពស់ឆន្ទៈម្ចាស់ការ និងមនសិការវិជ្ជាជីវៈក្នុងការបំពេញការងារ។ ជាមួយគ្នានេះដែរ ដើម្បីលើកទឹកចិត្តបុគ្គលិកទៅបម្រើការងារនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក កជទី២ ត្រូវរៀបចំ និងដាក់ឱ្យអនុវត្តនូវគោលនយោបាយលើកទឹកចិត្តបុគ្គលិកឱ្យបានសមស្រប។

កជទី២ ត្រូវរៀបចំនូវក្របខ័ណ្ឌអភិវឌ្ឍសមត្ថភាពមួយប្រកបដោយប្រសិទ្ធភាពសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល និងការអភិវឌ្ឍជំនាញវិជ្ជាជីវៈដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ស្របជាមួយនឹងការពិព័ណ៌នាមុខតំណែង និងលក្ខខណ្ឌការងាររបស់បុគ្គលិក។ កង្វះខាតជំនាញក្នុងចំណោមបុគ្គលិកនឹងត្រូវធ្វើការវាយតម្លៃ និងកំណត់ឱ្យបានច្បាស់លាស់ ដើម្បីជាមូលដ្ឋានសម្រាប់រៀបចំកម្មវិធីពង្រឹងជំនាញបុគ្គលិកផ្អែកតាមតម្រូវការជាក់ស្តែង។ ជាមួយគ្នានេះដែរ កជទី២ ត្រូវគាំទ្រការរៀបចំក្របខ័ណ្ឌអភិវឌ្ឍអាជីពវិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងកជទី២ ក្របខ័ណ្ឌអភិវឌ្ឍសមត្ថភាពត្រូវកំណត់ច្បាស់លាស់អំពីការទទួលខុសត្រូវក្នុងការរៀបចំ និងការអនុវត្តវគ្គបណ្តុះបណ្តាល រួមបញ្ចូលទាំងការរៀបចំខ្លឹមសារបណ្តុះបណ្តាល។ នៅថ្នាក់ជាតិ សាលាជាតិរដ្ឋបាលមូលដ្ឋាននឹងទទួលខុសត្រូវជាសំខាន់លើការរៀបចំស្តង់ដារបណ្តុះបណ្តាល សម្ភារៈបណ្តុះបណ្តាល និងការរៀបចំគ្រូឧទ្ទេស ក៏ដូចជាការអនុវត្តវគ្គបណ្តុះបណ្តាលនានាដោយផ្ទាល់ ដោយសហការជិតស្និទ្ធជាមួយស្ថាប័នជំនាញផ្នែកបណ្តុះបណ្តាលនានាទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន។ ជាមួយគ្នានេះដែរ នៅថ្នាក់តំបន់ក៏ត្រូវមានការសិក្សារៀបចំឱ្យមានយន្តការច្បាស់លាស់ និងរៀបចំឱ្យមានកម្មវិធីអភិវឌ្ឍសមត្ថភាពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាងនេះទៀត ការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំឡើងដោយផ្អែកជាមូលដ្ឋានលើវិធីសាស្ត្រផ្សេងៗ រួមបញ្ចូលទាំងការអភិវឌ្ឍសមត្ថភាពលើប្រធានបទសំខាន់ៗ ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច និងការសិក្សាដោយខ្លួនឯង។

### ៣.៣.២.៣. លទ្ធផលរំពឹងទុក

សមិទ្ធផលរំពឹងទុកខាងលើនឹងត្រូវបង្កើតឡើង តាមរយៈលទ្ធផលរំពឹកទុកជាយុទ្ធសាស្ត្រចំនួន ១០ ដូចខាងក្រោម៖

- **លទ្ធផលរំពឹងទុកទី១៖** អង្គមន្ត្រីរាជការស៊ីវិលត្រូវបានពិនិត្យ រៀបចំឡើងវិញ និងដាក់ឱ្យអនុវត្ត
- **លទ្ធផលរំពឹងទុកទី២ ៖** ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត

- **លទ្ធផលរំពឹងទុកទី៣ ៖** ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបុគ្គលិកត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត
- **លទ្ធផលរំពឹងទុកទី៤ ៖** តម្រូវការធនធានមនុស្សទាំងចំនួនបុគ្គលិក និងទាំងជំនាញវិជ្ជាជីវៈត្រូវបានវាយតម្លៃ និងកំណត់ច្បាស់លាស់
- **លទ្ធផលរំពឹងទុកទី៥ ៖** គោលនយោបាយលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត
- **លទ្ធផលរំពឹងទុកទី៦ ៖** ការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាព និងការរៀបចំផែនការអភិវឌ្ឍសមត្ថភាពត្រូវបានពង្រឹង និងកំណត់យ៉ាងច្បាស់លាស់
- **លទ្ធផលរំពឹងទុកទី៧ ៖** ស្ថាប័នបណ្តុះបណ្តាលថ្នាក់ជាតិត្រូវបានពង្រឹងការអនុវត្តពេញលេញ និងស្ថាប័នបណ្តុះបណ្តាលថ្នាក់តំបន់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត
- **លទ្ធផលរំពឹងទុកទី៨ ៖** កម្មវិធីសិក្សាសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត
- **លទ្ធផលរំពឹងទុកទី៩ ៖** វិធីសាស្ត្របណ្តុះបណ្តាលជាក់លាក់មួយចំនួនត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត
- **លទ្ធផលរំពឹងទុកទី១០ ៖** ក្របខ័ណ្ឌអភិវឌ្ឍជំនាញវិជ្ជាជីវៈពេញមួយអាជីពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត

#### ៣.៣.២.៤. យុទ្ធសាស្ត្រ និងសកម្មភាពជាអាទិភាពសម្រាប់អនុវត្តលទ្ធផលរំពឹងទុកនានា

### *លទ្ធផលរំពឹងទុក ៣.១៖ អង្គមន្ត្រីរាជការស៊ីវិលត្រូវបានពិនិត្យ រៀបចំឡើងវិញ និងដាក់ឱ្យអនុវត្ត*

ផ្អែកតាមគោលការណ៍រួមក្នុងការរៀបចំមុខងារសាធារណៈ និងលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ បានតម្រូវឱ្យរៀបចំនូវអង្គសម្រាប់មន្ត្រីរាជការ ដើម្បីប្រមូលផ្តុំ និងគ្រប់គ្រងមន្ត្រីដែលទទួលបានការបណ្តុះបណ្តាល មានបទពិសោធន៍ការងារ និងចំណេះដឹង ព្រមទាំងបំពេញការងារក្នុងវិស័យជំនាញវិជ្ជាជីវៈតែមួយនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងប្រព័ន្ធគ្រប់គ្រងមុខងារសាធារណៈបច្ចុប្បន្ននៅកម្ពុជា បានរៀបចំឱ្យមានជាក្របខ័ណ្ឌមួយចំនួនដែលប្រមូលផ្តុំមន្ត្រីតាមជំនាញវិជ្ជាជីវៈ និងតាមវិស័យនីមួយៗ ដូចជាក្របខ័ណ្ឌមន្ត្រីអប់រំ ក្របខ័ណ្ឌមន្ត្រីសុខាភិបាល ក្របខ័ណ្ឌមន្ត្រីបច្ចេកទេស និងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាដើម ដែលក្របខ័ណ្ឌទាំងនេះ គឺមានន័យសំដៅទៅលើអង្គមន្ត្រីជំនាញវិជ្ជាជីវៈទាំងនោះ។ ទោះបីជាយ៉ាងនេះក្តី អង្គមន្ត្រីរាជការទាំងនេះ ព្រមទាំងលិខិតបទដ្ឋានពាក់ព័ន្ធនានាក្នុងការអនុវត្តអង្គមន្ត្រីរាជការទាំងនេះចាំបាច់ត្រូវមានការរៀបចំ ការពិនិត្យ និងការកែសម្រួលឡើងវិញ ដើម្បីធានាដល់ការដាក់បញ្ចូលមុខតំណែងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិទៅក្នុងអង្គមន្ត្រីរាជការនីមួយៗ និងដើម្បីធានាដល់ការលើកទឹកចិត្តមន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ដើម្បីជានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី១ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ២ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៣.១.១៖ ការពិនិត្យ និងកែសម្រួលអង្គមន្ត្រីរាជការ

ដោយសារមន្ត្រីរាជការក្នុងវិស័យជាច្រើនត្រូវបានផ្ទេរឱ្យស្ថិតនៅក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផ្ទាល់តាមកិច្ចដំណើរការនៃការផ្ទេរមុខងារតាមវិស័យនានា អាស្រ័យហេតុនេះ ដើម្បីជានាដល់ការដាក់បញ្ចូលនូវមុខតំណែងនៃមន្ត្រីទាំងនេះ ទៅក្នុងអង្គមន្ត្រីវិជ្ជាជីវៈនីមួយៗឱ្យបានសមស្រប និងដើម្បីជានាដល់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការរៀបចំមន្ត្រីទៅតាមជំនាញវិជ្ជាជីវៈនីមួយៗ កជទី២ ត្រូវផ្តោតទៅលើការពិនិត្យ និងរៀបចំឡើងវិញនូវអង្គមន្ត្រីរាជការនីមួយៗដែលមានការពាក់ព័ន្ធទៅនឹងមុខតំណែងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទន្ទឹមនោះ អង្គនីមួយៗក៏ត្រូវកំណត់ឱ្យច្បាស់លាស់អំពីក្របខ័ណ្ឌឋានន្តរស័ក្តិ និងថ្នាក់ស្របតាមឧបនិស្ស័យ និងលក្ខណៈសម្បត្តិនានារបស់មន្ត្រីរាជការសម្រាប់ការជ្រើសរើស និងការតែងតាំងតាមមុខតំណែងនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែរ ការពិនិត្យ និងការរៀបចំអង្គមន្ត្រីរាជការនីមួយៗ ត្រូវគិតគូរដល់ការលើកទឹកចិត្តតាមរយៈការរៀបចំកំណត់អំពីក្របខ័ណ្ឌឋានន្តរស័ក្តិ ថ្នាក់ឱ្យស័ក្តិសមនឹងមុខតំណែង និងការទទួលខុសត្រូវរបស់មន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

### សកម្មភាពអាទិភាព ៣.១.២៖ ការដាក់ឱ្យអនុវត្តនូវអង្គមន្ត្រីរាជការនានា

បន្ទាប់ពីលិខិតបទដ្ឋានស្តីពីការរៀបចំអង្គមន្ត្រីរាជការត្រូវបានពិនិត្យ និងអនុម័ត កិច្ចការសំខាន់ៗដែលត្រូវផ្តោតការយកចិត្តទុកនៅក្នុងសកម្មភាពនេះ រួមមានការដាក់បញ្ចូលនូវមុខតំណែងមន្ត្រីរាជការនៃរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់នៃអង្គនីមួយៗ ព្រមទាំងការពិនិត្យ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ដើម្បីឱ្យមានសង្គតិភាពជាមួយនឹងអង្គមន្ត្រីរាជការនីមួយៗ។

## *លទ្ធផលរំពឹងទុក ៣.២៖ ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត*

ការរៀបចំ និងការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម គឺជាកិច្ចការដ៏ចាំបាច់ និងមានសារៈសំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការបំពេញការងាររបស់បុគ្គលិក សំដៅជានាដល់ការសម្រេចបាននូវគោលដៅ បេសកកម្ម និងការទទួលខុសត្រូវរបស់អង្គភាពនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ លទ្ធផលនៃការវាយតម្លៃផ្អែកលើសមិទ្ធកម្មនេះ គឺជាមូលដ្ឋានសម្រាប់ការតែងតាំង ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ ការអភិវឌ្ឍសមត្ថភាព ការលើកទឹកចិត្ត ក៏ដូចជាការដាក់ទណ្ឌកម្មខាងវិន័យផងដែរ។ អាស្រ័យហេតុនេះ កជទី២ ត្រូវរៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការដាក់ចេញនូវសេចក្តីណែនាំមួយច្បាស់លាស់ ដោយផ្តោតជាសំខាន់ទៅលើការរៀបចំការពិពណ៌នាមុខតំណែង លក្ខខណ្ឌការងារ ការគ្រប់គ្រងវត្តមានរបស់បុគ្គលិក ការវាយតម្លៃលើលទ្ធផលនៃការបំពេញការងារ ក៏ដូចជាការលើកទឹកចិត្តដល់បុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

ដើម្បីជានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី២ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៦ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៣.២.១៖ ការរៀបចំការពិពណ៌នាមុខតំណែងរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

សកម្មភាពនេះនឹងផ្តោតទៅលើការរៀបចំការពិព័ណ៌នាមុខតំណែងសម្រាប់ទាំងមុខតំណែងគ្រប់គ្រង និងទាំងមុខតំណែងវិជ្ជាជីវៈនៅតាមអង្គភាពនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជាមូលដ្ឋានសម្រាប់រៀបចំផែនការបុគ្គលិក ការជ្រើសរើស និងការផ្លាស់ប្តូរកន្លែងការងារ ព្រមទាំងសម្រាប់ការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិកម្នាក់ៗ។ ឯកសារពិពណ៌នាមុខតំណែង គឺជាឯកសារដែលរៀបរាប់ច្បាស់លាស់ និងលម្អិតអំពីតួនាទី ភារកិច្ច ការទទួលខុសត្រូវ និងខ្សែគណនេយ្យភាព ព្រមទាំងលក្ខណៈសម្បត្តិសមស្របសម្រាប់មុខតំណែងបុគ្គលិកនីមួយៗ។ ការរៀបចំការពិពណ៌នាមុខតំណែងនេះ ត្រូវផ្អែកជាសំខាន់ទៅលើមុខងារ តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់អង្គភាពនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

### សកម្មភាពអាទិភាព ៣.២.២៖ ការពង្រឹងការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

សកម្មភាពនេះនឹងផ្តោតទៅលើការពង្រឹងការរៀបចំលក្ខខណ្ឌការងារប្រចាំឆ្នាំសម្រាប់បុគ្គលិកដែលត្រូវធ្វើឡើងរវាងប្រធានអង្គភាព និងបុគ្គលិកម្នាក់ៗ ដើម្បីជាមូលដ្ឋានក្នុងការវាយតម្លៃលើលទ្ធផលនៃការបំពេញការងាររបស់បុគ្គលិកម្នាក់ៗ។ លក្ខខណ្ឌការងារនេះក៏អាចរៀបចំសម្រាប់រយៈពេលខ្លីជាក់លាក់ណាមួយសម្រាប់ទីប្រឹក្សាបច្ចេកទេស និងមន្ត្រីជាប់កិច្ចសន្យានានាផងដែរ។ លក្ខខណ្ឌការងារនេះគឺជាឯកសារដែលរៀបរាប់លម្អិតអំពីការទទួលខុសត្រូវ និងលទ្ធផលរំពឹងទុក សូចនាករ ឬចំណុចដៅ និងក្របខ័ណ្ឌពេលវេលាច្បាស់លាស់។ ការរៀបចំលក្ខខណ្ឌការងារនេះ ផ្អែកជាសំខាន់ទៅលើផែនការសកម្មភាពប្រចាំឆ្នាំរបស់អង្គភាពនីមួយៗ និងការពិពណ៌នាមុខតំណែងរបស់បុគ្គលិកម្នាក់ៗ។

### សកម្មភាពអាទិភាព ៣.២.៣៖ ការពង្រឹងការគ្រប់គ្រងវត្តមានបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

ការគ្រប់គ្រងវត្តមានបុគ្គលិក គឺជាយន្តការមួយរួមចំណែកក្នុងការតាមដានការអនុវត្តការងាររបស់បុគ្គលិក ដើម្បីលើកកម្ពស់មនសិការវិជ្ជាជីវៈ និងសមិទ្ធកម្ម។ លទ្ធផលនៃការគ្រប់គ្រងវត្តមានបុគ្គលិកនឹងត្រូវបានប្រើប្រាស់ជាផ្នែកមួយនៃការវាយតម្លៃផ្អែកលើសមិទ្ធកម្មរបស់បុគ្គលិក។ អ្នកគ្រប់គ្រងផ្ទាល់ ឬអភិបាល/មេឃុំ ចៅសង្កាត់អាចកំណត់អំពីបែបផែននៃការគ្រប់គ្រងវត្តមានបុគ្គលិករបស់ខ្លួន ដោយកំណត់អំពីពេលវេលាបម្រើការងារ រយៈពេលបំពេញការងារក្នុងមួយថ្ងៃ និងទីកន្លែងបម្រើការងាររបស់បុគ្គលិកឱ្យមានលក្ខណៈបត់បែនតាមស្ថានភាពជាក់ស្តែងនៃការផ្តល់សេវាសាធារណៈ។

### សកម្មភាពអាទិភាព ៣.២.៤៖ ការរៀបចំក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

ក្រមសីលធម៌វិជ្ជាជីវៈជាវិធាន ឬបទបញ្ញាផ្នែកសីលធម៌ដែលស្ថាប័ននីមួយៗបានកំណត់ឡើងសម្រាប់ដាក់ឱ្យបុគ្គលិកគ្រប់រូបប្រតិបត្តិដោយខ្ជាប់ខ្ជួន ដើម្បីធានារក្សាបាននូវគុណតម្លៃ កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់បុគ្គលិកម្នាក់ៗ និងរបស់ស្ថាប័ននីមួយៗ។ នាពេលបច្ចុប្បន្ននេះ ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អង្គវិជ្ជាជីវៈមួយចំនួនដូចជា អង្គគ្រូបង្រៀន អង្គសុខាភិបាល (គ្រូពេទ្យ) ត្រូវបានរៀបចំ និងកំពុងអនុវត្ត ក៏ប៉ុន្តែអង្គវិជ្ជាជីវៈមួយចំនួនទៀត នៅមិនទាន់បានរៀបចំនៅឡើយ។ អាស្រ័យហេតុនេះ កជទី២នឹងផ្ដោតទៅលើការរៀបចំ និងការពង្រឹងការអនុវត្តនូវក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការបំពេញការងាររបស់បុគ្គលិកជាពិសេសការធ្វើទំនាក់ទំនងសាធារណៈ ការផ្ដល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។

### សកម្មភាពអាទិភាព ៣.២.៥៖ ការលើកកម្ពស់ការតាមដាន និងការវាយតម្លៃលើការបំពេញការងារ

ផ្អែកលើការពិពណ៌នាមុខតំណែង លក្ខខណ្ឌការងារ និងប្រព័ន្ធគ្រប់គ្រងវត្តមានបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ចាំបាច់ត្រូវរៀបចំយន្តការតាមដានវាយតម្លៃដែលមានមានលក្ខណៈជាប្រព័ន្ធ និងមានភាពច្បាស់លាស់មួយ ដើម្បីធានានូវប្រសិទ្ធភាពនៃការបំពេញការងារ។ កិច្ចដំណើរការ និងនីតិវិធីនៃការតាមដាន និងវាយតម្លៃ រួមមានការវាយតម្លៃប្រចាំឆ្នាំ និងការត្រួតពិនិត្យឡើងវិញប្រចាំត្រីមាស ឆមាស និងនព្វមាស ដើម្បីធានាដល់ការណែនាំតម្រង់ទិសនិងផ្ដល់ដំណោះស្រាយទាន់ពេលវេលា ការកែសម្រួលលក្ខខណ្ឌការងារ និងការគាំទ្រដល់សមត្ថភាពរបស់បុគ្គលិក។ ការតាមដាន និងវាយតម្លៃនេះត្រូវផ្អែកលើលក្ខខណ្ឌការងារ លក្ខណៈវិនិច្ឆ័យ និងមានការកំណត់ជាពិន្ទុច្បាស់លាស់ប្រកបដោយសុក្រឹតភាព តម្លាភាព និងយុត្តិធម៌។

### សកម្មភាពអាទិភាព ៣.២.៦៖ ការផ្ដល់ការលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកតាមលទ្ធផលនៃការវាយតម្លៃការងារ

ការផ្ដល់ការលើកទឹកចិត្តដល់បុគ្គលិកផ្អែកតាមលទ្ធផលនៃការវាយតម្លៃការងារ គឺជាយន្តការមួយដ៏មានសារៈសំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការបំពេញការងាររបស់បុគ្គលិក។ បែបផែននៃការលើកទឹកចិត្តតាមរយៈយន្តការនេះ អាចជាការលើកទឹកចិត្តជាហិរញ្ញវត្ថុ និងការលើកទឹកចិត្តមិនមែនហិរញ្ញវត្ថុ ដូចជាប្រាក់រង្វាន់ ឬប្រាក់ឧបត្ថម្ភផ្សេងៗ ការតែងតាំងមុខតំណែង ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ការផ្ដល់គ្រឿងឥស្សរិយយស បណ្ណសរសើរ ការអភិវឌ្ឍសមត្ថភាពដែលរាប់បញ្ចូលទាំងសមត្ថភាពដែលគាំទ្រពីស្ថាប័ន ក៏ដូចជាការជំរុញឱ្យមានស្វ័យសិក្សារបស់បុគ្គលនីមួយៗ។ ជាមួយគ្នានេះដែរ ក៏ចាំបាច់ត្រូវមាន

វិធានការក្នុងការដាក់ទណ្ឌកម្មខាងវិន័យដល់បុគ្គលិកដែលពុំមានការទទួលខុសត្រូវ និងបំពេញការងារមិនបានល្អ។

### *លទ្ធផលរំពឹងទុក ៣.៣ ៖ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបុគ្គលិកត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត*

ដើម្បីធានាដល់ប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្របតាមការរីកចម្រើនយ៉ាងឆាប់រហ័សក្នុងការប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅក្នុងប្រទេសកម្ពុជា កជទី២ ត្រូវជំរុញគាំទ្រដល់ការរៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ដើម្បីធានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៣ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ១ ដូចខាងក្រោម៖

#### សកម្មភាពអាទិភាព ៣.៣.១៖ ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ

សកម្មភាពនេះផ្តោតលើការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ ដូចជាការគ្រប់គ្រងវត្តមាន ទិន្នន័យរបស់បុគ្គលិក ការជ្រើសរើស ការត្រួតពិនិត្យវាយតម្លៃការបំពេញការងារសម្រាប់ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ ការតែងតាំងមុខតំណែង ការដាក់វិន័យ ការចូលនិវត្តន៍ និងការគ្រប់គ្រងផ្សេងៗទៀត។ ក្រសួងមុខងារសាធារណៈក្រោមការសម្របសម្រួលដឹកនាំរបស់ គ.ជ.អ.ប. ត្រូវបំពេញតួនាទីក្នុងការរៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងបុគ្គលិកតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននេះ ដោយធានាថាប្រព័ន្ធនេះអាចអនុវត្តយ៉ាងមានប្រសិទ្ធភាពនៅថ្នាក់ក្រោមជាតិនីមួយៗ និងការផ្សារភ្ជាប់រវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

### *លទ្ធផលរំពឹងទុក ៣.៤៖ តម្រូវការធនធានមនុស្សទាំងចំនួនបុគ្គលិក និងទាំងជំនាញវិជ្ជាជីវៈត្រូវបានវាយតម្លៃ និងកំណត់ច្បាស់លាស់*

ការរៀបចំផែនការ និងការជ្រើសរើសបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានប្រគល់សិទ្ធិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ក្នុងអំឡុងពេលនៃការអនុវត្តផែនការអនុវត្តដំណាក់កាលចុងក្រោយនៃកជទី១។ ក៏ប៉ុន្តែ រដ្ឋបាលថ្នាក់ក្រោមជាតិនៅមិនទាន់អាចអនុវត្តឱ្យបានពេញលេញនូវតួនាទី និងសិទ្ធិអំណាចដែលបានប្រគល់នេះនៅឡើយទេ អាស្រ័យហេតុនេះ កជទី២ ត្រូវផ្តល់គោលការណ៍ឱ្យបានច្បាស់លាស់ និងពង្រឹងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីការរៀបចំផែនការបុគ្គលិក តាមរយៈការវិភាគអំពីស្ថានភាពធនធានមនុស្សនាពេលបច្ចុប្បន្ន និងធ្វើការព្យាករណ៍អំពីតម្រូវការធនធានមនុស្សនាពេលអនាគត ដោយមានការគិតគូរអំពីការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម។ ជាមួយគ្នានេះ ក្រសួង ស្ថាប័នត្រូវសហការ និងគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តកិច្ចដំណើរការវាយតម្លៃអំពីតម្រូវការធនធានមនុស្សដែលពាក់ព័ន្ធជាមួយវិស័យរបស់ខ្លួន។

ដើម្បីជានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៤ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៣ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៣.៤.១៖ ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីការវាយតម្លៃអំពីតម្រូវការទាំងបរិមាណ និងវិជ្ជាជីវៈ

សកម្មភាពនេះផ្តោតលើការរៀបចំ និងដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីការវាយតម្លៃតម្រូវការធនធានមនុស្ស (ចំនួន និងជំនាញវិជ្ជាជីវៈ) នៅតាមអង្គភាពនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានចំនួនបុគ្គលិកគ្រប់គ្រាន់ មានជំនាញវិជ្ជាជីវៈសមស្រប និងត្រូវបានចាត់ចែងឱ្យបំពេញការងារនៅតាមទីកន្លែងស្របតាមជំនាញវិជ្ជាជីវៈរបស់បុគ្គលិកម្នាក់ៗ និងទៅតាមតម្រូវការរបស់អង្គភាពនីមួយៗ។ សេចក្តីណែនាំនេះ ត្រូវកំណត់ឱ្យបានច្បាស់លាស់អំពីគោលការណ៍ បែបបទ នីតិវិធី វិធីសាស្ត្រនៃការវាយតម្លៃ វិភាគ និងការព្យាករណ៍អំពីតម្រូវការធនធានមនុស្ស។

### សកម្មភាពអាទិភាព ៣.៤.២៖ ការពង្រឹងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការបុគ្គលិក

សកម្មភាពនេះ ផ្តោតលើការពង្រឹងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសអង្គភាពទទួលខុសត្រូវក្នុងការរៀបចំផែនការបុគ្គលិកអំពីការវិភាគ និងការព្យាករណ៍តម្រូវការធនធានមនុស្ស ដើម្បីរៀបចំផែនការបុគ្គលិករបស់ខ្លួនឱ្យបានច្បាស់លាស់ ត្រឹមត្រូវស្របតាមគោលការណ៍ បែបបទ នីតិវិធី និងវិធីសាស្ត្រដែលបានកំណត់។

### សកម្មភាពអាទិភាព ៣.៤.៣៖ ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

សកម្មភាពនេះផ្តោតលើការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំផែនការបុគ្គលិកនេះ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធត្រូវធ្វើការសិក្សាវាយតម្លៃ វិភាគ និងព្យាករណ៍អំពីតម្រូវការធនធានមនុស្សក្នុងវិស័យជាក់លាក់ ដើម្បីកំណត់ចំនួនបុគ្គលិក និងជំនាញវិជ្ជាជីវៈឱ្យបានសមស្របសម្រាប់បំពេញតួនាទី និងភារកិច្ចតាមវិស័យឬកិច្ចការជំនាញនីមួយៗ។ ការសិក្សាវាយតម្លៃនេះ អាចរួមមានការវិភាគអំពីមុខងារ តួនាទី ភារកិច្ច ការទទួលខុសត្រូវរបស់អង្គភាពនីមួយៗ ស្ថានភាពធនធានមនុស្សនាពេលបច្ចុប្បន្ន និងការព្យាករណ៍អំពីតម្រូវការធនធានមនុស្សនាពេលអនាគត។ល។ ផ្អែកលើលទ្ធផលនៃការសិក្សាវាយតម្លៃនេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំ។ ផែនការបុគ្គលិកប្រចាំឆ្នាំត្រូវពិនិត្យ និងអនុម័តដោយក្រុមប្រឹក្សាស្របតាមគោលការណ៍ និងនីតិវិធីកំណត់។

## *លទ្ធផលរំពឹងទុក ៣.៥៖ គោលនយោបាយលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត*

មកទល់បច្ចុប្បន្ននេះ កង្វះខាតធនធានមនុស្សទាំងបរិមាណ និងគុណភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅតែជាបញ្ហាប្រឈមជាចម្បងនៅឡើយ បើទោះបីជាមុខងារ និងការទទួលខុសត្រូវទាំងក្នុង

ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវានានាត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែច្រើនឡើងៗ ក៏ដោយ។ បញ្ហាប្រឈមទាំងនេះ អាចបង្កឡើងដោយមូលហេតុសំខាន់ពីរ ពោលគឺ ១). ដោយសារការរៀបចំមុខតំណែង ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងប្រាក់បំណាច់មុខងារសម្រាប់មុខតំណែងនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិពុំបានលើកទឹកចិត្ត និងជំរុញឱ្យមានការស្ម័គ្រចិត្តរបស់បុគ្គលិកឱ្យទៅបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និង ២). បើទោះបីជាមានការអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ទូរគមនាគមន៍ក៏ប៉ុន្តែក៏នៅមានភូមិសាស្ត្រមួយចំនួនមានលក្ខណៈជាតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាកនៅឡើយដែលអាចជាបញ្ហាប្រឈមដល់សុខភាព និងជីវភាពរស់នៅរបស់បុគ្គលិកដែលទៅបំពេញការងារនៅទីនោះ។ អាស្រ័យហេតុនេះ ដើម្បីទាក់ទាញ និងធានាឱ្យមានបុគ្គលិកដែលមានសមត្ថភាព បទពិសោធន៍ និងជំនាញវិជ្ជាជីវៈសមស្របទៅបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅតំបន់ជនបទ តំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក កជទី២ ចាំបាច់ត្រូវពិនិត្យមើលឡើងវិញ និងរៀបចំគោលនយោបាយ និងលិខិតបទដ្ឋាននានា ដើម្បីលើកទឹកចិត្តដល់បុគ្គលិកទាំងផ្នែកថវិកា និងមិនមែនថវិកាសម្រាប់បុគ្គលិកដែលបានចាត់តាំងឱ្យទៅបំពេញការងារនៅក្នុងតំបន់ទាំងនោះ ដើម្បីធានាដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព។

ដើម្បីធានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៥ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៤ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៣.៥.១៖ ការសិក្សាអំពីជម្រើសនានាសម្រាប់ផ្តល់ការលើកទឹកចិត្តដល់បុគ្គលិកដែលបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

សកម្មភាពនេះនឹងផ្តោតលើការរៀបចំឱ្យមានការសិក្សាឱ្យបានស៊ីជម្រៅទៅលើការកែលម្អគោលនយោបាយ និងយន្តការផ្តល់ការលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានលក្ខណៈសមស្របទៅនឹងបរិបទ និងស្ថានភាពជាក់ស្តែងទៅនឹងរចនាសម្ព័ន្ធ ប្រព័ន្ធមុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានកែសម្រួលក្នុងអំឡុងពេលអនុវត្តនៃកជទី១។ ជាមួយគ្នានេះ ការសិក្សាក៏អាចផ្អែកលើបទពិសោធន៍ល្អៗដែលកំពុងអនុវត្តនៅបណ្តាប្រទេសមួយចំនួនផងដែរ។ ផ្អែកលើលទ្ធផលនៃការសិក្សានេះ ចាំបាច់ត្រូវរៀបចំឱ្យមានការអនុវត្តសាកល្បងអំពីយន្តការលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលបំពេញការងារនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក។

### សកម្មភាពអាទិភាព ៣.៥.២៖ ការរៀបចំ និងដាក់ឱ្យអនុវត្តនូវគោលនយោបាយ និងលិខិតបទដ្ឋាននានាស្តីពីការផ្តល់នូវការលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅតំបន់ជនបទ តំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក

ការអនុវត្តសាកល្បងនូវគោលនយោបាយលើកទឹកចិត្តខាងលើ ចាំបាច់ត្រូវមានការវាស់វែង និងប្រៀបធៀបអំពីឆន្ទៈបម្រើការងាររបស់បុគ្គលិក និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈជាតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក បន្ទាប់ពីការផ្តល់ការ

លើកទឹកចិត្តនានាទាំងផ្នែកថវិកា និងមិនមែនថវិការួមមានដូចជា ការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមលើបៀវត្ស ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ និងផ្តល់ការលើកទឹកចិត្តដែលមានលក្ខណៈសមស្របផ្សេងទៀត។ ផ្អែកលើបទពិសោធន៍នៃការអនុវត្តគោលនយោបាយលើកទឹកចិត្តដែលកំពុងអនុវត្តក្នុងវិស័យអប់រំ និងសុខាភិបាល និងផ្អែកលើលទ្ធផលនៃការអនុវត្តសាកល្បង កជទី២ ត្រូវរៀបចំកែសម្រួល និងដាក់ឱ្យអនុវត្តយ៉ាងពេញលេញនូវគោលនយោបាយ និងលិខិតបទដ្ឋានស្តីពីការលើកទឹកចិត្តនានាឱ្យបានសមស្របដល់បុគ្គលិកទាំងក្នុងវិស័យអប់រំ សុខាភិបាល និងវិស័យផ្សេងៗទៀតដែលបំពេញការងារនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក។

### សកម្មភាពអាទិភាព ៣.៥.៣៖ ការពិនិត្យមើលឡើងវិញនូវក្របខ័ណ្ឌ ឋានន្តរស័ក្តិសម្រាប់មុខតំណែងគ្រប់គ្រងនីមួយៗរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

កន្លងមកនេះ ការរៀបចំក្របខ័ណ្ឌ ឋានន្តរស័ក្តិសម្រាប់មុខតំណែងនីមួយៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិមានកម្រិតខុសគ្នាទៅតាមថ្នាក់រដ្ឋបាលនីមួយៗ។ ឧទាហរណ៍ ក្របខ័ណ្ឌ ឋានន្តរស័ក្តិរបស់ប្រធានការិយាល័យនៅថ្នាក់ក្រុង ស្រុក ខណ្ឌមានកម្រិតទាបជាងមុខតំណែងប្រធានការិយាល័យនៅថ្នាក់រាជធានី ខេត្ត និងទាបជាងមុខតំណែងប្រធានការិយាល័យនានានៅថ្នាក់ជាតិ។ ជាមួយគ្នានេះដែរ ក្របខ័ណ្ឌ ឋានន្តរស័ក្តិរបស់នាយកទីចាត់ការនៅរដ្ឋបាលរាជធានី ខេត្ត មានកម្រិតទាបជាងមុខតំណែងប្រធានមន្ទីរជំនាញនៅថ្នាក់រាជធានី ខេត្ត និងទាបជាងមុខតំណែងប្រធាននាយកដ្ឋាននៅថ្នាក់ជាតិ។ ការរៀបចំបែបនេះ ដោយសារកន្លងមកក្រសួង ស្ថាប័នជំនាញនីមួយៗមានតួនាទី និងការទទួលខុសត្រូវទាំងក្នុងការរៀបចំគោលនយោបាយ និងការផ្តល់សេវាសាធារណៈផ្ទាល់តាមរយៈអង្គភាពនានានៅថ្នាក់ជាតិ និងអង្គភាពខ្សែបណ្តោយរបស់ខ្លួននៅថ្នាក់ក្រោមជាតិ ហើយអង្គភាពនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិបំពេញមុខងារភាគច្រើនតែលើការងាររដ្ឋបាល និងពុំមានតួនាទី និងការទទួលខុសត្រូវច្បាស់លាស់ក្នុងការផ្តល់សេវាក្នុងវិស័យជំនាញនីមួយៗនោះឡើយ។

ផ្អែកតាមការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ មុខងារ និងការទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈក្នុងវិស័យនានាជាច្រើនត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសទៅឱ្យរដ្ឋបាលក្រុង ស្រុក។ ជាមួយគ្នានេះ ក្នុងដំណាក់កាលនៃកជទី២ នឹងបន្តជំរុញឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្លាយទៅជាស្ថាប័នផ្តល់សេវាក្នុងវិស័យនានាដោយផ្ទាល់ជូនប្រជាពលរដ្ឋ ហើយក្រសួង ស្ថាប័នជំនាញមានតួនាទីសំខាន់ក្នុងការរៀបចំគោលនយោបាយ ការកំណត់ស្តង់ដារ ការគាំទ្រ និងការតាមដានត្រួតពិនិត្យលើការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ អាស្រ័យហេតុនេះ កជទី២ ចាំបាច់ត្រូវពិនិត្យ និងកែសម្រួលឱ្យបានសមស្របនូវក្របខ័ណ្ឌ ឋានន្តរស័ក្តិសម្រាប់មុខតំណែងគ្រប់គ្រងនីមួយៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របទៅនឹងទំហំការងារ និងការទទួលខុសត្រូវរបស់អង្គភាពនីមួយៗក្នុងនាមជាអ្នកផ្តល់សេវាដោយផ្ទាល់ជូនប្រជាពលរដ្ឋ។ ការដំឡើងកម្រិតក្របខ័ណ្ឌ ឋានន្តរស័ក្តិនៃមុខតំណែងគ្រប់គ្រងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មិនត្រឹមតែធានាបាននូវប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាសាធារណៈប៉ុណ្ណោះ

នោះទេ ប៉ុន្តែវាជាកត្តាដ៏សំខាន់មួយក្នុងការលើកកម្ពស់ធនធានម្ចាស់ការ និងការទាក់ទាញធនធានមនុស្សដែលមានសមត្ថភាព និងបទពិសោធន៍ច្រើនឱ្យទៅបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

### សកម្មភាពអាទិភាព ៣.៥.៤៖ លើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងមុខតំណែងគ្រប់គ្រង នៅរដ្ឋបាលថ្នាក់ក្រោមជាតិ

កន្លងមក កជទី១ បានដាក់ចេញ និងអនុវត្តផែនការយុទ្ធសាស្ត្រក្នុងការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ នៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ ក្នុងដំណាក់កាលដំបូងនេះ កម្មវិធីជាតិទទួលបាននូវមេរៀនបទពិសោធន៍នានាដែលជាមូលដ្ឋានគ្រឹះយ៉ាងសំខាន់ ក្នុងការបន្តដាក់ចេញនូវទិសដៅនានាក្នុងការធានាឱ្យប្រព័ន្ធគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ បង្កឱកាសឱ្យបុរស និងស្ត្រីអាចចូលរួមបំរើការងារ និងបំពេញភារកិច្ចក្នុងមុខងារគ្រប់គ្រង និងដឹកនាំប្រកបដោយបរិយាប័ន្ន និងសមធម៌។ អាស្រ័យហេតុនេះ កជទី២ ចាំបាច់ត្រូវបន្តពង្រឹង និងធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រក្នុងការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងជំរុញការអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ ផ្អែកលើផែនការយុទ្ធសាស្ត្រនេះ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវរៀបចំឱ្យមានផែនការអនុវត្តច្បាស់លាស់ ដោយផ្អែកលើស្ថានភាពជាក់ស្តែង ដើម្បីកំណត់ឱ្យបាននូវសកម្មភាពជាអាទិភាពនានា ដើម្បីធានាដល់ការលើកកម្ពស់តួនាទីរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំ។

### *លទ្ធផលរំពឹងទុក ៣.៦ ៖ ការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាព និងការរៀបចំផែនការអភិវឌ្ឍសមត្ថភាពត្រូវបានពង្រឹង និងកំណត់យ៉ាងច្បាស់លាស់*

ការវិភាគអំពីតម្រូវការជំនាញរបស់បុគ្គលិក ត្រូវកំណត់ឱ្យបាននូវជំនាញនានាដែលបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិកំពុងមាន និងជំនាញនានាដែលជាតម្រូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឈានទៅកំណត់អំពីតម្រូវការបណ្តុះបណ្តាល និងការរៀបចំផែនការអភិវឌ្ឍសមត្ថភាព។ ដើម្បីកំណត់បានច្បាស់លាស់អំពីតម្រូវការជំនាញ ចាំបាច់ត្រូវប្រមូលទិន្នន័យ និងព័ត៌មានផ្សេងៗទៀតរបស់បុគ្គលិកម្នាក់ៗ។ ការវិភាគអំពីតម្រូវការជំនាញនេះ គឺជាមូលដ្ឋានចម្បងក្នុងការវាយតម្លៃ និងកំណត់អំពីតម្រូវការអភិវឌ្ឍសមត្ថភាព និងការរៀបចំផែនការអភិវឌ្ឍសមត្ថភាពសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

ក្នុងអំឡុងពេលនៃការអនុវត្តកជទី១ ការវាយតម្លៃលើតម្រូវការនៃការអភិវឌ្ឍសមត្ថភាពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះបីយ៉ាងនេះក៏ដោយ នៅក្នុងកិច្ចដំណើរការជាក់ស្តែងនៃការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ភាគច្រើនពុំបានផ្តោតជាសំខាន់ទៅលើរបាយការណ៍តម្រូវការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗឡើយ ប៉ុន្តែនៅតែផ្អែកលើការបណ្តុះបណ្តាលតាមកម្មវត្ថុដែលកំណត់ដោយថ្នាក់ជាតិប៉ុណ្ណោះ។ ជាមួយគ្នានេះដែរ ការរៀបចំនូវរបាយការណ៍អំពីតម្រូវការនៃការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ពុំទាន់បានរៀបចំឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយផងដែរ។

អាស្រ័យហេតុនេះ កជទី២ ចាំបាច់ត្រូវពង្រឹង និងកំណត់ឱ្យបានច្បាស់លាស់អំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព និងការរៀបចំផែនការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដើម្បីឈានទៅរៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលជាក់លាក់ សំដៅធានាឱ្យបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាព ជំនាញ និងអាចបំពេញមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ លើសពីនេះទៀត សកម្មភាពអភិវឌ្ឍសមត្ថភាពសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានពង្រឹងនៅទាំងកម្រិតស្ថាប័ន និងបុគ្គលនីមួយៗ។

ដើម្បីជានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៦ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៤ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៣.៦.១៖ ការពិនិត្យ និងការកែសម្រួលនូវឧបករណ៍ និងវិធីសាស្ត្រនៃការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

សកម្មភាពនេះផ្តោតលើការពិនិត្យ កែសម្រួលឡើងវិញនូវឧបករណ៍ និងវិធីសាស្ត្រនៃការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពដែលមានបច្ចុប្បន្ន ដើម្បីកំណត់ឱ្យបានជាក់លាក់អំពីភាពខ្វះខាតនៃជំនាញ និងចំណេះដឹងរបស់បុគ្គលិក ដែលកំពុងបំពេញការងារនៅតាមអង្គភាពនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ អាស្រ័យហេតុនេះ រាល់លិខិតបទដ្ឋាន និងសេចក្តីណែនាំបច្ចេកទេសនានាពាក់ព័ន្ធនឹងការកំណត់អំពីឧបករណ៍ និងវិធីសាស្ត្រនៃការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព ចាំបាច់ត្រូវធ្វើការពិនិត្យ និងកែសម្រួលឡើងវិញឱ្យបានសមស្រប ព្រមទាំងដាក់ឱ្យអនុវត្តឱ្យបានពេញលេញ។

### សកម្មភាពអាទិភាព ៣.៦.២៖ ការពង្រឹងសមត្ថភាពដល់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្ត អំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព

សកម្មភាពនេះផ្តោតលើការអភិវឌ្ឍសមត្ថភាព និងការគាំទ្រដល់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្ត ក្នុងការអនុវត្តការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពសម្រាប់រៀបចំផែនការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានសមស្រប។ ការអភិវឌ្ឍសមត្ថភាពដល់អង្គភាពអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី ខេត្តត្រូវផ្តោតជាសំខាន់ទៅលើការប្រើប្រាស់ឧបករណ៍ និងវិធីសាស្ត្រសម្រាប់ការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព។

### សកម្មភាពអាទិភាព ៣.៦.៣៖ ការរៀបចំការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

សកម្មភាពនេះផ្តោតទៅលើការអនុវត្តការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវធ្វើឡើងជាទៀងទាត់ និងអាចពិនិត្យ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ។ អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្តនឹងទទួលខុសត្រូវក្នុងការអនុវត្តការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

រដ្ឋបាលរាជធានីត្រូវធ្វើការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី រដ្ឋបាលខណ្ឌ និងរដ្ឋបាលសង្កាត់ក្នុងរាជធានី។ រដ្ឋបាលខេត្តត្រូវធ្វើការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក និងរដ្ឋបាលឃុំ សង្កាត់ក្នុងដែនដីរបស់ខ្លួន។

### សកម្មភាពអាទិភាព ៣.៦.៤៖ ការរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកតាមតម្រូវការអភិវឌ្ឍសមត្ថភាព

សកម្មភាពនេះផ្តោតលើការរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ដោយផ្អែកទៅលើលទ្ធផលនៃការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាព។ ផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំត្រូវរៀបចំ និងអនុវត្តដោយឆ្លុះបញ្ចាំងពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិកទៅតាមលំដាប់អាទិភាព តាមដំណាក់កាលនីមួយៗ និងទៅតាមក្របខ័ណ្ឌពេលវេលាសម្រាប់រយៈពេលខ្លី មធ្យម ឬរយៈពេលវែង។ ផែនការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង ស្រុក ត្រូវមានការសម្របសម្រួលគ្នា និងបំពេញឱ្យគ្នាទៅវិញទៅមក បានសេចក្តីថា ផែនការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលខេត្តអាចមានវិសាលភាពគ្របដណ្តប់ទៅលើការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនលើប្រធានបទចាំបាច់មួយចំនួន ប៉ុន្តែផែនការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលខេត្តក៏មិនចាំបាច់លើកឡើងអំពីប្រធានបទមួយចំនួនដែលរដ្ឋបាលក្រុង ស្រុកអាចមានលទ្ធភាពអនុវត្តបានដោយខ្លួនឯង។ ផែនការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានីមានវិសាលភាពគ្របដណ្តប់ទៅលើរដ្ឋបាលខណ្ឌ និងសង្កាត់ក្នុងរាជធានី។ ផែនការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលក្រុងមានវិសាលភាពគ្របដណ្តប់ទៅលើរដ្ឋបាលសង្កាត់ក្នុងក្រុង។ ផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំត្រូវបានត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីរកឱ្យឃើញនូវចំណុចខ្វះខាតសម្រាប់កែលម្អផងដែរ។

### *លទ្ធផលរំពឹងទុក ៣.៧៖ ស្ថាប័នបណ្តុះបណ្តាលថ្នាក់ជាតិត្រូវបានពង្រឹងការអនុវត្តពេញលេញ និងស្ថាប័នបណ្តុះបណ្តាលថ្នាក់តំបន់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត*

ការអភិវឌ្ឍសមត្ថភាពដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាគោលបំណងដ៏ចម្បងនៃកជទី១ ក្នុងការធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានបុគ្គលិកប្រកបដោយសមត្ថភាព ជំនាញ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈនៅមូលដ្ឋាន។ ផ្អែកលើគោលបំណងនេះ សាលាជាតិរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៦។ ទោះបីយ៉ាងណាក៏ដោយ ការបង្កើតសាលាជាតិរដ្ឋបាលមូលដ្ឋាននេះមានគោលបំណងសំខាន់ចំនួនបី ពោលគឺ ១). ការធានាឱ្យមានប្រព័ន្ធអភិវឌ្ឍសមត្ថភាពជាអចិន្ត្រៃយ៍ ដោយមានកម្មវិធីសិក្សាជាក់លាក់សម្រាប់ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ សមាជិកក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ សិស្សនិស្សិតលើប្រធានបទនានាពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ២). ការបង្កើតជាមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវអំពីគោលនយោបាយនានា ដើម្បីជានាដល់ការចូលរួមចំណែកក្នុងការរៀបចំ និងកែលម្អគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងការធ្វើកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ព្រមទាំងសិក្សាស្រាវជ្រាវអំពីគំនិតផ្តួចផ្តើមថ្មីៗពាក់ព័ន្ធនឹងការ

ពង្រឹងប្រព័ន្ធអភិបាលកិច្ច ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវានានារបស់រដ្ឋបាលមូលដ្ឋាន និង ៣). ជាយន្តការមួយក្នុងការចូលរួមចំណែកផ្តល់វិញ្ញាបនបត្របញ្ជាក់ការសិក្សាដល់បុគ្គលិក។

ក្នុងដំណើរការអនុវត្ត ស្ថាប័នបណ្តុះបណ្តាលទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់តំបន់ចាំបាច់ត្រូវមានកិច្ចសហប្រតិបត្តិការបច្ចេកទេសជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈនិងឯកជន វិស័យឯកជន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាដើម្បីគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពទាក់ទងនឹងការរៀបចំកម្មវិធីបណ្តុះបណ្តាល ការរៀបចំសម្ភារៈបណ្តុះបណ្តាល និងការអនុវត្តការបណ្តុះបណ្តាល។ល។ ជាមួយគ្នានេះ សាលាជាតិរដ្ឋបាលមូលដ្ឋានក៏ត្រូវស្វែងរកការគាំទ្រ និងបង្កើតកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអន្តរជាតិនានាផងដែរ។

នាពេលអនាគត ទោះបីជាមានគោលការណ៍ជ្រើសរើសអ្នកជំនាញដែលបានទទួលការបណ្តុះបណ្តាល ដើម្បីគ្រប់គ្រងកិច្ចការរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន រួមទាំងការកសាងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិនិងអន្តរជាតិសំដៅប្រែក្លាយទៅជាស្ថាប័នមួយ ដែលមានវិជ្ជាជីវៈច្បាស់លាស់ក៏ដោយ ក៏សាលាជាតិរដ្ឋបាលមូលដ្ឋានអាចមានការលំបាក ក្នុងការធានានូវនិរន្តរភាពនៃដំណើរការបណ្តុះបណ្តាលរបស់ខ្លួន។ អាស្រ័យហេតុនេះ កជទី២ ត្រូវពិចារណាលើការផ្តល់លទ្ធភាពឱ្យសាលាជាតិរដ្ឋបាលមូលដ្ឋានអាចរកចំណូលនានាពីការផ្តល់សេវានានារបស់ខ្លួនដែលក្នុងនោះរួមមានដូចជា ការរៀបចំកម្មវិធីបណ្តុះបណ្តាលជាក់លាក់មួយចំនួនដោយមានការបង់កម្រៃ ការជួលទីតាំងសម្រាប់កិច្ចប្រជុំនានារបស់ក្រសួង ស្ថាប័ន ការផ្តល់សេវាទីប្រឹក្សា ឬការសិក្សាស្រាវជ្រាវជាក់លាក់ណាមួយ។ល។

សាលាជាតិរដ្ឋបាលមូលដ្ឋានមានបំណងបង្កើតប្រព័ន្ធអភិវឌ្ឍសមត្ថភាពអចិន្ត្រៃយ៍ ដើម្បីពង្រឹងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំ និងអនុវត្តការបណ្តុះបណ្តាលដោយផ្អែកលើតម្រូវការដោយប្រើប្រាស់សមត្ថភាព និងធនធានផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ បន្ថែមលើសាលាជាតិរដ្ឋបាលមូលដ្ឋាន កជទី២ នឹងពិចារណាលើការសិក្សារៀបចំបង្កើតយន្តការបណ្តុះបណ្តាលនៅថ្នាក់តំបន់ដែលយន្តការនេះស្ថិតក្រោមការគាំទ្រ និងការណែនាំពីសាលាជាតិរដ្ឋបាលមូលដ្ឋាន។ យន្តការនេះអាចមានវិសាលភាពគ្រប់ដណ្តប់លើសពីមួយខេត្តអាស្រ័យទៅតាមលទ្ធភាពជាក់ស្តែង ។

ដើម្បីជានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៧ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៥ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៣.៧.១៖ ការជ្រើសរើស និងការពង្រឹងសមត្ថភាពបុគ្គលិកនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន

បន្ទាប់ពីការបង្កើតសាលាជាតិរដ្ឋបាលមូលដ្ឋានក្នុងឆ្នាំ២០១៦ បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលបាន និងកំពុងសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់សាលាដោយមានការគាំទ្របច្ចេកទេស និងការផ្តល់ហិរញ្ញប្បទានកម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី។ ផ្អែកតាមផែនការយុទ្ធសាស្ត្ររយៈប្រាំឆ្នាំ (២០១៩-២០២៣) ស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅក្រសួងមហាផ្ទៃ និងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

សាលាជាតិរដ្ឋបាលមូលដ្ឋានបាននិងកំពុងរៀបចំវគ្គបណ្តុះបណ្តាលរបស់ខ្លួនជាបណ្តើរៗ ដោយប្រើប្រាស់ទីតាំងបណ្តុះបណ្តាលជាបណ្តោះអាសន្ននៅក្នុងក្រសួងមហាផ្ទៃ។ សាលាជាតិរដ្ឋបាលមូលដ្ឋាននឹងចាប់ផ្តើមដំណើរការពេញលេញក្រោយពេលដែលហេដ្ឋារចនាសម្ព័ន្ធអគាររបស់ខ្លួនត្រូវបានសាងសង់បញ្ចប់នៅឆ្នាំ២០២៣។ ជាមួយគ្នានេះ ថ្នាក់ដឹកនាំសាលា (នាយក និងនាយករងសាលា) ត្រូវបានតែងតាំងរួចហើយ ប៉ុន្តែមុខតំណែងផ្សេងៗនៃរចនាសម្ព័ន្ធរបស់សាលានៅមិនទាន់បានជ្រើសរើសនៅឡើយ។

ហេតុដូច្នេះ សកម្មភាពនេះត្រូវផ្តោតលើការជ្រើសរើសបុគ្គលិក ដើម្បីបំពេញមុខតំណែងដែលនៅទំនេរសម្រាប់បម្រើការងារនៅសាលាជាតិរដ្ឋបាលមូលដ្ឋាន។ ជាមួយគ្នានេះ សមត្ថភាពរបស់គ្រូបណ្តុះបណ្តាល និងបុគ្គលិកនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន ត្រូវបន្តពង្រឹងតាមរយៈការបណ្តុះបណ្តាលដោយផ្អែកតាមតម្រូវការ ដើម្បីឱ្យគ្រូបណ្តុះបណ្តាល និងបុគ្គលិកទាំងនេះអាចបំពេញមុខតំណែង និងអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងផ្តល់ការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាពដល់មន្ត្រីរាជការស៊ីវិលរបស់ក្រសួងមហាផ្ទៃ និងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

### សកម្មភាពអាទិភាព ៣.៧.២៖ កិច្ចសហការជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈនិងឯកជន និងស្ថាប័នពាក់ព័ន្ធនានាដើម្បីរៀបចំ និងអនុវត្តការបណ្តុះបណ្តាល

សកម្មភាពនេះ ត្រូវផ្តោតលើការពង្រឹងកិច្ចសហប្រតិបត្តិការបច្ចេកទេសរវាងសាលាជាតិរដ្ឋបាលមូលដ្ឋានជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន វិស័យឯកជន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា រួមទាំងអង្គការ ស្ថាប័នអន្តរជាតិល្បីៗ ដើម្បីធានាដល់ការគាំទ្រការអភិវឌ្ឍសមត្ថភាពជាពិសេសដល់សាលាជាតិរដ្ឋបាលមូលដ្ឋាន និងស្ថាប័នបណ្តុះបណ្តាលនៅថ្នាក់តំបន់ក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាល ការរៀបចំឯកសារសម្ភារៈ និងការផ្តល់ការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាព។ ការពង្រឹងកិច្ចសហការគ្នានេះអាចធ្វើឡើងតាមរយៈកិច្ចព្រមព្រៀង ឬអនុស្សារណៈនៃការយោគយល់គ្នាជាមួយអង្គការ ឬស្ថាប័នដែលមានវិជ្ជាជីវៈ ពិសេសជាមួយសាលាភូមិន្ទរដ្ឋបាល និងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### សកម្មភាពអាទិភាព ៣.៧.៣៖ ការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពសម្រាប់ក្រុមគោលដៅផ្សេងៗ

សកម្មភាពនេះត្រូវផ្តោតលើការរៀបចំនូវកម្មវិធីអភិវឌ្ឍសមត្ថភាពដែលជាយុទ្ធសាស្ត្រដ៏សំខាន់មួយនៃផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅក្រសួងមហាផ្ទៃ និងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (២០១៩-២០២៣)។ កម្មវិធីអភិវឌ្ឍសមត្ថភាពនេះ រួមមានកម្មវិធីបណ្តុះបណ្តាលជាកាតព្វកិច្ច និងសកម្មភាពអភិវឌ្ឍសមត្ថភាពដទៃទៀត។

កម្មវិធីបណ្តុះបណ្តាលជាកាតព្វកិច្ច ដូចជាវគ្គគ្រប់គ្រងកម្រិតខ្ពស់ វគ្គគ្រប់គ្រងកម្រិតទី១ វគ្គគ្រប់គ្រងកម្រិតទី២ វគ្គជំនាញ វគ្គជាមូលដ្ឋាន និងវគ្គលេខាធិការរដ្ឋបាលសម្រាប់បុគ្គលិកនៅក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងសម្រាប់សាធារណជននានា ដែលមានបំណងទទួលបាននូវ

ការបណ្តុះបណ្តាលពីសាលាជាតិរដ្ឋបាលមូលដ្ឋាន។ សកម្មភាពអភិវឌ្ឍសមត្ថភាពដទៃៗទៀត រួមមានដូចជាសិក្ខាសាលា ការចែករំលែកបទពិសោធន៍ ការហ្វឹកហ្វឺន។ល។ កម្មវិធីបណ្តុះបណ្តាលទាំងនេះចាំបាច់ត្រូវមានការត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំដោយក្រសួងមហាផ្ទៃ។ លើសពីនេះទៀត ដោយមានភាពជាដៃគូជាមួយសមាគមជាតិក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ សាលាជាតិរដ្ឋបាលមូលដ្ឋាននឹងរៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញដល់គ្រូបណ្តុះបណ្តាលនៃសមាគមជាតិក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងសមាជិកក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

ជាមួយគ្នានេះដែរ ក៏ចាំបាច់ត្រូវគិតគូរដល់ការរៀបចំអ្នកបន្តវេនសម្រាប់មុខតំណែងគ្រប់គ្រងតាមអង្គភាពនានាតាមរយៈការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពជាក់លាក់ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសចំពោះបុគ្គលិកដែលមានបទពិសោធន៍ការងារច្រើន ឬមានសក្តានុពលដែលអាចបន្តទទួលមុខតំណែងជាអ្នកដឹកនាំទៅអនាគត។

## សកម្មភាពអាទិភាព ៣.៧.៤៖ ការបង្កើតស្ថាប័នបណ្តុះបណ្តាលថ្នាក់តំបន់ និងការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពនៅថ្នាក់តំបន់

នៅក្នុង ផអ៥ទី១នៃកជទី២ ចាំបាច់ត្រូវរៀបចំការសិក្សាអំពីលទ្ធភាព និងជម្រើសនានានៃការរៀបចំបង្កើតស្ថាប័នបណ្តុះបណ្តាលនៅថ្នាក់តំបន់ ក្នុងដំណាក់កាលនៃផអ៥ទី២ដែលអាចធ្វើជាជំហានៗទៅតាមលទ្ធភាព និងធនធានដែលមាន ហើយស្ថាប័នបណ្តុះបណ្តាលនេះអាចមានវិសាលភាពគ្របដណ្តប់លើរាជធានី ខេត្តមួយចំនួន ដើម្បីជួយដល់សាលាជាតិរដ្ឋបាលមូលដ្ឋានក្នុងការបង្កើនល្បឿននៃការបណ្តុះបណ្តាល និងការដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងកង្វះខាតសមត្ថភាពជំនាញរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិបានឆាប់រហ័ស និងមានប្រសិទ្ធភាព។ ស្ថាប័នបណ្តុះបណ្តាលនៅថ្នាក់តំបន់នេះស្ថិតនៅក្រោមការគាំទ្រ និងការណែនាំពីសាលាជាតិរដ្ឋបាលមូលដ្ឋាន។

ជាមួយគ្នានេះដែរ ក៏ត្រូវផ្តោតទៅលើការរៀបចំ និងដាក់ឱ្យអនុវត្តនូវកម្មវិធីអភិវឌ្ឍសមត្ថភាពនៅថ្នាក់តំបន់ដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន ក្នុងពេលដែលយន្តការបណ្តុះបណ្តាលនៅថ្នាក់តំបន់មិនទាន់អាចមានលទ្ធភាពបង្កើតឡើង។ ក្នុងការរៀបចំ និងអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពថ្នាក់តំបន់នេះក៏ត្រូវសហការជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនានា ជាពិសេសជាមួយគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជននានាទាំងក្នុងការរៀបចំឯកសារសម្ភារៈបណ្តុះបណ្តាលនិងការផ្តល់ការបណ្តុះបណ្តាលនៅថ្នាក់តំបន់។

លើសពីនេះទៀត សកម្មភាពនេះក៏ត្រូវយកចិត្តទុកដាក់ទៅលើការបន្តសិក្សាវាយតម្លៃអំពីលទ្ធភាពក្នុងការដំឡើងការិយាល័យអភិវឌ្ឍន៍សមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្តបច្ចុប្បន្នទៅជាថ្នាក់ទីចាត់ការដើម្បីធានាដល់ការពង្រឹងសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្ត ក្នុងការទទួលខុសត្រូវដល់ការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ក្នុងដែនសមត្ថកិច្ចរបស់រាជធានី ខេត្តនីមួយៗ។

## សកម្មភាពអាទិភាព ៣.៧.៥៖ ការធានាផ្នែកហិរញ្ញវត្ថុសម្រាប់គាំទ្រដល់កិច្ចដំណើរការសាលាជាតិរដ្ឋបាលមូលដ្ឋាន

ការគ្រប់គ្រងរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន គឺអាស្រ័យទៅលើកត្តាជាច្រើន ដែលក្នុងនោះបញ្ហាហិរញ្ញវត្ថុ គឺជាកត្តាមួយដ៏សំខាន់ក្នុងការធានាដល់និរន្តរភាព និងប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការរបស់សាលា។ នៅក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន សាលាជាតិរដ្ឋបាលមូលដ្ឋានចាំបាច់ត្រូវរៀបចំឱ្យក្លាយជាស្ថាប័នបណ្តុះបណ្តាលមួយ ដែលមានប្រភពធនធានពីថវិកាជាតិដែលជាឧបសម្ព័ន្ធក្នុងកញ្ចប់ថវិការបស់ក្រសួងមហាផ្ទៃ ថវិកាដែលទទួលបានពីការបង់ថ្លៃបណ្តុះបណ្តាល និងពីប្រភពផ្សេងទៀត។

### *លទ្ធផលរំពឹងទុក ៣.៨៖ កម្មវិធីសិក្សាសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត*

ការរៀបចំកម្មវិធីសិក្សាត្រូវផ្តោតជាសំខាន់ទៅលើអ្វីដែលអ្នកសិក្សាត្រូវដឹង ដើម្បីអនុវត្តការងារឱ្យមានប្រសិទ្ធភាព។ កម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលនីមួយៗ គឺជាកញ្ចប់សកម្មភាពនៃការសិក្សាដែលត្រូវបានរៀបចំឡើងដើម្បីសម្រេចបាននូវគោលបំណងនានានៃកម្មវិធីបណ្តុះបណ្តាល។ កម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលណាមួយចាំបាច់ត្រូវរៀបចំឡើង ដោយត្រូវធានាថាសិក្ខាកាមនឹងទទួលបានចំណេះដឹង និងជំនាញជាក់លាក់ដែលជាតម្រូវការរបស់បុគ្គលិកទាំងនោះក្នុងការអនុវត្តនូវតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។ អាស្រ័យហេតុនេះ ការរៀបចំកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលនានាចាំបាច់ត្រូវផ្តោតជាសំខាន់ទៅលើការពិនិត្យកែលម្អខ្លឹមសារឯកសារ ព្រមទាំងការរៀបចំនូវរចនាសម្ព័ន្ធ បែបផែន ភាពលំដាប់លំដោយ និងវិធីសាស្ត្រនៃការបណ្តុះបណ្តាល។ បន្ថែមលើនេះទៀត កម្មវិធីបណ្តុះបណ្តាលនានា ចាំបាច់ត្រូវរួមមាននូវសំណុំឯកសារសម្ភារៈសម្រាប់ការបណ្តុះបណ្តាលមានលក្ខណៈល្អប្រសើរមួយ ដែលរួមមាននូវព័ត៌មានពាក់ព័ន្ធនានាដើម្បីសម្រេចបាននូវគោលបំណងនៃការសិក្សា។ ឯកសារសម្ភារៈសម្រាប់ការបណ្តុះបណ្តាល គឺជាស្នូលដ៏សំខាន់មួយនៃកម្មវិធីបណ្តុះបណ្តាលដែលត្រូវបានប្រើប្រាស់ ដើម្បីធានាដល់ប្រសិទ្ធភាពនៃការបណ្តុះបណ្តាល។

អាស្រ័យហេតុនេះ ក្នុងអំឡុងពេលអនុវត្តកជទី២ កិច្ចការសំខាន់ដែលត្រូវផ្តោតការយកចិត្តទុកដាក់គឺការរៀបចំ និងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាសម្រាប់គ្រប់កម្រិតនៃកម្មវិធីបណ្តុះបណ្តាល រួមបញ្ចូលទាំងកម្មវិធីបណ្តុះបណ្តាលដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃតម្រូវការបណ្តុះបណ្តាល។ កម្មវិធីសិក្សាត្រូវរៀបចំឡើងឱ្យបានច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយដែលជាទូទៅកម្មវិធីសិក្សានីមួយៗចាំបាច់ត្រូវកំណត់ឱ្យបានច្បាស់លាស់អំពីគោលបំណងនិងគោលដៅនៃកម្មវិធី លទ្ធផលរំពឹងទុក សិក្ខាកាមដែលត្រូវទទួលការបណ្តុះបណ្តាល អ្នកបណ្តុះបណ្តាល ខ្លឹមសារនៃមេរៀន ប្លង់មេរៀន វិធីសាស្ត្របង្រៀន រយៈពេល និងទីកន្លែង ការវាយតម្លៃលទ្ធផលនៃការសិក្សា និងឯកសារយោងនានា។ លើសពីនេះទៀត កិច្ចការជាអាទិភាពផ្សេងទៀត គឺការរៀបចំឯកសារសម្ភារបណ្តុះបណ្តាលនានាសម្រាប់បណ្តុះបណ្តាលដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព។ កម្មវិធីបណ្តុះបណ្តាលភាពជាអ្នកដឹកនាំរបស់ស្ត្រីសម្រាប់

ថ្នាក់ដឹកនាំស្ត្រីនៅថ្នាក់ក្រោមជាតិ និងកម្មវិធីវគ្គជាកាតព្វកិច្ច ស្តីពីសមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមសម្រាប់ថ្នាក់ដឹកនាំនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបញ្ចូល និងអនុវត្តនៅក្នុងកម្មវិធីសិក្សានេះ។

ដើម្បីជានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៨ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៣ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៣.៨.១៖ ការជ្រើសរើសស្ថាប័នអភិវឌ្ឍសមត្ថភាព ស្ថាប័នជំនាញវិជ្ជាជីវៈ និងអ្នកជំនាញវិជ្ជាជីវៈដើម្បីចូលរួមរៀបចំកម្មវិធីសិក្សា និងឯកសារសម្ភារបណ្តុះបណ្តាល

សកម្មភាពនេះផ្តោតលើការជ្រើសរើសស្ថាប័នអភិវឌ្ឍន៍សមត្ថភាព រួមទាំងស្ថាប័នជំនាញវិជ្ជាជីវៈ និងក្រុមអ្នកជំនាញផ្សេងៗគ្នាតាមរយៈការចុះកិច្ចព្រមព្រៀង ឬអនុស្សារណៈនៃការយោគយល់គ្នាជាមួយសាលាជាតិរដ្ឋបាលមូលដ្ឋាន ដើម្បីចូលរួមរៀបចំកម្មវិធីសិក្សា និងឯកសារសម្ភារបណ្តុះបណ្តាល។ សាលាជាតិរដ្ឋបាលមូលដ្ឋានមានតួនាទី និងភារកិច្ចដឹកនាំ សម្របសម្រួល និងអនុវត្តសកម្មភាពនេះ។

### សកម្មភាពអាទិភាព ៣.៨.២៖ ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលនានា

សកម្មភាពនេះផ្តោតលើការរៀបចំកម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលនានា ដែលស្ថិតក្រោមការដឹកនាំ និងសម្របសម្រួលរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន។ ក្នុងការរៀបចំកិច្ចការនេះ ចាំបាច់ត្រូវសិក្សាទៅលើលិខិតបទដ្ឋាន និងឯកសារពាក់ព័ន្ធនានា ដើម្បីជានាដល់ការកំណត់នូវប្រធានបទនានាដែលត្រូវដាក់បញ្ចូលក្នុងកម្មវិធីសិក្សានីមួយៗឱ្យស្របតាមកម្មវិធីបណ្តុះបណ្តាល។ កម្មវិធីសិក្សានានាដែលបានរៀបចំ អាចត្រូវបានពិនិត្យកែសម្រួល និងធ្វើបច្ចុប្បន្នភាពបន្ថែមទៀត ដើម្បីជានាឱ្យកម្មវិធីសិក្សានោះឆ្លើយតបទៅនឹងគោលបំណង និងតម្រូវការរបស់សិក្ខាកាម។

### សកម្មភាពអាទិភាព ៣.៨.៣៖ ការរៀបចំ ការពិនិត្យកែសម្រួល និងធ្វើបច្ចុប្បន្នភាពលើឯកសារសម្ភារបណ្តុះបណ្តាលសម្រាប់កម្មវិធីសិក្សានានា

ដើម្បីជានាដល់ប្រសិទ្ធភាពក្នុងការបណ្តុះបណ្តាលសិក្ខាកាមឱ្យមានជំនាញច្បាស់លាស់ ចាំបាច់ត្រូវយកចិត្តទុកដាក់ទៅលើការរៀបចំឱ្យមានឯកសារសម្ភារបណ្តុះបណ្តាលឱ្យបានគ្រប់គ្រាន់ ដែលឯកសារសម្ភារទាំងនោះត្រូវផ្តោតទៅលើខ្លឹមសារនានានៃវគ្គបណ្តុះបណ្តាលនីមួយៗ ដែលបានកំណត់នៅក្នុងកម្មវិធីអភិវឌ្ឍសមត្ថភាព។ អាស្រ័យហេតុនេះ កជទី២ ត្រូវជានាដល់ការរៀបចំនូវឯកសារសម្ភារបណ្តុះបណ្តាលដែលត្រូវរៀបចំឡើងដោយសាលាជាតិរដ្ឋបាលមូលដ្ឋានដោយផ្ទាល់ និងដោយស្ថាប័នជំនាញក្នុងការផ្តល់ការបណ្តុះបណ្តាលនានា ក៏ដូចជាអ្នកជំនាញការនានា ដែលជាទូទៅការរៀបចំឯកសារសម្ភារទាំងអស់នេះស្ថិតក្រោមការដឹកនាំ និងសម្រួលដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន។ ឯកសារសម្ភារបណ្តុះបណ្តាលសម្រាប់កម្មវិធីបណ្តុះបណ្តាលទាំងនេះ ចាំបាច់ត្រូវបានកែសម្រួល និងធ្វើបច្ចុប្បន្នភាពជាប្រចាំ។

### លទ្ធផលរំពឹងទុក ៣.៩៖ វិធីសាស្ត្របណ្តុះបណ្តាលជាក់លាក់មួយចំនួនត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត

វិធីសាស្ត្របណ្តុះបណ្តាល គឺជាមធ្យោបាយដែលត្រូវប្រើសម្រាប់បញ្ជូនខ្លឹមសារនៃការបណ្តុះបណ្តាល ដើម្បីជំរុញការសិក្សារៀនសូត្រ។ វិធីសាស្ត្របណ្តុះបណ្តាល និងសកម្មភាពសិក្សារៀនសូត្រត្រូវបង្កឱកាសឱ្យសិក្ខាកាមម្នាក់ៗ ចូលរួមយ៉ាងសកម្មក្នុងការផ្លាស់ប្តូរយោបល់ទៅលើខ្លឹមសារមេរៀនជាមួយគ្រូបណ្តុះបណ្តាល និងសិក្ខាកាមផ្សេងៗទៀត។ ជាមួយគ្នានេះ ដើម្បីធានាឱ្យមានប្រសិទ្ធភាពនៃការផ្ទេរខ្លឹមសារមេរៀនទៅឱ្យសិក្ខាកាម ចាំបាច់ត្រូវរៀបចំឱ្យមានការពិភាក្សា ដើម្បីលើកកម្ពស់នូវការទទួលបានព័ត៌មាននានា និងការយល់ដឹងកាន់តែច្រើនឡើង។ ការប្រាស្រ័យទាក់ទងជាមួយសិក្ខាកាម ឬការធ្វើលំហាត់នានានឹងផ្តល់នូវព័ត៌មានត្រលប់ទៅគ្រូបណ្តុះបណ្តាលអំពីកម្រិតយល់ដឹងរបស់សិក្ខាកាមលើខ្លឹមសារដែលបានរៀន។

ការសិក្សាដោយផ្តោតលើប្រធានបទជាក់លាក់ គឺជាវិធីសាស្ត្របង្រៀនដ៏មានឥទ្ធិពលមួយសម្រាប់ការបញ្ចូលនូវគំនិតផ្សេងៗគ្នាក្នុងកម្មវិធីសិក្សា ដែលពាក់ព័ន្ធនឹងសកម្មភាពជាឧទាហរណ៍ និងបទពិសោធន៍នៃការអនុវត្តជាក់ស្តែងប្រចាំថ្ងៃពាក់ព័ន្ធនឹងប្រធានបទនោះ ដើម្បីធានាដល់ការលើកកម្ពស់ការសិក្សា។ ការសិក្សាតាមបែបផែននេះនឹងផ្តល់នូវបទពិសោធន៍យ៉ាងទូលំទូលាយដល់សិក្ខាកាម និងជួយឱ្យសិក្ខាកាមអាចផ្សារភ្ជាប់ការសិក្សាទៅនឹងសកម្មភាពបំពេញការងារប្រចាំថ្ងៃរបស់ខ្លួន។

ស្របពេលជាមួយនឹងការវិវត្តនៃសេវាអ៊ិនធឺណែតកាន់តែល្អប្រសើរឡើង វិធីសាស្ត្របណ្តុះបណ្តាលក៏អាចធ្វើឡើងតាមរយៈការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច។ ការសិក្សាតាមបែបផែននេះជាវិធីសាស្ត្រមួយដែលធ្វើឱ្យចំណេញពេលវេលាសម្រាប់ការបណ្តុះបណ្តាល និងជំរុញលើកទឹកចិត្តដល់អ្នកសិក្សារៀនសូត្រឱ្យចូលរួមក្នុងសកម្មភាពសិក្សាបានច្រើនជាងមុន។ ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិចនេះត្រូវបានគេចាត់ទុកថាមធ្យោបាយមួយដែលមានអត្ថប្រយោជន៍ខ្ពស់ ដែលបង្កលទ្ធភាពឱ្យអ្នកសិក្សាពីទីកន្លែងផ្សេងៗគ្នាបានចូលរួមក្នុងសកម្មភាពសិក្សារៀនសូត្រក្នុងពេលតែមួយជាមួយគ្នា។ម្យ៉ាងវិញទៀត ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិចគឺជាបែបផែននៃសិក្សាមួយ ដែលជំរុញឱ្យសិក្ខាកាមបានចូលរួមកាន់តែច្រើនជាងការប្រមូលផ្តុំការសិក្សានៅក្នុងថ្នាក់ ដោយហេតុថាបែបផែននេះមានភាពបត់បែនយ៉ាងច្រើនសម្រាប់អ្នកសិក្សាទាំងក្នុងក្របខ័ណ្ឌនៃពេលវេលា និងទីកន្លែងផ្សេងៗគ្នា ដោយមិនចាំបាច់កំណត់ឱ្យមានពេលវេលាតែមួយក្នុងការសិក្សារួមគ្នានោះឡើយ។

កិច្ចការសំខាន់មួយទៀត គឺការបង្កលទ្ធភាពឱ្យគ្រូបង្រៀនក្នុងការប្រើប្រាស់នូវវិធីសាស្ត្រផ្សេងៗក្នុងការបណ្តុះបណ្តាល ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការបណ្តុះបណ្តាល។ បន្ថែមលើនេះទៀត ក៏ចាំបាច់ត្រូវបង្កបរិយាកាសអំណោយផលដល់សិក្ខាកាមក្នុងការអនុវត្តស្វ័យសិក្សាផងដែរ។

ដើម្បីធានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៩ ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៣ ដូចខាងក្រោម៖

## សកម្មភាពអាទិភាព ៣.៩.១៖ ការជ្រើសរើស និងការអនុម័តវិធីសាស្ត្រផ្សេងៗសម្រាប់វគ្គបណ្តុះបណ្តាលនានា

សកម្មភាពនេះផ្តោតលើការកំណត់ជ្រើសរើស និងការអនុម័តនូវវិធីសាស្ត្រផ្សេងៗគ្នាក្នុងការផ្តល់ការបណ្តុះបណ្តាលនានាឱ្យស្របតាមក្រុមសិក្ខាកាមគោលដៅ និងប្រធានបទជាក់លាក់នីមួយៗ។ អ្នករៀបចំកម្មវិធីសិក្សា និងគ្រូបណ្តុះបណ្តាល រួមទាំងសាលាជាតិរដ្ឋបាលមូលដ្ឋានត្រូវពិចារណាអំពីវិធីសាស្ត្រនៃការបណ្តុះបណ្តាលផ្សេងៗ ដូចជាការបណ្តុះបណ្តាលដែលដឹកនាំដោយគ្រូបណ្តុះបណ្តាលផ្ទាល់ ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច ការសម្តែងតួ ករណីសិក្សា ការហ្វឹកហ្វឺន ឬការអនុវត្តជាក់ស្តែងជាដើម។ វិធីសាស្ត្របណ្តុះបណ្តាលនឹងត្រូវបានពិនិត្យមើល និងសម្រេចឡើងវិញសម្រាប់ការបណ្តុះបណ្តាលដល់សិក្ខាកាម។ សាលាជាតិរដ្ឋបាលមូលដ្ឋាន នឹងទទួលខុសត្រូវក្នុងការដឹកនាំការរៀបចំវិធីសាស្ត្របណ្តុះបណ្តាល។

## សកម្មភាពអាទិភាព ៣.៩.២៖ ការលើកកម្ពស់ការបណ្តុះបណ្តាលតាមបណ្តុំវិស័យ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច

សកម្មភាពនេះត្រូវផ្តោតទៅលើការរៀបចំវគ្គបណ្តុះបណ្តាលតាមបណ្តុំវិស័យ។ តាមរយៈបែបផែនបណ្តុះបណ្តាលនេះ គ្រូបណ្តុះបណ្តាលត្រូវជ្រើសរើសយកប្រធានបទដែលមានលក្ខណៈបណ្តុំវិស័យមួយសម្រាប់បង្រៀនដោយដាក់បញ្ចូលនូវឧទាហរណ៍ និងបទពិសោធន៍នៃការអនុវត្តជាក់ស្តែងប្រចាំថ្ងៃពាក់ព័ន្ធនឹងប្រធានបទនោះ ព្រមទាំងរួមមាននូវព័ត៌មានផ្សេងៗ ដើម្បីបង្ហាញ ឬបរិយាយអំពីប្រធានបទដែលត្រូវពិភាក្សា។

សកម្មភាពនេះក៏នឹងផ្តោតទៅលើការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច។ ការសិក្សាតាមបែបផែននេះនឹងជួយសម្រួលដល់អ្នកចូលរួមក្នុងការទទួលបានខ្លឹមសារនៃការបណ្តុះបណ្តាលពីទីតាំងនៃអ្នកចូលរួមដែលអាចចំណេញថវិកា និងពេលវេលាសម្រាប់ការធ្វើដំណើរទៅទីកន្លែងបណ្តុះបណ្តាល និងការស្នាក់នៅ។ ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិចអាចរៀបចំឡើងតាមបែបផែនដូចជា ការសិក្សាដែលគ្រប់គ្រងដោយកម្មវិធីកុំព្យូទ័រ ការសិក្សាដែលមានជំនួយពីកម្មវិធីកុំព្យូទ័រ និងការសិក្សាតាមអនឡាញជាដើម។ ជាពិសេស ការសិក្សាតាមអនឡាញដែលមានកំណត់ពេលវេលាជាក់លាក់សម្រាប់សិក្សារួមគ្នាក្នុងការជជែក ពិភាក្សា និងការធ្វើសន្និសីទវីដេអូ ព្រមទាំងការសិក្សាតាមអនឡាញដែលសិក្ខាកាមនីមួយៗអាចចូលរៀនទៅតាមពេលវេលា និងទីតាំងខុសៗគ្នានឹងត្រូវបានប្រើប្រាស់យ៉ាងសមស្របក្នុងការផ្តល់ខ្លឹមសារនៃការបណ្តុះបណ្តាលដល់ក្រុមសិក្ខាកាមគោលដៅនីមួយៗ។ ការបណ្តុះបណ្តាលតាមបែបផែននៃការសិក្សាតាមប្រព័ន្ធកុំព្យូទ័រនឹងទទួលបានជោគជ័យ លុះត្រាតែសិក្ខាកាមមានចំណេះដឹងក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន។ ដូច្នេះ នៅក្នុងកជទី២នេះ បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនឹងទទួលបានយ៉ាងហោចណាស់នូវការបណ្តុះបណ្តាលវគ្គសិក្សាជាមូលដ្ឋាននៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

### សកម្មភាពអាទិភាព ៣.៩.៣៖ ការលើកទឹកចិត្តដល់ស្វ័យសិក្សា និងស្រាវជ្រាវ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការសិក្សា

សកម្មភាពនេះនឹងផ្តោតលើការរៀបចំ និងគាំទ្រដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តការស្រាវជ្រាវ និងការសិក្សាដោយខ្លួនឯងលើខ្លឹមសារបណ្តុះបណ្តាលផ្សេងៗនៃកម្មវិធីអភិវឌ្ឍន៍សមត្ថភាព។ ក្នុងន័យនេះ សាលាជាតិរដ្ឋបាលមូលដ្ឋានត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធចាំបាច់ (ទីកន្លែង បណ្ណាល័យ សម្ភារៈសិក្សា និងធនធានមនុស្ស) និងគាំទ្រដល់អ្នកចូលរួមតាមរយៈការណែនាំរបស់គ្រូបណ្តុះបណ្តាលក្នុងការអនុវត្តការ ស្រាវជ្រាវ និងការសិក្សាដោយខ្លួនឯង។

### *លទ្ធផលរំពឹងទុក ៣.១០៖ ក្របខ័ណ្ឌអភិវឌ្ឍជំនាញវិជ្ជាជីវៈពេញមួយអាជីពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត*

ការអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិគឺជាតម្រូវការចាំបាច់ដែលបុគ្គលិកម្នាក់ៗត្រូវការដើម្បីទទួលបានជោគជ័យនៅក្នុងអាជីពរបស់ខ្លួន។ តាមរយៈការអភិវឌ្ឍជំនាញវិជ្ជាជីវៈ បុគ្គលិកអាចរៀនសូត្រអំពីជំនាញដែលត្រូវការ ដើម្បីបង្កើន និងបន្ថែមសមត្ថភាពជំនាញរបស់ខ្លួន បង្កើនផលិតភាពការងារ ព្រមទាំងបង្កើនភាពជឿជាក់និងការទទួលខុសត្រូវក្នុងការបំពេញការងារឱ្យកាន់តែមានប្រសិទ្ធភាពក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ។ ក្របខ័ណ្ឌសម្រាប់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈត្រូវតែរៀបចំសម្រាប់បុគ្គលិកទាំងអស់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការផ្តល់ឱកាសសម្រាប់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈត្រូវរៀបចំឡើងឱ្យបានជាក់លាក់ មានប្រយោជន៍ និងមានតម្លៃសម្រាប់បុគ្គលិកក្នុងការបំពេញតួនាទី ភារកិច្ចរបស់ខ្លួន។ ក្របខ័ណ្ឌសម្រាប់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈនេះក៏នឹងបង្កើតឱកាសសម្រាប់ការសហការសិក្សារៀនសូត្រ ការលើកទឹកចិត្តដល់ការពិភាក្សា និងការជួយគ្នាទៅវិញទៅមកផងដែរ។ លើសពីនេះទៀត ឱកាសនៃការអភិវឌ្ឍជំនាញវិជ្ជាជីវៈនឹងត្រូវផ្តល់ដល់បុគ្គលិកនានា ដោយផ្អែកលើបុគ្គលិកម្នាក់ៗ។

នៅក្នុងអំឡុងពេលអនុវត្តកជទី២ ក្របខ័ណ្ឌអភិវឌ្ឍជំនាញវិជ្ជាជីវៈនឹងត្រូវរៀបចំឡើងដោយផ្តល់ការលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ លើការអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់ខ្លួនឱ្យបានជាប្រចាំ និងយូរអង្វែង។ ក្របខ័ណ្ឌអភិវឌ្ឍជំនាញវិជ្ជាជីវៈនេះនឹងជួយគាំទ្រដល់បុគ្គលិកក្នុងការគិតពិចារណាអំពីចំណេះដឹង និងបទពិសោធន៍បច្ចុប្បន្នរបស់ខ្លួន ព្រមទាំងការអភិវឌ្ឍសមត្ថភាព ដើម្បីតម្រង់ទិស និងរៀបចំផែនការសម្រាប់ការសិក្សារៀនសូត្របន្ថែមទៀតនាពេលខាងមុខ។ ការបន្តអភិវឌ្ឍជំនាញវិជ្ជាជីវៈអាចផ្តល់អត្ថប្រយោជន៍យ៉ាងធំធេងដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងជួយឱ្យបុគ្គលិកទាំងនោះចេះពង្រឹងចំណេះដឹង និងជំនាញផ្ទាល់ខ្លួនផងដែរ។

ក្រៅពីនេះ ក្របខ័ណ្ឌសម្រាប់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈពេញមួយអាជីពរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវផ្សារភ្ជាប់ជាមួយនឹងលិខិតបញ្ជាក់ការសិក្សា ការតម្លើងថ្នាក់ ឋានន្តរស័ក្តិ ឬមុខតំណែង។

ដើម្បីជានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី១០ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៣ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៣.១០.១៖ ការរៀបចំ និងការអនុម័តក្របខ័ណ្ឌអភិវឌ្ឍជំនាញវិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

សកម្មភាពនេះនឹងផ្តោតលើការវាយតម្លៃអំពីចំណេះដឹង ជំនាញវិជ្ជាជីវៈ និងបទពិសោធន៍ការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលមានបច្ចុប្បន្នធៀបជាមួយនឹងមុខតំណែង តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់បុគ្គលិកម្នាក់ៗ។ ផ្អែកលើលទ្ធផលនៃការវាយតម្លៃនេះ ត្រូវកំណត់អំពីតម្រូវការអភិវឌ្ឍជំនាញវិជ្ជាជីវៈបន្ថែម និងត្រូវរៀបចំ និងអនុម័តនូវក្របខ័ណ្ឌអភិវឌ្ឍវិជ្ជាជីវៈពេញមួយអាជីពសម្រាប់បុគ្គលិកនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### សកម្មភាពអាទិភាព ៣.១០.២៖ ការអភិវឌ្ឍជំនាញវិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

សកម្មភាពនេះនឹងផ្តោតលើការអភិវឌ្ឍជំនាញវិជ្ជាជីវៈសម្រាប់រយៈពេលយូរអង្វែងក្នុងអាជីពការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ ការចូលរួមក្នុងវគ្គបណ្តុះបណ្តាលនានា វិញ្ញាបនបត្របញ្ជាក់ការទទួលស្គាល់ និងកម្រិតនៃការសិក្សានានារបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានពិនិត្យមើលឡើងវិញជារៀងរាល់ឆ្នាំ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់បុគ្គលិកទាំងនោះ។

### សកម្មភាពអាទិភាព ៣.១០.៣៖ ការផ្សារភ្ជាប់ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ មុខតំណែងទៅនឹងការអភិវឌ្ឍជំនាញវិជ្ជាជីវៈ

សកម្មភាពនេះ ត្រូវផ្តោតលើការលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបន្តអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់ខ្លួន តាមរយៈការផ្សារភ្ជាប់គ្នាយ៉ាងត្រឹមត្រូវរវាងការអភិវឌ្ឍជំនាញវិជ្ជាជីវៈជាមួយនឹងលក្ខខណ្ឌនានានៃការតម្លើងថ្នាក់ ឋានន្តរស័ក្តិ ឬមុខតំណែងដល់បុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ ចាំបាច់ត្រូវរៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានចាំបាច់នានាដែលពាក់ព័ន្ធនឹងការផ្សារភ្ជាប់រវាងការអភិវឌ្ឍជំនាញវិជ្ជាជីវៈទៅនឹងការតម្លើងថ្នាក់ ឋានន្តរស័ក្តិ ឬមុខតំណែងដល់បុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

## តារាងទី ៥៖ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពនានាសម្រាប់សមាសភាគទី៣

<table>
<tr><td colspan="2">សមិទ្ធផលរំពឹងទុកនៃសមាសភាគទី៣៖ រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិជ្រើសរើស គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិករបស់ខ្លួនផ្អែកលើទំហំការងារ និងលទ្ធភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងមានបុគ្គលិកដែលប្រកបដោយឆន្ទៈម្ចាស់ការ ភក្ដីភាព និងមនសិការជំនាញវិជ្ជាជីវៈស្របតាមតួនាទី ភារកិច្ចទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងទទួលបានការអភិវឌ្ឍសមត្ថភាពនិងជំនាញវិជ្ជាជីវៈជាប្រចាំ។</td></tr>
<tr><td colspan="2">លទ្ធផលរំពឹងទុក ៣.១៖ អង្គមន្ត្រីរាជការស៊ីវិលត្រូវបានពិនិត្យ រៀបចំឡើងវិញ និងដាក់ឱ្យអនុវត្ត។</td></tr>
<tr><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</td><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</td></tr>
<tr><td>✓ ៣.១.១៖ ការពិនិត្យ និងកែសម្រួលអង្គមន្ត្រីរាជការ<br>✓ ៣.១.២៖ ការដាក់ឱ្យអនុវត្តនូវអង្គមន្ត្រីរាជការនានា</td><td>✓ ៣.១.២៖ ការដាក់ឱ្យអនុវត្តនូវអង្គមន្ត្រីរាជការនានា</td></tr>
<tr><td colspan="2">លទ្ធផលរំពឹងទុក ៣.២៖ ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។</td></tr>
<tr><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</td><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</td></tr>
<tr><td>✓ ៣.២.១៖ ការរៀបចំការពិពណ៌នាមុខតំណែងរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៣.២.២៖ ការពង្រឹងការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៣.២.៣៖ ការពង្រឹងការគ្រប់គ្រងវត្តមានបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៣.២.៤៖ ការរៀបចំក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៣.២.៥៖ ការលើកកម្ពស់ការតាមដាន និងការវាយតម្លៃលើការបំពេញការងារ<br>✓ ៣.២.៦៖ ការផ្តល់ការលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកតាមលទ្ធផលនៃការវាយតម្លៃការងារ</td><td>✓ ៣.២.៣៖ ការពង្រឹងការគ្រប់គ្រងវត្តមានបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៣.២.៤៖ ការរៀបចំក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៣.២.៥៖ ការលើកកម្ពស់ការតាមដាន និងការវាយតម្លៃលើការបំពេញការងារ<br>✓ ៣.២.៦៖ ការផ្តល់ការលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកតាមលទ្ធផលនៃការវាយតម្លៃការងារ</td></tr>
</table>

<table>
<tr><td colspan="2">លទ្ធផលរំពឹងទុក ៣.៣៖ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបុគ្គលិកត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។</td></tr>
<tr><th>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</th><th>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</th></tr>
<tr><td>✓ ៣.៣.១៖ ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ</td><td>✓ ៣.៣.១៖ ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ</td></tr>
<tr><td colspan="2">លទ្ធផលរំពឹងទុក ៣.៤៖ តម្រូវការធនធានមនុស្សទាំងចំនួនបុគ្គលិក និងទាំងជំនាញវិជ្ជាជីវៈត្រូវបានវាយតម្លៃ និងកំណត់ច្បាស់លាស់។</td></tr>
<tr><th>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</th><th>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</th></tr>
<tr><td>✓ ៣.៤.១៖ ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវសេចក្ដីណែនាំស្ដីពីការវាយតម្លៃអំពីតម្រូវការទាំងបរិមាណ និងវិជ្ជាជីវៈ<br>✓ ៣.៤.២៖ ការពង្រឹងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការបុគ្គលិក<br>✓ ៣.៤.៣៖ ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ</td><td>✓ ៣.៤.២៖ ការពង្រឹងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការបុគ្គលិក<br>✓ ៣.៤.៣៖ ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ</td></tr>
<tr><td colspan="2">លទ្ធផលរំពឹងទុក ៣.៥៖ គោលនយោបាយលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។</td></tr>
<tr><th>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</th><th>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</th></tr>
<tr><td>✓ ៣.៥.១៖ ការសិក្សាអំពីជម្រើសនានាសម្រាប់ផ្ដល់ការលើកទឹកចិត្តដល់បុគ្គលិកដែលបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៣.៥.២៖ ការរៀបចំ និងដាក់ឱ្យអនុវត្តនូវគោលនយោបាយ និងលិខិតបទដ្ឋាននានាស្ដីពីការផ្ដល់នូវការលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅតំបន់ជនបទ តំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក</td><td>✓ ៣.៥.២៖ ការរៀបចំ និងដាក់ឱ្យអនុវត្តនូវគោលនយោបាយ និងលិខិតបទដ្ឋាននានាស្ដីពីការផ្ដល់នូវការលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅតំបន់ជនបទ តំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក</td></tr>
</table>

<table>
<tr><td>✓ ៣.៥.៣៖ ការពិនិត្យមើលឡើងវិញនូវក្របខ័ណ្ឌ ឋានន្តរស័ក្តិសម្រាប់មុខតំណែងគ្រប់គ្រងនីមួយៗរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៣.៥.៤៖ លើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងមុខតំណែងគ្រប់គ្រង នៅរដ្ឋបាលថ្នាក់ក្រោមជាតិ</td><td>✓ ៣.៥.៣៖ ការពិនិត្យមើលឡើងវិញនូវក្របខ័ណ្ឌ ឋានន្តរស័ក្តិសម្រាប់មុខតំណែងគ្រប់គ្រងនីមួយៗរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៣.៥.៤៖ លើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងមុខតំណែងគ្រប់គ្រង នៅរដ្ឋបាលថ្នាក់ក្រោមជាតិ</td></tr>
<tr><td colspan="2">លទ្ធផលរំពឹងទុក ៣.៦៖ ការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាព និងការរៀបចំផែនការអភិវឌ្ឍសមត្ថភាពត្រូវបានពង្រឹង និងកំណត់យ៉ាងច្បាស់លាស់។</td></tr>
<tr><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</td><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</td></tr>
<tr><td>✓ ៣.៦.១៖ ការពិនិត្យ និងការកែសម្រួលនូវឧបករណ៍ និងវិធីសាស្ត្រនៃការ វាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៣.៦.២៖ ការពង្រឹងសមត្ថភាពដល់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានីខេត្ត អំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព<br>✓ ៣.៦.៣៖ ការរៀបចំការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៣.៦.៤៖ ការរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកតាមតម្រូវការអភិវឌ្ឍសមត្ថភាព</td><td>✓ ៣.៦.២៖ ការពង្រឹងសមត្ថភាពដល់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្ត អំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព<br>✓ ៣.៦.៣៖ ការរៀបចំការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៣.៦.៤៖ ការរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកតាមតម្រូវការអភិវឌ្ឍសមត្ថភាព</td></tr>
<tr><td colspan="2">លទ្ធផលរំពឹងទុក ៣.៧៖ ស្ថាប័នបណ្តុះបណ្តាលថ្នាក់ជាតិត្រូវបានពង្រឹងការអនុវត្តពេញលេញ និងស្ថាប័នបណ្តុះបណ្តាលថ្នាក់តំបន់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។</td></tr>
<tr><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</td><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</td></tr>
<tr><td>✓ ៣.៧.១៖ ការជ្រើសរើស និងការពង្រឹងសមត្ថភាពបុគ្គលិកនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន</td><td></td></tr>
</table>

| | |
|---|---|
| ✓ **៣.៧.២៖** កិច្ចសហការជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានបណ្ដុះបណ្ដាលសាធារណៈ និងឯកជន និងស្ថាប័នពាក់ព័ន្ធនានាដើម្បីរៀបចំ និងអនុវត្តការបណ្ដុះបណ្ដាល<br>✓ **៣.៧.៣៖** ការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពសម្រាប់ក្រុមគោលដៅផ្សេងៗ<br>✓ **៣.៧.៤៖** ការបង្កើតស្ថាប័នបណ្ដុះបណ្ដាលថ្នាក់តំបន់ និងការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពនៅថ្នាក់តំបន់<br>✓ **៣.៧.៥៖** ការធានាផ្នែកហិរញ្ញវត្ថុសម្រាប់គាំទ្រដល់កិច្ចដំណើរការសាលាជាតិរដ្ឋបាលមូលដ្ឋាន | ✓ **៣.៧.២៖** កិច្ចសហការជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានបណ្ដុះបណ្ដាលសាធារណៈនិងឯកជន និងស្ថាប័នពាក់ព័ន្ធនានាដើម្បីរៀបចំ និងអនុវត្តការបណ្ដុះបណ្ដាល<br>✓ **៣.៧.៣៖** ការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពសម្រាប់ក្រុមគោលដៅផ្សេងៗ<br>✓ **៣.៧.៤៖** ការបង្កើតស្ថាប័នបណ្ដុះបណ្ដាលថ្នាក់តំបន់ និងការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពនៅថ្នាក់តំបន់<br>✓ **៣.៧.៥៖** ការធានាផ្នែកហិរញ្ញវត្ថុសម្រាប់គាំទ្រដល់កិច្ចដំណើរការសាលាជាតិរដ្ឋបាលមូលដ្ឋាន |
| **លទ្ធផលរំពឹងទុក ៣.៨៖ កម្មវិធីសិក្សាសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។** | |
| **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១** | **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២** |
| ✓ **៣.៨.១៖** ការជ្រើសរើសស្ថាប័នអភិវឌ្ឍសមត្ថភាព ស្ថាប័នជំនាញវិជ្ជាជីវៈ និងអ្នកជំនាញវិជ្ជាជីវៈដើម្បីចូលរួមរៀបចំកម្មវិធីសិក្សា និងឯកសារសម្ភារបណ្ដុះបណ្ដាល<br>✓ **៣.៨.២៖** ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាសម្រាប់វគ្គបណ្ដុះបណ្ដាលនានា<br>✓ **៣.៨.៣៖** ការរៀបចំ ការពិនិត្យកែសម្រួល និងធ្វើបច្ចុប្បន្នភាពលើឯកសារសម្ភារបណ្ដុះបណ្ដាលសម្រាប់កម្មវិធីសិក្សានានា | ✓ **៣.៨.១៖** ការជ្រើសរើសស្ថាប័នអភិវឌ្ឍសមត្ថភាព ស្ថាប័នជំនាញវិជ្ជាជីវៈ និងអ្នកជំនាញវិជ្ជាជីវៈដើម្បីចូលរួមរៀបចំកម្មវិធីសិក្សា និងឯកសារសម្ភារបណ្ដុះបណ្ដាល<br>✓ **៣.៨.២៖** ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាសម្រាប់វគ្គបណ្ដុះបណ្ដាលនានា<br>✓ **៣.៨.៣៖** ការរៀបចំ ការពិនិត្យកែសម្រួល និងធ្វើបច្ចុប្បន្នភាពលើឯកសារសម្ភារបណ្ដុះបណ្ដាលសម្រាប់កម្មវិធីសិក្សានានា |

| លទ្ធផលរំពឹងទុក ៣.៩៖ វិធីសាស្ត្របណ្តុះបណ្តាលជាក់លាក់មួយចំនួនត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។ | |
|---|---|
| **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១** | **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២** |
| ✓ **៣.៩.១៖** ការជ្រើសរើស និងការអនុម័តវិធីសាស្ត្រផ្សេងៗសម្រាប់វគ្គបណ្តុះបណ្តាលនានា<br>✓ **៣.៩.២៖** ការលើកកម្ពស់ការបណ្តុះបណ្តាលតាមបណ្តុំវិស័យ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច<br>✓ **៣.៩.៣៖** ការលើកទឹកចិត្តដល់ស្វ័យសិក្សា និងស្រាវជ្រាវ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការសិក្សា | ✓ **៣.៩.១៖** ការជ្រើសរើស និងការអនុម័តវិធីសាស្ត្រផ្សេងៗសម្រាប់វគ្គបណ្តុះបណ្តាលនានា<br>✓ **៣.៩.២៖** ការលើកកម្ពស់ការបណ្តុះបណ្តាលតាមបណ្តុំវិស័យ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច<br>✓ **៣.៩.៣៖** ការលើកទឹកចិត្តដល់ស្វ័យសិក្សា និងស្រាវជ្រាវ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការសិក្សា |
| **លទ្ធផលរំពឹងទុក ៣.១០៖ ក្របខ័ណ្ឌអភិវឌ្ឍជំនាញវិជ្ជាជីវៈពេញមួយអាជីពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | |
| **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១** | **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២** |
| ✓ **៣.១០.១៖** ការរៀបចំ និងការអនុម័តក្របខ័ណ្ឌអភិវឌ្ឍជំនាញវិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ **៣.១០.២៖** ការអភិវឌ្ឍជំនាញវិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ **៣.១០.៣៖** ការផ្សារភ្ជាប់ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ មុខតំណែង ទៅនឹងការអភិវឌ្ឍជំនាញវិជ្ជាជីវៈ | ✓ **៣.១០.២៖** ការអភិវឌ្ឍជំនាញវិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ **៣.១០.៣៖** ការផ្សារភ្ជាប់ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ មុខតំណែង ទៅនឹងការអភិវឌ្ឍជំនាញវិជ្ជាជីវៈ |

## តារាងទី ៦៖ ការគ្រប់គ្រងហានិភ័យសំខាន់ៗសម្រាប់សមាសភាគទី៣

| ល.រ | ហានិភ័យ | ផលប៉ះពាល់ | លទ្ធភាពកើតមាន | វិធានការកាត់បន្ថយ |
|---|---|---|---|---|
| ១ | សិទ្ធិអំណាចក្នុងការជ្រើសរើស និងរៀបចំបុគ្គលិកមិនអាចអនុវត្តបានតាមគោលការណ៍ បទបញ្ញត្តិដែលបានកំណត់ | មធ្យម | មធ្យម | - ការរៀបចំសេចក្តីណែនាំបន្ថែមរបស់ថ្នាក់ជាតិ ដើម្បីពង្រឹងការអនុវត្តគោលការណ៍ និងបទបញ្ញត្តិដែលបានកំណត់រួចហើយ<br>- ការពង្រឹងការតាមដាន ការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស និងរៀបចំបុគ្គលិក |
| ២ | សមភាពយេនឌ័រនៃមន្ត្រីក្នុងមុខតំណែងគ្រប់គ្រង និងមន្ត្រីដែលត្រូវជ្រើសរើសថ្មីមានចំនួនតិចជាងផែនការដែលបានកំណត់ | មធ្យម | មធ្យម | - ការបន្តពង្រឹងវគ្គបំប៉នសមត្ថភាពគ្រប់គ្រងដល់បុគ្គលិកជាស្ត្រីគោលដៅដើម្បីក្លាយខ្លួនជាអ្នកដឹកនាំ<br>- ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីព័ត៌មាននៃការជ្រើសរើស ព្រមទាំងមានការលើកទឹកចិត្ត និងផ្តល់អាទិភាពដល់បេក្ខជនជាស្ត្រីក្នុងការជ្រើសរើសបុគ្គលិកថ្មី |
| ៣ | ការវាយតម្លៃបុគ្គលិកមិនត្រូវបានអនុវត្តទៀងទាត់ និងត្រឹមត្រូវ | ខ្ពស់ | មធ្យម | - ពង្រឹងការគាំទ្រ ការតាមដានត្រួតពិនិត្យការអនុវត្តផែនការវាយតម្លៃបុគ្គលិកទាំងក្នុងក្របខ័ណ្ឌផ្ទៃក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ និងពីថ្នាក់ជាតិ |
| ៤ | ការវាយតម្លៃអំពីតម្រូវការបណ្តុះបណ្តាល និងការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពពុំមានគុណភាព | មធ្យម | មធ្យម | - ពង្រឹងការគាំទ្រ ការតាមដានត្រួតពិនិត្យរបស់ថ្នាក់ជាតិទៅលើការវាយតម្លៃអំពីតម្រូវការបណ្តុះបណ្តាល និងការរៀបចំនិងអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៥ | សាលាជាតិរដ្ឋបាលមូលដ្ឋានពុំអាចជ្រើសរើសបាននូវបុគ្គលិកដែលមានសមត្ថភាព និងបទពិសោធន៍ក្នុងការគ្រប់គ្រង ការរៀបចំកម្មវិធីសិក្សា និងការបណ្តុះបណ្តាល | ខ្ពស់ | មធ្យម | - ផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីព័ត៌មាននៃការជ្រើសរើស និងលើកទឹកចិត្តបេក្ខជននានាឱ្យដាក់ពាក្យបម្រើការងារនៅសាលាជាតិរដ្ឋបាលមូលដ្ឋាន |

| | | | | |
|---|---|---|---|---|
| | | | | - ការរៀបចំប្រព័ន្ធលើកទឹកចិត្តដល់បុគ្គលិករបស់សាលា ដាពិសេសបុគ្គលិកដែលមានសមត្ថភាព ជំនាញ និងបទពិសោធន៍ ក្នុងការបណ្តុះបណ្តាល និងការរៀបចំកម្មវិធីសិក្សា |
| ៦ | សាលាជាតិរដ្ឋបាលមូលដ្ឋានពុំមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ក្នុងកិច្ចដំណើរការរបស់ខ្លួន | ខ្ពស់ | មធ្យម | - ថវិកាចំណាយរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន នឹងត្រូវបានផ្តល់គ្រប់ចំនួនតាមគម្រោងថវិកាប្រចាំឆ្នាំ<br>- កៀរគរធនធានពីដៃគូ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវជានាដល់ការរៀបចំកញ្ចប់ថវិកាសម្រាប់ការអភិវឌ្ឍសមត្ថភាពនៅក្នុងផែនការថវិការបស់ខ្លួនឱ្យបានដាក់លាក់ ដើម្បីធានាដល់ការបង់កម្រៃសម្រាប់ការបញ្ជូនបុគ្គលិករបស់ខ្លួនមកសិក្សានៅសាលាជាតិរដ្ឋបាលមូលដ្ឋាន |

## ៣.៤. សមាសភាគទី៤៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

### ៣.៤.១. សនិទានភាព

ការរៀបចំឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ មានលទ្ធភាពទទួលបាននូវធនធានហិរញ្ញវត្ថុពីប្រភពនានាក្នុងទំហំសមស្របទៅនឹងកាតព្វកិច្ចចំណាយរបស់ខ្លួនទាំងបរិមាណ និងប្រភេទចំណាយ គឺជាកត្តាមួយក្នុងចំណោមកត្តាដ៏សំខាន់នានាដែលរួមចំណែកដល់ការសម្រេចបាននូវចក្ខុវិស័យរួមនៃ កជទី២។ សមាសភាគនេះរួមមានពីរផ្នែកសំខាន់ៗ ពោលគឺទីមួយ៖ ការបន្តលើកកម្ពស់វិមជ្ឈការហិរញ្ញវត្ថុ និងទីពីរ៖ ការកែលម្អប្រព័ន្ធកសាងផែនការ និងប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ផ្នែកទាំងពីរនេះមានទំនាក់ទំនងគ្នាទៅវិញទៅមកយ៉ាងជិតស្និទ្ធ ប៉ុន្តែអាចញែកដាច់ដោយឡែកពីគ្នាតាមបែបផែនការងារដូចខាងក្រោម៖

- ការធ្វើវិមជ្ឈការហិរញ្ញវត្ថុសំដៅទៅលើការផ្ទេរធនធានពីថ្នាក់ជាតិ និងការពង្រឹងប្រសិទ្ធភាពការប្រមូលចំណូលនៅមូលដ្ឋាន ព្រមទាំងការកំណត់នូវសិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងធនធានទាំងនោះ ដោយធានាឱ្យមានសង្គតិភាពកម្រិតគោលការណ៍ និងអភិក្រមនៃការគ្រប់គ្រងថវិការដ្ឋ ព្រមទាំងគោលការណ៍នៃវិមជ្ឈការ
- ការកែលម្អប្រព័ន្ធកសាងផែនការ និងប្រព័ន្ធថវិកាសំដៅលើការធានាឱ្យមានប្រសិទ្ធភាព គណនេយ្យភាព តម្លាភាព និងសមធម៌នៅក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានទាំងនោះ។

សមាសភាគទី៤មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសមាសភាគផ្សេងៗទៀត ព្រមទាំងកិច្ចការអន្តរវិស័យនានានៃ កជទី២។ ក្នុងន័យនេះ ការរៀបចំតាក់តែង និងការអនុវត្តសមាសភាគនេះត្រូវធ្វើឡើងឱ្យស្របទៅនឹងយន្តការ និងកិច្ចដំណើរការនៃការគ្រប់គ្រងការងារកំណែទម្រង់ទាំងមូល និងត្រូវឆ្លុះបញ្ចាំងទៅនឹងរចនាសម្ព័ន្ធ មុខងារ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ព្រមទាំងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការបន្តលើកកម្ពស់វិមជ្ឈការហិរញ្ញវត្ថុ និងការកែលម្អប្រព័ន្ធកសាងផែនការ និងប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ត្រូវផ្សារភ្ជាប់ទៅនឹងការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ព្រមទាំងការបញ្ជ្រាបភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា។

ការរៀបចំតាក់តែង និងការគ្រប់គ្រងកិច្ចដំណើរការវិមជ្ឈការហិរញ្ញវត្ថុ និងកំណែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់រយៈពេល១០ឆ្នាំទៅមុខ ត្រូវផ្អែកលើចក្ខុវិស័យមួយដ៏ច្បាស់លាស់ និងការគិតគូរពិចារណា ដែលមានលក្ខណៈជាយុទ្ធសាស្ត្រសម្រាប់ធានាដល់ការសម្រេចបាននូវចក្ខុវិស័យនេះ។ ជាមួយគ្នានេះដែរ កិច្ចការទាំងនេះត្រូវរៀបចំឱ្យមានសង្គតិភាពជាមួយសមិទ្ធផលរំពឹងទុកនានានៃ កជទី២ និងត្រូវផ្អែកលើគោលការណ៍ជាគន្លឹះនានានៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (ឧទាហរណ៍ គោលការណ៍សាប់ស៊ីឌៀរីធី គោលការណ៍ម្ចាស់ការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ)។ ម៉្យាងវិញទៀត កំណែ

ទម្រង់នេះក៏ត្រូវមានភាពប្រាកដប្រជាផងដែរដោយពឹងផ្អែកលើមូលដ្ឋានជាក់ស្តែងនៃសមិទ្ធផលដែលសម្រេចបាននាពេលកន្លងមក។ ទន្ទឹមនឹងនេះ បញ្ហាប្រឈមដែលនៅសេសសល់ និងវិបត្តិនានា បានបង្កឱ្យមានភាពមិនប្រាកដប្រជាទៅថ្ងៃអនាគតអំពីផលវិបាកផ្នែកធនធានហិរញ្ញវត្ថុ (ជាពិសេសការដោះស្រាយនូវវិបត្តិសេដ្ឋកិច្ច និងសង្គមកិច្ចក្នុងអំឡុងពេល និងក្រោយនៃពេលការរីករាលដាលនៃជំងឺកូវីដ-១៩)។

បញ្ហាប្រឈមសំខាន់ៗដែលត្រូវដោះស្រាយដោយសមាសភាគទី៤ នេះ រួមមាន៖

- ធនធានថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ពីគ្រប់ប្រភព) នាបច្ចុប្បន្ន នៅមិនទាន់សមស្របសម្រាប់ការចំណាយលើការអនុវត្តមុខងារនានារបស់ខ្លួន ជាពិសេសនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងពេលដែលរចនាសម្ព័ន្ធ និងប្រព័ន្ធថ្មីត្រូវបានរៀបចំ និងបានដាក់ឱ្យដំណើរការ ហើយក៏មានមុខងារថ្មីៗជាច្រើនត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលទាំងនេះផងដែរ
- ការវិភាជធនធានដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ នៅពុំទាន់ឆ្លើយតបទៅនឹងមុខងារ និងការទទួលខុសត្រូវផ្សេងៗគ្នានៃថ្នាក់រដ្ឋបាលនីមួយៗ (ថ្នាក់រាជធានី ខេត្ត ថ្នាក់ក្រុង ស្រុក និងថ្នាក់ឃុំ សង្កាត់) និងពុំទាន់មានសមធម៌ និងផ្អែកលើតម្រូវការពិតប្រាកដរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានប្រភេទដូចគ្នា (រវាងខេត្ត និងខេត្ត រវាងក្រុង ស្រុក និងក្រុង ស្រុក ព្រមទាំងរវាងឃុំ សង្កាត់ និងឃុំ សង្កាត់)
- បច្ចុប្បន្ននេះ ថវិការដ្ឋបាលរាជធានី ខេត្តមួយចំណែកធំមានប្រភពពីចំណូលផ្ទាល់នៅមូលដ្ឋាន (ចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ) និងមួយចំណែកទៀតទទួលបានការផ្ទេរថវិកាពីថ្នាក់ជាតិ។ រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ទទួលបានការផ្ទេរថវិកាពីថ្នាក់ជាតិ និងការបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្ត។ ទោះបីជាយ៉ាងនេះក្តី នាពេលខាងមុខ ត្រូវបន្តផ្តោតការយកចិត្តទុកលើការពិនិត្យមើលឡើងវិញក្នុងការបង្កើនធនធានហិរញ្ញវត្ថុបន្ថែមដល់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការបង្កើនប្រភពចំណូលមូលដ្ឋានដែលបានមកពីចំណូលមិនមែនសារពើពន្ធ និងការពិចារណាក្នុងការបង្កើនអត្រាចែករំលែកចំណូលសារពើពន្ធ និងលទ្ធភាពបន្ថែមប្រភេទពន្ធថ្មីៗបន្ថែមទៀត
- កិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់មានភាពប្រទាក់ក្រឡាគ្នានៅឡើយ ដែលចាំបាច់ត្រូវកែលម្អដើម្បីឱ្យប្រព័ន្ធទាំងនេះមានភាពប្រទាក់ក្រឡាគ្នាយ៉ាងពេញលេញ ព្រមទាំងមានលក្ខណៈសមស្របទៅនឹងរចនាសម្ព័ន្ធ និងមុខងាររបស់ថ្នាក់និងប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ
- រដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់ទទួលបានសិទ្ធអំណាច និងការទទួលខុសត្រូវពេញលេញក្នុងកិច្ចដំណើរការរៀបចំផែនការ និងការអនុវត្តថវិការបស់ខ្លួន។ សិទ្ធិអំណាចរបស់ក្រុម

ប្រឹក្សាក្នុងការធ្វើសេចក្តីសម្រេចលើផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងគម្រោងថវិកានៅមិនទាន់មានប្រសិទ្ធភាពនៅឡើយ

- បែបផែនសម្រាប់ផ្តល់ហិរញ្ញប្បទានដល់គម្រោងវិនិយោគសាធារណៈ ដែលគ្រប់គ្រងដោយរដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់មានការកំណត់ជាក្របខ័ណ្ឌច្បាស់លាស់មួយនៅឡើយ
- ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងប្រព័ន្ធសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិទៅលើការអនុវត្តថវិកា នៅពុំទាន់ត្រូវបានបង្កើតឱ្យបានពេញលេញ និងអនុវត្តប្រកបដោយប្រសិទ្ធភាពនៅឡើយ។

### ៣.៤.២. និន្នាការនានៃសមាសភាគទីបួន

#### ៣.៤.២.១. សមិទ្ធផលរំពឹងទុក

សមិទ្ធផលរំពឹងទុកនៃសមាសភាគនេះគឺ *"រដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានថវិកាដែលអាចព្យាករណ៍បាន និងមានទំហំសមស្របទៅនឹងមុខងារ និងអាទិភាពគោលនយោបាយជាតិ ហើយត្រូវបានវិភាជសម្រាប់ការប្រើប្រាស់ប្រកបដោយភាពបត់បែនក្នុងការឆ្លើយតបទៅនឹងតម្រូវការនានាដូចមានកំណត់នៅក្នុងផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ"*។

#### ៣.៤.២.២. យុទ្ធសាស្ត្រដើម្បីសម្រេចសមិទ្ធផលរំពឹងទុក

សមាសភាគទី៤នេះ ត្រូវអនុវត្តដោយមានកិច្ចសហការ និងការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយនឹងកម្មវិធីកំណែទម្រង់ និងក្រសួង ស្ថាប័នអនុវត្តនានា ជាពិសេសជាមួយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រសួងផែនការ។ អាស្រ័យហេតុនេះ សមាសភាគនេះចាំបាច់ត្រូវផ្តោតលើការពិនិត្យ និងការកែសម្រួលកិច្ចដំណើរការនៃការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមរចនាសម្ព័ន្ធ ប្រព័ន្ធ និងមុខងារថ្មីៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការបន្សីុគ្នារវាងកិច្ចដំណើរការរៀបចំផែនការយុទ្ធសាស្ត្រថវិកាជាមួយកម្មវិធីវិនិយោគបីឆ្នាំរំកិលផ្អែកលើទិន្នន័យ និងព័ត៌មានច្បាស់លាស់អំពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងអំពីធនធានហិរញ្ញវត្ថុដែលអាចព្យាករណ៍បាន។

ជាមួយគ្នានេះដែរ សមាសភាគទី៤ត្រូវបន្តផ្តោតការយកចិត្តទុកលើការពិនិត្យមើលឡើងវិញ និងការបង្កើនធនធានហិរញ្ញវត្ថុដល់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការបង្កើនប្រភពចំណូលមូលដ្ឋានដែលបានមកពីចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការពិចារណាក្នុងការបង្កើនអត្រាចែករំលែកចំណូលសារពើពន្ធ និងលទ្ធភាពបន្ថែមប្រភេទពន្ធថ្មីៗបន្ថែមទៀត និងការផ្ទេរធនធានគ្មានភ្ជាប់លក្ខខណ្ឌ និងធនធានមានភ្ជាប់លក្ខខណ្ឌ និងតាមរយៈការបង្កើតនូវយន្តការផ្ទេរធនធានហិរញ្ញវត្ថុបន្ថែមទៀតដូចជា ការបង្កើតមូលនិធិភាតរភាពសំដៅកាត់បន្ថយគម្លាតនៃការអភិវឌ្ឍរវាងតំបន់ទីប្រជុំជន

និងតំបន់ជនបទ ព្រមទាំងកញ្ចប់ថវិកាពិសេសសម្រាប់ជួយគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសក្តានុពលតិចតួច។

តាមរយៈ ការបង្កើនធនធានហិរញ្ញវត្ថុដល់រដ្ឋបាលថ្នាក់ក្រោមជាតិ កជទី២ ក៏ត្រូវបន្តពង្រឹងការអនុវត្តសវនកម្ម និងការអធិការកិច្ចលើការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថា ធនធាន និងទ្រព្យសម្បត្តិទាំងនោះត្រូវបានចាត់ចែង និងប្រើប្រាស់ស្របតាមនីតិវិធីដែលបានកំណត់ និងប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

ជាមួយគ្នានេះដែរ កជទី២ ក៏ត្រូវពង្រឹងការយកចិត្តទុកដាក់លើការរៀបចំ និងការដាក់ឱ្យអនុវត្តនូវគោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តនានា ដែលពាក់ព័ន្ធនឹងការលើកកម្ពស់ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការវិនិយោគក្នុងភាពជាដៃគូជាមួយវិស័យឯកជន និងអង្គការសង្គមស៊ីវិលនានា។

### ៣.៩.២.៣. លទ្ធផលរំពឹងទុក

សមិទ្ធផលនៃសមាសភាគទី៤នេះនឹងត្រូវបានសម្រេច តាមរយៈលទ្ធផលរំពឹងទុកជាយុទ្ធសាស្ត្រចំនួន១០ ដែលត្រូវអនុវត្តក្នុងអំឡុងពេលនៃកជទី២ ដូចខាងក្រោម ៖

- **លទ្ធផលរំពឹងទុកទី១** ៖ កិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អ និងបន្ស៊ីគ្នា ដោយផ្អែកលើចរិតលក្ខណៈ នៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗឱ្យស្របជាមួយនឹងគោលនយោបាយជាអាទិភាពថ្នាក់ជាតិ និងទិសដៅនៃកម្មវិធីកំណែទម្រង់សំខាន់ៗ និងផ្អែកលើទិន្នន័យច្បាស់លាស់
- **លទ្ធផលរំពឹងទុកទី២** ៖ ការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អដោយផ្តល់សិទ្ធិអំណាចកាន់តែច្រើនឡើងទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមទិសដៅនៃយុទ្ធសាស្ត្រកែទម្រង់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- **លទ្ធផលរំពឹងទុកទី៣** ៖ ការបង្កើនប្រភពចំណូលមូលដ្ឋានជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានមកពីចំណូលសារពើពន្ធត្រូវបានសិក្សា និងដាក់ឱ្យអនុវត្ត
- **លទ្ធផលរំពឹងទុកទី៤** ៖ ការបង្កើនប្រភពចំណូលមូលដ្ឋានជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានមកពីចំណូលមិនមែនសារពើពន្ធត្រូវបានសិក្សា និងដាក់ឱ្យអនុវត្ត
- **លទ្ធផលរំពឹងទុកទី៥** ៖ ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្ទេរទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលាស្របតាមផែនការច្បាស់លាស់

- **លទ្ធផលរំពឹងទុកទី៦** ៖ មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌត្រូវបានកំណត់ទំហំដែលមានលក្ខណៈសមស្រប និងត្រូវបានវិភាជទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗតាមរូបមន្ត និងលក្ខណៈវិនិច្ឆ័យប្រកបដោយសមធម៌ ព្រមទាំងត្រូវបានបង្កើនទំហំជាបន្តបន្ទាប់ ដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (ជាពិសេសថ្នាក់ក្រុង ស្រុក) ក្នុងការអនុវត្តមុខងារជាជម្រើស ឬមុខងារជាអាណត្តិទូទៅ
- **លទ្ធផលរំពឹងទុកទី៧** ៖ មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌត្រូវបានកំណត់នូវទំហំ ដែលមានលក្ខណៈសមស្រប និងត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ក្នុងការអនុវត្តមុខងារជាកាតព្វកិច្ចនានា ដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- **លទ្ធផលរំពឹងទុកទី៨** ៖ ក្របខ័ណ្ឌសម្រាប់ផ្ដល់ហិរញ្ញប្បទានការវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដ៏ច្បាស់លាស់មួយត្រូវបានបង្កើត និងពង្រឹងការអនុវត្ត
- **លទ្ធផលរំពឹងទុកទី៩** ៖ ក្របខ័ណ្ឌសម្រាប់ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងវិស័យឯកជនត្រូវបានបង្កើតឡើង និងដាក់ឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាព
- **លទ្ធផលរំពឹងទុកទី១០**៖ ប្រព័ន្ធសវនកម្ម និងអធិការកិច្ចលើការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង។

### ៣.៤.២.៤. យុទ្ធសាស្ត្រ និងសកម្មភាពជាអាទិភាពសម្រាប់អនុវត្តលទ្ធផលរំពឹងទុកនានា

*លទ្ធផលរំពឹងទុក ៤.១៖ កិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អ និងបន្សុីគ្នា ផ្អែកលើចរិតលក្ខណៈនិងប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ស្របជាមួយគោលនយោបាយអាទិភាពថ្នាក់ជាតិ និងទិសដៅនៃកម្មវិធីកំណែទម្រង់សំខាន់ៗ និងផ្អែកលើទិន្នន័យច្បាស់លាស់*

នៅក្នុងអំឡុងពេលនៃការអនុវត្ត កជទី២ កិច្ចដំណើរការកសាងផែនការ និងការរៀបចំថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើទំនើបកម្ម និងផ្សារភ្ជាប់គ្នាសំដៅធានាដល់ការបង្កើតនូវប្រព័ន្ធមួយដែលមានលក្ខណៈសមាហរណកម្មគ្នាមួយ ដើម្បី៖

- ធានា និងសម្របសម្រួលដល់ការចូលរួមយ៉ាងទូលំទូលាយរបស់ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល និងវិស័យឯកជននៅក្នុងកិច្ចដំណើរការកសាងផែនការ និងការកំណត់អំពីអាទិភាពនានាសម្រាប់ការប្រើប្រាស់ថវិកាធន្ទានុសិទ្ធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បន្តការផ្ដល់សិទ្ធិអំណាច និងការទទួលខុសត្រូវជាបណ្ដើរៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសំដៅបង្កើនភាពជាម្ចាស់ការ ស្របតាមយុទ្ធសាស្ត្រនៃការកែទម្រង់ថវិកាថ្នាក់ក្រោមជាតិឆ្នាំ

២០១៩-២០២៥ក្នុងការកសាងផែនការ ការរៀបចំគម្រោងថវិកា ការប្រើប្រាស់ថវិកាផ្អែកតាមចំណាយជាកាតព្វកិច្ច និងស្របតាមស្តង់ដារនៃការផ្តល់សេវា ប៉ុន្តែត្រូវធានាដល់ការបន្សុីគ្នាជាមួយគោលនយោបាយជាអាទិភាពរបស់ថ្នាក់ជាតិ

- ធានាថាក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទីជាអង្គធ្វើសេចក្តីសម្រេចចិត្តលើផែនការ និងគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ
- ផ្តល់លទ្ធភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការប្រើប្រាស់អ្នកជំនាញបច្ចេកទេស និងមានលក្ខខណ្ឌការងារច្បាស់លាស់នៅក្នុងការរៀបចំផែនការយុទ្ធសាស្ត្រនានា ដើម្បីធានាដល់ការរៀបចំតាក់តែងផែនការសកម្មភាព និងផែនការថវិកាសម្រាប់ដោះស្រាយបញ្ហាចាំបាច់ទាំងឡាយតាមស្ថានភាពជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ
- លទ្ធផលរំពឹងទុកនានានៅក្នុងផែនការអភិវឌ្ឍន៍៥ឆ្នាំត្រូវបានកំណត់យ៉ាងច្បាស់លាស់ដោយផ្អែកលើការវិភាគផ្នែកបច្ចេកទេស និងការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនានា និងស្របតាមគោលនយោបាយជាអាទិភាពរបស់ថ្នាក់ជាតិ
- លទ្ធផលរំពឹងទុកនានានៃកម្មវិធីវិនិយោគបីឆ្នាំរំកិលត្រូវបានកំណត់យ៉ាងច្បាស់លាស់ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការកំណត់លទ្ធផលរំពឹងទុកនានានៃការរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ
- លទ្ធផលរំពឹងទុកនានានៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរ៉ាប់រងដោយចំណាយចរន្ត និងចំណាយមូលធននៃគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួនដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងដែលធានាបាននូវតុល្យភាពរវាងគម្រោងចំណូល និងចំណាយថវិកា។

ការធ្វើសមាហរណកម្មនៃកិច្ចដំណើរការកសាងផែនការ និងការរៀបចំថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកិច្ចដំណើរការដែលត្រូវអនុវត្តជាបណ្តើរៗក្នុងអំឡុងពេលនៃការអនុវត្តកជទី២។ អាស្រ័យហេតុនេះ នៅក្នុងផអ៥ទី១ ត្រូវផ្តោតជាចម្បងទៅលើការអនុវត្តថវិកា និងការកែលម្អនូវលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធដែលមានស្រាប់ ដើម្បីធានាឱ្យមានការផ្សារភ្ជាប់គ្នារវាងកិច្ចដំណើរការកសាងផែនការ ការរៀបចំថវិកា និងការវិនិយោគទៅលើគម្រោងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ការចូលរួមរបស់ប្រជាពលរដ្ឋ ត្រូវបានបន្តលើកកម្ពស់ឱ្យកាន់តែទូលំទូលាយនៅក្នុងកិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយរាប់បញ្ចូលទាំងការចាប់ផ្តើមប្រើប្រាស់នូវវិធីសាស្ត្រដោយផ្អែកលើបច្ចេកវិទ្យាឌីជីថលក្នុងការចែករំលែកព័ត៌មាន និងការពិគ្រោះយោបល់។

ទិន្នន័យ និងការគ្រប់គ្រងទិន្នន័យ គឺជាមធ្យោបាយដ៏មានសារៈសំខាន់សម្រាប់ការកសាងផែនការ និងការត្រួតពិនិត្យនិងការវាយតម្លៃ។ អាស្រ័យហេតុនេះ កជទី២ ត្រូវបន្តគាំទ្រដល់ការប្រើប្រាស់

ទិន្នន័យនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការកសាងផែនការឱ្យកាន់តែមានភាពល្អប្រសើរឡើង ព្រមទាំងការកសាងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិអំពីវិធីសាស្ត្រក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលផងដែរ។

ដើម្បីជានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី១ ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៥ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៤.១.១៖ ការបន្សុីគ្នារវាងកិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

កិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបន្សុីគ្នាជាបណ្តើរៗក្នុងអំឡុងពេលនៃការអនុវត្តកជទី២។ ជំហានសំខាន់ៗក្នុងការបន្សុីគ្នានេះរួមមាន៖

- ពង្រឹងការអនុវត្តប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងផែនការលេខ១៤៩ ស្តីពីការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបំពេញបន្ថែមលើសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ដែលបានដាក់ឱ្យអនុវត្តនាពេលថ្មីៗកន្លងមកនេះ ដើម្បីបន្សុីគ្នារវាងប្រតិទិននៃការធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំនៃកម្មវិធីវិនិយោគបីឆ្នាំរំកិល ជាមួយនឹងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ព្រមទាំងត្រូវបន្សុីគ្នាជាមួយនឹងការធ្វើបច្ចុប្បន្នភាពទិន្នន័យមូលដ្ឋាននានា ជាពិសេសទិន្នន័យមូលដ្ឋានឃុំ សង្កាត់ផងដែរ
- កែលម្អការរៀបចំ និងការអនុម័តផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំនៅថ្នាក់រាជធានី ខេត្តដូចជា ការភ្ជាប់ផែនការលទ្ធកម្មនិងផែនការរដ្ឋទេយ្យបុរេប្រទានជាមួយនឹងគម្រោងថវិកាប្រចាំឆ្នាំសម្រាប់ការចរចាថវិកា និងការប្រើប្រាស់នូវចំណាត់ថ្នាក់ថវិកាផ្សេងៗបន្ថែមទៀតលើចំណាត់ថ្នាក់ថវិកាដែលមានស្រាប់ ព្រមទាំងការកែលម្អសារាចរណែនាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ
- កែលម្អការរៀបចំ និងការអនុម័តគម្រោងថវិកាប្រចាំឆ្នាំនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ដូចជា ការភ្ជាប់ផែនការលទ្ធកម្មនិងផែនការរដ្ឋទេយ្យបុរេប្រទានជាមួយនឹងគម្រោងថវិកាប្រចាំឆ្នាំសម្រាប់ការពិនិត្យបញ្ជាក់អនុលោមភាព ការប្រើប្រាស់នូវចំណាត់ថ្នាក់ថវិកាផ្សេងៗបន្ថែមទៀតលើចំណាត់ថ្នាក់ថវិកាដែលមានស្រាប់ និងការកែលម្អសារាចរណែនាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ
- សិក្សាអំពីការបន្សុីគ្នារវាងផែនការអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុកជាមួយផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលខេត្ត និងពិនិត្យកែសម្រួលរចនាសម្ព័ន្ធថវិកាកម្មវិធីរបស់រដ្ឋបាលខេត្តដើម្បីបន្សុីគ្នាជាមួយនឹងមុខងារ និងរចនាសម្ព័ន្ធស្ថាប័នជាក់ស្តែងនៃរដ្ឋបាលក្រុង ស្រុក

- រៀបចំ និងដាក់ឱ្យអនុវត្តនូវក្របខ័ណ្ឌថវិការយៈពេលមធ្យមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការកសាងផែនការ និងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ
- ការលើកកម្ពស់សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាក្នុងការអនុម័តគម្រោងថវិកា និងកែសម្រួលថវិកា ព្រមទាំងផែនការលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងធានាថាគម្រោងថវិកា និងផែនការលទ្ធកម្មទាំងនេះត្រូវបានអនុវត្តយ៉ាងពេញលេញផ្អែកតាមឆន្ទានុសិទ្ធិរបស់ខ្លួន និងស្របតាមលិខិតបទដ្ឋានកំណត់។

គោលបំណងសំខាន់នៃការអនុវត្តសកម្មភាពខាងលើនេះ គឺដើម្បីធានាថា នៅឆ្នាំ២០៣០ ផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ត្រូវបានរៀបចំផ្អែកលើអាទិភាពនានាដែលបានកំណត់ក្នុងផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយជាមួយគ្នានោះដែរត្រូវពិចារណាអំពីការធ្វើសមាហរណកម្មរវាងផែនការយុទ្ធសាស្ត្រថវិកាជាមួយកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

សកម្មភាពជាអាទិភាពនេះត្រូវរៀបចំ និងអនុវត្តជាបន្តបន្ទាប់ក្នុងរយៈពេលនៃផអ៥ទី១ និងផអ៥ទី២ នៃកជទី២។

### សកម្មភាពអាទិភាព ៤.១.២៖ ការពិនិត្យ និងកែសម្រួលឡើងវិញប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ការពិនិត្យ និងកែសម្រួលប្រព័ន្ធកសាងផែនការនេះ ត្រូវផ្តោតទៅលើកិច្ចការសំខាន់ៗដូចខាងក្រោម ៖

- ការរៀបចំផែនការទៅតាមថ្នាក់ ប្រភេទ និងចរិតលក្ខណៈផ្សេងៗគ្នារបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗដែលមានលក្ខណៈជារដ្ឋបាលក្រុងមេត្រូប៉ូលីតែន ឬរដ្ឋបាលតំបន់ ឬរដ្ឋបាលមូលដ្ឋាន និងមានលក្ខណៈជាតំបន់ទីប្រជុំជន ឬតំបន់ជនបទ និងមានសក្តានុពលសេដ្ឋកិច្ចដោយឡែកផ្សេងៗពីគ្នា
- ការពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល និងវិស័យឯកជននៅក្នុងកិច្ចដំណើរការកសាងផែនការ ដើម្បីធានាដល់ការឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពនានារបស់ប្រជាពលរដ្ឋ
- ការរៀបចំគោលការណ៍ណែនាំស្តីពីការដាក់ឱ្យប្រើប្រាស់នូវបច្ចេកវិទ្យាឌីជីថល ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចដំណើរការកសាងផែនការដូចជា ការចែករំលែកព័ត៌មាន ការស្ទាបស្ទង់មតិតាមរយៈប្រព័ន្ធអនឡាញ និងការទទួលមតិយោបល់ត្រលប់

- ការពង្រឹងតួនាទីរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការទទួលខុសត្រូវលើការកំណត់អំពីទិសដៅជាយុទ្ធសាស្ត្រនៃផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល និងការអនុម័តលើផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល
- ការកែសម្រួលនូវរចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវនៃយន្តការនានារបស់ក្រុមប្រឹក្សាដែលពាក់ព័ន្ធនឹងការគាំទ្រការកសាងផែនការ ដូចជាការពិនិត្យមើលឡើងវិញនូវរចនាសម្ព័ន្ធរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ការបង្កើតគណៈកម្មាធិការផ្សេងៗបន្ថែមទៀតជាដើម
- ការធានាថាកម្មវិធីវិនិយោគ៣ឆ្នាំរំកិលត្រូវបានរៀបចំតាមទំហំធនធានដែលមានជាក់ស្តែង
- ការកំណត់ឱ្យបានច្បាស់លាស់ និងដាច់ដោយឡែកពីគ្នានូវគម្រោងវិនិយោគនានានៅក្នុងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលដែលត្រូវប្រើប្រាស់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគម្រោងវិនិយោគនានាដែលអាចកៀរគរការគាំទ្រពីប្រភពស្របច្បាប់ផ្សេងទៀត (ក្រសួង ស្ថាប័ន មន្ទីរជំនាញ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងសប្បុរសជន) ដើម្បីដាក់បញ្ចូលគម្រោងវិនិយោគទាំងនោះក្នុងផែនការយុទ្ធសាស្ត្រថវិកា។ កិច្ចដំណើរការនេះជាជំហានដំបូងមួយនៃការធ្វើសមាហរណកម្មរវាងផែនការយុទ្ធសាស្ត្រថវិកាជាមួយនឹងកម្មវិធីវិនិយោគបីឆ្នាំរំកិលនាពេលខាងមុខ
- ការយកចិត្តទុកដាក់ និងឆ្លើយតបនឹងការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម។

## សកម្មភាពអាទិភាព ៤.១.៣ ៖ ការរៀបចំឯកសារជាយុទ្ធសាស្ត្រនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ក្នុងអំឡុងពេលនៃកជទី២នេះ ត្រូវរៀបចំឱ្យមានសេចក្តីណែនាំយ៉ាងច្បាស់លាស់អំពីការរៀបចំឯកសារយុទ្ធសាស្ត្រនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលស្របទៅតាមអាណត្តិ និងមុខងាររបស់ខ្លួន។ ឯកសារយុទ្ធសាស្ត្រទាំងនេះរួមមានដូចជា ៖

- ផែនការប្រើប្រាស់ដីធ្លី (ជាពិសេសសម្រាប់តំបន់ទីក្រុង)
- យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា
- យុទ្ធសាស្ត្រសម្រាប់ការផ្តល់សេវាតាមវិស័យនានាដែលស្ថិតក្រោមការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ឯកសារយុទ្ធសាស្ត្រទាំងនេះត្រូវរៀបចំឡើងដោយមានការចូលរួម និងការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ប៉ុន្តែក៏អាចមានជំនួយពីអ្នកជំនាញបច្ចេកទេសតាមការចាំបាច់ផងដែរ។ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំឯកសារយុទ្ធសាស្ត្រទាំងនេះស្របតាមស្ថានភាពភូមិសាស្ត្រ តម្រូវការចាំបាច់ និងធនធាន

ដែលខ្លួនមាន ព្រមទាំងត្រូវធ្វើបច្ចុប្បន្នភាពតាមការចាំបាច់។ ក្នុងន័យនេះ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ នឹងមិនតម្រូវឱ្យរៀបចំគ្រប់ឯកសារយុទ្ធសាស្ត្រទាំងនេះដូចៗគ្នានោះទេ។

ឯកសារយុទ្ធសាស្ត្រទាំងនេះនឹងអាចត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ទាំងការអនុវត្តផែនការអភិវឌ្ឍ៥ឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងអាណត្តិបច្ចុប្បន្ន ឬការរៀបចំផែនការអភិវឌ្ឍ៥ឆ្នាំរបស់ក្រុមប្រឹក្សាអាណត្តិថ្មីឱ្យកាន់តែមានប្រសិទ្ធភាព និងគុណភាព។

## សកម្មភាពអាទិភាព ៤.១.៤ ៖ ការពង្រឹងការប្រើប្រាស់ទិន្នន័យសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបង្កើនការប្រើប្រាស់ទិន្នន័យដែលត្រូវបានពង្រឹងតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីរៀបចំផែនការអភិវឌ្ឍ៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល និងក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ និងកម្មវិធីទាំងនោះ។ ទិន្នន័យមូលដ្ឋានរដ្ឋបាលឃុំ សង្កាត់នឹងត្រូវបានធ្វើកែលម្អ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ ចំណែកឯទិន្នន័យផ្សេងៗទៀត ជាពិសេសទិន្នន័យដែលពាក់ព័ន្ធនឹងការវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏នឹងត្រូវបានកែលម្អ និងប្រើប្រាស់ផងដែរ។ រដ្ឋបាលថ្នាក់ក្រោមជាតិអាចប្រើប្រាស់នូវទិន្នន័យផ្សេងទៀត ដូចជាទិន្នន័យអត្តសញ្ញាណគ្រួសារក្រីក្ររបស់ក្រសួងផែនការ និងទិន្នន័យរបស់ក្រសួង ស្ថាប័នវិស័យពាក់ព័ន្ធផ្សេងទៀត។ កិច្ចការសំខាន់ៗដែលត្រូវផ្តោតយកចិត្តទុកដាក់រួមមាន ៖

- ការកែលម្អគុណភាពទិន្នន័យនានា និងការប្រើប្រាស់ដោយមានការសម្របសម្រួលគ្នារវាងទិន្នន័យនានាដែលពាក់ព័ន្ធនឹងការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងនោះរួមមាន ៖
  - ការបង្កើតក្រុមការងារបច្ចេកទេសមួយដើម្បីពិនិត្យ និងធ្វើសន្ទានកម្ម ឬសុខដុមនីយកម្មរវាងទិន្នន័យនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការធានាឱ្យមានភាពចម្រុះពាក់ព័ន្ធនឹងយេនឌ័រនៅក្នុងប្រព័ន្ធទិន្នន័យទាំងនោះ
  - ការរៀបចំបង្កើតនូវប្រព័ន្ធរួមមួយនៃទិន្នន័យនានា ដែលពាក់ព័ន្ធនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ និងនីតិវិធីនៃការគ្រប់គ្រងប្រព័ន្ធរួមនេះ ដើម្បីបង្កលក្ខណៈឱ្យមានកិច្ចសហការកាន់តែប្រសើរឡើងរវាងតួអង្គពាក់ព័ន្ធនានា និងធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិប្រើប្រាស់ប្រព័ន្ធទិន្នន័យនេះកាន់តែមានប្រសិទ្ធភាពក្នុងការរៀបចំ និងអនុវត្តផែនការ និងថវិការបស់ខ្លួន
- ការពិនិត្យ កែសម្រួល និងកាត់បន្ថយនូវសំណុំ ឬកម្រងព័ត៌មាននៃទិន្នន័យមូលដ្ឋានរបស់រដ្ឋបាលឃុំ សង្កាត់ដែលមានប្រភពស្រាប់ ដើម្បីធានាដល់ការសម្រាលបន្ទុកការងារ និងការចំណាយសម្រាប់ការប្រមូលព័ត៌មាននៃទិន្នន័យទាំងនេះ ដោយផ្តោតលើព័ត៌មានណាដែលមិនអាចរកបានពីប្រភពទិន្នន័យផ្សេងទៀត

- ការបង្កើតនូវប្រព័ន្ធអនឡាញមួយសម្រាប់អ្នកប្រើប្រាស់ទិន្នន័យមូលដ្ឋានរបស់រដ្ឋបាលឃុំ សង្កាត់។ ជាមួយគ្នានេះដែរ ទិន្នន័យមូលដ្ឋានរបស់រដ្ឋបាលឃុំ សង្កាត់ត្រូវបានរៀបចំឱ្យក្លាយជាទិន្នន័យមួយដ៏មានសារៈសំខាន់ដែលមានលទ្ធភាពអាចវិភាគអំពីនិន្នាការសម្រាប់រយៈពេលច្រើនឆ្នាំ។ ក្រៅពីនេះ ចាំបាច់ត្រូវតែមានការរៀបចំឱ្យមានតំណភ្ជាប់តាមប្រព័ន្ធអនឡាញនៃអ្នកប្រើប្រាស់ ទិន្នន័យមូលដ្ឋានរបស់រដ្ឋបាលឃុំ សង្កាត់ជាមួយទិន្នន័យពាក់ព័ន្ធផ្សេងៗទៀត សំដៅបង្កលក្ខណៈឱ្យអ្នកធ្វើផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអាចមើលឃើញប្រព័ន្ធគ្រប់គ្រង និងអាចទាញយកទិន្នន័យពាក់ព័ន្ធផ្សេងទៀត ដូចជាទិន្នន័យអត្តសញ្ញាណគ្រួសារក្រីក្រ ទិន្នន័យជំរឿនប្រជាពលរដ្ឋជាដើម
- ការពិនិត្យមើលឡើងវិញអំពីលទ្ធភាពក្នុងការដាក់ឱ្យប្រើប្រាស់ជាសាធារណៈ និងឱ្យបានកាន់តែមានភាពទូលំទូលាយសម្រាប់ប្រើប្រាស់នូវទិន្នន័យមូលដ្ឋានរបស់រដ្ឋបាលឃុំ សង្កាត់ដែលត្រូវបានធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ

## សកម្មភាពអាទិភាព ៤.១.៥៖ ការរៀបចំយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០២៦-២០៣០

ទិសដៅជាយុទ្ធសាស្ត្រសម្រាប់ការកែលម្អបន្ថែមនូវប្រព័ន្ធកសាងផែនការ និងប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវបានកំណត់តាមរយៈការសិក្សា និងការពិគ្រោះយោបល់នានាក្នុងអំឡុងពេលនៃការអនុវត្តផអ៥ទី១ នៃកជទី២។ លទ្ធផលនៃការសិក្សានេះត្រូវយកមកពិចារណា និងប្រើប្រាស់ជាធាតុចូលក្នុងការរៀបចំយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០២៦-២០៣០ និងផអ៥ទី២នៃកជទី២ ដោយមានសង្គតិភាពកម្រិតគោលការណ៍ និងអភិក្រមនៃការគ្រប់គ្រងថវិការដ្ឋ ស្របតាមយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ជាតិ និងគោលការណ៍វិមជ្ឈការ។

- យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០២៦-២០៣០) ចាំបាច់ត្រូវរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមរយៈការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយកម្មវិធីកំណែទម្រង់នានា និងដោយមានការចូលរួមផ្តល់មតិយោបល់ និងធាតុចូលពីភាគីពាក់ព័ន្ធនានា ជាពិសេស លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា
- យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០២៦-២០៣០) ត្រូវឆ្លុះបញ្ចាំងអំពីមេរៀន និងបទពិសោធន៍ល្អៗដែលសម្រេចបានក្នុងអំឡុងពេលនៃការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥ និងការអនុវត្តផអ៥ទី១នៃកជទី២
- យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០២៦-២០៣០) មិនត្រឹមតែត្រូវកែលម្អជំហាន និងយន្តការដាក់លាក់មួយចំនួននោះទេ ប៉ុន្តែត្រូវផ្សារភ្ជាប់ជាមួយ

ប្រព័ន្ធថវិកាជាតិទាំងមូល ព្រមទាំងការបន្សុីគ្នារវាងការគ្រប់គ្រងថវិកាជាមួយនឹងការពង្រឹងភាពម្ចាស់ការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្ទេរមុខងារនានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

- ជាមួយគ្នានឹងការខិតខំលើកកម្ពស់នូវតម្លាភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការគ្រប់គ្រងថវិកា ទិសដៅនៃយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០២៦-២០៣០) ត្រូវផ្តោតជាសំខាន់លើការពង្រឹងភាពម្ចាស់ការថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្រោមសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា។
- ការរៀបចំឧបករណ៍ វិធីសាស្ត្រ និងនីតិវិធីក្នុងការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័ររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### *លទ្ធផលរំពឹងទុក ៤.២៖ ការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អដោយមានការផ្តល់សិទ្ធិអំណាចកាន់តែច្រើនឡើងទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមទិសដៅនៃយុទ្ធសាស្ត្រកែទម្រង់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ*

ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបវិមជ្ឈការ ដូចជា ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុនានាប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ នៅក្នុងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការកន្លងមក ដំណើរការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈថ្នាក់ក្រោមជាតិមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់។ ទោះបីជាការកែទម្រង់ទាំងមានវឌ្ឍនភាពជាច្រើនក៏ដោយក៏ប៉ុន្តែនៅមានបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលចាំបាច់ត្រូវបន្តជំរុញ និងកែលម្អការអនុវត្តនេះឱ្យកាន់តែប្រសើរឡើង។ បញ្ហាប្រឈមទាំងនោះ រួមមាន ៖

- រដ្ឋបាលរាជធានី ខេត្ត នៅពុំទាន់មានសិទ្ធិអំណាចពេញលេញក្នុងការគ្រប់គ្រង និងប្រើប្រាស់ថវិការបស់ខ្លួនតាមគោលការណ៍វិមជ្ឈការហិរញ្ញវត្ថុនៅឡើយ។ អាស្រ័យហេតុនេះ ដើម្បីធានាដល់ការបន្សុីគ្នានៃការធ្វើវិមជ្ឈការហិរញ្ញវត្ថុជាមួយនឹងរចនាសម្ព័ន្ធ ប្រព័ន្ធរបស់រដ្ឋបាលរាជធានី ខេត្តដែលបានកែសម្រួលផ្អែកតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការចាំបាច់ត្រូវគិតគូរអំពីការផ្តល់សិទ្ធិអំណាច និងការលើកកម្ពស់ដល់ស្វ័យភាពក្នុងការគ្រប់គ្រង និងការប្រើប្រាស់ថវិការបស់ខ្លួន ស្របតាមផែនការនៃការធ្វើវិមជ្ឈការហិរញ្ញវត្ថុ
- ការគ្រប់គ្រង និងការប្រើប្រាស់នូវធនធានធន្មានុសិទ្ធិរបស់រដ្ឋបាលក្រុង ស្រុកនៅពុំទាន់មានប្រសិទ្ធភាពនៅឡើយដោយសារសិទ្ធិអំណាចរបស់រដ្ឋបាលក្រុង ស្រុកលើការគ្រប់គ្រង និងការប្រើប្រាស់ធនធានទាំងនោះនៅមានកម្រិត ក្នុងនោះរួមបញ្ចូលទាំងកិច្ចលទ្ធកម្មផងដែរ
- ការវិភាជធនធានសម្រាប់ផ្នែកសមាសភាគអភិវឌ្ឍមូលដ្ឋាននៃមូលនិធិក្រុង ស្រុកនៅមានទំហំតិចតួចបើប្រៀបធៀបទៅនឹងតម្រូវការជាអាទិភាពរបស់មូលដ្ឋាននីមួយៗ

- ក្នុងករណីខ្លះ លិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីនៃការអនុវត្តថវិកាដែលបានដាក់ឱ្យអនុវត្ត នៅមានភាពមិនទាន់ច្បាស់លាស់ ដែលជាហេតុបង្កឱ្យមានការលំបាកដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការបែងចែក និងប្រើប្រាស់ថវិកាសម្រាប់អនុវត្តសកម្មភាពមួយចំនួន ជាពិសេសសកម្មភាពដែលពាក់ព័ន្ធនឹងសេវាសង្គម
- សមត្ថភាពរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មនៅមានកម្រិត ជាពិសេសសម្រាប់កិច្ចលទ្ធកម្មដែលមានលក្ខណៈបច្ចេកទេសស្មុគស្មាញ
- លិខិតបទដ្ឋានគតិយុត្តនាពេលបច្ចុប្បន្ន បានប្រគល់សិទ្ធិអំណាចពេញលេញដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការពិនិត្យ និងសម្រេចលើការអនុវត្តកិច្ចលទ្ធកម្មរបស់ខ្លួន។ តែទោះជាយ៉ាងនេះក្តី ក្នុងការអនុវត្តជាក់ស្តែងនៅមានភាពមិនច្បាស់លាស់ដែលចាំបាច់ត្រូវមានការពិនិត្យមើលឡើងវិញ ដើម្បីជានាឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាចអនុវត្តនូវសិទ្ធិអំណាចរបស់ខ្លួនក្នុងកិច្ចដំណើរការលទ្ធកម្មស្របតាមបទដ្ឋានគតិយុត្តកំណត់។

ដើម្បីធានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី២ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ២ ដូចខាងក្រោម ៖

### សកម្មភាពអាទិភាព ៤.២.១ ៖ ការបន្តការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០១៩-២០២៥)

កជទី២ ត្រូវបន្ត និងពង្រឹងការអនុវត្តថវិកា ស្របតាមផែនការសកម្មភាពដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០១៩-២០២៥) ដែលក្នុងនោះរួមមានសកម្មភាពសំខាន់ៗដូចខាងក្រោម ៖

- ការរៀបចំ និងអនុវត្តបែបផែនថ្មីពាក់ព័ន្ធនឹងមុខងារត្រួតពិនិត្យហិរញ្ញវត្ថុ និងកិច្ចលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្តដែលត្រូវបានធ្វើប្រតិភូកម្មទៅឱ្យមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត
- ការរៀបចំ និងអនុវត្តបែបផែនថ្មីពាក់ព័ន្ធនឹងមុខងារត្រួតពិនិត្យហិរញ្ញវត្ថុ និងការទូទាត់ថវិការបស់ថ្នាក់ក្រុង ស្រុកដែលត្រូវបានធ្វើប្រតិភូកម្មទៅឱ្យរតនាគារខេត្ត (ដូចករណីថវិកាឃុំ សង្កាត់ដែរ)
- ការធ្វើឱ្យមានលក្ខណៈសាមញ្ញ និងការពន្លឿនកិច្ចដំណើរការអនុវត្តថវិកាតាមរយៈការបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ (រួមបញ្ចូលទាំងការដាក់បញ្ចូលនូវចំណាត់ថ្នាក់ថវិកាចំនួន២បន្ថែមទៀត ពោលគឺចំណាត់ថ្នាក់មុខងារ និងចំណាត់ថ្នាក់គម្រោងទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននេះ) និងការដោះស្រាយបញ្ហានានាដោយផ្អែកលើបច្ចេកវិទ្យាព័ត៌មាន

- ការរៀបចំក្របខ័ណ្ឌរួមមួយស្តីពីការធ្វើរបាយការណ៍ និងការត្រួតពិនិត្យតាមដានថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការរៀបចំក្របខ័ណ្ឌរួមមួយស្តីពីការវាយតម្លៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### សកម្មភាពអាទិភាព ៤.២.២ ៖ ការធ្វើវិមជ្ឈការ និងការពង្រឹងការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

កដទី២ ត្រូវបន្តជំរុញការធ្វើវិមជ្ឈការ និងការពង្រឹងការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលក្នុងនោះផ្តោតលើកិច្ចការសំខាន់ៗដូចខាងក្រោម ៖

- ការផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវពេញលេញលើការអនុវត្តកិច្ចលទ្ធកម្មទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការប្រគល់សិទ្ធិសម្រេច និងការទទួលខុសត្រូវលើកិច្ចលទ្ធកម្មជូនរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌនឹងត្រូវអនុវត្តជាបណ្តើរៗតាមរយៈការបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេចលើកលែងតែមុខចំណាយមួយចំនួន ដែលមានទំហំធំ មិនមានគោលការណ៍/គោលរបបច្បាស់លាស់និង/ឬមានវេទយិតភាពខ្ពស់ ដែលចាំបាច់ត្រូវតែជាកម្មវត្ថុនៃការស្នើសុំការឯកភាពជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ការធានាថាគោលការណ៍ណែនាំស្តីពីកិច្ចលទ្ធកម្មមានលក្ខណៈច្បាស់លាស់ និងសមស្របសម្រាប់ប្រភេទលទ្ធកម្មនានាដែលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុវត្ត ក្នុងនោះរួមមានលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម
- ការពង្រឹងការអនុវត្តកិច្ចលទ្ធកម្មសម្រាប់គម្រោងឃុំ សង្កាត់ និងគម្រោងក្រុង ស្រុក

### *លទ្ធផលរំពឹងទុក ៤.៣៖ ការបង្កើនប្រភពចំណូលមូលដ្ឋានជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានមកពីចំណូលសារពើពន្ធត្រូវបានសិក្សា និងដាក់ឱ្យអនុវត្ត*

មកទល់បច្ចុប្បន្ននេះ ចំណូលថវិកាមួយចំណែកធំរបស់រដ្ឋបាលរាជធានី ខេត្តបានមកពីចំណូលសារពើពន្ធមួយចំនួនដែលថ្នាក់ជាតិបានប្រគល់ជាគុណប្រយោជន៍ឱ្យរដ្ឋបាលទាំងនោះ។ ទោះបីជាយ៉ាងនេះក៏ដោយ ប្រភពចំណូលមូលដ្ឋានដ៏សំខាន់នេះពុំមានតុល្យភាពគ្នារវាងរដ្ឋបាលរាជធានី ខេត្តនីមួយៗឡើយ ដែលក្នុងនោះរដ្ឋបាលរាជធានីទទួលបានចំណូលដ៏ច្រើនលើសលុបធៀបនឹងខេត្តដទៃទៀត។ អាស្រ័យហេតុនេះ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកាត់យកនូវចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានីមួយចំណែកទៅឱ្យរដ្ឋបាលខេត្តនានា។ ការបែងចែកចំណូលសារពើពន្ធនេះនឹងត្រូវគិតគូរឱ្យមានរូបមន្ត និងលក្ខណៈវិនិច្ឆ័យច្បាស់លាស់ ដើម្បីធានាដល់ការបែងចែកនូវថវិកានេះទៅឱ្យរដ្ឋបាលខេត្តនីមួយៗប្រកបដោយតម្លាភាព និងសមធម៌។

ជាមួយគ្នានោះដែរ រាជរដ្ឋាភិបាលក៏បានកំណត់អំពីការចែករំលែកចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុកចំនួន៤% និងឃុំ សង្កាត់ចំនួន៤% (សម្រាប់ថវិកាឆ្នាំ ២០២០) ដើម្បីផ្តល់ធនធានបន្ថែមទៅឱ្យរដ្ឋបាលទាំងនេះ ប្រើប្រាស់សម្រាប់តែការចំណាយលើការអភិវឌ្ឍមូលដ្ឋានប៉ុណ្ណោះ។ ទោះបីយ៉ាងនេះក៏ដោយ រដ្ឋបាលថ្នាក់ក្រោមជាតិជាពិសេសរដ្ឋបាល ក្រុង ស្រុកនៅតែមានធនធានថវិកាតិចតួចបើប្រៀបធៀបនឹងមុខងារ និងការទទួលខុសត្រូវរបស់ខ្លួន។

អ្វីដែលជាកិច្ចការអាទិភាពចំពោះមុខ គឺការបង្កើនចំណូលមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការបង្កើនប្រសិទ្ធភាពលើការប្រមូលចំណូលសារពើពន្ធ និងការកំណត់ឱ្យបានច្បាស់លាស់លើការបែងចែកនូវចំណូលសារពើពន្ធ ដោយកាត់បន្ថយវិសមភាពនៃចំណូលសារពើពន្ធរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ សម្រាប់រយៈពេលវែង ការបង្កើនចំណូលមូលដ្ឋានដែលបានមកពីចំណូលសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវពិចារណាក្នុងការបង្កើនអត្រាចែករំលែកចំណូលសារពើពន្ធ និងលទ្ធភាពបន្ថែម ប្រភេទពន្ធថ្មីៗបន្ថែមទៀត ព្រមទាំងការកំណត់នូវក្របខ័ណ្ឌច្បាស់លាស់មួយសម្រាប់ការប្រើប្រាស់លើចំណូលពីប្រភេទពន្ធបន្ថែមថ្មីទាំងនេ (ឧទាហរណ៍ ចំណូលបន្ថែមនេះអាចត្រូវបានកំណត់ឱ្យប្រើប្រាស់សម្រាប់ជាការបង្កើននូវធនធានធន្ទានុសិទ្ធិ ឬសម្រាប់អនុវត្តមុខងារជាកាតព្វកិច្ចណាមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ)។

ដើម្បីជានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៣ ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៣ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៤.៣.១៖ ការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រងចំណូលសារពើពន្ធដែលមានស្រាប់

ក្នុងរយៈពេលកន្លងមក ថ្នាក់ជាតិបានប្រគល់ប្រភេទពន្ធមួយចំនួនទៅឱ្យរដ្ឋបាលរាជធានី ខេត្តដើម្បីបង្កើតបានជាចំណូលជាគុណប្រយោជន៍ថវិកា ដែលមកទល់បច្ចុប្បន្ននេះរួមមានពន្ធចំនួនប្រាំបួនប្រភេទ (ពន្ធលើឈ្នួលផ្ទះនិងដី ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានយន្តគ្រប់ប្រភេទ ពន្ធប៉ាតង់ ពន្ធប្រថាប់ត្រា ពន្ធលើអចលនទ្រព្យ អាករសម្រាប់បំភ្លឺសាធារណៈ អាករលើការស្នាក់នៅ ពន្ធតែមប្រិ៍សារពើពន្ធ ពន្ធលើដីធ្លីមិនបានប្រើប្រាស់)។ អាស្រ័យហេតុនេះ កជទី២ នឹងបន្តលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រងនូវចំណូលសារពើពន្ធទាំងនេះ ដោយផ្តោតជាសំខាន់ទៅលើកិច្ចការដូចខាងក្រោម ៖

- ការលើកកម្ពស់ការព្យាករណ៍ ការគ្រប់គ្រង និងការត្រួតពិនិត្យតាមដានលើការប្រមូលចំណូលសារពើពន្ធពីប្រភេទពន្ធដែលមានស្រាប់ទាំងនេះ ជាពិសេសចំពោះប្រភេទពន្ធសំខាន់ៗ (ពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់។ល។) ដើម្បីធានាដល់ប្រសិទ្ធភាពនៃការរៀបចំថវិកា

- ការរៀបចំ និងអនុវត្តនូវរូបមន្តនិងលក្ខណៈវិនិច្ឆ័យច្បាស់លាស់ តម្លាភាព និងសមធម៌សម្រាប់ការបែងចែកចំណូលដែលបានពីអតិរេកថវិការបស់រដ្ឋបាលរាជធានី ខេត្តជាពិសេសអំពីចំណូលសារពើពន្ធរបស់រាជធានីភ្នំពេញទៅខេត្តផ្សេងៗទៀត។

## សកម្មភាពអាទិភាព ៤.៣.២៖ ការចែករំលែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់

ក្នុងអំឡុងពេលនៃការអនុវត្តផែនការអនុវត្តផអ៥ទី១ នៃកជទី២ ការគ្រប់គ្រងលើការចែករំលែកចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់នៅក្នុងដំណាក់កាលនៃការរៀបចំថវិការបស់ខ្លួននឹងត្រូវបានលើកកម្ពស់តាមរយៈ៖

- ការសិក្សា រៀបចំ និងអនុវត្តនូវយន្តការនៃការចែករំលែកចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ដោយធានាឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់អាចទទួលបានការជូនដំណឹងជាមុនអំពីចំណូលនេះ ដើម្បីដាក់បញ្ចូលក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន (ឧទាហរណ៍ ការកំណត់អំពីទំហំនៃចំណូលនេះដោយផ្អែកលើចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្តដែលបានអនុម័តពីឆ្នាំមុន)
- ការសិក្សាអំពីលទ្ធភាពនៃការបង្កើនអត្រាសម្រាប់ចែករំលែកចំណូលសារពើពន្ធពីរាជធានីខេត្តទៅឱ្យក្រុង ស្រុកដើម្បីបង្កើនចំណូលមូលដ្ឋានរបស់រដ្ឋបាលក្រុង ស្រុក។

## សកម្មភាពអាទិភាព ៤.៣.៣ ៖ ការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ការបង្កើតមូលនិធិភាតរភាព និងការបន្ថែមប្រភេទពន្ធទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

ក្នុងអំឡុងពេលនៃការអនុវត្តផអ៥ទី១នៃកជទី២ នឹងរៀបចំឱ្យមានការសិក្សាអំពីការបង្កើតមូលនិធិភាតរភាព និងការពិនិត្យលទ្ធភាពបន្ថែមប្រភេទពន្ធថ្មីៗ ដើម្បីជាគុណប្រយោជន៍ដល់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ផ្អែកលើលទ្ធផលនៃការសិក្សានេះ ត្រូវរៀបចំនូវក្របខ័ណ្ឌយុទ្ធសាស្ត្រមួយស្តីពីការបង្កើតមូលនិធិភាតរភាព និងលទ្ធភាពក្នុងការបន្ថែមប្រភេទពន្ធទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលក្របខ័ណ្ឌត្រូវផ្តោតទៅលើបញ្ហាសំខាន់ៗមួយចំនួន ដូចជា ៖

- ការកំណត់អំពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការពង្រឹង និងគាំទ្រដល់សាខានៃអគ្គនាយកដ្ឋានពន្ធដារនៅរដ្ឋបាលថ្នាក់ក្រោមជាតិលើការប្រមូលចំណូលសារពើពន្ធដែលជាចំណូលជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការកំណត់អំពីគោលបំណងជាក់លាក់នៃការប្រើប្រាស់ចំណូលសារពើពន្ធទាំងនោះ (ចំណូលសម្រាប់ប្រើប្រាស់ជាធន្ទានុសិទ្ធិ ឬសម្រាប់ប្រើប្រាស់ក្នុងការអនុវត្តនូវមុខងារជាកាតព្វកិច្ចណាមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ)

- ការកំណត់អំពីការបង្កើតយន្តការនានា ដូចជា "**មូលនិធិភាតរភាព**" សំដៅកាត់យកចំណូលសារពើពន្ធមួយចំណែកសមស្រប ពីរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានសក្តានុពលក្នុងការប្រមូលចំណូលសារពើពន្ធ ដើម្បីបែងចែកទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិប្រភេទដូចគ្នាដែលពុំសូវមានសក្តានុពល។

ក្របខ័ណ្ឌជាយុទ្ធសាស្ត្រនេះត្រូវរៀបចំបញ្ចប់នៅក្នុងដំណាក់កាលនៃការអនុវត្តផអ៥ទី១ ដើម្បីធានានូវសមធម៌នៃការបែងចែក**មូលនិធិភាតរភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ** និងលទ្ធភាពបន្ថែមប្រភេទពន្ធថ្មីបន្ថែមទៀតជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងអំឡុងពេលនៃការចាប់ផ្តើមអនុវត្តផអ៥ទី២ នៃកជទី២ ស្របតាមការគ្រោងរៀបចំក្របខ័ណ្ឌថវិការយៈពេលមធ្យម និងយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធគ្រប់គ្រងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០២៦-២០៣០។

### *លទ្ធផលរំពឹងទុក ៤.៤៖ ការបង្កើនប្រភពចំណូលមូលដ្ឋានជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានមកពីចំណូលមិនមែនសារពើពន្ធត្រូវបានសិក្សា និងដាក់ឱ្យអនុវត្ត*

ការប្រមូលចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្តដោយទទួលបានលទ្ធផលយ៉ាងល្អប្រសើរក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ តាមរយៈការផ្តល់សេវានានានៃយន្តការច្រកចេញចូលតែមួយរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងការផ្តល់សេវារបស់រដ្ឋបាលឃុំ សង្កាត់។ ដើម្បីពង្រឹង និងពង្រីកការប្រមូលចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវបង្កើននូវការលើកទឹកចិត្តដល់អង្គភាពផ្តល់សេវាផ្ទាល់ និងការផ្ទេរមុខងារផ្តល់សេវាកាន់តែច្រើនបន្ថែមទៀតពីក្រសួង ស្ថាប័នពាក់ព័ន្ធនានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការប្រមូលចំណូលពីការផាកពិន័យ និងការជួលទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិក៏ជាសក្តានុពលនៃប្រភពចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

នៅឆ្នាំ២០១៨ រាជរដ្ឋាភិបាលបានអនុម័តអនុក្រឹត្យស្តីពីចំណូលមិនមែនសារពើពន្ធ និងកំពុងរៀបចំផែនការមេរយៈពេល១០ឆ្នាំមួយស្តីពីចំណូលមិនមែនសាពើពន្ធ ២០២១-២០៣០ ដែលគ្របដណ្តប់លើចំណូលមិនមែនសារពើពន្ធចំនួន៥ រួមមានចំណូលពី ១) សេវាសាធារណៈ ២) ការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ៣) ការពិន័យ និងការដាក់ទណ្ឌកម្ម ៤) សហគ្រាសសាធារណៈ ភាគកម្មសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុ និង ៥) ប្រភពផ្សេងទៀត។ នៅក្នុងផែនការមេនេះនឹងកំណត់ឱ្យមានការពិនិត្យនិងពិចារណាអំពីការធ្វើវិមជ្ឈការលើការកំណត់កម្រៃ ឬឈ្នួលសេវាសាធារណៈ ការប្រមូលថវិកាពីការផាកពិន័យ និងចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិពីការជួលទ្រព្យសម្បត្តិរដ្ឋ និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការទូទាត់ ការប្រមូល និងការគ្រប់គ្រងចំណូល។

ក្នុងការធានាដល់ការបង្កើនចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ កជទី២ ត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើការកែលម្អការគ្រប់គ្រងចំណូលដែលមានស្រាប់ ការប្រគល់ប្រភេទចំណូលមិនមែនសារពើពន្ធបន្ថែម។

ដើម្បីជានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៤ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៣ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៤.៤.១ ៖ ការបន្សុីគ្នារវាងកម្មវិធីជាតិដំណាក់កាលទី២ និងឯកសារគោលស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

កិច្ចការជាសំខាន់ គឺការធានាឱ្យមានភាពស៊ីសង្វាក់គ្នាផ្នែកគោលនយោបាយរវាងកជទី២ និងឯកសារគោលស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។ ដើម្បីធានាដល់ការសម្រេចបាននូវកិច្ចការនេះទាមទារឱ្យមានការសម្របសម្រួល និងកិច្ចសហការយ៉ាងជិតស្និទ្ធរវាងស្ថាប័នពាក់ព័ន្ធនានា ជាពិសេសរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប.។

### សកម្មភាពអាទិភាព ៤.៤.២ ៖ ការលើកកម្ពស់ការប្រមូល និងការគ្រប់គ្រងកម្រៃ ឬឈ្នួលសេវា

នៅក្នុងអំឡុងពេលអនុវត្តផអ៥ទី១ កជទី២ ត្រូវបន្តផ្តោតលើការពង្រឹងការប្រមូលចំណូលពីកម្រៃ ឬឈ្នួលសេវានៃយន្តការច្រកចេញចូលតែមួយ និងកម្រៃពីសេវាផ្សេងទៀតតាមរយៈ ៖

- ការប្រមូល និងការគ្រប់គ្រងកម្រៃ ឬឈ្នួលសេវារបស់យន្តការច្រកចេញចូលតែមួយ និងអង្គភាពទទួលខុសត្រូវលើការប្រមូលចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការប្រមូល និងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដើម្បីប្រមូល និងគ្រប់គ្រងចំណូលមិនមែនសារពើពន្ធតាមរយៈយន្តការច្រកចេញចូលតែមួយ ព្រមទាំងទីចាត់ការ ការិយាល័យ និងអង្គភាពពាក់ព័ន្ធនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ទូទាត់កម្រៃ ឬឈ្នួលសេវានៃយន្តការច្រកចេញចូលតែមួយ ព្រមទាំងទីចាត់ការ ការិយាល័យ និងអង្គភាពពាក់ព័ន្ធនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- រាល់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលបង្កើតឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវមានការចូលរួមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានាអំពីការធ្វើសន្ទានកម្មទិន្នន័យ ជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ការផ្ទេរមុខងារផ្តល់សេវារដ្ឋបាល ឬសេវាសាធារណៈថ្មីបន្ថែមទៀតដែលអាចយកកម្រៃ ឬឈ្នួលសេវាបានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការសិក្សាអំពីជម្រើសនានានៃការប្រើប្រាស់ចំណូលដែលទទួលបានកម្រៃពីអ្នកប្រើប្រាស់សេវាសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (ឧទាហរណ៍

មុខងារគ្រប់គ្រងសំរាមសំណល់រឹង សេវាដឹកជញ្ជូនសាធារណៈ សេវាកម្សាន្ត សេវាអប់រំ និងសេវាសុខភាពនៅតាមមូលដ្ឋានជាដើម)

- ការលើកកម្ពស់ការប្រមូលចំណូលពីការជួលទ្រព្យសម្បត្តិដែលគ្រប់គ្រងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

## សកម្មភាពអាទិភាព ៤.៤.៣ ៖ ការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

កជទី២ ត្រូវរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រមួយស្តីពីចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយផ្អែកលើការសិក្សាដ៏ច្បាស់លាស់មួយ ព្រមទាំងមេរៀន និងបទពិសោធន៍ដែលបានអនុវត្តនៅក្នុងអំឡុងពេលនៃការអនុវត្តផអ៥ទី១។ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះនឹងត្រូវដាក់ឱ្យអនុវត្តក្នុងអំឡុងពេលនៃការអនុវត្តផអ៥ទី២ ស្របជាមួយយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ២០២៦-២០៣០។

ក្នុងការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ ចាំបាច់ត្រូវយកចិត្តទុកដាក់លើបញ្ហាមួយចំនួនដូចខាងក្រោម ៖

- ការកំណត់ឱ្យបានច្បាស់លាស់នូវទស្សនទាន និងក្របខ័ណ្ឌគតិយុត្តជាមូលដ្ឋានស្តីពីកម្រៃ ឬឈ្នួលសេវាក្នុងគោលបំណងលើកកម្ពស់ការប្រមូលចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិបន្ថែមទៀតពីការផ្តល់សេវាសាធារណៈ
- ការពិនិត្យឡើងវិញ ដើម្បីបង្កើនទំហំសេវា និង/ឬបន្ថែមសេវាថ្មីៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើនប្រភពថ្មីបន្ថែមទៀតនៃចំណូលមិនមែនសារពើពន្ធ
- ការលើកកម្ពស់ការចែករំលែកចំណូលមិនមែនសារពើពន្ធរវាងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការលើកកម្ពស់ការគ្រប់គ្រងចំណូលពីទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការរៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធអភិបាលកិច្ចឌីជីថលសម្រាប់ការផ្តល់សេវា និងការគ្រប់គ្រងចំណូលឱ្យកាន់តែមានភាពល្អប្រសើរឡើង (ឧទាហរណ៍ ការតភ្ជាប់ការផ្តល់សេវា ការគ្រប់គ្រងការងាររដ្ឋបាល និងការទទួលយោបល់ត្រលប់តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន)

### *លទ្ធផលរំពឹងទុក ៤.៥៖ ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្ទេរទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលាស្របតាមផែនការច្បាស់លាស់*

ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០១១) បានដាក់ចេញនូវគោលការណ៍ និងវិធានសំខាន់ៗនានាពាក់ព័ន្ធនឹងការគ្រប់គ្រង ចាត់ចែង ប្រើប្រាស់ និង

ទាញយកផលប្រយោជន៍ពីទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ផ្អែកតាមច្បាប់នេះ រដ្ឋបាលថ្នាក់ក្រោមជាតិអាចមានទ្រព្យសម្បត្តិពីរប្រភេទ ពោលគឺទ្រព្យសម្បត្តិដែលផ្ទេរពីថ្នាក់ជាតិ និងទ្រព្យសម្បត្តិដែលរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗរកបានដោយខ្លួនឯងផ្ទាល់។

ជាមួយគ្នានេះដែរ ក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្តនានាត្រូវបានរៀបចំឡើង ដើម្បីផ្តល់គោលការណ៍ណែនាំលម្អិតអំពីវិធីសាស្ត្រនានាសម្រាប់គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដែលក្នុងនោះរួមមានការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ ក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្តទាំងនោះរួមមាន អនុក្រឹត្យលេខ៦៦ ស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ (ឆ្នាំ២០១៧) ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ (ឆ្នាំ២០២០) និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាច្រើនទៀត។

ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋត្រូវបានលើកកម្ពស់ដោយតម្រូវឱ្យគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបង្កើតគណៈកម្មាធិការមួយ ដើម្បីត្រួតពិនិត្យលើបញ្ជីសារពើភ័ណ្ឌ ការចុះបញ្ជីការគ្រប់គ្រង និងជម្រះបញ្ជីទ្រព្យសម្បត្តិចេញពីបញ្ជីសារពើភ័ណ្ឌ ព្រមទាំងការរៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងការចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋ។ រដ្ឋបាលរាជធានី ខេត្ត និងមន្ទីរ អង្គភាពជំនាញនៃក្រសួង ស្ថាប័ននានានៅថ្នាក់រាជធានី ខេត្តត្រូវបានកំណត់ឱ្យប្រើប្រាស់ប្រព័ន្ធនេះចាប់ពីឆ្នាំ២០២១តទៅ ដោយឡែករដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅបន្តអនុវត្តតាមរបៀបការចុះបញ្ជីដោយដៃ។

មកទល់បច្ចុប្បន្ននេះ ការគ្រប់គ្រង និងការផ្ទេរទ្រព្យសម្បត្តិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់បានអនុវត្តឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលានៅឡើយ បើទោះបីជាមានការផ្ទេរមុខងារជាច្រើនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលតម្រូវឱ្យមានការផ្ទេរទ្រព្យសម្បត្តិភ្ជាប់ជាមួយនឹងមុខងារទាំងនោះក៏ដោយ។

ដើម្បីជានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៥ ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៣ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៤.៥.១ ៖ ការពិនិត្យឡើងវិញនូវក្របខ័ណ្ឌនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

កជទី២ ត្រូវរៀបចំឱ្យមានការសិក្សាមួយ ដើម្បីត្រួតពិនិត្យឡើងវិញឱ្យបានច្បាស់លាស់ទៅលើស្ថានភាពបច្ចុប្បន្ននៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយផ្តោតលើទិដ្ឋភាពសំខាន់ៗមួយចំនួនក្នុងនោះរួមមាន ការផ្សារភ្ជាប់រវាងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ការរៀបចំស្ថាប័ន (អាជ្ញាធរគ្រប់គ្រង អាជ្ញាធរកាន់កាប់ និងអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិ) ការតាមដានត្រួតពិនិត្យ សក្តានុពលចំណូល។ ជាមួយគ្នានេះដែរ ការសិក្សានេះក៏ត្រូវយកចិត្តទុកដាក់លើការវាយតម្លៃអំពីតម្រូវការសម្រាប់ការអភិវឌ្ឍសមត្ថភាព និងលទ្ធភាពនៃការដាក់ឱ្យអនុវត្តនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងការចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្ទេរទ្រព្យសម្បត្តិទៅឱ្យរដ្ឋបាលក្រុង ស្រុក។

## សកម្មភាពអាទិភាព ៤.៥.២ ៖ ការធ្វើវិមជ្ឈការលើការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ផ្អែកលើលទ្ធផលពីការសិក្សា កជទី២ ត្រូវរៀបចំផែនការលម្អិតមួយសម្រាប់លើកកម្ពស់ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ផ្អែកតាមផែនការនេះ ទ្រព្យសម្បត្តិរដ្ឋដែលពាក់ព័ន្ធនានានឹងត្រូវបានផ្ទេរពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការទទួលខុសត្រូវលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋពាក់ព័ន្ធនានាក៏នឹងត្រូវផ្ទេរពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសង្កាត់ (សង្កាត់ក្នុងរាជធានី) ព្រមទាំងពីរដ្ឋបាលក្រុង ស្រុកទៅឱ្យរដ្ឋបាលឃុំ សង្កាត់ស្របតាមមុខងារដែលបានផ្ទេរផងដែរ។

## សកម្មភាពអាទិភាព ៤.៥.៣ ៖ ការបង្កើនចំណូលពីការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ការពង្រឹង និងពង្រីកការប្រមូលចំណូលពីទ្រព្យសម្បត្តិដែលជាចំណែកមួយនៃចំណូលមូលដ្ឋានពីចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងនោះរួមមាន ការរៀបចំ ឬការកែលម្អសេចក្តីណែនាំនានាស្តីពីការកំណត់ថ្លៃឈ្នួល ការប្រមូល ការគ្រប់គ្រង និងបញ្ជិកាចំណូល ព្រមទាំងការប្រើប្រាស់ចំណូលនេះនៅក្នុងក្របខ័ណ្ឌថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

*លទ្ធផលរំពឹងទុក ៤.៦៖ មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌត្រូវបានកំណត់ទំហំដែលមានលក្ខណៈសមស្រប និងត្រូវបានវិភាជទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗតាមរូបមន្ត និងលក្ខណៈវិនិច្ឆ័យប្រកបដោយសមធម៌ ព្រមទាំងត្រូវបានបង្កើនទំហំជាបន្តបន្ទាប់ដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (ជាពិសេសថ្នាក់ក្រុង ស្រុក) ក្នុងការអនុវត្តមុខងារជាជម្រើស ឬមុខងារជាអាណត្តិទូទៅ*

មូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុក ត្រូវបានបង្កើតឡើងបន្ទាប់ពីរដ្ឋបាលទាំងនេះត្រូវបានរៀបចំបង្កើតឡើងក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអាណត្តិទី១របស់ខ្លួន និងក្នុងពេលដែលរដ្ឋបាលទាំងនោះ នៅពុំទាន់បានរៀបចំឱ្យមានចំណូលមូលដ្ឋានសម្រាប់អនុវត្តមុខងារចាំបាច់មួយចំនួន។ មូលនិធិទាំងនេះត្រូវបានវិភាជទៅឱ្យរដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុកនីមួយៗដោយផ្អែកតាមរូបមន្ត និងលក្ខណៈវិនិច្ឆ័យជាក់លាក់មួយចំនួនដើម្បីផ្តល់ធនធានជាធន្ទានុសិទ្ធិដល់រដ្ឋបាលឃុំ សង្កាត់ និងក្រុង ស្រុកសម្រាប់រ៉ាប់រងលើចំណាយប្រតិបត្តិការរដ្ឋបាលទូទៅ ដែលរួមមានបន្ទុកបុគ្គលិកនិងចំណាយប្រតិបត្តិការផ្នែករដ្ឋបាល ព្រមទាំងចំណាយសម្រាប់ការអភិវឌ្ឍន៍មូលដ្ឋានដែលរួមមាននូវការអនុវត្តគម្រោងខ្នាតតូចនានាដែលជាតម្រូវការជាអាទិភាពរបស់មូលដ្ឋាននីមួយៗ។

ធនធានមូលនិធិឃុំ សង្កាត់ដែលបានវិភាជទៅឱ្យរដ្ឋបាលឃុំ សង្កាត់នីមួយៗត្រូវបានបង្កើនឡើងជាបន្តបន្ទាប់ ដែលរហូតមកទល់បច្ចុប្បន្ននេះ ធនធាននៃមូលនិធិនេះត្រូវបានវាយតម្លៃថាមានអត្រា

សមស្របធៀបនឹងចំណូលរបស់ថវិកាជាតិ និងអាចផ្តល់លទ្ធភាពដល់រដ្ឋបាលឃុំ សង្កាត់នីមួយៗបំពេញការងារស្របតាមតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន។

ដោយឡែក ធនធានមូលនិធិក្រុង ស្រុកដែលបានវិភាជឱ្យទៅរដ្ឋបាលក្រុង ស្រុកនីមួយៗនៅមានទំហំតូចនៅឡើយបើប្រៀបធៀបនឹងតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។ បន្ទាប់ពីរដ្ឋបាលក្រុងស្រុកត្រូវបានសម្រួលមុខងារ និងរចនាសម្ព័ន្ធ ព្រមទាំងត្រូវបានប្រគល់នូវមុខងារថ្មីៗជាច្រើនបន្ថែមទៀត រដ្ឋបាលក្រុង ស្រុកនៅតែបន្តពឹងផ្អែកភាគច្រើនលើធនធានដែលទទួលបានពីការផ្ទេររបស់មូលនិធិក្រុងស្រុក បើទោះបីជាមានការផ្ទេរធនធានបន្ថែមមួយចំនួនពីថ្នាក់ជាតិក៏ដោយ។

មកទល់បច្ចុប្បន្ននេះ ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្តភាគច្រើនបានមកពីប្រភពចំណូលនៃប្រភេទពន្ធមួយចំនួនដែលត្រូវបានប្រគល់ទៅឱ្យរដ្ឋបាលទាំងនេះ។ ទោះបីយ៉ាងនេះក្តី ការប្រគល់នូវប្រភេទពន្ធ និងមិនមែនពន្ធជាក់លាក់មួយចំនួនទៅឱ្យរដ្ឋបាលរាជធានី ខេត្តធ្វើជាចំណូលមូលដ្ឋានសម្រាប់រ៉ាប់រងទាំងស្រុងទៅលើចំណាយរបស់ខ្លួនបានបង្កលក្ខណៈអំណោយផលដល់រដ្ឋបាលនៃតំបន់ទីប្រជុំជនឱ្យមានលទ្ធភាពប្រមូលចំណូលបានច្រើនលើសលុបជាងរដ្ឋបាលតំបន់ជនបទ ដែលតម្រូវឱ្យមានការពិនិត្យ និងដោះស្រាយឡើងវិញដើម្បីធានាបាននូវប្រព័ន្ធបែងចែកធនធានហិរញ្ញវត្ថុរវាងរដ្ឋបាលរាជធានីខេត្តប្រកបដោយសមធម៌។ ពាក់ព័ន្ធនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកាត់យកនូវចំណូលមួយចំណែកពីរដ្ឋបាលរាជធានីភ្នំពេញ និងខេត្តមួយចំនួន ដើម្បីបែងចែកឡើងវិញទៅឱ្យរដ្ឋបាលខេត្តដទៃទៀត។ ក្នុងការបែងចែកឡើងវិញនេះ ចាំបាច់ត្រូវកំណត់បាននូវប្រព័ន្ធបែងចែកមួយដែលមានរូបមន្ត និងលក្ខណៈវិនិច្ឆ័យច្បាស់លាស់ដែលអាចធានាបានសមធម៌ និងអាចព្យាករណ៍បាន។

ជារួម នៅក្នុងក្របខ័ណ្ឌនៃការផ្ទេរធនធានហិរញ្ញវត្ថុតាមរយៈមូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុងស្រុក ព្រមទាំងការប្រគល់នូវប្រភេទពន្ធ និងមិនមែនពន្ធជាក់លាក់មួយចំនួនទៅឱ្យរដ្ឋបាលរាជធានី ខេត្តនៅមានបញ្ហាប្រឈមពាក់ព័ន្ធនឹងអតុល្យភាព ក្នុងការទទួលបាននូវចំណូលថវិការវាងរដ្ឋបាលប្រភេទដូចគ្នានិងរវាងរដ្ឋបាលថ្នាក់ផ្សេងៗគ្នា ដែលតម្រូវឱ្យមានការពិនិត្យ និងរៀបចំកែលម្អឡើងវិញនូវប្រព័ន្ធបែងចែកធនធានហិរញ្ញវត្ថុប្រកបដោយសមធម៌ផ្អែកលើរូបមន្ត និងលក្ខណៈវិនិច្ឆ័យសមស្របនឹងស្ថានភាពរីកចម្រើនសេដ្ឋកិច្ច និងសង្គមនាពេលបច្ចុប្បន្ន និងផ្អែកលើតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់នីមួយៗជាពិសេសការទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈចាំបាច់នានាជូនប្រជាពលរដ្ឋ។

អាស្រ័យហេតុនេះ អាទិភាពជាយុទ្ធសាស្ត្ររបស់ កជទី២ ពាក់ព័ន្ធនឹងមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌរួមមាន ១). ការបង្កើនការផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលក្រុង ស្រុក ២). ការពង្រឹងនូវប្រព័ន្ធគ្រប់គ្រងមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ និង ៣). ការលើកកម្ពស់សិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌសម្រាប់គម្រោងសេវាកម្មនានា។

ដើម្បីធានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៦ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៣ ដូចខាងក្រោម ៖

## សកម្មភាពអាទិភាព ៤.៦.១ ៖ ការបង្កើនការផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាល ក្រុង ស្រុក

រដ្ឋបាលក្រុង ស្រុកបាន និងកំពុងកែសម្រួលនូវរចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវរបស់ខ្លួនសំដៅជំរុញឱ្យរដ្ឋបាលទាំងនេះក្លាយទៅជារដ្ឋបាលមូលដ្ឋានដ៏សំខាន់ ដោយមានកិច្ចសហការជាមួយរដ្ឋបាលឃុំ សង្កាត់ក្នុងការអនុវត្តគម្រោងខ្នាតតូច និងមធ្យមនានា ដើម្បីអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈចាំបាច់មួយចំនួនដោយផ្ទាល់ជូនប្រជាពលរដ្ឋ។ ទោះបីយ៉ាងនេះក៏ដោយ រហូតមកទល់បច្ចុប្បន្ននេះចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុកនៅបន្តពឹងផ្អែកស្ទើរទាំងស្រុងទៅលើការផ្ទេរធនធានពីមូលនិធិក្រុង ស្រុក ដែលផ្អែកតាមការចំណាយជាក់ស្តែងបានបង្ហាញឱ្យឃើញថា មួយចំណែកធំនៃធនធាននេះត្រូវបានប្រើប្រាស់សម្រាប់ចំណាយប្រតិបត្តិការរដ្ឋបាលទូទៅ និងមានចំណែកសេសសល់តិចតួចបំផុតសម្រាប់ចំណាយលើការអភិវឌ្ឍ និងការបំពេញមុខងារជាអាណត្តិទូទៅរបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពនានារបស់មូលដ្ឋាន។ ជាមួយគ្នានឹងការផ្ទេរមុខងារថ្មីៗជាច្រើនទៅឱ្យរដ្ឋបាលក្រុង ស្រុក នៅឆ្នាំ២០២១ថ្នាក់ជាតិបានផ្ទេរធនធានមនុស្ស និងធនធានថវិកាមួយចំនួនបន្ថែមទៀតទៅឱ្យរដ្ឋបាលក្រុង ស្រុក ក៏ប៉ុន្តែធនធានថវិកាបន្ថែមនេះភាគច្រើនសម្រាប់តែចំណាយលើបន្ទុកបុគ្គលិកប៉ុណ្ណោះ ដែលជាហេតុបង្កឱ្យរដ្ឋបាលក្រុង ស្រុកនៅតែមានបញ្ហាប្រឈមជាច្រើនអំពីកង្វះខាតធនធានក្នុងការចំណាយលើផ្នែកប្រតិបត្តិការរដ្ឋបាល និងការអនុវត្តមុខងារថ្មីៗទាំងនោះ។

អាស្រ័យហេតុនេះ ក្នុងដំណាក់កាលនៃផអ៥ទី១នៃកជទី២ មូលនិធិក្រុង ស្រុកនឹងត្រូវបានពិនិត្យ និងកែលម្អឡើងវិញក្នុងគោលបំណងបង្កើនអត្រាការផ្ទេរធនធានពីថវិការដ្ឋសំដៅផ្តល់លទ្ធភាពឱ្យរដ្ឋបាលក្រុង ស្រុកទទួលបានធនធានសមស្របពីមូលនិធិនេះសម្រាប់អនុវត្តមុខងារជាអាណត្តិទូទៅរបស់ខ្លួន និងអាចចូលរួមបំពេញនូវកង្វះខាតនៃចំណាយប្រតិបត្តិការរដ្ឋបាល ព្រមទាំងការអនុវត្តមុខងារថ្មីៗផងដែរ។ ជាមួយគ្នានេះដែរ រូបមន្ត និងលក្ខណៈវិនិច្ឆ័យសម្រាប់ការបែងចែកធនធានពីមូលនិធិនេះទៅឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗចាំបាច់ត្រូវពិនិត្យ និងកែសម្រួលឡើងវិញដើម្បីធានាដល់ការបែងចែកប្រកបដោយសមធម៌ ព្រមទាំងធានាបាននូវការកាត់បន្ថយគម្លាតនៃការអភិវឌ្ឍរវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ និងស្របតាមស្ថានភាពបច្ចុប្បន្ននៃការរីកចម្រើនសេដ្ឋកិច្ច និងសង្គមជាតិ។

នៅក្នុងដំណាក់កាលផអ៥ទី១នេះ ក៏ចាំបាច់រៀបចំឱ្យមានការសិក្សាអំពីប្រភេទចំណូលមិនមែនសារពើពន្ធជាក់លាក់មួយចំនួនដែលត្រូវបន្ថែមទៅឱ្យរដ្ឋបាលក្រុងស្រុក និងសិក្សាអំពីលទ្ធភាពប្រភេទពន្ធដែលជាគុណប្រយោជន៍ដល់ថវិការបស់រដ្ឋបាលក្រុង ស្រុកចាប់ផ្តើមអនុវត្តនៅក្នុងដំណាក់កាលនៃផអ៥ទី២ ដើម្បីបង្កើតជាចំណូលមូលដ្ឋានរបស់ខ្លួន។ ចំណូលមូលដ្ឋានរបស់រដ្ឋបាលក្រុង ស្រុកដែលបានមកពីចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធនឹងត្រូវបានបង្កើនជាបណ្តើរៗ ដើម្បីធានាដល់ការកាត់បន្ថយនូវការពឹងផ្អែកទៅលើការផ្ទេរធនធានពីថ្នាក់ជាតិ ការលើកកម្ពស់ភាពប្រកួតប្រជែង និងប្រសិទ្ធភាពនៃការប្រមូលចំណូលមូលដ្ឋាន និងការលើកកម្ពស់គណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុកចំពោះប្រជាពលរដ្ឋ។

## សកម្មភាពអាទិភាព ៤.៦.២ ៖ ការពង្រឹងនូវប្រព័ន្ធគ្រប់គ្រងមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ

កន្លងមកនេះ "មូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ" ត្រូវបានបង្កើតឡើងតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រងគ្រងឆ្នាំ២០២០ ដែលមានប្រភពចំណូលពីអតិរេកថវិកានៅដំណាច់ឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់។ មូលនិធិនេះត្រូវបានបែងចែកត្រឡប់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមថ្នាក់នីមួយៗតាមបែបផែនខុសៗគ្នា ពោលគឺ រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់នីមួយៗទទួលបានការបែងចែកត្រលប់ទៅវិញតាមទំហំអតិរេកថវិការបស់រដ្ឋបាលសាមីនីមួយៗ។ ដោយឡែកមូលនិធិនេះពុំត្រូវបានបែងចែកទៅឱ្យរដ្ឋបាលរាជធានី ខេត្តនីមួយៗវិញទៅតាមទំហំអតិរេកថវិការបស់រដ្ឋបាលរាជធានី ខេត្តសាមីនីមួយៗនោះទេ ពោលគឺបានបែងចែកទៅតាមសំណើនានារបស់រដ្ឋបាលរាជធានី ខេត្តនីមួយៗ ដែលត្រូវពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទោះបីយ៉ាងណាក៏ដោយ ការបែងចែកមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាចំណែកមួយនៃចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ អាស្រ័យហេតុនេះ នៅក្នុងដំណាក់កាលនៃការអនុវត្តផអ៥ទី១ នៃកជទី២ ចាំបាច់ត្រូវរៀបចំនូវក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្តច្បាស់លាស់មួយលើការគ្រប់គ្រង និងការបែងចែកមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការអនុវត្តក្របខ័ណ្ឌថវិការយៈពេលមធ្យមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលនឹងត្រូវរៀបចំនៅពេលខាងមុខឆាប់ៗនេះ និងធានាបាននូវការបែងចែកមូលនិធិនេះប្រកបដោយតម្លាភាព ស័ក្តិសិទ្ធិភាព និងសមធម៌។

នៅក្នុងដំណាក់កាលនៃផអ៥ទី២ នៃកជទី២ ចាំបាច់ត្រូវរៀបចំឱ្យមានការសិក្សា និងពិនិត្យកែលម្អឡើងវិញលើការប្រមូល គ្រប់គ្រង និងបែងចែកធនធាននៃមូលនិធិនេះទាំងថ្នាក់រាជធានី ខេត្ត និងនៅថ្នាក់ក្រុង ស្រុក ដើម្បីធានាដល់ការកាត់បន្ថយគម្លាតនៃការអភិវឌ្ឍនៃតំបន់នានាតាមរយៈការកាត់យកចំណូលមួយចំណែកសមស្របពីរដ្ឋបាលដែលមានចំណូលខ្ពស់មកជួយគាំទ្រដល់រដ្ឋបាលដែលមានចំណូលទាប។

## សកម្មភាពអាទិភាព ៤.៦.៣. ៖ ការលើកកម្ពស់សិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌសម្រាប់គម្រោងសេវាកម្មនានា

ក្នុងដំណាក់កាលផអ៥ទី១ នៃកជទី២ ចាំបាច់ត្រូវរៀបចំឱ្យមានការសិក្សា និងពិនិត្យមើលឡើងវិញលើលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីធានាដល់ការលើកកម្ពស់ដល់សិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តនូវគម្រោងសេវាកម្មនានាដែលបម្រើឱ្យការអភិវឌ្ឍមូលដ្ឋានទាំងផ្នែកសេដ្ឋកិច្ច និងសង្គមផងដែរ។

*លទ្ធផលរំពឹងទុក ៤.៧៖ មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌត្រូវបានកំណត់នូវទំហំដែលមានលក្ខណៈសមស្រប និងត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ក្នុងការអនុវត្តមុខងារជាកាតព្វកិច្ចនានាដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ*

ជាគោលការណ៍ មុខងារជាកាតព្វកិច្ចណាមួយដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានផ្តល់ហិរញ្ញប្បទានជាការឧបត្ថម្ភធនពីថ្នាក់ជាតិក្នុងក្របខ័ណ្ឌជាការផ្ទេរធនធានផ្ទេរមានភ្ជាប់លក្ខខណ្ឌក្នុងទំហំសមស្របដែលរដ្ឋបាលថ្នាក់ក្រោមជាតិអាចបំពេញមុខងារនេះប្រកបដោយប្រសិទ្ធភាព និងតាមស្តង់ដារដែលបានកំណត់ដោយថ្នាក់ជាតិ។

នៅក្នុងការអនុវត្តជាក់ស្តែងនាពេលកន្លងមក ការកំណត់ធនធានមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារជាកាតព្វកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្តតាមបែបផែនផ្សេងៗគ្នាពោលគឺ ធនធានសម្រាប់អនុវត្តមុខងារជាកាតព្វកិច្ចមួយចំនួនត្រូវបានផ្ទេរពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការកាត់ថវិការបស់ក្រសួងស្ថាប័នសាមី និងមួយចំនួនទៀតត្រូវកំណត់ឱ្យប្រើប្រាស់ថវិកាដែលបានពីចំណូលមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ដោយឡែក រដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានតម្រូវឱ្យរៀបចំសំណើគម្រោងថវិកាសម្រាប់អនុវត្តមុខងារជាកាតព្វកិច្ចនីមួយៗ ក្នុងក្របខ័ណ្ឌជាកញ្ចប់ថវិកាដាច់ដោយឡែកមួយពីគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងតម្រូវឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិការពារសំណើគម្រោងថវិកានេះជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយមានការចូលរួមពីក្រសួងវិស័យសាមីនីមួយៗផងដែរ។

ជាមួយគ្នានេះដែរ ក្នុងចំណោមមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសការផ្ទេរមុខងារចំនួន៥៥ទៅឱ្យរដ្ឋបាលក្រុង ស្រុកនាពេលថ្មីៗនេះ នៅពុំទាន់មានការបែងចែកច្បាស់លាស់ថាតើមុខងារណាមួយជាមុខងារជាកាតព្វកិច្ច និងមុខងារណាមួយជាមុខងារជាជម្រើសនៅឡើយទេ។ ទន្ទឹមគ្នានេះ ក៏មានមុខងារដែលបានផ្ទេរមួយចំនួនពុំមានមូលដ្ឋានច្បាស់លាស់សម្រាប់ការកំណត់ថវិកាចំណាយ និងមានមុខងារមួយចំនួនទៀតក៏ក្រសួង ស្ថាប័នពុំដែលមានថវិកាសម្រាប់អនុវត្តនៅមុនពេលមុខងារទាំងនេះត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកផងដែរ។

ផ្អែកតាមស្ថានភាពខាងលើនេះ បានឆ្លុះបញ្ចាំងឱ្យឃើញអំពីបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងប្រព័ន្ធផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលតម្រូវឱ្យមានការដោះស្រាយឱ្យបានសមស្របតាមគោលការណ៍វិមជ្ឈការហិរញ្ញវត្ថុ។

អាស្រ័យហេតុនេះ សកម្មភាពជាអាទិភាពរបស់កជទី២ ពាក់ព័ន្ធនឹងការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌគឺ ការបន្តអនុវត្តការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌក្នុងក្របខ័ណ្ឌដែលមានបច្ចុប្បន្ន និងការរៀបចំកែលម្អក្របខ័ណ្ឌទូទៅនៃការផ្តល់ហិរញ្ញប្បទានដល់មុខងារជាកាតព្វកិច្ចជាបណ្តើរៗ ក្នុងគោលបំណងធានាដល់ការអនុវត្តពេញលេញនូវក្របខ័ណ្ឌដែលបានកែលម្អនេះនៅក្នុងអំឡុងពេលផអ៥ទី២ នៃកជទី២។

ដើម្បីជានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៧ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ១ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៤.៧.១ ៖ ការលើកកម្ពស់ការអនុវត្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌក្នុងក្របខ័ណ្ឌដែលមានបច្ចុប្បន្ន ព្រមទាំងរៀបចំ និងកែលម្អក្របខ័ណ្ឌផ្ដល់ហិរញ្ញប្បទានដល់មុខងារជាកាតព្វកិច្ចឱ្យកាន់តែប្រសើរឡើង

នៅក្នុងអំឡុងពេលនៃផអ៥ទី១ នៃកជទី២ ការអនុវត្តក្របខ័ណ្ឌដែលមានស្រាប់នាពេលបច្ចុប្បន្ននៃការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌនឹងត្រូវបានពង្រឹង ដើម្បីធានាថាមុខងារជាកាតព្វកិច្ចដែលផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងនោះរាប់បញ្ចូលទាំងមុខងារជាកាតព្វកិច្ចទាំងឡាយដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកនាពេលថ្មីៗកន្លងនេះត្រូវបានផ្ដល់ហិរញ្ញប្បទានយ៉ាងពេញលេញ ដើម្បីធានាដល់ការផ្ដល់សេវាជូនប្រជាពលរដ្ឋបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។ កជទី២នឹងបន្តតាមដានត្រួតពិនិត្យលើការអនុវត្តមុខងារដែលបានផ្ទេរ និងធានាថាក្នុងករណីមានបញ្ហាកើតឡើងពាក់ព័ន្ធនឹងការផ្ទេរធនធាន និងការអនុវត្តថវិកា បញ្ហានោះនឹងត្រូវបានដោះស្រាយជាបន្ទាន់។

ក្នុងអំឡុងពេលនៃផអ៥ទី១នេះដែរ ក្របខ័ណ្ឌទូទៅសម្រាប់ផ្ដល់ហិរញ្ញប្បទានដល់មុខងារជាកាតព្វកិច្ចនឹងត្រូវបានពិនិត្យមើល និងកែលម្អឡើងវិញផ្អែកតាមមេរៀន និងបទពិសោធន៍នៃការអនុវត្តមុខងារជាកាតព្វកិច្ចនានាដែលបានផ្ទេរកន្លងមក ដើម្បីធានាដល់ការចាប់ផ្ដើមអនុវត្តការគ្រប់គ្រងធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌរបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយលក្ខណៈជាប្រព័ន្ធ និងមានប្រសិទ្ធភាពចាប់ពីផអ៥ទី២ នៃកជទី២តទៅ។ បញ្ហាសំខាន់ៗដែលត្រូវពិនិត្យមើល និងកែលកម្អឡើងវិញរួមមាន ៖

- ការរៀបចំបង្កើតបទដ្ឋានជារួមមួយដែលរួមមាននូវលក្ខណៈវិនិច្ឆ័យ រូបមន្ត និងលក្ខខណ្ឌនានា ដើម្បីជាមូលដ្ឋានសម្រាប់គណនាទំហំធនធានហិរញ្ញវត្ថុដ៏សមស្របមួយដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់រ៉ាប់រងទាំងបន្ទុកបុគ្គលិក ចំណាយប្រតិបត្តិការ និងចំណាយលើការអនុវត្តមុខងារជាកាតព្វកិច្ចនីមួយៗដែលបាន និងត្រូវបន្តផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការពិនិត្យមើល និងកែលម្អឡើងវិញនូវលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹង លក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ ដើម្បីធានាដល់ការដាក់បញ្ចូលធនធានទាំងនេះទៅក្នុងគម្រោងថវិការួមតែមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការពិនិត្យ និងកែសម្រួលឡើងវិញនូវខ្ទង់ថវិកាទាំងរបស់ថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការឧបត្ថម្ភធនរបស់ថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើតនូវខ្ទង់

ថវិកាដាច់ដោយឡែកពីគ្នាដោយរួមមានខ្ទង់ថវិកាសម្រាប់ការឧបត្ថម្ភធនពីថ្នាក់ជាតិក្នុងក្របខ័ណ្ឌជាធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌ និងខ្ទង់ថវិកាសម្រាប់ការឧបត្ថម្ភធនក្នុងក្របខ័ណ្ឌជាធនធានហិរញ្ញវត្ថុផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ

- ការពិនិត្យមើល និងរៀបចំឡើងវិញនូវការធ្វើសមាហរណកម្មធនធានដែលផ្តល់ហិរញ្ញប្បទានពីគម្រោងរបស់ដៃគូអភិវឌ្ឍន៍នានាទៅក្នុងក្របខ័ណ្ឌនៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ
- ការពិនិត្យ និងកែលម្អឡើងវិញនូវប្រព័ន្ធគណនេយ្យថវិការបស់ថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលបំណងធានាដល់ការកត់ត្រាឱ្យបានច្បាស់លាស់លើការប្រើប្រាស់ធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌក្នុងការអនុវត្តមុខងារជាកាតព្វកិច្ចនីមួយៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការវាយតម្លៃលើលទ្ធផលនៃការអនុវត្ត "ថវិកាផ្សារភ្ជាប់ទៅនឹងគោលនយោបាយ" តាមវិស័យនីមួយៗ។

លិខិតបទដ្ឋាន និងប្រព័ន្ធដែលបានរៀបចំ និងកែលម្អខាងលើពាក់ព័ន្ធនឹងក្របខ័ណ្ឌទូទៅនៃការផ្តល់ហិរញ្ញប្បទានដល់មុខងារជាកាតព្វកិច្ចនឹងត្រូវបានអនុវត្តពេញលេញនៅក្នុងអំឡុងពេលផអ៥ទី២ នៃ កជទី២ ដោយមានការបន្សុីគ្នាជាមួយនឹងការរៀបចំ និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្រ្តកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលក្រោមជាតិឆ្នាំ២០២៦-២០៣០។

### *លទ្ធផលរំពឹងទុក ៤.៨៖ ក្របខ័ណ្ឌសម្រាប់ផ្តល់ហិរញ្ញប្បទានការវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដ៏ច្បាស់លាស់មួយត្រូវបានបង្កើត និងពង្រឹងការអនុវត្ត*

កន្លងមកនេះ រួមមានគម្រោងវិនិយោគសាធារណៈមួយចំនួនត្រូវបានអនុវត្តដោយប្រើប្រាស់ដោយថវិកាផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ ជាមួយគ្នានោះដែរ មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើតនៅក្នុងឆ្នាំ២០១៦ ដើម្បីផ្តល់ហិរញ្ញប្បទានបន្ថែមដល់រដ្ឋបាលថ្នាក់ក្រោមជាតិជាពិសេសរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលខណ្ឌក្នុងការអនុវត្តនូវគម្រោងអភិវឌ្ឍចាំបាច់មួយចំនួនដែលរដ្ឋបាលទាំងនោះ ពុំអាចមានលទ្ធភាពប្រើប្រាស់នូវថវិការបស់ខ្លួនដែលបានមកពីការវិភាជនៃមូលនិធិក្រុង ស្រុក និងថវិការបស់រដ្ឋបាលរាជធានី។ ទោះបីយ៉ាងណាក៏ដោយ រហូតដល់បច្ចុប្បន្ននេះការផ្តល់មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិនៅមានទំហំតូចនៅឡើយ ហើយនៅពុំទាន់បានជួយគាំទ្រដល់រដ្ឋបាលរាជធានី ខេត្ត និងឃុំ សង្កាត់នៅឡើយ។ ក្នុងន័យនេះ ដើម្បីធានាបាននូវការបង្កើនការផ្តល់ហិរញ្ញប្បទានសម្រាប់ការវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានជម្រើសចំនួន៣ ដែលចាំបាច់ត្រូវបានគិតគូរពិចារណានៅក្នុងការអនុវត្ត កជទី២ ពោលគឺ៖ ១). ការបង្កើនធនធានមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីពង្រីកការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ ២). ការបង្កើតមូលនិធិភាតរភាពដែលមានគោលបំណងក្នុងការកាត់បន្ថយនូវគម្លាតទំហំថវិការវាងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗដែលមានប្រភេទដូចគ្នា និង ៣). ការបង្កើតកញ្ចប់ថវិកាពិសេសសម្រាប់ជួយគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសក្តានុពលតិចតួច ក៏ដូចជាការអភិវឌ្ឍបន្ថែមនូវហេដ្ឋា

របេនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនានាដែលជាតំបន់ប៉ូលសេដ្ឋកិច្ចសំខាន់ៗរបស់ជាតិ ដើម្បីធានាដល់ការកាត់បន្ថយនូវគម្លាតនៃការអភិវឌ្ឍរវាងតំបន់នានា និងការចូលរួមចំណែកដ៏មានប្រសិទ្ធភាពក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ។

យុទ្ធសាស្ត្រស្តីពីការកែទម្រង់ការគ្រប់គ្រងការវិនិយោគសាធារណៈ (២០១៩-២០២៥) មានវិសាលភាពគ្របដណ្តប់ទាំងការវិនិយោគសាធារណៈនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ យុទ្ធសាស្ត្រនេះបានកំណត់នូវផ្នែកសំខាន់ៗដែលត្រូវកែទម្រង់ដូចខាងក្រោម ៖

- ការតម្រឹមនូវការគ្រប់គ្រងការវិនិយោគសាធារណៈទាំងអស់ដោយយកចិត្តទុកដាក់ទៅលើអាទិភាពនានានៃការអភិវឌ្ឍដែលមានលក្ខណៈជាយុទ្ធសាស្ត្រ
- ការអនុវត្តតាមដំណាក់កាលទាំង៨នៃវដ្តគម្រោងវិនិយោគសាធារណៈ
- សារៈសំខាន់នៃការបង្កើតទិន្នន័យមូលដ្ឋានមួយសម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈគ្រប់ប្រភេទ។

ដើម្បីធានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៨ ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៤ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៤.៨.១៖ ការពិនិត្យមើលឡើងវិញ និងពង្រឹងការគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ

ក្នុងអំឡុងឆ្នាំទី១ និងឆ្នាំទី២នៃផអ៥ទី១ នៃកជទី២ ចាំបាច់ត្រូវរៀបចំឱ្យមានការសិក្សាមួយដើម្បីពិនិត្យមើលឡើងវិញលើមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងគោលបំណង ១). វាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តគម្រោងនានាដែលផ្តល់ហិរញ្ញប្បទានដោយមូលនិធិ ២). កំណត់អំពីអនាគតនៃប្រភពចំណូលរបស់មូលនិធិ ៣). កែសម្រួលរូបមន្តសម្រាប់ការបែងចែក និងលក្ខណៈវិនិច្ឆ័យរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលអាចទទួលបានធនធានពីមូលនិធិ និង ៤). ធានាដល់ការដាក់បញ្ចូលធនធានផ្តល់ពីមូលនិធិនេះទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការធ្វើលទ្ធកម្មគម្រោងដោយរដ្ឋបាលថ្នាក់ក្រោមជាតិផ្ទាល់។

ក្នុងអំឡុងពេលផអ៥ទី២ ចាំបាច់ត្រូវមានការសិក្សាពីជម្រើសនានាដែលអាចធានាដល់ការបន្សុីគ្នាអំពីបែបផែននៃការអនុវត្តរវាងយន្តការមួយចំនួន ដែលផ្តល់ហិរញ្ញប្បទានបន្ថែមដល់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់វិនិយោគលើវិស័យដាក់លាក់នានាដូចជា យន្តការផ្តល់ហិរញ្ញប្បទានពីមូលនិធិអាកាសធាតុបៃតង(GCF) សម្រាប់ដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុដែលគ្រប់គ្រងដោយលេខាធិការដ្ឋាន គ.ជ.អ.ប.ជាមួយនឹងមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងលទ្ធភាពក្នុងការធ្វើសមាហរណកម្មយន្តការទាំងនេះទៅក្នុងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិនាពេលអនាគត។

### សកម្មភាពអាទិភាព ៤.៨.២៖ ការលើកកម្ពស់ក្របខ័ណ្ឌសម្រាប់គ្រប់គ្រងធនធានរបស់ដៃគូអភិវឌ្ឍន៍ដែលផ្ដល់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

នាពេលបច្ចុប្បន្ន ការផ្ដល់ហិរញ្ញប្បទានពីគម្រោងដៃគូអភិវឌ្ឍន៍មួយចំនួនត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈប្រព័ន្ធរតនាគារជាតិ ដោយឡែកក៏មានគម្រោងដៃគូអភិវឌ្ឍន៍មួយចំនួនបានផ្ទេរធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈគណនីធនាគារពាណិជ្ជឯកជន និងពុំត្រូវបានដាក់បញ្ចូលទៅក្នុងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។ អាស្រ័យហេតុនេះ ក្នុងអំឡុងផអ៥ទី១ កជទី២ ត្រូវពិនិត្យឡើងវិញនូវក្របខ័ណ្ឌសម្រាប់គ្រប់គ្រងធនធាននៃគម្រោងរបស់ដៃគូអភិវឌ្ឍន៍នានា ដែលផ្ដល់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់គាំទ្រគម្រោងវិនិយោគនានា ដើម្បីធានាដល់ការត្រួតពិនិត្យតាមដាន និងការដាក់បញ្ចូលធនធាននៃគម្រោងរបស់ដៃគូអភិវឌ្ឍន៍ទៅក្នុងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### សកម្មភាពអាទិភាព ៤.៨.៣៖ ការសិក្សា និងរៀបចំក្របខ័ណ្ឌសម្រាប់បង្កើតមូលនិធិភាតរភាព និងកញ្ចប់ថវិកាពិសេស

កជទី២ នឹងរៀបចំឱ្យមានការសិក្សាមួយដើម្បីកំណត់អំពីជម្រើសនានាក្នុងការផ្ដល់លទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចទទួលបានធនធានពីប្រភពនានាបន្ថែមទៀតសម្រាប់ការវិនិយោគ។ ជម្រើសទាំងនេះរួមមាន ១). ការបង្កើតនូវមូលនិធិភាតរភាពដែលបានមកពីការកាត់ចំណូលមួយចំណែកពីរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានចំណូលខ្ពស់ ដើម្បីបែងចែកទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងប្រភេទតែមួយដែលមានចំណូលតិចតួច ដើម្បីធានាកាត់បន្ថយនូវគម្លាតធនធាន និងការអភិវឌ្ឍរវាងតំបន់នានា និង ២). ការបង្កើតកញ្ចប់ថវិកាពិសេសនៃថវិកាជាតិសម្រាប់ជួយគាំទ្រដោយឡែកដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសក្ដានុពលតិចតួច ក៏ដូចជាការអភិវឌ្ឍបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនានាដែលជាតំបន់ប៉ូលសេដ្ឋកិច្ចសំខាន់ៗរបស់ជាតិ ដើម្បីធានាដល់ការកាត់បន្ថយនូវគម្លាតនៃការអភិវឌ្ឍរវាងតំបន់នានា និងការចូលរួមចំណែកដ៏មានប្រសិទ្ធភាពក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ។ ក្នុងករណីដែលយន្តការទាំងនេះត្រូវបានបង្កើតឡើង ចាំបាច់ត្រូវពិចារណាអំពីជម្រើសនានានៃការគ្រប់គ្រងយន្តការទាំងនេះដែលអាចអនុវត្តតាមបែបផែនដោយឡែកពីគ្នា ឬត្រូវធ្វើសមាហរណកម្មទៅក្នុងយន្តការគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។

### សកម្មភាពអាទិភាព ៤.៨.៤៖ ការពង្រឹងក្របខ័ណ្ឌគ្រប់គ្រងការវិនិយោគសាធារណៈដែលប្រើប្រាស់ថវិកាផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ក្នុងអំឡុងផអ៥ទី១ នៃកជទី២ ការគ្រប់គ្រងវិនិយោគសាធារណៈដែលប្រើប្រាស់ថវិកាផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបន្តអនុវត្តផ្អែកតាមយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ (២០១៩-២០២៥) ដែលមានស្រាប់។ ជាមួយគ្នានេះដែរ នៅឆ្នាំទី៤ នៃផអ៥ ទី១ ចាំបាច់ត្រូវរៀបចំឱ្យមានការសិក្សា អំពីការរៀបចំយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ (២០២៦-២០៣០) ដើម្បីបន្សុីគ្នាជាមួយនឹងការរៀបចំយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (២០២៦-២០៣០) សំដៅធានាដល់ការផ្ដល់សិទ្ធិអំណាចកាន់តែច្រើនឡើង

ដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង និងអនុវត្តនូវគម្រោងវិនិយោគសាធារណៈដែលប្រើប្រាស់ថវិកាផ្ទាល់របស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព និងធានាដល់ការពង្រឹងនូវប្រព័ន្ធត្រួតពិនិត្យតាមដាន និងសវនកម្មរបស់ថ្នាក់ជាតិ។

### *លទ្ធផលរំពឹងទុក ៤.៩៖ ក្របខ័ណ្ឌសម្រាប់ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន ត្រូវបានបង្កើតឡើង និងដាក់ឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាព*

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជនសម្រាប់គ្រប់គ្រងវិនិយោគសាធារណៈ (២០១៦-២០២០) ដែលជាផែនទីបង្ហាញផ្លូវមួយសម្រាប់រៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជនស្របតាមស្តង់ដារអន្តរជាតិ។ សេចក្តីព្រាងច្បាប់ស្តីពីយន្តការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជនកំពុងត្រូវបានរៀបចំតាក់តែងដែលនឹងកំណត់អំពីសេចក្តីណែនាំនៃការគ្រប់គ្រងកិច្ចសន្យា ការសិក្សាលទ្ធភាពគម្រោង ការវិភាគផ្នែកហិរញ្ញវត្ថុ និងនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់គម្រោង។

ទោះបីយ៉ាងណាក៏ដោយ កជទី២ ត្រូវផ្តួចផ្តើមឱ្យមានការសិក្សាបន្ថែម ដើម្បីកំណត់នូវសក្តានុពលនៃគម្រោងក្នុងវិស័យនានា ដែលមានលក្ខណៈចាំបាច់សម្រាប់ដាក់បញ្ចូលទៅក្នុងក្របខ័ណ្ឌនៃភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន ហើយក្របខ័ណ្ឌភាពជាដៃគូនេះនឹងត្រូវបានដាក់ឱ្យអនុវត្តពេញលេញនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែរ នៅក្នុងការអនុវត្តសមាសភាគទី៥នៃកជទី២ ការផ្តល់សេវាសាធារណៈចាំបាច់នានាមួយចំនួនក៏ត្រូវបានចាត់ទុកជាកិច្ចការអាទិភាពមួយនៃក្របខ័ណ្ឌគ្រប់គ្រងភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនផងដែរ។

ដើម្បីធានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៩ ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ២ ដូចខាងក្រោម៖

#### សកម្មភាពអាទិភាព ៤.៩.១៖ ការសិក្សា និងរៀបចំនូវក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន

ក្នុងអំឡុងផអ៥ទី១ នៃកជទី២ ចាំបាច់ត្រូវរៀបចំឱ្យមានការសិក្សាមួយអំពីវិសាលភាព និងវិស័យជាសក្តានុពលនានាសម្រាប់រៀបចំក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន។ ការសិក្សានេះនឹងផ្តោតលើ៖ ១). ការកំណត់នូវវិស័យនានាសម្រាប់ការវិនិយោគក្នុងក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនដែលមានលទ្ធភាពបង្កើនចំណូលបានច្រើនជាងមុន មានការចំណាយតិច និង/ឬមានការលើកកម្ពស់ការផ្តល់សេវាបានល្អប្រសើរជាងមុន ២). ការកំណត់អំពីវិស័យវិនិយោគដែលមានភាពទាក់ទាញសម្រាប់វិនិយោគិនឯកជនក្នុងការវិនិយោគនៅកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ និង ៣). លទ្ធភាពនៃការបង្កើត និងកិច្ចប្រតិបត្តិការនៃភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន។

លទ្ធផលនៃការសិក្សានេះនឹងផ្តល់ជាអនុសាសន៍សម្រាប់ការរៀបចំបង្កើតក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនក្នុងអំឡុងផអ៥ទី១។ ជាមួយគ្នានេះដែរ គម្រោងវិនិយោគលើវិស័យសំខាន់ៗមួយចំនួនក្នុងក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជននឹងត្រូវបានអនុវត្តសាកល្បងក្នុងបណ្តាឆ្នាំចុងក្រោយនៃផអ៥ទី១ផងដែរ។

### សកម្មភាពអាទិភាព ៤.៩.២៖ ការដាក់ឱ្យអនុវត្តពេញលេញនូវក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន

ផ្អែកលើលទ្ធផលនៃការអនុវត្តសាកល្បងខាងលើ ក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជននឹងត្រូវបានពិនិត្យ និងកែលម្អឡើងវិញ ហើយបន្ទាប់មករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលបាននូវការបណ្តុះបណ្តាលសមត្ថភាពយ៉ាងគ្រប់គ្រាន់ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទាំងឡាយអាចចាប់ផ្តើមអនុវត្តពេញលេញនូវក្របខ័ណ្ឌនេះក្នុងបណ្តាឆ្នាំចុងក្រោយនៃផអ៥ទី២។

## *លទ្ធផលរំពឹងទុក ៤.១០៖ ប្រព័ន្ធសវនកម្ម និងអធិការកិច្ចលើការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង*

ក្នុងពេលដែល ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិកាន់តែច្រើនត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវពង្រឹងការធ្វើសវនកម្មផ្ទៃក្នុង និងការធ្វើអធិការកិច្ចពីខាងក្រៅ ដើម្បីធានាថាធនធានទាំងនោះត្រូវបានគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ស្របតាមច្បាប់ និងលិខិតបទដ្ឋាននានាដែលបានកំណត់។ កន្លងមកនេះ នៅក្នុងផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (២០១៩-២០២៥) បានកំណត់ឱ្យមានការរៀបចំបង្កើតនូវអង្គភាពសវនកម្មផ្ទៃក្នុង និងនីតិវិធីសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលរាជធានី ខេត្ត។ ជាមួយគ្នានោះដែរ រចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក និងខណ្ឌ បានបង្កើតឱ្យមានការិយាល័យត្រួតពិនិត្យផ្ទៃក្នុង។ ប៉ុន្តែនីតិវិធីនៃកិច្ចដំណើរការត្រួតពិនិត្យផ្ទៃក្នុងដែលមានបែបផែនជាការធ្វើសវនកម្មផ្ទៃក្នុងនៅពុំទាន់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនៅឡើយ។

ជាមួយគ្នានោះដែរ ដើម្បីធានាដល់ប្រសិទ្ធភាពនៃការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ចាំបាច់ត្រូវមានការធ្វើអធិការកិច្ចហិរញ្ញវត្ថុពីខាងក្រៅ (ពីថ្នាក់ជាតិ) ដែលប្រព័ន្ធនេះចាំបាច់ត្រូវបន្តពង្រឹងឱ្យមានលក្ខណៈជាប្រព័ន្ធ និងមានផែនការសកម្មភាពច្បាស់លាស់មួយ ព្រមទាំងធានាថាប្រព័ន្ធអធិការកិច្ចហិរញ្ញវត្ថុពីខាងក្រៅនេះធ្វើឱ្យមានការរំខានតិចតួចបំផុតដល់ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ដើម្បីធានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី១០ ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ២ ដូចខាងក្រោម៖

## សកម្មភាពអាទិភាព ៤.១០.១៖ ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង និងការរៀបចំនីតិវិធីសវនកម្មផ្ទៃក្នុងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

នៅក្នុងបណ្តាឆ្នាំដំបូងរបស់ផអ៥ទី១ នៃកជទី២ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងរួមសហការគ្នាជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃរៀបចំ និងដាក់ឱ្យអនុវត្តនីតិវិធីសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

អង្គភាពសវនកម្មផ្ទៃក្នុងនៃរដ្ឋបាលរាជធានី ខេត្តក៏នឹងត្រូវបានរៀបចំបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្តនីមួយៗ។ ជាមួយគ្នានោះដែរ តួនាទី និងភារកិច្ចរបស់ការិយាល័យត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក និងខណ្ឌនីមួយៗក៏នឹងត្រូវបានពិនិត្យមើលឡើងវិញដើម្បីជានាឱ្យមានការទទួលខុសត្រូវច្បាស់លាស់លើការងារសវនកម្មផ្ទៃក្នុង។ សវនករផ្ទៃក្នុងនៃអង្គភាពសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីដែលមានសមត្ថភាព និងចំណេះដឹងស្របតាមការកំណត់របស់ស្តង់ដារវិជ្ជាជីវៈសវនកម្មផ្ទៃក្នុង។

ប្រធានអង្គភាពសវនកម្មផ្ទៃក្នុង ឬប្រធានការិយាល័យត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំ និងដាក់របាយការណ៍សវនកម្មជូនទៅអភិបាលនៃគណៈអភិបាលដោយផ្ទាល់ក្នុងនាមជាប្រធានអង្គប្រតិបត្តិនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានោះដែរ ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក៏អាចបង្កើតនូវគណៈកម្មាធិការត្រួតពិនិត្យផ្ទៃក្នុង ឬសវនកម្មផ្ទៃក្នុងរបស់ខ្លួន ដើម្បីជានាបាននូវការធ្វើសវនកម្មទៅលើការបំពេញការងាររបស់ផ្នែកប្រតិបត្តិ។

## សកម្មភាពអាទិភាព ៤.១០.២៖ ការពង្រឹងការធ្វើអធិការកិច្ចហិរញ្ញវត្ថុពីខាងក្រៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ

ក្រៅពីការរៀបចំ និងពង្រឹងសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ កជទី២ ចាំបាច់ត្រូវរៀបចំឱ្យមានការសិក្សា ដើម្បីពិនិត្យមើលឡើងវិញសំដៅពង្រឹងប្រព័ន្ធអធិការកិច្ចហិរញ្ញវត្ថុរបស់ថ្នាក់ជាតិទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជានាឱ្យដំណើរការអធិការកិច្ចហិរញ្ញវត្ថុនេះ មានលក្ខណៈជាប្រព័ន្ធ និងមានការរំខានជាអប្បបរមាទៅលើបន្ទុកការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

នីតិវិធីនានាពាក់ព័ន្ធនឹងការធ្វើអធិការកិច្ចហិរញ្ញវត្ថុពីខាងក្រៅ នឹងត្រូវកែសម្រួលឱ្យមានលក្ខណៈសាមញ្ញ រួមទាំងមានការកំណត់ឱ្យបានច្បាស់លាស់នូវតួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចក្នុងការធ្វើអធិការកិច្ចហិរញ្ញវត្ថុពីខាងក្រៅទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ។

## តារាងទី ៧៖ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពនានាសម្រាប់សមាសភាគទី៤

<table>
<tr><td colspan="2">សមិទ្ធផលរំពឹងទុកនៃសមាសភាគទី៤៖ រដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានថវិកាដែលអាចព្យាករណ៍បាន និងមានទំហំសមស្របទៅនឹងមុខងារ និងអាទិភាពគោលនយោបាយជាតិ ហើយត្រូវបានវិភាជសម្រាប់ការប្រើប្រាស់ប្រកបដោយភាពបត់បែនក្នុងការឆ្លើយតបទៅនឹងតម្រូវការនានាដូចមានកំណត់នៅក្នុងផែនការអភិវឌ្ឍកម្មវិធីវិនិយោគ និងផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។</td></tr>
<tr><td colspan="2">លទ្ធផលរំពឹងទុក ៤.១៖ កិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អ និងបន្សុីគ្នា ផ្អែកលើចរិតលក្ខណៈនិងប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ស្របជាមួយគោលនយោបាយអាទិភាពថ្នាក់ជាតិ និងទិសដៅនៃកម្មវិធីកំណែទម្រង់សំខាន់ៗ និងផ្អែកលើទិន្នន័យច្បាស់លាស់។</td></tr>
<tr><th>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</th><th>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</th></tr>
<tr><td>✓ ៤.១.១៖ ការបន្សុីគ្នារវាងកិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៤.១.២៖ ការពិនិត្យ និងកែសម្រួលឡើងវិញប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៤.១.៣៖ ការរៀបចំឯកសារជាយុទ្ធសាស្ត្រនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៤.១.៤៖ ការពង្រឹងការប្រើប្រាស់ទិន្នន័យសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៤.១.៥៖ ការរៀបចំយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០២៦-២០៣០</td><td>✓ ៤.១.១៖ ការបន្សុីគ្នារវាងកិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៤.១.២៖ ការពិនិត្យ និងកែសម្រួលឡើងវិញប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៤.១.៣៖ ការរៀបចំឯកសារជាយុទ្ធសាស្ត្រនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៤.១.៤៖ ការពង្រឹងការប្រើប្រាស់ទិន្នន័យសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៤.១.៥៖ ការរៀបចំយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០២៦-២០៣០</td></tr>
</table>

<table>
<tr><td colspan="2">លទ្ធផលរំពឹងទុក ៤.២៖ ការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អដោយមានការ ផ្តល់សិទ្ធិអំណាចកាន់តែច្រើនឡើងទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមទិសដៅនៃយុទ្ធសាស្ត្រកែទម្រង់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។</td></tr>
<tr><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</td><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</td></tr>
<tr><td>✓ ៤.២.១៖ ការបន្តការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០១៩-២០២៥)<br>✓ ៤.២.២៖ ការធ្វើវិមជ្ឈការ និងការពង្រឹងការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ</td><td>✓ ៤.២.២៖ ការធ្វើវិមជ្ឈការ និងការពង្រឹងការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ</td></tr>
<tr><td colspan="2">លទ្ធផលរំពឹងទុក ៤.៣៖ ការបង្កើនប្រភពចំណូលមូលដ្ឋានជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានមកពីចំណូលសារពើពន្ធត្រូវបានសិក្សា និងដាក់ឱ្យអនុវត្ត។</td></tr>
<tr><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</td><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</td></tr>
<tr><td>✓ ៤.៣.១៖ ការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រងចំណូលសារពើពន្ធដែលមានស្រាប់<br>✓ ៤.៣.២៖ ការចែករំលែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់<br>✓ ៤.៣.៣ ៖ ការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ការបង្កើតមូលនិធិភាគរភាព និងការបន្ថែមប្រភេទពន្ធទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ</td><td>✓ ៤.៣.៣ ៖ ការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ការបង្កើតមូលនិធិភាគរភាព និងការបន្ថែមប្រភេទពន្ធទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ</td></tr>
</table>

<table>
<tr><td colspan="2">លទ្ធផលរំពឹងទុក ៤.៤៖ ការបង្កើនប្រភពចំណូលមូលដ្ឋានជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានមកពីចំណូលមិនមែនសារពើពន្ធត្រូវបានសិក្សា និងដាក់ឱ្យអនុវត្ត។</td></tr>
<tr><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</td><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</td></tr>
<tr><td>✓ ៤.៤.១ ៖ ការបន្សុីគ្នារវាងកម្មវិធីជាតិដំណាក់កាលទី២ និងឯកសារគោលស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ<br>✓ ៤.៤.២៖ ការលើកកម្ពស់ការប្រមូល និងការគ្រប់គ្រងកម្រៃ ឬឈ្នួលសេវា<br>✓ ៤.៤.៣៖ ការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ</td><td>✓ ៤.៤.៣៖ ការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ</td></tr>
<tr><td colspan="2">លទ្ធផលរំពឹងទុក ៤.៥.៖ ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្ទេរទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលាស្របតាមផែនការច្បាស់លាស់។</td></tr>
<tr><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</td><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</td></tr>
<tr><td>✓ ៤.៥.១៖ ការពិនិត្យឡើងវិញនូវក្របខ័ណ្ឌនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៤.៥.២៖ ការធ្វើវិមជ្ឈការលើការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៤.៥.៣៖ ការបង្កើនចំណូលពីការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ</td><td>✓ ៤.៥.៣៖ ការបង្កើនចំណូលពីការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ</td></tr>
</table>

<table>
<tr><td colspan="2">លទ្ធផលរំពឹងទុក ៤.៦.៖ មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌត្រូវបានកំណត់ទំហំដែលមានលក្ខណៈសមស្រប និងត្រូវបានវិភាជទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗតាមរូបមន្ត និងលក្ខណៈវិនិច្ឆ័យប្រកបដោយសមធម៌ ព្រមទាំងត្រូវបានបង្កើនទំហំជាបន្តបន្ទាប់ ដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (ជាពិសេសថ្នាក់ក្រុង ស្រុក) ក្នុងការអនុវត្តមុខងារជាជម្រើស ឬមុខងារជាអាណត្តិទូទៅ។</td></tr>
<tr><th>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</th><th>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</th></tr>
<tr><td>✓ ៤.៦.១៖ ការបង្កើនការផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលក្រុង ស្រុក<br>✓ ៤.៦.២៖ ការពង្រឹងនូវប្រព័ន្ធគ្រប់គ្រងមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៤.៦.៣៖ ការលើកកម្ពស់សិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌសម្រាប់គម្រោងសេវាកម្មនានា</td><td>✓ ៤.៦.២៖ ការពង្រឹងនូវប្រព័ន្ធគ្រប់គ្រងមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ</td></tr>
<tr><td colspan="2">លទ្ធផលរំពឹងទុក ៤.៧.៖ មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌត្រូវបានកំណត់នូវទំហំដែលមានលក្ខណៈសមស្រប និងត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ក្នុងការអនុវត្តមុខងារជាកាតព្វកិច្ចនានាដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។</td></tr>
<tr><th>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</th><th>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</th></tr>
<tr><td>✓ ៤.៧.១៖ ការលើកកម្ពស់ការអនុវត្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌក្នុងក្របខ័ណ្ឌដែលមានបច្ចុប្បន្ន ព្រមទាំងរៀបចំ និងកែលម្អក្របខ័ណ្ឌផ្ដល់ហិរញ្ញប្បទានដល់មុខងារជាកាតព្វកិច្ចឱ្យកាន់តែប្រសើរឡើង</td><td></td></tr>
<tr><td colspan="2">លទ្ធផលរំពឹងទុក ៤.៨.៖ ក្របខ័ណ្ឌសម្រាប់ផ្ដល់ហិរញ្ញប្បទានការវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដ៏ច្បាស់លាស់មួយត្រូវបានបង្កើត និងពង្រឹងការអនុវត្ត។</td></tr>
<tr><th>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</th><th>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</th></tr>
<tr><td>✓ ៤.៨.១៖ ការពិនិត្យមើលឡើងវិញ និងពង្រឹងការគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ</td><td></td></tr>
</table>

<table>
<tr><td>✓ ៤.៨.២៖ ការលើកកម្ពស់ក្របខ័ណ្ឌសម្រាប់គ្រប់គ្រងធនធានរបស់ដៃគូអភិវឌ្ឍន៍ ដែលផ្តល់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>✓ ៤.៨.៣៖ ការសិក្សា និងរៀបចំក្របខ័ណ្ឌសម្រាប់បង្កើតមូលនិធិភាតរភាព និងកញ្ចប់ថវិកាពិសេស<br>✓ ៤.៨.៤៖ ការពង្រឹងក្របខ័ណ្ឌគ្រប់គ្រងការវិនិយោគសាធារណៈដែលប្រើប្រាស់ថវិកាផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ</td><td></td></tr>
<tr><td colspan="2">លទ្ធផលរំពឹងទុក ៤.៩.៖ ក្របខ័ណ្ឌសម្រាប់ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន ត្រូវបានបង្កើតឡើង និងដាក់ឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាព។</td></tr>
<tr><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</td><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</td></tr>
<tr><td>✓ ៤.៩.១៖ ការសិក្សា និងរៀបចំនូវក្របខ័ណ្ឌ ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន</td><td>✓ ៤.៩.២៖ ការដាក់ឱ្យអនុវត្តពេញលេញនូវក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន</td></tr>
<tr><td colspan="2">លទ្ធផលរំពឹងទុក ៤.១០.៖ ប្រព័ន្ធសវនកម្ម និងអធិការកិច្ចលើការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង។</td></tr>
<tr><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</td><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</td></tr>
<tr><td>✓ ៤.១០.១៖ ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង និងការរៀបចំនីតិវិធីសវនកម្មផ្ទៃក្នុងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ</td><td>✓ ៤.១០.២៖ ការពង្រឹងការធ្វើអធិការកិច្ចហិរញ្ញវត្ថុពីខាងក្រៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ</td></tr>
</table>

## តារាងទី ៨៖ ការគ្រប់គ្រងហានិភ័យសំខាន់ៗសម្រាប់សមាសភាគទី៤

| ល.រ | ហានិភ័យ | ផលប៉ះពាល់ | លទ្ធភាពកើតមាន | វិធានការកាត់បន្ថយ |
|---|---|---|---|---|
| ១ | ដំណើរការរៀបចំកម្មវិធីវិនិយោគ និងគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅតែមិនអាចបន្សីុគ្នាបានទាំងក្របខ័ណ្ឌពេលវេលា និងខ្លឹមសារ | ខ្ពស់ | មធ្យម | -ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវរួមគ្នាពិនិត្យ និងកែសម្រួលនូវនីតិវិធី និងក្របខ័ណ្ឌពេលវេលានៃការរៀបចំកម្មវិធីវិនិយោគ និងគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>-ការសិក្សាអំពីលទ្ធភាពក្នុងការប្របាច់បញ្ចូលគ្នារវាងក្រុមការងារកសាងផែនការ និងក្រុមការងារហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ២ | វិមជ្ឈការហិរញ្ញវត្ថុ និងកំណែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ នៅពុំទាន់ស្របគ្នាជាមួយនឹងគោលដៅកំណែទម្រង់វិមជ្ឈការ | ខ្ពស់ | មធ្យម | ការរៀបចំ និងអនុម័តនូវឯកសារទស្សនទានស្តីពីចក្ខុវិស័យ និងយុទ្ធសាស្ត្រនៃកម្មវិធីកំណែទម្រង់បីបូកមួយ |
| ៣ | រដ្ឋបាលក្រុង ស្រុក ខណ្ឌ មិនត្រូវបានផ្តល់ថវិកាគ្រប់គ្រាន់ ដើម្បីអនុវត្តមុខងារថ្មីៗនានាដែលបានផ្ទេរ | ខ្ពស់ | មធ្យម | -លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃត្រូវបន្តធ្វើការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីស្វែងយល់រួមគ្នាពីផលប៉ះពាល់អវិជ្ជមានដោយសារហានិភ័យនេះ ហើយអាចដោះស្រាយរួមគ្នា<br>-ការកំណត់ឱ្យបានច្បាស់លាស់នូវមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសនៅក្នុងចំណោមមុខងារដែលបានផ្ទេររួចហើយទៅឱ្យរដ្ឋបាលក្រុង ស្រុក |
| ៤ | ការផ្ទេរការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវពន្យារពេល | មធ្យម | ខ្ពស់ | លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃត្រូវបន្តធ្វើការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងផ្ទេរមុខងារពាក់ព័ន្ធនានា |
| ៥ | ការបង្កើតឱ្យមានប្រព័ន្ធ ឬយន្តការផ្សេងៗគ្នាជាច្រើនដើម្បីផ្ទេរធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលបង្កឱ្យមានការចំណាយបន្ថែមច្រើន និងបង្កឱ្យគ្មានសង្គតិភាពជាមួយនឹងគោលការណ៍នៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។ | ខ្ពស់ | ខ្ពស់ | -ការកាត់បន្ថយឱ្យបានជាអតិប្បរមានូវការប្រើប្រាស់យន្តការចំពោះកិច្ចនានាពាក់ព័ន្ធនឹងការផ្ទេរធនធាន |

| ល.រ | ហានិភ័យ | ផលប៉ះពាល់ | លទ្ធភាពកើតមាន | វិធានការកាត់បន្ថយ |
|---|---|---|---|---|
| | | | | -ធានាថាគោលបំណងជាទូទៅមួយនៃការបង្កើតប្រព័ន្ធផ្ទេរធនធានអន្តររដ្ឋបាលមួយត្រូវបានកំណត់ឱ្យបានច្បាស់លាស់ និងមានលក្ខណៈសាមញ្ញ |
| ៦ | ភាពដាច់ដោយឡែកៗពីគ្នានៃការប្រមូល ការចងក្រង ការរក្សាទុក ការចែកចាយ និងការប្រើប្រាស់ទិន្នន័យ ដែលធ្វើឱ្យការវាយតម្លៃ ការតាមដានទៅលើការវិភាជ និងការចំណាយថវិកាពុំមានប្រសិទ្ធភាព | ខ្ពស់ | ខ្ពស់ | ត្រូវបង្កើតក្រុមការងារដើម្បីពិនិត្យមើលឡើងវិញនូវប្រព័ន្ធគ្រប់គ្រងទិន្នន័យមូលដ្ឋានបច្ចុប្បន្ន រួមទាំងទិន្នន័យដែលគ្រប់គ្រងដោយលេខាធិការដ្ឋានគ.ជ.អ.ប. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួងផែនការ និងរៀបចំឱ្យមានផែនការច្បាស់លាស់មួយដើម្បីបញ្ចូល ឬធ្វើសន្ធានកម្មរវាងទិន្នន័យទាំងនេះ។ |

## ៣.៥. សមាសភាគទី៥៖ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន

### ៣.៥.១. សនិដ្ឋានភាព

ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានគឺជាគោលបំណងដ៏ចម្បងរបស់រាជរដ្ឋាភិបាលនៅក្នុងកម្មវិធីកំណែទម្រង់សំខាន់ៗនានារបស់រាជរដ្ឋាភិបាល។ ដើម្បីចូលរួមសម្រេចបាននូវគោលបំណងនេះ ក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បានផ្តោតទៅលើការពិនិត្យ និងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ការពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស រួមជាមួយនឹងការផ្ទេរសិទ្ធិអំណាច មុខងារ ធនធាន និងការទទួលខុសត្រូវទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅបង្កិតការធ្វើសេចក្តីសម្រេចចិត្តក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឱ្យទៅកៀកជិតប្រជាពលរដ្ឋ។

ក្នុងអំឡុងពេលនៃការអនុវត្ត កជទី១ (២០១០-២០២០) ទោះបីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែសម្រួល ព្រមទាំងមុខងារ និងធនធាននានាត្រូវបានផ្ទេរជាបណ្តើរៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក៏ដោយ ក៏ការគ្រប់គ្រង ការចាត់ចែងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅពុំទាន់អាចឆ្លើយតបបានយ៉ាងមានប្រសិទ្ធភាពទៅនឹងតម្រូវការ និងបញ្ហាប្រឈមនានារបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានដែលមានការកើនឡើងជាប្រចាំនោះឡើយ។

ជាទូទៅ ការរីកចំរើនផ្នែកសេដ្ឋកិច្ច សង្គម នគរូបនីយកម្ម បច្ចេកវិទ្យាព័ត៌មាន និងការវិវឌ្ឍនៃជីវភាពរស់នៅតាមបែបទំនើប បានធ្វើឱ្យកើនឡើងនូវតម្រូវការថ្មីៗជាច្រើនបន្ថែមទៀតរបស់ប្រជាពលរដ្ឋ។ ទន្ទឹមគ្នានេះ ការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា ក៏ជាបញ្ហាប្រឈមចំពោះប្រជាពលរដ្ឋ ដែលទាមទារឱ្យមានការផ្តល់អន្តរាគមន៍ដោះស្រាយពីរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានទាន់ពេលវេលាផងដែរ។ ជារួម ដើម្បីពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការ និងបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋ គឺអាស្រ័យទៅលើកត្តាសំខាន់ៗមួយចំនួនរួមមាន៖ ១).ការកំណត់ឱ្យបានច្បាស់លាស់នូវមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើស និងយន្តការ គោលការណ៍ បែបបទ និងនីតិវិធីនៃការអនុវត្តមុខងារទាំងនេះ ២).ធនធានមនុស្ស និងការផ្លាស់ប្តូរឥរិយាបថរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ៣). ធនធានហិរញ្ញវត្ថុ និង៤).ភាពជាដៃគូផ្តល់សេវាក្នុងចំណោមស្ថាប័នសាធារណៈ ជាមួយអង្គការសង្គមស៊ីវិល និងវិស័យឯកជន។

### ៣.៥.២. និន្នាការឆ្ពោះទៅនៃសមាសភាគទី៥

#### ៣.៥.២.១. សមិទ្ធផលរំពឹងទុក

សមិទ្ធផលរំពឹងទុកនៃសមាសភាគនេះគឺ *"រដ្ឋបាលថ្នាក់ក្រោមជាតិមានយន្តការ នីតិវិធី និងស្តង់ដារសម្រាប់ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការប្រាស្រ័យទាក់ទងសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គមតាមរយៈការអនុវត្តមុខងារជាអាណត្តិទូទៅ ឬមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន"*។

#### ៣.៥.២.២. យុទ្ធសាស្ត្រសម្រាប់ការសម្រេចសមិទ្ធផលរំពឹងទុក

ដើម្បីសម្រេចបាននូវសមិទ្ធផលរំពឹងទុកទី៥នេះ កជទី២ ត្រូវផ្តោតលើកិច្ចការសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- មុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទនីមួយៗត្រូវកំណត់ឱ្យបានច្បាស់លាស់ ដូចមានកំណត់ក្នុងសមាសភាគទី២នៃកជទី២នេះ។ ដើម្បីធានាការគ្រប់គ្រង និងការអនុវត្តមុខងារទាំងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាំបាច់ក៏ត្រូវកំណត់ឱ្យមានគោលការណ៍ បែបបទ និងនីតិវិធីច្បាស់លាស់ សាមញ្ញ តម្លាភាព បរិយាប័ន្ន និងសមធម៌ ព្រមទាំងមានលក្ខណៈងាយស្រួលក្នុងការប្រតិបត្តិ។ នីតិវិធីសម្រាប់ការអនុវត្តមុខងារជាកាតព្វកិច្ចនឹងមានភាពខុសគ្នាពីនីតិវិធីសម្រាប់អនុវត្តមុខងារជាជម្រើស។ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានលើកទឹកចិត្តក្នុងការជ្រើសរើស និងអនុវត្តមុខងារជាជម្រើសនានាដើម្បីផ្តល់សេវាជូនក្រុមប្រជាពលរដ្ឋដែលងាយរងគ្រោះ។ ការប្រែប្រួលអាកាសធាតុ និងភាពងាយរងគ្រោះពីគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា ក៏ជាបញ្ហាប្រឈមដ៏ធំចំពោះប្រជាពលរដ្ឋ ដូច្នេះ ចាំបាច់ត្រូវផ្តោតលើការបញ្ជ្រាបភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានាទៅក្នុងនីតិវិធីនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានផងដែរ។
- ការពង្រឹង និងការកែលម្អនូវយន្តការនានា ដើម្បីធានាដល់ការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋដោយឆាប់រហ័ស តម្លាភាព សមធម៌ និងប្រកបដោយលក្ខណៈងាយស្រួល
- រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានធនធានហិរញ្ញវត្ថុឆន្ទានុសិទ្ធិក្នុងទំហំសមស្រប និងមានធនធានមនុស្សប្រកបដោយសមត្ថភាព និងជំនាញវិជ្ជាជីវៈជាក់លាក់ ព្រមទាំងប្រកបដោយមនសិការវិជ្ជាជីវៈក្នុងការគ្រប់គ្រង ការចាត់ចែង និងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន

- ការផ្លាស់ប្តូរឥរិយាបថរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិឱ្យក្លាយទៅជាអ្នកផ្តល់សេវាដ៏ល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពដោយត្រូវប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួននូវឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈក្នុងការបម្រើសេវាជូនប្រជាពលរដ្ឋ
- ការបង្កើនកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិ និងកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសាមីនីមួយៗប្រកបដោយភាពជឿជាក់ និងឈរលើស្មារតីបម្រើផលប្រយោជន៍ប្រជាពលរដ្ឋដោយស្មោះត្រង់។

### ៣.៥.២.៣. លទ្ធផលរំពឹងទុក

សមិទ្ធផលរំពឹងទុកខាងលើនឹងត្រូវបានសម្រេច តាមរយៈលទ្ធផលរំពឹងទុកជាយុទ្ធសាស្ត្រចំនួន ៤ ដូចខាងក្រោម៖

- **លទ្ធផលរំពឹងទុកទី១** ៖ ការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង និងកែលម្អឱ្យកាន់តែមានប្រសិទ្ធភាព
- **លទ្ធផលរំពឹងទុកទី២** ៖ យន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ កែលម្អ និងពង្រឹងការអនុវត្តដើម្បីធានាដល់ការផ្តល់សេវារដ្ឋបាលឱ្យកាន់តែមានភាពសាមញ្ញ ងាយស្រួល ឆាប់រហ័ស ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ព្រមទាំងជំរុញការរៀបចំ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- **លទ្ធផលរំពឹងទុកទី៣** ៖ យុទ្ធសាស្ត្រលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គការសង្គមស៊ីវិល និងផ្នែកឯកជនត្រូវបានពិនិត្យ កែសម្រួល និងជំរុញការអនុវត្ត
- **លទ្ធផលរំពឹងទុកទី៤** ៖ ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ ជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនានា ត្រូវបានបញ្ជ្រាបទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

### ៣.៥.២.៤. *យុទ្ធសាស្ត្រ និងសកម្មភាពជាអាទិភាពសម្រាប់អនុវត្តលទ្ធផលរំពឹងទុកនានា*

#### *លទ្ធផលរំពឹងទុក៥.១៖ ការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង និងកែលម្អឱ្យកាន់តែមានប្រសិទ្ធភាព*

ច្បាប់រៀបចំអង្គការ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធបានផ្តល់សិទ្ធិអំណាច មុខងារ និងធនធាន ដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន តាមរយៈការអនុវត្តមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទនីមួយៗ។ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុវត្តមុខងារជាកាតព្វកិច្ចនានាដោយប្រើប្រាស់

ធនធានផ្ទេរមានភ្ជាប់លក្ខខណ្ឌ និងអាចប្រើប្រាស់ធនធានធន្ទានុសិទ្ធិរបស់ខ្លួនបន្ថែមសម្រាប់អនុវត្តមុខងារជាកាតព្វកិច្ចទាំងនោះ ដើម្បីធានាឱ្យសម្រេចបាននូវលទ្ធផលយ៉ាងហោចក្នុងកម្រិតអប្បបរមានៃស្តង់ដារដែលបានកំណត់។ រដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទនីមួយៗ ក៏មានសិទ្ធិសម្រេចជ្រើសរើសយកមុខងារជាជម្រើសនានាមកអនុវត្តផ្អែកតាមតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដោយប្រើប្រាស់ធនធានធន្ទានុសិទ្ធិរបស់ខ្លួន និងធនធានដែលកៀរគរបានពីប្រភពស្របច្បាប់ផ្សេងទៀត។

ក្នុងអំឡុងពេលនៃការអនុវត្តកជទី១ ទោះបីមានមុខងារមួយចំនួនត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក៏ដោយ ក៏ការផ្ទេរធនធាននានាសម្រាប់គាំទ្រដល់ការអនុវត្តមុខងារទាំងនេះក៏នៅមិនទាន់មានភាពសមស្របនៅឡើយ។ ជាមួយគ្នានេះដែរ គោលការណ៍ បែបបទ និងនីតិវិធីសម្រាប់គ្រប់គ្រង និងអនុវត្តមុខងារដែលបានផ្ទេរទាំងនោះមួយចំនួននៅពុំទាន់មានភាពច្បាស់លាស់ និងមួយចំនួនទៀតពុំទាន់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់នៅឡើយ។ ប្រការទាំងនេះបានធ្វើនៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិជួបការលំបាកក្នុងការអនុវត្តមុខងារទាំងនោះផង និងជួបការលំបាកក្នុងការរៀបចំការគ្រប់គ្រង និងការចាត់ចែងមុខងារទាំងនោះប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពផងដែរ។ ដោយឡែក ដើម្បីធានាដល់ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈក៏ចាំបាច់ត្រូវបន្តផ្ទេរមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសចាំបាច់នានាបន្ថែមទៀតទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែរ ចាំបាច់ត្រូវពិនិត្យមើលឡើងវិញនូវមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលថ្នាក់ក្រុង ស្រុក ដើម្បីកំណត់ឱ្យច្បាស់លាស់ថាតើមុខងារណាមួយជាមុខងារជាកាតព្វកិច្ច និងមុខងារណាមួយជាមុខងារជាជម្រើស។

ក្នុងន័យនេះ ក្នុងអំឡុងពេលនៃការអនុវត្ត កជទី២ ចាំបាច់ត្រូវបន្តពង្រឹង និងកែលម្អការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសឱ្យកាន់តែមានប្រសិទ្ធភាព។

ដើម្បីធានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី១ ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៣ ដូចខាងក្រោម៖

## សកម្មភាពអាទិភាព ៥.១.១៖ ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច

មុខងារជាកាតព្វកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានកំណត់ច្បាស់លាស់ តាមរយៈសកម្មភាពជាអាទិភាពនានាដែលបានកំណត់នៅក្នុងសមាសភាគទី២។ ដើម្បីធានាដល់ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តមុខងារជាកាតព្វកិច្ចនឹងតម្រូវឱ្យមាន៖

- គោលការណ៍ បែបបទ នីតិវិធី និងស្តង់ដារច្បាស់លាស់ដែលត្រូវរៀបចំឡើងដោយកិច្ចសហការជាមួយក្រសួង ស្ថាប័នតាមវិស័យពាក់ព័ន្ធនានា

- ការកំណត់នូវតម្រូវការធនធានថវិកា ធនធានមនុស្ស ទ្រព្យសម្បត្តិ ឧបករណ៍ សម្ភារៈ និងមធ្យោបាយនានាសម្រាប់អនុវត្តមុខងារជាកាតព្វកិច្ចនីមួយៗស្របតាមស្តង់ដារដែលបានកំណត់
- ការធានាឱ្យបានថា រដ្ឋបាលថ្នាក់ក្រោមជាតិមានថវិកាសមស្រប និងដែលអាចព្យាករណ៍បាន ព្រមទាំងមានភាពបត់បែនក្នុងការប្រើប្រាស់ធនធានមានភ្ជាប់លក្ខខណ្ឌទាំងនោះស្របតាមស្ថានភាពជាក់ស្តែង និងប្រកបដោយប្រសិទ្ធភាពស្របតាមលក្ខខណ្ឌ និងស្តង់ដារដែលបានកំណត់ (តាមរយៈសមាសភាគទី៤)
- ការធានាឱ្យបានថា រដ្ឋបាលថ្នាក់ក្រោមជាតិមានបុគ្គលិកក្នុងចំនួនសមស្រប និងប្រកបដោយសមត្ថភាព ជំនាញវិជ្ជាជីវៈច្បាស់លាស់ ព្រមទាំងមានការផ្តល់ការអភិវឌ្ឍសមត្ថភាពដល់បុគ្គលិកទាំងនោះឱ្យបានសមស្របផងដែរ (តាមរយៈសមាសភាគទី៣)

## សកម្មភាពអាទិភាព ៥.១.២៖ ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាជម្រើស

កជទី២ ត្រូវបន្តជំរុញ ពង្រឹងការគ្រប់គ្រង និងការអនុវត្តមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការដោះស្រាយបញ្ហាប្រឈម និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនានារបស់ប្រជាពលរដ្ឋតាមមូលដ្ឋាននីមួយៗ បន្ថែមពីលើការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ចតាមរយៈ ៖

- ការរៀបចំគោលការណ៍ណែនាំឱ្យបានច្បាស់លាស់បន្ថែមទៀតអំពីមុខងារជាជម្រើសនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចកំណត់បាននូវមុខងារជាជម្រើសនានាដែលអាចជ្រើសរើសយកមកអនុវត្ត
- ការពិនិត្យ ការរៀបចំ និងការកែលម្អបែបបទ នីតិវិធីនៃការជ្រើសរើសការរៀបចំ និងការអនុវត្តគម្រោងក្នុងក្របខ័ណ្ឌនៃមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានដូចជា នីតិវិធីរៀបចំ និងអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្តជាដើម។ ការរៀបចំ និងការកែលម្អបែបបទ និងនីតិវិធីនៃការអនុវត្តគម្រោងនានាត្រូវធានាដល់ការបញ្ជ្រាបភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយផលប៉ះពាល់បរិស្ថាន។
- ការពិនិត្យ និងកែសម្រួលនីតិវិធីនៃការប្រើប្រាស់ធនធានធន្ទានុសិទ្ធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់អនុវត្តមុខងារជាជម្រើសនានា ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានភាពកាន់តែងាយស្រួលក្នុងការរៀបចំ និងការអនុវត្តគម្រោងពាក់ព័ន្ធនឹងការផ្តល់សេវាសង្គមនានាឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់មូលដ្ឋាននីមួយៗ

- ការរៀបចំយន្តការចែករំលែកមេរៀនបទពិសោធន៍នៅក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការផ្តួចផ្តើមគំនិតប្រកបដោយភាពច្នៃប្រឌិតក្នុងការជ្រើសរើស និងការអនុវត្តប្រកបដោយជោគជ័យនូវមុខងារជាជម្រើសនានា។
- ការផ្តល់ការអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការ និងការអនុវត្តមុខងារជាជម្រើស (តាមរយៈសមាសភាគទី៣)។

### សកម្មភាពអាទិភាព ៥.១.៣៖ ការរៀបចំបែបផែននៃកិច្ចសហការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ

កជទី២ ត្រូវធ្វើការសិក្សា ប្រមូលមេរៀន បទពិសោធន៍ ដើម្បីរៀបចំនិងដាក់ឱ្យអនុវត្តនូវបែបផែននៃកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំ និងផ្តល់សេវាសាធារណៈដែលផ្តល់ផលប្រយោជន៍រួម ឬដោះស្រាយបញ្ហារួមរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលទាំងនោះរួមមានដូចជា ការរៀបចំនិងអនុវត្តកម្មវិធីលើកកម្ពស់បរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ កម្មវិធីកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ កម្មវិធីធុរកិច្ចដើម្បីលើកកម្ពស់ផលិតផលក្នុងតំបន់ និងសេវាដឹកជញ្ជូនសាធារណៈជាដើម។ ការបង្កើតឱ្យមានបែបផែននៃកិច្ចសហការគ្នារវាងរដ្ឋបាលថ្នាក់ក្រោមជាតិនឹងជួយលើកកម្ពស់ដល់ការផ្តល់សេវារួមគ្នា ដែលមានលក្ខណៈផ្តល់ផលប្រយោជន៍ដល់រដ្ឋបាលពីរឬច្រើន និងមានលក្ខណៈឆ្លងកាត់ព្រំប្រទល់នៃរដ្ឋបាលពីរឬច្រើន។

ភាពជោគជ័យនៃការអនុវត្តតាមបែបផែននៃកិច្ចសហប្រតិបត្តិការនេះ នឹងត្រូវរៀបចំចងក្រងជាមេរៀន និងបទពិសោធន៍ល្អៗសម្រាប់ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងតាមបណ្តាញព័ត៌មានសង្គមនានា។ ការបណ្តុះបណ្តាលដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិអំពីក្របខ័ណ្ឌគតិយុត្ត និងបែបផែននៃកិច្ចសហការនេះក៏នឹងត្រូវរៀបចំផងដែរ។

### *លទ្ធផលរំពឹងទុក ៥.២៖ យន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ កែលម្អ និងពង្រឹងការអនុវត្តដើម្បីធានាដល់ការផ្តល់សេវារដ្ឋបាលឱ្យកាន់តែមានភាពសាមញ្ញ ងាយស្រួល ឆាប់រហ័ស ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ព្រមទាំងជំរុញការរៀបចំ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន*

យន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានបង្កើតឡើងក្នុងគោលបំណងប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗជូនប្រជាពលរដ្ឋនៅកន្លែងតែមួយ តាមនីតិវិធីសាមញ្ញ បង្កលក្ខណៈងាយស្រួលជូនប្រជាពលរដ្ឋក្នុងការស្វែងរក និងការទទួលបាននូវសេវាឆាប់រហ័ស សំដៅឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព។

ក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ យន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើត និងពង្រីកជាជំហានៗ។ គិតរហូតដល់ឆ្នាំ

២០២០ អង្គភាពច្រកចេញចូលតែមួយត្រូវបានបង្កើត និងដាក់ឱ្យដំណើរការនៅទូទាំងរដ្ឋបាលរាជធានី ខេត្តទាំងអស់ និងការិយាល័យច្រកចេញចូលតែមួយបានបង្កើត និងដាក់ឱ្យដំណើរការដែលមានលក្ខណៈពេញលេញនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌសរុបចំនួន១១៤ ព្រមទាំងបាន និងកំពុងរៀបចំជាបណ្តើរៗដើម្បីដាក់ឱ្យអនុវត្តឱ្យបានពេញលេញចំពោះរដ្ឋបាលក្រុង ស្រុកដែលនៅសេសសល់។

ការិយាល័យច្រកចេញចូលតែមួយនៅថ្នាក់ក្រុង ស្រុក ខណ្ឌទាំងនេះត្រូវបានរៀបចំបង្កើត និងដាក់ឱ្យប្រតិបត្តិការនៅក្រុង ស្រុក ខណ្ឌចំនួន១១៤ មុនពេលដែលមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានកែសម្រួលជាថ្មីតាមរយៈអនុក្រឹត្យលេខ១៨២ លេខ១៨៣ និងលេខ១៨៤ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ដែលបានធ្វើសមាហរណកម្មការិយាល័យជំនាញនានាចូលទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព។

ទោះបីយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិបាន និងកំពុងប្រតិបត្តិការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋបានល្អគួរឱ្យកត់សម្គាល់ក៏ដោយ ក៏បែបបទ និងនីតិវិធីនៃផ្តល់សេវារដ្ឋបាលភាគច្រើននៅមានលក្ខណៈដាច់ដោយឡែកតាមវិស័យនីមួយៗ និងរបៀបនៃការផ្តល់សេវាផ្អែកលើមូលដ្ឋាននៃការប្រើប្រាស់ក្រដាសស្នាម និងការជួបប្រាស្រ័យទាក់ទងដោយផ្ទាល់រវាងអ្នកស្នើសុំ និងអ្នកផ្តល់សេវាដែលធ្វើឱ្យការផ្តល់សេវានៅមានការលំបាក ស្មុគស្មាញ យឺតយ៉ាវ និងធ្វើឱ្យប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋដែលស្ថិតនៅតំបន់ឆ្ងាយពីកន្លែងផ្តល់សេវានៅតែជួបការលំបាកក្នុងការស្វែងរក និងទទួលបានសេវារដ្ឋបាល។

អាស្រ័យហេតុនេះ ក្នុងអំឡុងពេលនៃកជទី២ ចាំបាច់តម្រូវឱ្យមានការពិនិត្យ កែលម្អ និងការធ្វើទំនើបកម្មនូវរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយឱ្យស្របទៅតាមមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានកែសម្រួលថ្មីផង និងដើម្បីជានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាព និងសមត្ថភាពក្នុងការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយភាពឆ្លាតវៃ កាន់តែឆាប់រហ័សងាយស្រួល តម្លាភាព គណនេយ្យភាព និងកាន់តែមានភាពជឿជាក់ពីប្រជាពលរដ្ឋ។ ជាមួយគ្នានេះដែរក្នុងដំណាក់កាលនេះ ផអ៥ទី១ នៃកជទី២ ក៏ចាំបាច់ត្រូវខិតខំរៀបចំនូវយន្តការច្រកចេញចូលតែមួយឱ្យមានលក្ខណៈពេញលេញនៅថ្នាក់ក្រុង ស្រុក ខណ្ឌឱ្យបានទូទាំងប្រទេស។

ដើម្បីធានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី២ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៣ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៥.២.១៖ ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត

កិច្ចការចំពោះមុខ ចាំបាច់ត្រូវពិនិត្យ និងកែសម្រួលនូវបែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលរបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ដើម្បីធានាដល់ការផ្តល់សេវាឱ្យកាន់តែមានភាពរលូន មានលក្ខណៈសាមញ្ញ និងមានលក្ខណៈជាកញ្ចប់សេវា។

ក្នុងអំឡុងពេលដែលរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានីត្រូវបានរៀបចំឱ្យក្លាយទៅជារដ្ឋបាលក្រុងមេត្រូប៉ូលីតែន ហើយរដ្ឋបាលខេត្តឱ្យក្លាយទៅជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់តាមគោលការណ៍នៃរដ្ឋបាលឯកភាព ក៏មានភាពចាំបាច់ក្នុងការពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការគ្រប់គ្រង និងការផ្តល់សេវារបស់អង្គភាពច្រកចេញចូលមួយរាជធានី ខេត្ត ឱ្យស្របទៅនឹងរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងថ្មី។ ទន្ទឹមនឹងនោះ ក៏ត្រូវផ្តោតទៅលើការផ្ទេរមុខងារផ្តល់សេវារដ្ឋបាលចាំបាច់មួយចំនួនពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីបង្ខិតការផ្តល់សេវាឱ្យកាន់តែកៀកជិតប្រជាពលរដ្ឋ និងផ្តល់សេវាឱ្យបានឆាប់រហ័ស។

### សកម្មភាពអាទិភាព ៥.២.២៖ ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ

កជទី២ នឹងធ្វើការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យស្របទៅនឹងមុខងារ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងថ្មីរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌតាមគោលការណ៍នៃរដ្ឋបាលឯកភាព។ ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីផ្តល់សេវាតាមការិយាល័យច្រកចេញចូលតែមួយនេះ ក៏ត្រូវផ្តោតផងដែរទៅលើលទ្ធភាពនៃការបង្កើតសាខាការិយាល័យច្រកចេញចូលតែមួយសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលមានតម្រូវការសេវាច្រើន និងការបង្កើតភ្នាក់ងារចល័តរបស់ការិយាល័យច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋរស់នៅតាមភូមិ ឃុំដែលស្ថិតនៅឆ្ងាយពីមូលដ្ឋាននៃការិយាល័យច្រកចេញចូលតែមួយ ឬប្រើប្រាស់យន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលឃុំ សង្កាត់ជួយទទួលពាក្យស្នើសុំសេវា និងផ្តល់លទ្ធផលចុងក្រោយជូនប្រជាពលរដ្ឋនូវបណ្ណាសេវាដែលត្រូវផ្តល់ដោយការិយាល័យច្រកចេញតែមួយ។

### សកម្មភាពអាទិភាព ៥.២.៣៖ ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ

ការប្រាស្រ័យទាក់ទងរវាងអង្គភាព/ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននឹងត្រូវរៀបចំឡើង ដើម្បីធានាដល់ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាជូនប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋនឹងអាចស្នើសុំសេវា

នានាតាមប្រព័ន្ធអនឡាញ ព្រមទាំងអាចតាមដានដឹងអំពីស្ថានភាពកិច្ចដំណើរការវិវឌ្ឍនៃសំណើសុំសេវារបស់ខ្លួនផងដែរ។ ទន្ទឹមគ្នានេះ ការបង់កម្រៃសេវាតាមប្រព័ន្ធអេឡិចត្រូនិចក៏នឹងត្រូវរៀបចំ និងដាក់ឱ្យអនុវត្តផងដែរ។ ថ្នាលកម្មវិធីអេឡិចត្រូនិចនឹងត្រូវរៀបចំឡើងតាមស្តង់ដារជាតិ សម្រាប់ការដាក់ឱ្យប្រើប្រាស់លើការផ្តល់សេវាតាមប្រព័ន្ធអនឡាញនៅតាមការិយាល័យ/អង្គភាពច្រកចេញចូលតែមួយ។ កិច្ចការទាំងនេះនឹងត្រូវរៀបចំអនុវត្តជាជំហានៗ រួមមានដូចជាការបំពាក់នូវឧបករណ៍ សម្ភារៈ និងការបណ្តុះបណ្តាលជំនាញបច្ចេកវិទ្យាព័ត៌មានដល់បុគ្គលិកនៃការិយាល័យ/អង្គភាពច្រកចេញចូលតែមួយនៅទូទាំងប្រទេសជាដើម។

ទន្ទឹមគ្នានេះ តាមរយៈការអនុវត្តសកម្មភាពអាទិភាពនានាដែលបានកំណត់ក្នុងសមាសភាគទី៣ នឹងរៀបចំឱ្យមានបុគ្គលិកក្នុងចំនួនសមស្រប និងមានសមត្ថភាពជំនាញ និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បម្រើការងារតាមការិយាល័យ/អង្គភាពច្រកចេញចូលតែមួយ ដើម្បីជានាដល់ការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋតាមគោលការណ៍ បែបបទ និងនីតិវិធីដែលបានកំណត់។

### *លទ្ធផលរំពឹងទុក ៥.៣៖ យុទ្ធសាស្ត្រលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គការសង្គមស៊ីវិល និងផ្នែកឯកជនត្រូវបានពិនិត្យ កែសម្រួល និងជំរុញការអនុវត្ត*

ការចូលរួមរបស់អង្គការសង្គមស៊ីវិល និងផ្នែកឯកជនក្នុងកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការត្រូវបានកំណត់នៅក្នុងសមាសភាគនានានៃកម្មវិធីជាតិ ជាពិសេសការចូលរួមក្នុងការលើកកម្ពស់អភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានកំណត់ក្នុងសមាសភាគទី២ និងការចូលរួមក្នុងកិច្ចដំណើរការរៀបចំផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏បានកំណត់ក្នុងសមាសភាគទី៤។ ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល និងផ្នែកឯកជនក៏ជាតួអង្គដ៏មានសារៈសំខាន់ក្នុងការចូលរួមក្នុងភាពជាដៃគូជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរួមចំណែកលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាជូនប្រជាពលរដ្ឋ។ ភាពជាដៃគូនេះអាចរៀបចំក្នុងបែបផែនច្រើនយ៉ាងផ្សេងគ្នា ដែលក្នុងនោះអាចរួមមានដូចជា ៖

- អង្គការសង្គមស៊ីវិលអាចប្រើប្រាស់ធនធានរបស់ខ្លួនក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋក្រោមកិច្ចព្រមព្រៀងកិច្ចសហប្រតិបត្តិការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ
- ក្រុមហ៊ុនឯកជន និងអង្គការសង្គមស៊ីវិលអាចចុះកិច្ចសន្យាជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវានានា ដោយប្រើប្រាស់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ក្រុមហ៊ុនឯកជន និងអង្គការសង្គមស៊ីវិលអាចផ្តល់សេវាជូនប្រជាពលរដ្ឋក្រោមកិច្ចព្រមព្រៀងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយការប្រើប្រាស់កម្រៃសេវាដែលប្រមូលបានពីការផ្តល់សេវាទាំងនោះ
- ការផ្តល់សេវាក្នុងភាពជាដៃគូរវាងរដ្ឋជាមួយផ្នែកឯកជន ដែលក្នុងនោះរដ្ឋបាលថ្នាក់ក្រោមជាតិគឺជាម្ចាស់នៃទ្រព្យសម្បត្តិ ហើយផ្នែកឯកជនអាចប្រើប្រាស់ទ្រព្យសម្បត្តិនោះដើម្បីផ្តល់សេវា

សាធារណៈជូនប្រជាពលរដ្ឋ ឧទាហរណ៍ដូចជាទីលានចាក់សំរាមសំណល់រឹងជាដើម ដែលជាកម្មសិទ្ធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តែផ្នែកឯកជនអាចប្រើប្រាស់ទីលានចាក់សំរាមនេះសម្រាប់ការផ្តល់សេវាប្រមូលសំរាម។

ទោះយ៉ាងណាក៏ដោយ ក៏ត្រូវបែងចែកឱ្យដាច់ពីគ្នានូវតួនាទីរបស់អង្គការសង្គមស៊ីវិល និងផ្នែកឯកជនក្នុងការចូលរួមក្នុងកិច្ចការអភិបាលកិច្ច និងការរៀបចំផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងតួនាទីក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។ ជាគោលការណ៍ ត្រូវជៀសវាងឱ្យបាននូវការរៀបចំនានាដែលឈានទៅធ្វើឱ្យអង្គការសង្គមស៊ីវិល និងផ្នែកឯកជនមានឥទ្ធិពលទៅលើការសម្រេចចិត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិលើការប្រគល់កិច្ចសន្យាផ្តល់សេវាសាធារណៈ ឬការផ្តល់ឱកាសសម្រាប់ការធ្វើអាជីវកម្មផ្តាច់មុខដោយគ្មានការប្រកួតប្រជែង។

ដើម្បីជានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៣ ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៣ ដូចខាងក្រោម ៖

### សកម្មភាពអាទិភាព ៥.៣.១៖ ការរៀបចំបញ្ជីមូលដ្ឋានអាជីវកម្ម ឬសហគ្រាសនៅតាមមូលដ្ឋាន

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវរៀបចំចងក្រង និងធ្វើបច្ចុប្បន្នភាពជាប្រចាំនូវទិន្នន័យមូលដ្ឋានអាជីវកម្ម សិប្បកម្ម សេវាកម្ម សហគមន៍ផលិតនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីប្រើប្រាស់ក្នុងគោលបំណងបង្កលក្ខណៈងាយស្រួល និងគាំទ្រដល់ផ្នែកឯកជនក្នុងការជំរុញ និងពង្រីកការវិនិយោគលើអាជីវកម្មរបស់ខ្លួន ដែលជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានឱ្យកាន់តែមានភាពរីកចម្រើន និងបង្កើតការងារនៅមូលដ្ឋាន ព្រមទាំងការចូលរួមរបស់ផ្នែកឯកជនក្នុងដំណើរការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។

### សកម្មភាពអាទិភាព ៥.៣.២៖ ការលើកកម្ពស់ភាពជាដៃគូជាមួយវិស័យឯកជនក្នុងការផ្តល់សេវាសាធារណៈ

កជទី២ នឹងរៀបចំសិក្សា និងដាក់ឱ្យអនុវត្តនូវគំរូនៃបែបបទ និងនីតិវិធីស្តីពីការលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្នែកឯកជនក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន (តាមរយៈការអនុវត្តសកម្មភាពជាអាទិភាពដែលបានកំណត់ក្នុងសមាសភាគទី៤)។ ការសិក្សា និងការរៀបចំនូវគំរូបែបបទនេះ ត្រូវផ្តោតលើ៖

- ទស្សនទាន អត្ថប្រយោជន៍ និងវិសាលភាពនៃភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្នែកឯកជន
- គំរូ ឬបែបផែននៃភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្នែកឯកជនដែលមានលក្ខណៈសមស្របសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទនីមួយៗ
- ការបង្កើតបរិយាកាសសមស្រប (ក្របខ័ណ្ឌច្បាប់ គោលនយោបាយ ការលើកទឹកចិត្ត...) សម្រាប់គាំទ្រដល់កិច្ចដំណើរភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្នែកឯកជន

- ការកំណត់ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យនៃភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្នែកឯកជន
- រចនាសម្ព័ន្ធ និងហិរញ្ញប្បទាននៃភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្នែកឯកជន។

## សកម្មភាពអាទិភាព ៥.៣.៣៖ ការបង្កើតក្របខ័ណ្ឌនៃការផ្តល់សេវាសាធារណៈតាមរយៈអ្នកផ្គត់ផ្គង់សេវា

សេវាសាធារណៈមួយចំនួនអាចត្រូវបានផ្តល់យ៉ាងមានប្រសិទ្ធភាព តាមរយៈការផ្តល់កិច្ចសន្យាទៅឱ្យអ្នកផ្គត់ផ្គង់សេវា ឬអ្នកទទួលការជាអ្នកអនុវត្តការផ្តល់សេវាទាំងនោះ។ នាពេលកន្លងមក រដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំ និងអនុវត្តនូវក្របខ័ណ្ឌនេះបានយ៉ាងល្អ ជាពិសេសចំពោះកិច្ចសន្យាឱ្យទៅអ្នកទទួលការក្នុងការអនុវត្ត ឬការសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅតាមមូលដ្ឋាននានា ក៏ប៉ុន្តែបែបផែននេះមិនទាន់ត្រូវបានអនុវត្តប្រកបដោយភាពច្បាស់លាស់សម្រាប់ការផ្តល់សេវាសង្គមនានាក្រៅពីហេដ្ឋារចនាសម្ព័ន្ធរូបវន្តនោះឡើយ។

ហេតុផលដែលតម្រូវឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំ និងអនុវត្តនូវក្របខ័ណ្ឌនេះរួមមាន៖

១. សេវាមួយចំនួនទាមទារនូវជំនាញបច្ចេកទេសជាក់លាក់ ដែលរដ្ឋបាលថ្នាក់ក្រោមជាតិមិនមានអ្នកជំនាញនេះនៅក្នុងក្របខ័ណ្ឌនៃស្ថាប័នរបស់ខ្លួន

២. សេវាមួយចំនួនទាមទារឱ្យមានការជ្រើសរើសបុគ្គលិកក្នុងចំនួនច្រើនសម្រាប់បំពេញការងារក្នុងរយៈពេលខ្លី ដែលប្រការនេះរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវការពេលវេលា និងពិបាកក្នុងការជ្រើសរើសបុគ្គលិកជំនាញទាំងនេះ ហេតុនេះ រដ្ឋបាលថ្នាក់ក្រោមជាតិអាចអនុវត្តសេវាមួយចំនួនតាមរយៈអ្នកផ្គត់ផ្គង់សេវា

៣. ជំរុញ និងលើកកម្ពស់គំនិតផ្តួចផ្តើមប្រកបដោយនវានុវត្តន៍ និងការប្រកួតប្រជែងដោយហេតុថាអ្នកផ្គត់ផ្គង់សេវា ដែលរដ្ឋបាលថ្នាក់ក្រោមជាតិផ្តល់កិច្ចសន្យានឹងព្យាយាមរៀបចំសំណើគម្រោងឱ្យបានល្អតាមដែលអាចធ្វើទៅបានសម្រាប់ការផ្តល់សេវា។

កិច្ចការជាអាទិភាពដែលត្រូវរៀបចំ រួមមាន ៖

- សេចក្តីណែនាំស្តីពីលក្ខណៈវិនិច្ឆ័យសម្រាប់ការកំណត់ប្រភេទសេវាដែលត្រូវផ្តល់ដោយអ្នកផ្គត់ផ្គង់សេវា ឬអ្នកទទួលការ
- សេចក្តីណែនាំស្តីពីការរៀបចំលក្ខខណ្ឌការងារ/កិច្ចសន្យាសម្រាប់អ្នកផ្គត់ផ្គង់សេវា ឬអ្នកទទួលការ
- សេចក្តីណែនាំស្តីពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរបស់រដ្ឋបាលថ្នាក់ក្រោមជាតិលើការផ្តល់សេវារបស់អ្នកផ្គត់ផ្គង់សេវា ឬអ្នកទទួលការ។

*លទ្ធផលរំពឹងទុក ៥.៤៖ ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ ជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនានា ត្រូវបានបញ្ជ្រាបទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ*

នៅក្នុងតំបន់ជាច្រើននៃប្រទេសកម្ពុជាបានទទួលរងគ្រោះមហន្តរាយជាញឹកញាប់ ដោយបានផ្តល់ផលប៉ះពាល់ដល់អាយុជីវិត ទ្រព្យសម្បត្តិ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងធ្វើឱ្យខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធនៅតាមមូលដ្ឋាននានាផងដែរ។ ការប្រែប្រួលអាកាសធាតុនៅលើពិភពលោកដែលបង្កឱ្យមានគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានាទាំងនេះបានកើតឡើងកាន់តែញឹកញាប់ និងកាន់តែធ្ងន់ធ្ងរឡើងៗ ហើយក៏នឹងបង្កផលប៉ះពាល់អវិជ្ជមានក្នុងរយៈពេលវែងនៅក្នុងវិស័យជាច្រើននៃសេដ្ឋកិច្ច និងសង្គមផងដែរ។ ឧទាហរណ៍នៅពេលដែលសីតុណ្ហភាពឡើងខ្ពស់ អាចតម្រូវឱ្យមានការផ្លាស់ប្តូរនូវការសាងសង់អគារសាលារៀនដើម្បីឱ្យកុមារអាចរៀនបានស្រួល។ សីតុណ្ហភាពឡើងកាន់តែខ្ពស់ក៏នឹងជះឥទ្ធិពលដល់សុខភាពរបស់មនុស្សនិងតម្រូវការនៃសេវាសុខភាពក៏ត្រូវកើនឡើងផងដែរ។ ការសាងសង់ផ្លូវ ស្ពាននិងហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងទៀតក៏នឹងផ្លាស់ប្តូរដើម្បីធានាដល់ការការពារទៅនឹងទឹកភ្លៀង និងទឹកជំនន់ដែលកើនឡើង។ ការផ្លាស់ប្តូរ ឬការប្រែប្រួលនៃលំនាំទឹកភ្លៀងក៏ធ្វើឱ្យកសិករត្រូវផ្លាស់ប្តូរពូជដំណាំនានាផងដែរ។

ការជះឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ក៏ធ្វើឱ្យប៉ះពាល់ដល់ប្រភេទសេវានានាដែលត្រូវផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ នៅពេលដែលគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានាកើតឡើង រដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវតែមានលទ្ធភាពដោះស្រាយ និងឆ្លើយតបយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាព ដោយមិនចាំបាច់រង់ចាំការណែនាំ ឬការផ្ទេរធនធានពីថ្នាក់ជាតិឡើយ។

ជំងឺកូវីដ-១៩ ជាជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរដែលបាននិងកំពុងរីករាលដាលនៅទូទាំងពិភពលោកដែលបានធ្វើឱ្យប៉ះពាល់ដល់អាយុជីវិតរបស់ប្រជាពលរដ្ឋ សុខភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ និងសេដ្ឋកិច្ច-សង្គម។ ដើម្បីឈានទៅគ្រប់គ្រង និងទប់ស្កាត់ការរីករាលដាលនៃជម្ងឺកាចសាហាវនេះ និងឈានទៅបើកឱ្យដំណើរការឡើងវិញនូវសកម្មភាពសេដ្ឋកិច្ច-សង្គម រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិតមានតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមជាមួយរាជរដ្ឋាភិបាល និងស្ថាប័នមានសមត្ថកិច្ចនានាក្នុងដឹកនាំ គ្រប់គ្រង និងចាត់ចែងអនុវត្តនូវគោលនយោបាយ គោលការណ៍ណែនាំ និងសកម្មភាពនានាដែលរួមចំណែកដល់ការទប់ស្កាត់នូវការរីករាលដាលនូវជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនានា ជាពិសេសការពង្រឹងការអប់រំនិងបង្កើនការយល់ដឹងដ៏ទូលំទូលាយដល់ប្រជាពលរដ្ឋជាមួយនិងការដាក់ចេញ និងការអនុវត្តនូវវិធានការសុខាភិបាល វិធានការច្បាប់ និងវិធានការផ្សេងៗទៀតស្របតាមច្បាប់ និងលិខិតបទដ្ឋានកំណត់។

ការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានាមិនត្រឹមតែផ្តល់ផលប៉ះពាល់ទៅលើវិស័យ ឬសេវាណាមួយឡើយ ក៏ប៉ុន្តែវាផ្តល់ផលប៉ះពាល់លើវិស័យ ឬសេវាទាំងអស់ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ អាស្រ័យហេតុនេះ ការ

ប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានាត្រូវបានចាត់ទុកថា ជាបញ្ហាអន្តរវិស័យនៃកជទី២។ យុទ្ធសាស្ត្រសម្រាប់ការបញ្ជ្រាបភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានាត្រូវបានកំណត់នៅឧបសម្ព័ន្ធ "ឃ"៖ យុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា។

ដើម្បីជានាសម្រេចបាននូវលទ្ធផលរំពឹងទុកទី៤ខាងលើនេះ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវសកម្មភាពជាអាទិភាពចំនួន ៤ ដូចខាងក្រោម៖

### សកម្មភាពអាទិភាព ៥.៤.១៖ ការបង្កើតគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា

គណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានានឹងត្រូវបង្កើតនៅគ្រប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទាំងអស់ ដើម្បីសម្របសម្រួលលើការងារបញ្ជ្រាបភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការឆ្លើយតបនឹងគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានាទៅក្នុងកិច្ចដំណើរការរៀបចំផែនការ កិច្ចដំណើរការរៀបចំគម្រោងថវិកា និងក្នុងការផ្តល់សេវាសាធារណៈនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ យន្តការបច្ចុប្បន្នដែលកំពុងបំពេញការងារកិច្ចការទាំងនេះ នឹងត្រូវសមាហរណកម្មបញ្ចូលទៅក្នុងគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

### សកម្មភាពអាទិភាព ៥.៤.២៖ ការកំណត់បទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវាដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ

បទដ្ឋានបច្ចេកទេសសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធដោយរដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវពិនិត្យឡើងវិញ និងកែលម្អដើម្បីធានាឱ្យបានថាហេដ្ឋារចនាសម្ព័ន្ធនានាដែលសាងសង់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ បទដ្ឋានបច្ចេកទេសដែលត្រូវបានប្រើប្រាស់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងសកម្មភាពគាំទ្រវិស័យកសិកម្មនឹងត្រូវបានពិនិត្យឡើងវិញ និងកែលម្អ ដើម្បីធានាថាការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានយកមកអនុវត្តនៅគ្រប់សកម្មភាពគាំទ្រកសិកម្ម ហើយកសិករត្រូវបានលើកទឹកចិត្តឱ្យទទួលយកបច្ចេកទេសផលិតកម្ម ដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងតម្រូវការនៃការត្រៀមបង្ការសម្រាប់គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា ក៏នឹងត្រូវយកមកពិចារណាផងដែរក្នុងការរៀបចំសេចក្តីណែនាំបច្ចេកទេស និងស្តង់ដារសម្រាប់ការអនុវត្តមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### សកម្មភាពអាទិភាព ៥.៤.៣. ការពង្រឹងការប្រើប្រាស់ទិន្នន័យអាកាសធាតុ សន្ទស្សន៍ភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា

កជទី២ ត្រូវរៀបចំឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពទទួលបាន និងប្រើប្រាស់នូវទិន្នន័យអាកាសធាតុ សន្ទស្សន៍ភាពងាយរងគ្រោះ និងទិន្នន័យនៃការវិភាគការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ទិន្នន័យគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា និងផែនទីភូមិសាស្ត្រប្រព័ន្ធព័ត៌មានវិទ្យាស្តីពីភាពងាយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ។

### សកម្មភាពអាទិភាព ៥.៤.៤៖ ការវិនិយោគសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា

កជទី២ នឹងផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំការវិនិយោគនានាសម្រាប់បង្កើតភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានានៅក្នុងសហគមន៍មូលដ្ឋាន។

ការវិនិយោគទាំងនេះអាចរួមបញ្ចូលទាំងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ការវិនិយោគលើសកម្មភាពកសិកម្មដែលធន់នឹងអាកាសធាតុ និងការវិនិយោគដទៃទៀតដែលត្រូវការដើម្បីពង្រឹងនូវភាពធន់នឹងការប្រែប្រួលអាកាសធាតុ។ ការវិនិយោគក៏អាចរួមបញ្ចូល ទាំងឧបករណ៍ និងសម្ភារៈសម្រាប់ឆ្លើយតបនឹងគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានាផងដែរ។

**តារាងទី ៩៖ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពនានាសម្រាប់សមាសភាគទី៥**

<table>
<tr><td colspan="2">សមិទ្ធផលរំពឹងទុកនៃសមាសភាគទី៥៖ រដ្ឋបាលថ្នាក់ក្រោមជាតិមានយន្តការ នីតិវិធី និងស្តង់ដារសម្រាប់ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការប្រាស្រ័យទាក់ទងសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គមតាមរយៈការអនុវត្តមុខងារជាអាណត្តិទូទៅ ឬមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។</td></tr>
<tr><td colspan="2">លទ្ធផលរំពឹងទុក ៥.១៖ ការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង និងកែលម្អឱ្យកាន់តែមានប្រសិទ្ធភាព។</td></tr>
<tr><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</td><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</td></tr>
<tr><td>✓ ៥.១.១៖ ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការអនុវត្តមុខងារជាកាតព្វកិច្ច<br>✓ ៥.១.២៖ ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាជម្រើស<br>✓ ៥.១.៣៖ ការរៀបចំបែបផែននៃកិច្ចសហការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ</td><td>✓ ៥.១.១៖ ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការអនុវត្តមុខងារជាកាតព្វកិច្ច<br>✓ ៥.១.២៖ ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាជម្រើស<br>✓ ៥.១.៣៖ ការរៀបចំបែបផែននៃកិច្ចសហការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ</td></tr>
</table>

<table>
<tr><td colspan="2">លទ្ធផលរំពឹងទុក ៥.២៖ យន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ កែលម្អ និងពង្រឹងការអនុវត្តដើម្បីធានាដល់ការផ្តល់សេវារដ្ឋបាលឱ្យកាន់តែមានភាពសាមញ្ញ ងាយស្រួល ឆាប់រហ័ស ប្រសិទ្ធភាព តម្លាភាពគណនេយ្យភាព ព្រមទាំងជំរុញការរៀបចំ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន</td></tr>
<tr><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</td><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</td></tr>
<tr><td>✓ ៥.២.១៖ ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត<br>✓ ៥.២.២៖ ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>✓ ៥.២.៣៖ ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ</td><td>✓ ៥.២.៣៖ ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ</td></tr>
<tr><td colspan="2">លទ្ធផលរំពឹងទុក ៥.៣៖ យុទ្ធសាស្ត្រលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គការសង្គមស៊ីវិល និងផ្នែកឯកជនត្រូវបានពិនិត្យ កែសម្រួល និងជំរុញការអនុវត្ត។</td></tr>
<tr><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១</td><td>សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២</td></tr>
<tr><td>✓ ៥.៣.១៖ ការរៀបចំបញ្ជីមូលដ្ឋានអាជីវកម្ម ឬសហគ្រាសនៅតាមមូលដ្ឋាន<br>✓ ៥.៣.២៖ ការលើកកម្ពស់ភាពជាដៃគូជាមួយវិស័យឯកជនក្នុងការផ្តល់សេវាសាធារណៈ<br>✓ ៥.៣.៣៖ ការបង្កើតក្របខ័ណ្ឌនៃការផ្តល់សេវាសាធារណៈតាមរយៈអ្នកផ្គត់ផ្គង់សេវា</td><td>✓ ៥.៣.១៖ ការរៀបចំបញ្ជីមូលដ្ឋានអាជីវកម្ម ឬសហគ្រាសនៅតាមមូលដ្ឋាន<br>✓ ៥.៣.២៖ ការលើកកម្ពស់ភាពជាដៃគូជាមួយវិស័យឯកជនក្នុងការផ្តល់សេវាសាធារណៈ</td></tr>
</table>

| លទ្ធផលរំពឹងទុក ៥.៤៖ ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ ជំងឺងកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនានា ត្រូវបានបញ្ជ្រាបទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ | |
|---|---|
| **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី១** | **សកម្មភាពជាអាទិភាពសម្រាប់ ផអ៥ទី២** |
| ✓ **៥.៤.១៖** ការបង្កើតគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា<br>✓ **៥.៤.២៖** ការកំណត់បទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវាដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ<br>✓ **៥.៤.៣៖** ការពង្រឹងការប្រើប្រាស់ទិន្នន័យអំពីការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា<br>✓ **៥.៤.៤៖** ការវិនិយោគសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | ✓ **៥.៤.៣៖** ការពង្រឹងការប្រើប្រាស់ទិន្នន័យអំពីការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា<br>✓ **៥.៤.៤៖** ការវិនិយោគសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា |

## តារាងទី ១០៖ ការគ្រប់គ្រងហានិភ័យសំខាន់ៗសម្រាប់សមាសភាគទី៥

| ល.រ | ហានិភ័យ | ផលប៉ះពាល់ | លទ្ធភាពកើតមាន | វិធានការកាត់បន្ថយ |
|---|---|---|---|---|
| ១ | គុណភាពសេវាទាបដោយសារភាពយឺតយ៉ាវនៃរៀបចំនីតិវិធី និងស្តង់ដារសម្រាប់អនុវត្តមុខងារជាកាតព្វកិច្ចនានា | មធ្យម | មធ្យម | - ការគាំទ្រផ្នែកនយោបាយដើម្បីជានាឱ្យមានកិច្ចសហការយ៉ាងរលូនជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំនីតិវិធី និងស្តង់ដារសេវា |
| ២ | គុណភាពសេវាទាបដោយសារថវិកា និងបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិមិនគ្រប់គ្រាន់ដើម្បីបំពេញតាមស្តង់ដារផ្តល់សេវាដែលបានកំណត់ | ខ្ពស់ | មធ្យម | - ការប៉ាន់ប្រមាណតម្រូវការធនធានធៀបជាមួយស្តង់ដារ<br>- ផ្តល់អាទិភាពក្នុងការវិភាជធនធានសម្រាប់ការអនុវត្តមុខងារជាកាតព្វកិច្ចនៅក្នុងសមាសភាគទី៣ និងទី៤ |
| ៣ | មុខងារជាជម្រើសពាក់ព័ន្ធនឹងសេវាសង្គមមិនអាចអនុវត្តស្របទៅតាមឆន្ទានុសិទ្ធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | មធ្យម | មធ្យម | - គោលការណ៍ណែនាំច្បាស់លាស់ស្តីពីការជ្រើសរើស ការរៀបចំ និងការអនុវត្តមុខងារជាជម្រើសដែលពាក់ព័ន្ធនឹងសេវាសង្គម<br>- ការលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់អាទិភាពដល់ការចំណាយលើការផ្តល់សេវាសង្គមសម្រាប់ក្រុមក្រីក្រ និងងាយរងគ្រោះ |
| ៤ | ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ មិនអាចសម្រេចបានតាមគោលបំណង និងគោលការណ៍នៃការផ្តល់សេវាតាមយន្តការច្រកចេញចូលតែមួយដោយសារនីតិវិធីស្មុគស្មាញ ចំណាយពេលវេលាច្រើន មិនមានការរៀបចំជាកញ្ចប់សេវា និងតម្រូវឱ្យសុំសេវាច្រើនកន្លែង | មធ្យម | មធ្យម | - ការពិនិត្យ និងការកែសម្រួលយន្តការ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានសមស្របទៅតាមគោលបំណង និងគោលការណ៍នៃច្រកចេញចូលតែមួយ<br>- ការរៀបចំ ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ |

## ៣.៦. កិច្ចការអន្តរវិស័យ

កិច្ចការអន្តរវិស័យសំខាន់ៗចំនួន២ ដែលនឹងត្រូវបញ្ជ្រាប និងសមាហរណកម្មទៅក្នុងសមាសភាគទាំងប្រាំ និងផ្នែកផ្សេងទៀតនៃកជទី២ រួមមាន៖ ការបញ្ជ្រាបសមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម និងការគ្រប់គ្រងការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា។ គោលបំណង និងយុទ្ធសាស្ត្រលម្អិតនៃកិច្ចការអន្តរវិស័យទាំងនេះមានបរិយាយនៅក្នុងឧបសម្ព័ន្ធនៃឯកសារកម្មវិធីជាតិនេះ។

### ៣.៦.១. ការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម

សមិទ្ធផលរំពឹងទុកនៃការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម គឺរដ្ឋបាលថ្នាក់ក្រោមជាតិជ្រើសរើស និងគ្រប់គ្រងបុគ្គលិក រៀបចំផែនការ និងធនធាន ព្រមទាំងចាត់ចែងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដោយគ្មានការរើសអើង និងមិនប្រកាន់ជាតិសាសន៍ សាសនា ភេទ ជនដែលមានពិការភាព និងឆ្លើយតបដល់ក្រុមជនងាយរងគ្រោះនានាប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គម។

គោលនយោបាយ លិខិតបទដ្ឋាន និងឯកសារណែនាំ ព្រមទាំងសកម្មភាពនានាដែលបានរៀបចំ និងអនុវត្តក្នុងក្របខ័ណ្ឌនៃកជទី១ បានបញ្ជ្រាបនូវការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម។ កជទី២ នឹងបន្តគាំទ្រសមិទ្ធផលនេះ និងពង្រឹងពង្រីកឱ្យកាន់តែទូលំទូលាយនូវគណនេយ្យភាព និងការទទួលខុសត្រូវពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការដាក់បញ្ចូលនូវរាល់បញ្ហាទាំងឡាយពាក់ព័ន្ធនឹងការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ជាពិសេសក្រុមជនងាយរងគ្រោះនានានៅក្នុងសហគមន៍ដែលរួមមាន ក្រុមចាស់ជរា ក្រុមជនមានពិការភាពជនជាតិដើមភាគតិច និងក្រុមជនងាយរងគ្រោះផ្សេងទៀត ដែលមានតម្រូវការផ្សេងពីប្រជាពលរដ្ឋទូទៅ។

វិធីសាស្ត្រក្នុងការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមនៅក្នុង កជទី២នេះ នឹងត្រូវបានគិតគូរទាំងនៅក្នុងកម្រិតក្របខ័ណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយនានា ទាំងនៅក្នុងកម្រិតស្ថាប័ន និងក្នុងការធ្វើសេចក្តីសម្រេចចិត្តនានាក្នុងការងាររដ្ឋបាលទូទៅ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន និងទាំងនៅក្នុងកម្រិតបុគ្គលក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធី និងកិច្ចការពាក់ព័ន្ធនានា។

លទ្ធផលរំពឹងទុកនៃការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម រួមមានដូចខាងក្រោម៖

- គោលនយោបាយ លិខិតបទដ្ឋាន និងឯកសារណែនាំនានាពាក់ព័ន្ធនានានឹងត្រូវបានរៀបចំ ពិនិត្យ និងកែសម្រួល ឱ្យឆ្លើយតបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ដើម្បីធានាថាស្ត្រី និង

ក្រុមជនងាយរងគ្រោះនានាត្រូវបានចូលរួមធ្វើសេចក្ដីសម្រេចចិត្ត និងទទួលផលប្រយោជន៍ពីការផ្ដល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន

- ការអនុវត្តលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមត្រូវបានសម្របសម្រួលជាមួយភាគីពាក់ព័ន្ធនានា ព្រមទាំងត្រូវបានត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំនៅថ្នាក់ក្រោមជាតិ
- យន្តការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានពង្រឹង និងគាំទ្រ ដើម្បីឆ្លើយតបទៅនឹងបញ្ហា និងតម្រូវការនានារបស់ស្ត្រី និងក្រុមជនងាយរងគ្រោះនានា
- ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ កែសម្រួល និងដាក់ឱ្យអនុវត្ត ដើម្បីលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម
- ចំនួនស្ត្រី និងក្រុមជនងាយរងគ្រោះនានា ត្រូវបានបង្កើននៅក្នុងមុខតំណែងជាថ្នាក់ដឹកនាំ និងមុខតំណែងវិជ្ជាជីវៈនៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- សមត្ថភាព និងជំនាញរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងការបញ្ជ្រាបសមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ភាពជាអ្នកដឹកនាំ ការពង្រឹងសិទ្ធិអំណាច សេវាសង្គម និងជំនាញពាក់ព័ន្ធផ្សេងទៀតត្រូវបានលើកកម្ពស់
- ការយល់ដឹងរបស់សាធារណជន ជាពិសេសប្រជាពលរដ្ឋជាស្ត្រី និងក្រុមជនងាយរងគ្រោះនានាពាក់ព័ន្ធនឹងសមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម នឹងត្រូវបានបង្កើន
- ការបង្កើនភាពអង់អាចដល់ស្ត្រី និងក្រុមជនងាយរងគ្រោះ ដើម្បីមានលទ្ធភាពចូលរួម និងទទួលបានផលប្រយោជន៍ពេញលេញក្នុងការងារអភិបាលកិច្ច និងការអភិវឌ្ឍមូលដ្ឋាន
- ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង និងគាំទ្រ ដើម្បីឆ្លើយតបទៅនឹងបញ្ហា និងតម្រូវការនានានៃការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម រួមទាំងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពតាមរយៈការរៀបចំវគ្គជាកាតព្វកិច្ចដល់ថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- យន្តការ និងហេដ្ឋារចនាសម្ព័ន្ធនានានៅកន្លែងបំពេញការងារត្រូវបានបង្កើត ឬកែលម្អ ដើម្បីបង្កលក្ខណៈងាយស្រួលដល់បុគ្គលិកជាស្ត្រី និងក្រុមជនងាយរងគ្រោះនានា
- ការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានការឆ្លើយតបទៅនឹងយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ត្រូវបានលើកកម្ពស់
- ការផ្ទេរមុខងារ និងធនធានដែលមានការឆ្លើយតបទៅនឹងយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ត្រូវបានចាត់ជាអាទិភាព និងគាំទ្រ

- គម្រោង និងកម្មវិធីនានាដែលមានការឆ្លើយតបទៅនឹងយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមត្រូវបានរៀបចំ និងផ្តល់មូលនិធិគាំទ្រ ដើម្បីឆ្លើយតបនឹងបញ្ហា និងតម្រូវការនានារបស់ស្ត្រី និងក្រុមជនងាយរងគ្រោះនានា
- យន្តការ ទីកន្លែងនៃការផ្តល់សេវា និងហេដ្ឋារចនាសម្ព័ន្ធនានាត្រូវបានរៀបចំ និងកែលម្អ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ស្ត្រី និងជនងាយរងគ្រោះនានាក្នុងការទទួល និងការប្រើប្រាស់សេវាសាធារណៈទាំងនោះប្រកបដោយបរិយាប័ន្ន និងសមធម៌។
- ជំរុញការរៀបចំប្រព័ន្ធតាមដាន និងវាយតម្លៃ ប្រព័ន្ធទិន្នន័យរបស់កម្មវិធីជាតិដែលឆ្លើយតបទៅនឹងយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម។

ស្ថាប័នអនុវត្តទាំងអស់នៃ កជទី២ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបញ្ជ្រាបសមភាពយេនឌ័របរិយាប័ន្ន និងសមធម៌សង្គមក្នុងលទ្ធផលរំពឹងទុកពាក់ព័ន្ធនានាក្នុងផែនការសកម្មភាព និងថវិការបស់ខ្លួន។

**៣.៦.២. ការគ្រប់គ្រងការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា**

សមិទ្ធផលរំពឹងទុកនៃការគ្រប់គ្រងការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា គឺរដ្ឋបាលថ្នាក់ក្រោមជាតិអាចវាយតម្លៃ គ្រប់គ្រង និងឆ្លើយតបដោយប្រសិទ្ធភាពទៅនឹងភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា ដើម្បីគាំទ្រដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋ និងអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងមូលដ្ឋានរបស់ខ្លួន។

លទ្ធផលរំពឹងទុកនៃការគ្រប់គ្រងការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា រួមមានដូចខាងក្រោម៖

- យន្តការ និង/ឬអង្គភាពជាក់លាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗទទួលខុសត្រូវលើការវាយតម្លៃហានិភ័យនៃការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ ជំងឺឆ្លងកាចសាហាវនានា និងការឆ្លើយតបរយៈពេលខ្លី និងរយៈពេលមធ្យមប្រកបដោយប្រសិទ្ធភាពនឹងត្រូវបានសិក្សា រៀបចំ និងពង្រឹង
- យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ជំងឺឆ្លងកាចសាហាវនានាត្រូវបានរៀបចំសម្រាប់រដ្ឋបាលរាជធានី ខេត្ត ក្រុង និងស្រុកនីមួយៗ ហើយសកម្មភាពជាអាទិភាពនានាដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រនេះ ត្រូវបានបញ្ជ្រាបក្នុងផែនការ និងថវិកានានានៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់កម្រិត

- ធនធានពីប្រភពស្របច្បាប់នានាទាំងក្នុងប្រទេស និងក្រៅប្រទេស ត្រូវបានកៀរគរសម្រាប់ផ្តល់ហិរញ្ញប្បទានដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានភាពងាយរងគ្រោះជាងគេនឹងការប្រែប្រួលអាកាសធាតុ
- ប្រព័ន្ធផ្តល់ព័ត៌មានជាមុន និងសមត្ថភាពក្នុងការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានាត្រូវបានរៀបចំ អនុវត្ត និងពង្រឹង។

ស្ថាប័នអនុវត្តទាំងអស់នៃកជទី២ ត្រូវបញ្ជ្រាបការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានាទៅក្នុងផែនការសកម្មភាព និងថវិការបស់ខ្លួន។

## តារាងទី ១១៖ ការគ្រប់គ្រងហានិភ័យសំខាន់ៗសម្រាប់កិច្ចការអន្តរវិស័យ

| ល.រ | ហានិភ័យ | ផលប៉ះពាល់ | លទ្ធភាពកើតមាន | វិធានការកាត់បន្ថយ |
|---|---|---|---|---|
| **ការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម** | | | | |
| ១ | ថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់តិចតួចក្នុងការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម | ខ្ពស់ | មធ្យម | – បញ្ចូលយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ទៅក្នុងកម្មវិធីបណ្តុះបណ្តាលវគ្គជាកាតព្វកិច្ច និងភាពជាអ្នកដឹកនាំ<br>– ពង្រឹងការលើកកម្ពស់គោលការណ៍លើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម |
| ២ | ចំនួនបុគ្គលិកជាស្ត្រី និងក្រុមជនងាយរងគ្រោះទទួលបានមុខតំណែងគ្រប់គ្រងមានចំនួនតិចតួចដោយសារខ្វះកន្លែងទំនេរ និងបេក្ខជនសមស្រប | មធ្យម | មធ្យម | – រៀបចំប្រព័ន្ធទិន្នន័យឱ្យបានច្បាស់លាស់អំពីបុគ្គលិកជាស្ត្រី និងក្រុមជនងាយរងគ្រោះដែលមានសក្តានុពល<br>– រៀបចំវគ្គបណ្តុះបណ្តាលដោយឡែកសម្រាប់បុគ្គលិកជាស្ត្រី និងក្រុមជនងាយរងគ្រោះដែលមានសក្តានុពលសម្រាប់បំពេញមុខតំណែងគ្រប់គ្រង<br>– បន្តពង្រឹងការអនុវត្តនូវលក្ខខណ្ឌនៃការជ្រើសរើស និងតែងតាំងបំពេញមុខតំណែងដែលទំនេរដោយផ្តល់អាទិភាពដល់បេក្ខភាពជាស្ត្រី និងក្រុមជនងាយរងគ្រោះ<br>– បង្កើនការផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីសារៈសំខាន់នៃការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចនៅថ្នាក់ក្រោមជាតិ។ |

| | | | | |
|---|---|---|---|---|
| ៣ | រដ្ឋបាលថ្នាក់ក្រោមជាតិយកចិត្តទុកដាក់តិចតួចអំពីអាទិភាពរបស់ស្ត្រី និងក្រុមជនងាយរងគ្រោះទាំងនៅក្នុងការរៀបចំ និងការអនុវត្តផែនការសកម្មភាព និងគម្រោងថវិកានានា | ខ្ពស់ | មធ្យម | – រៀបចំសេចក្តីណែនាំស្តីពីការប្រើប្រាស់ថវិកាឱ្យបានច្បាស់លាស់ និងឆ្លើយតបយេនឌ័រ<br>– រៀបចំផែនការសកម្មភាព និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈឆ្លើយតបនឹងយេនឌ័រ<br>– ពង្រឹងការគាំទ្រផ្នែកបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>– ពង្រឹងការវាយតម្លៃ និងតាមដានដល់ការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរៀបចំ និងអនុវត្តកម្មវិធីផ្តល់ពានរង្វាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបំពេញការងារបានល្អ។ |
| **ការគ្រប់គ្រងការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា** | | | | |
| ៤ | រដ្ឋបាលថ្នាក់ក្រោមជាតិពុំមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ក្នុងការចំណាយបន្ថែមលើការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុសម្រាប់គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានា | មធ្យម | ខ្ពស់ | – កៀរគរធនធានបន្ថែមពីមូលនិធិអាកាសធាតុបៃតង និងពីប្រភពផ្សេងទៀត ដើម្បីផ្តល់ហិរញ្ញប្បទានបន្ថែមដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ |
| ៥ | រដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់មានការយល់ដឹងច្បាស់លាស់អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ | មធ្យម | មធ្យម | – បញ្ចូលការលើកកម្ពស់ចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុទៅក្នុងវគ្គបណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៦ | រដ្ឋបាលថ្នាក់ក្រោមជាតិខ្វះសមត្ថភាពបច្ចេកទេសក្នុងការសិក្សាវាយតម្លៃហានិភ័យនៃការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | មធ្យម | មធ្យម | – ផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការសិក្សាវាយតម្លៃហានិភ័យនៃការប្រែប្រួលអាកាសធាតុ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីរៀបចំយុទ្ធសាស្ត្រ និងគម្រោងនានាពាក់ព័ន្ធនឹងការកាត់បន្ថយហានិភ័យនៃការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា |

# ជំពូកទី៤

# ការគ្រប់គ្រង និងការអនុវត្តកម្មវិធីជាតិ

## ៤.១. ក្របខ័ណ្ឌសម្រាប់អនុវត្តកម្មវិធីជាតិដំណាក់កាលទី២

កជទី២ គឺជាផែនទីបង្ហាញផ្លូវសម្រាប់បន្តការអនុវត្តកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ក្រោមការដឹកនាំ ការគ្រប់គ្រង និងការសម្របសម្រួលរបស់ គ.ជ.អ.ប. កម្មវិធីជាតិនេះនឹងត្រូវអនុវត្តដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ ព្រមទាំងមានការចូលរួមគាំទ្រ និង/ឬអនុវត្តដោយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា។ ប្រជាពលរដ្ឋនឹងត្រូវបានលើកទឹកចិត្ត និងជំរុញឱ្យចូលរួមកាន់តែសកម្មក្នុងកិច្ចដំណើរការកំណែទម្រង់នេះ។ ដើម្បីធានាដល់ការសម្រេចបាននូវសមិទ្ធផលនានានៃ កជទី២ ទាមទារនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំ និងការចូលរួមយ៉ាងសកម្មប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំនៃក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់។ អាស្រ័យហេតុនេះ តួនាទី និងការទទួលខុសត្រូវរបស់គ.ជ.អ.ប. ក្នុងការដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការអនុវត្ត កជទី២ គឺពិតជាមានសារសំខាន់ក្នុងការធានាឱ្យការអនុវត្ត កជទី២សម្រេចបានជោគជ័យតាមសមិទ្ធផលដែលបានគ្រោងទុក។

កជទី២នេះ ត្រូវរៀបចំអនុវត្តជាពីរដំណាក់កាលដែលដំណាក់កាលនីមួយៗមានរយៈពេល០៥ឆ្នាំ (ផអ៥)។ ក្នុងការរៀបចំផែនការអនុវត្តរយៈពេលប្រាំឆ្នាំនៃកម្មវិធីជាតិ នឹងធ្វើការបែងចែកឱ្យបានច្បាស់លាស់អំពីស្ថាប័នអនុវត្តទទួលខុសត្រូវតាមលទ្ធផលរំពឹងទុកនីមួយៗ។ ស្ថាប័នអនុវត្តនីមួយៗត្រូវរៀបចំផែនការសកម្មភាព និងថវិកា (ផ.ស.ថ.) ប្រចាំឆ្នាំសម្រាប់អនុវត្តសកម្មភាពជាអាទិភាពនានានៃលទ្ធផលរំពឹងទុកទាំងនេះ។ ស្ថាប័នអនុវត្តនីមួយៗត្រូវរៀបចំរបាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈមក្នុងការសម្រេចបាននូវលទ្ធផលរំពឹងទុកទាំងនេះតាមគោលការណ៍កំណត់។ ផ.ស.ថ.ប្រចាំឆ្នាំរបស់ស្ថាប័នអនុវត្តនីមួយៗនឹងត្រូវបានបូកសរុប និងរៀបចំជាផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់គ.ជ.អ.ប.។ ក្នុងនាម គ.ជ.អ.ប. លេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលខុសត្រូវក្នុងការសម្របសម្រួល និងគាំទ្រស្ថាប័នអនុវត្តលើដំណើរការរៀបចំផ.ស.ថ.ប្រចាំឆ្នាំ ការតាមដានការអនុវត្ត ផ.ស.ថ.ប្រចាំឆ្នាំ របស់គ.ជ.អ.ប. ការគ្រប់គ្រងហានិភ័យ និងការផ្តល់ជំនួយបច្ចេកទេសដល់ស្ថាប័នអនុវត្តនានាក្នុងការគ្រប់គ្រងកម្មវិធី។ លេខាធិការដ្ឋាន គ.ជ.អ.ប. ក៏ត្រូវគ្រប់គ្រងធនធានហិរញ្ញវត្ថុដែលគាំទ្រពីដៃគូអភិវឌ្ឍន៍នានាសម្រាប់ជំនួយបច្ចេកទេស។

### ៤.១.១. ស្ថាប័នអនុវត្តកម្មវិធីជាតិដំណាក់កាលទី២

ស្ថាប័នអនុវត្ត កជទី២ រួមមាន ៖

- លេខាធិការដ្ឋាន គ.ជ.អ.ប.

- ក្រសួង ស្ថាប័នថ្នាក់ជាតិពាក់ព័ន្ធនានានៃរាជរដ្ឋាភិបាល រួមមានក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងផែនការ ក្រសួងកិច្ចការនារី និងក្រសួង ស្ថាប័នវិស័យនីមួយៗដែលពាក់ព័ន្ធនឹងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- រដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់
- ស្ថាប័នមិនមែនរដ្ឋាភិបាលមានដូចជា សមាគមជាតិក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល ស្ថាប័នឯកជន និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត។

### ៤.១.១.១. តួនាទីរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.

លេខាធិការដ្ឋាន គ.ជ.អ.ប. មានតួនាទីសំខាន់ៗចំនួន២គឺ ១). តួនាទីក្នុងការគ្រប់គ្រងកម្មវិធីទាំងមូលក្នុងនាមជាសេនាធិការរបស់គ.ជ.អ.ប. និង ២). តួនាទីជាស្ថាប័នអនុវត្តដែលទទួលខុសត្រូវអនុវត្តលទ្ធផលរំពឹងទុកនានាដែលបានកំណត់នៅក្នុងកម្មវិធីជាតិ និងផអ៥ តាមដំណាក់កាលនីមួយៗ។

១). តួនាទីក្នុងការគ្រប់គ្រងកម្មវិធីទាំងមូលក្នុងនាមជាសេនាធិការរបស់ គ.ជ.អ.ប. រួមមាន ៖

- លើកកម្ពស់ការផ្សព្វផ្សាយ ការយល់ដឹង និងការគាំទ្រចំពោះកំណែទម្រង់នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងចំណោមស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ស្ថាប័នឯកជន ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា
- សម្របសម្រួល និងគាំទ្រដល់កិច្ចដំណើរការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- សហការ និងសម្របសម្រួលជិតស្និទ្ធជាមួយស្ថាប័នដឹកនាំកម្មវិធីកំណែទម្រង់នានាដូចជាកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- គាំទ្រក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំ និងអនុវត្តផ.ស.ថ.ប្រចាំឆ្នាំ
- បូកសរុប និងរៀបចំសេចក្តីព្រាង ផ.ស.ថ.ប្រចាំឆ្នាំរបស់ គ.ជ.អ.ប.
- កៀរគរធនធានពីប្រភពខាងក្រៅសម្រាប់អនុវត្តកជទី២ តាមរយៈការប្រាស្រ័យទាក់ទងជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ស្ថាប័នឯកជន និងអ្នកពាក់ព័ន្ធផ្សេងទៀត
- គ្រប់គ្រងធនធានហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍សម្រាប់គាំទ្រជំនួយបច្ចេកទេសដល់ស្ថាប័នអនុវត្តកជទី២
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការសម្រេចបាននូវចំណុចដៅដែលបានកំណត់ក្នុងផ.ស.ថ.ប្រចាំឆ្នាំ និងរាយការណ៍ជូន គ.ជ.អ.ប.

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើលទ្ធផលនានាដែលបានកំណត់នៅក្នុងកម្មវិធីជាតិ និងផអ៥
- បំពេញតួនាទីជាលេខាធិការដ្ឋានរបស់គ.ជ.អ.ប. និងអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. ក្នុងការរៀបចំកិច្ចប្រជុំ ការរៀបចំរបាយការណ៍ និងកិច្ចការពាក់ព័ន្ធផ្សេងទៀត។

ក្រៅពីនេះ លេខាធិការដ្ឋាន គ.ជ.អ.ប.ត្រូវសម្របសម្រួលការអនុវត្ត និងការគ្រប់គ្រង កជទី២ ជាមួយដៃគូអភិវឌ្ឍន៍នានា តាមរយៈការរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គណៈកម្មការនិង/ឬក្រុមប្រឹក្សាភិបាលដឹកនាំការអនុវត្តគម្រោង និងកម្មវិធីនានាដែលពាក់ព័ន្ធនឹងវិមជ្ឈការ ដើម្បីជានាដល់ការរៀបចំ និងការអនុវត្តកម្មវិធីជាតិ ផអ៥ និង ផ.ស.ថ.ប្រចាំឆ្នាំ។

២). តួនាទីជាស្ថាប័នអនុវត្តមួយក្នុងចំណោមស្ថាប័នអនុវត្តនានានៃកម្មវិធីជាតិ រួមមាន ៖

- ការអនុវត្តសកម្មភាពជាអាទិភាពនានា ដែលជាការទទួលខុសត្រូវផ្ទាល់របស់លេខាធិការដ្ឋាន គ.ជ.អ.ប. ដូចបានកំណត់នៅក្នុងលទ្ធផលរំពឹងទុកជាក់លាក់មួយចំនួននៃកម្មវិធីជាតិ និងផអ៥
- ការគ្រប់គ្រង និងសម្របសម្រួលគម្រោង/កម្មវិធីជាច់ដោយឡែកនានាដែលគាំទ្រថវិកាដោយដៃគូអភិវឌ្ឍន៍ ដើម្បីរួមចំណែកដល់ការសម្រេចបាននូវលទ្ធផលរំពឹងទុកជាក់លាក់នានាដែលបានកំណត់នៅក្នុងកម្មវិធីជាតិ និងផអ៥
- ការប្រមូលសរុបវឌ្ឍនភាពនៃការអនុវត្តគម្រោង/កម្មវិធីជាច់ដោយឡែកនានា ដើម្បីដាក់បញ្ចូលទៅក្នុងរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តផ.ស.ថ.ប្រចាំឆ្នាំរបស់គ.ជ.អ.ប.។

### ៤.១.១.២. តួនាទីរបស់ក្រសួង ស្ថាប័ន

ការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២នៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធនីមួយៗ ស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលមានរដ្ឋមន្ត្រី ឬប្រធានស្ថាប័នជាប្រធាន។ ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងនោះរួមមាន ក្រសួងដែលទទួលខុសត្រូវពាក់ព័ន្ធនឹងការងារអន្តរស្ថាប័ន និងក្រសួង ស្ថាប័នជំនាញតាមវិស័យនីមួយៗឬហៅថាក្រសួងផ្ទេរមុខងារ។

**១). តួនាទីរបស់ក្រសួងដែលទទួលខុសត្រូវពាក់ព័ន្ធនឹងការងារអន្តរស្ថាប័ន៖**

ក្រសួងទាំងនេះរួមមានដូចជា ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងផែនការ និងក្រសួងកិច្ចការនារី នឹងមានតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តកជទី២។ ជាក់ស្តែង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងទទួលខុសត្រូវអនុវត្តសកម្មភាពស្ទើរតែទាំងអស់ក្នុងសមាសភាគទី៤ ដែលពាក់ព័ន្ធនឹងវិមជ្ឈការហិរញ្ញវត្ថុ។ ទោះជាយ៉ាងក៏ដោយ ពុំមែនមានន័យថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាអ្នកទទួលខុសត្រូវទាំងស្រុងលើវិមជ្ឈការហិរញ្ញវត្ថុនោះឡើយ ពីព្រោះមាន

សកម្មភាពមួយចំនួនពាក់ព័ន្ធនឹងវិមជ្ឈការហិរញ្ញវត្ថុនេះត្រូវទទួលខុសត្រូវក្នុងការអនុវត្តដោយក្រសួង ស្ថាប័នផ្សេងៗទៀត និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលតម្រូវឱ្យក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ទាំងនោះត្រូវរាយការណ៍អំពីលទ្ធផលនៃការអនុវត្តសកម្មភាពជាអាទិភាពនានានៃសមាសភាគទី៤ ជូន ទាំងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគ.ជ.អ.ប.។ តួនាទីសំខាន់ៗរបស់ក្រសួងទាំងនេះរួមមាន ៖

- ធានាថា លទ្ធផលរំពឹងទុកពាក់ព័ន្ធនានាក្នុងកជទី២ និងផអ៥ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុង ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័នសាមី
- ធានាថា សកម្មភាពពាក់ព័ន្ធនានានៃកជទី២ និងផអ៥ ត្រូវបានដាក់បញ្ចូល និងផ្តល់ថវិកា គាំទ្រគ្រប់គ្រាន់ពីថវិការបស់ក្រសួង ស្ថាប័នសាមី
- បែងចែកភារកិច្ចដល់អង្គភាពជំនាញពាក់ព័ន្ធចំណុះក្រសួង ស្ថាប័ន និងត្រួតពិនិត្យមើល លើការអនុវត្តសកម្មភាពនានានៃកជទី២ ដែលក្រសួង ស្ថាប័ននីមួយៗទទួលអនុវត្ត
- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ លិខិតបទដ្ឋាន និងបទដ្ឋានបច្ចេកទេសនានា សម្រាប់អនុវត្តសកម្មភាពនានានៃលទ្ធផលរំពឹងទុកក្នុងកជទី២ ដែលក្រសួងទទួលអនុវត្ត
- សហការជាមួយសាលាជាតិរដ្ឋបាលមូលដ្ឋានក្នុងការរៀបចំកម្មវិធីសិក្សា និងអនុវត្ត ផែនការអភិវឌ្ឍសមត្ថភាពស្តីពីគោលនយោបាយ លិខិតបទដ្ឋាន យុទ្ធសាស្ត្រ និងបទដ្ឋាន បច្ចេកទេសនានាដែលបានរៀបចំ
- តាមដាន ត្រួតពិនិត្យ និងផ្តល់ការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្ត គោលនយោបាយ លិខិតបទដ្ឋាន យុទ្ធសាស្ត្រ និងបទដ្ឋានបច្ចេកទេសនានា
- កៀរគរធនធានសម្រាប់គាំទ្រការអនុវត្តសកម្មភាពនានានៃកជទី២
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលដែលសម្រេចបាន ជូន គ.ជ.អ.ប.។

**២). តួនាទីសំខាន់ៗរបស់ក្រសួង ស្ថាប័នជំនាញតាមវិស័យនីមួយៗរួមមាន៖**

- ធានាថា លទ្ធផលរំពឹងទុកពាក់ព័ន្ធនានាក្នុងកជទី២ និងផអ៥ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុង ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័នសាមី
- ធានាថា សកម្មភាពពាក់ព័ន្ធនានានៃកជទី២ និងផអ៥ ត្រូវបានដាក់បញ្ចូល និងផ្តល់ថវិកា គាំទ្រគ្រប់គ្រាន់ពីថវិការបស់ក្រសួង ស្ថាប័នសាមី
- បែងចែកភារកិច្ចដល់អង្គភាពជំនាញពាក់ព័ន្ធចំណុះក្រសួង ស្ថាប័ន និងត្រួតពិនិត្យមើល លើការអនុវត្តសកម្មភាពនានានៃកជទី២ ដែលក្រសួង ស្ថាប័ននីមួយៗទទួលអនុវត្ត
- កំណត់មុខងារ និងធនធានដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងរៀបចំលិខិត បទដ្ឋានសម្រាប់ការផ្ទេរមុខងារ និងធនធានទាំងនោះ

- សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានាថាធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការអនុវត្តមុខងារដែលបានផ្ទេរពីវិស័យរបស់ខ្លួន
- សហការជាមួយក្រសួងមុខងារសាធារណៈ ដើម្បីធានាថាមានបុគ្គលិកគ្រប់គ្រាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តមុខងារនានាដែលបានផ្ទេរពីវិស័យរបស់ខ្លួន
- រៀបចំសេចក្ដីណែនាំបច្ចេកទេស ឬឯកសារបច្ចេកទេស និងកំណត់ស្តង់ដារ/បទដ្ឋានបច្ចេកទេសសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- សហការជាមួយសាលាជាតិរដ្ឋបាលមូលដ្ឋានក្នុងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិស្ដីពីសេចក្ដីណែនាំបច្ចេកទេស ឬឯកសារបច្ចេកទេស ស្តង់ដារ/បទដ្ឋានបច្ចេកទេសដែលបានរៀបចំ
- ផ្ដល់ការគាំទ្រ និងតាមដាន ត្រួតពិនិត្យនិងការវាយតម្លៃដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារដែលបានផ្ទេរ
- កៀរគរធនធានសម្រាប់គាំទ្រការអនុវត្តសកម្មភាពនានានៃ កជទី២
- រៀបចំរបាយការណ៍ស្ដីពីលទ្ធផលដែលសម្រេចបាន ជូន គ.ជ.អ.ប.។

### ៩.១.១.៧. តួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ការអនុវត្ត កជទី២ នៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌស្ថិតក្រោមការដឹកនាំ និងគ្រប់គ្រងរបស់គណៈកម្មាធិការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលមានអភិបាលជាប្រធាន។ តួនាទីសំខាន់ៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន ៖

- ដឹកនាំ និងសម្របសម្រួលការអនុវត្តកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធានាថា លទ្ធផលរំពឹងទុកនានានៃកជទី២ ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវបានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិការបស់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌសាមីនីមួយៗ
- ធានាថា សកម្មភាពនានានៃកជទី២ ត្រូវបានដាក់បញ្ចូល និងផ្ដល់ថវិកាគាំទ្រគ្រប់គ្រាន់ពីថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសាមីនីមួយៗ
- បែងចែកភារកិច្ចដល់អង្គភាពពាក់ព័ន្ធចំណុះរដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រួតពិនិត្យមើលលើការអនុវត្តសកម្មភាពនានានៃ កជទី២ ដែលរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗទទួលអនុវត្ត

- ពិនិត្យ និងលើកសំណើកែសម្រួលតួនាទី និងរចនាសម្ព័ន្ធក្នុងស្ថាប័នរបស់ខ្លួន
- រៀបចំ និងអនុវត្តផែនការអភិវឌ្ឍសមត្ថភាពសម្រាប់រដ្ឋបាលរបស់ខ្លួន
- អនុវត្តមុខងារដែលបានផ្ទេរប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងមានតម្លាភាព
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលដែលសម្រេចបាន ជូន គ.ជ.អ.ប.។

រដ្ឋបាលរាជធានី ខេត្តនឹងទទួលខុសត្រូវក្នុងការត្រួតពិនិត្យ ការអភិវឌ្ឍសមត្ថភាព និងការគាំទ្ររដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តសកម្មភាពនានានៃ កជទី២ ផងដែរ។ រដ្ឋបាលក្រុង ស្រុក ខណ្ឌ នឹងទទួលខុសត្រូវក្នុងការត្រួតពិនិត្យ ការអភិវឌ្ឍសមត្ថភាព និងការគាំទ្រឃុំ សង្កាត់ក្នុងការអនុវត្តសកម្មភាពនានានៃកំណែទម្រង់។ រដ្ឋបាលឃុំ សង្កាត់នីមួយក៏ត្រូវចូលអនុវត្តសកម្មភាពជាអាទិភាពពាក់ព័ន្ធនានាដែលមានកំណត់នៅក្នុងកម្មវិធីជាតិនេះ។

#### ៩.១.១.៩. តួនាទីរបស់ស្ថាប័នមិនមែនរដ្ឋាភិបាល

ស្ថាប័នមិនមែនរដ្ឋាភិបាលមានដូចជា សមាគមជាតិក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល ស្ថាប័នឯកជន និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត។ ស្ថាប័នទាំងនេះចូលរួម និងសហការអនុវត្តកជទី២នេះ ដោយប្រើប្រាស់ថវិការបស់ខ្លួន ឬតាមរយៈការចុះកិច្ចព្រមព្រៀង ឬកិច្ចសន្យាជាមួយ គ.ជ.អ.ប. ក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តសកម្មភាពជាអាទិភាពនានានៃលទ្ធផលរំពឹងទុកក្នុងកម្មវិធីជាតិ។

### ៩.១.២. កិច្ចដំណើរការរៀបចំផែនការ និងថវិកា

#### ៩.១.២.១. ប្រភពថវិកាសម្រាប់កម្មវិធីជាតិដំណាក់កាលទី២

ធនធានថវិកាសម្រាប់ កជទី២ រួមមាន ៖

- ថវិកាជាតិ (ថវិកាមួយផ្នែករបស់ក្រសួង ស្ថាប័នសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ថវិការបស់លេខាធិការដ្ឋាន គ.ជ.អ.ប. និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ)
- ធនធានរបស់ដៃគូអភិវឌ្ឍន៍ (ធនធានដែលគ្រប់គ្រងដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ធនធានដែលគ្រប់គ្រងផ្ទាល់ដោយស្ថាប័នអនុវត្តនីមួយៗ និងធនធានដែលគ្រប់គ្រងផ្ទាល់ដោយដៃគូអភិវឌ្ឍន៍)
- ធនធានផ្សេងទៀតដែលកៀរគរ ដើម្បីគាំទ្រកជទី២ ដូចជាធនធានរបស់អង្គការសង្គមស៊ីវិលនានាដែលចូលរួមអនុវត្តកជទី២។

សកម្មភាពជាអាទិភាពនានានៃកជទី២ ដែលត្រូវអនុវត្តដោយក្រសួង ស្ថាប័ន (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) នឹងត្រូវគាំទ្រដោយថវិការបស់ក្រសួង ស្ថាប័នសាមីនីមួយៗ។ ដូច្នេះ សកម្មភាពអាទិភាពនានា សូចនាករ លទ្ធផលរំពឹងទុក និងផែនការអនុវត្តនៃកជទី២ នៅតាមស្ថាប័នអនុវត្ត ចាំបាច់ត្រូវឆ្លុះ

បញ្ចាំងនៅក្នុងកម្មវិធី អនុកម្មវិធី សកម្មភាព និងសូចនាករនានានៃផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់ស្ថាប័នអនុវត្តនីមួយៗ។ ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវធានាថាស្ថាប័នអនុវត្តនីមួយៗមានថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តសកម្មភាពនានានៃកជទី២។

ជាមួយគ្នានេះ គ.ជ.អ.ប. នឹងកៀរគរ និងគ្រប់គ្រងធនធានហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសនានាពីប្រភពខាងក្រៅ ដើម្បីគាំទ្រដល់ស្ថាប័នអនុវត្តក្នុងការអនុវត្តសកម្មភាពជាអាទិភាពនានានៃកជទី២។

លេខាធិការដ្ឋាន គ.ជ.អ.ប. និងស្ថាប័នអនុវត្តក៏អាចគ្រប់គ្រង និងអនុវត្តគម្រោង/កម្មវិធីដាច់ដោយឡែកក្នុងក្របខ័ណ្ឌនៃ កជទី២ ផងដែរ។

### ៩.១.២.២. ការរៀបចំផែនការអនុវត្តរយៈពេលប្រាំឆ្នាំនៃកម្មវិធីជាតិដំណាក់កាលទី២

ការរៀបចំផអ៥ នៃកជទី២ ត្រូវផ្អែកលើលទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពនានាដែលបានកំណត់ក្នុងកម្មវិធីជាតិ។ ជាតុសំខាន់ៗនៃ ផអ៥ រួមមាន ៖

- ស្ថាប័នអនុវត្ត
- សូចនាករនៃលទ្ធផលរំពឹងទុក
- ចំណុចដៅសម្រាប់សូចនាករនីមួយៗតាមបណ្តាឆ្នាំនៃផអ៥
- ថវិកាប៉ាន់ស្មាន។

ទិន្នន័យទាំងនេះ បង្ហាញអំពីគម្រោងផែនការរយៈពេលវែងរបស់ស្ថាប័នអនុវត្តនីមួយៗ។

### ៩.១.២.៣. ផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ

ស្ថាប័នអនុវត្តនីមួយៗដែលជាអង្គភាពថវិកានឹងត្រូវដាក់បញ្ចូលនូវសកម្មភាពជាអាទិភាពនានាពាក់ព័ន្ធនឹងស្ថាប័នខ្លួនដែលបានកំណត់នៅក្នុងផអ៥ ទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ស្ថាប័នសាមីតាមរយៈការបង្កើតជាអនុកម្មវិធី ឬចង្កោមសកម្មភាពស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

បច្ចុប្បន្ន រដ្ឋបាលក្រុង ស្រុក ខណ្ឌពុំទាន់មានផែនការយុទ្ធសាស្ត្រថវិកានៅឡើយ អាស្រ័យហេតុនេះ សកម្មភាពនានានៃកជទី២ នឹងត្រូវរ៉ាប់រងដោយថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

គម្រោងថវិកាសម្រាប់ការចំណាយលើការអនុវត្តមុខងារផ្តល់សេវានានា ដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំដាក់បញ្ចូលទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ពោលគឺពុំត្រូវបានដាក់បញ្ចូលទៅក្នុងផ.ស.ថ.ប្រចាំឆ្នាំរបស់គ.ជ.អ.ប.ឡើយ។

### ៤.១.២.៤. ផែនការសកម្មភាព និងថវិកា (ផ.ស.ថ.) ប្រចាំឆ្នាំ របស់ គ.ជ.អ.ប.

ផ.ស.ថ.ប្រចាំឆ្នាំរបស់គ.ជ.អ.ប. ត្រូវបានរៀបចំដោយបូកសរុបនូវ ៖

- សកម្មភាព សូចនាករ ចំណុចដៅ ក្របខ័ណ្ឌពេលវេលា និងថវិកាសម្រាប់សកម្មភាពនានានៃកជទី២ ដែលបានរៀបចំនៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ស្ថាប័នអនុវត្តនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- សកម្មភាព សូចនាករ ចំណុចដៅ ក្របខ័ណ្ឌពេលវេលា និងថវិការបស់គម្រោង/កម្មវិធីជាច់ដោយឡែកនានាដែលបានដាក់បញ្ចូលក្នុងកជទី២

លេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលខុសត្រូវបូកសរុប និងរៀបចំនូវសេចក្តីព្រាងផ.ស.ថ.ប្រចាំឆ្នាំរបស់គ.ជ.អ.ប. ផ្អែកលើផ.ស.ថ.ប្រចាំឆ្នាំរបស់ស្ថាប័នអនុវត្តនានា ដើម្បីបង្ហាញ និងពិភាក្សានៅក្នុងសិក្ខាសាលាជាតិស្តីពីការរៀបចំផ.ស.ថ.ប្រចាំឆ្នាំ។ បន្ទាប់មក ផ.ស.ថ.ប្រចាំឆ្នាំត្រូវដាក់ជូន គ.ជ.អ.ប. ពិនិត្យ និងអនុម័ត។

### ៤.១.២.៥. គម្រោង ឬកម្មវិធីនានាដែលគាំទ្រពីប្រភពខាងក្រៅ

លេខាធិការដ្ឋាន គ.ជ.អ.ប. និងស្ថាប័នអនុវត្តនានានៃកជទី២ អាចទទួល និងគ្រប់គ្រងមូលនិធិជំនួយពីប្រភពខាងក្រៅសម្រាប់អនុវត្តសកម្មភាពនានានៃកជទី២ ដែលជាទូទៅ ថវិកាទាំងនេះជាថវិការបស់គម្រោង/កម្មវិធីជាច់ដោយឡែកនានា។

សម្រាប់គម្រោង/កម្មវិធីជាច់ដោយឡែកនានារបស់ដៃគូអភិវឌ្ឍន៍ដែលសហការគ្រប់គ្រងដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ឬក្រសួង ស្ថាប័នអនុវត្តផ្សេងទៀតត្រូវមានការរៀបចំនូវក្របខ័ណ្ឌលទ្ធផលដែលមានលក្ខណៈច្បាស់លាស់ក្នុងការចូលរួមចំណែកដល់ការអនុវត្តលទ្ធផលរំពឹងទុកនានានៃកជទី២។ ជាទូទៅ គម្រោង/កម្មវិធីជាច់ដោយឡែកតែងផ្តោតទៅលើការផ្តល់ហិរញ្ញប្បទានទៅលើគម្រោងវិនិយោគ ឬការផ្តល់សេវាកម្មជាក់លាក់នានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះជាយ៉ាងនេះក្តី គម្រោង/កម្មវិធីទាំងនេះត្រូវប្រើប្រាស់នូវយន្តការនានាដែលមានកំណត់ក្នុងកជទី២ ដើម្បីចូលរួមចំណែកនៅក្នុងកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិកាន់តែមានប្រសិទ្ធភាព។

ក្នុងករណីភាគច្រើន គម្រោង/កម្មវិធីជាច់ដោយឡែក តែងរៀបចំការគ្រប់គ្រងតាមនីតិវិធីប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍នានាដែលផ្តល់ហិរញ្ញប្បទានដល់គម្រោង/កម្មវិធីទាំងនោះ។ ជាមួយគ្នានេះដែរ លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងអនុវត្តនូវនីតិវិធីជាក់លាក់មួយចំនួនស្របតាមសៀវភៅណែនាំស្តីពីការគ្រប់គ្រងគម្រោងរបស់គ.ជ.អ.ប.បន្ថែមទៀត ដើម្បីគ្រប់គ្រងគម្រោង/កម្មវិធីទាំងនោះឱ្យមានកាន់តែប្រសិទ្ធភាព។ គម្រោង/កម្មវិធីជាច់ដោយឡែកទាំងអស់ត្រូវរៀបចំ ផ.ស.ថ.ប្រចាំឆ្នាំរបស់ខ្លួន។

អាស្រ័យហេតុនេះ ក្នុងករណីដែលអាចអនុវត្តបាន ការផ្តល់ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ទៅលើគម្រោង/កម្មវិធីជាច់ដោយឡែកនានាដែលគ្រប់គ្រង ចាត់ចែងដោយស្ថាប័នអនុវត្តនៃកជទី២ ចាំបាច់ត្រូវ

ដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័នអនុវត្តនីមួយៗ ដើម្បីធានាដល់ការបន្សុីគ្នារវាងថវិការដ្ឋ និងថវិកាពីប្រភពផ្សេងទៀត នឹងកាត់បន្ថយនូវការចំណាយត្រួតស៊ីគ្នានៅក្នុងការអនុវត្តកជទី២។

### ៤.១.២.៦. ការតាមដាន និងការរៀបចំរបាយការណ៍អំពីការអនុវត្ត ផ.ស.ថ.ប្រចាំឆ្នាំ

ការតាមដានការអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំ គឺជាកិច្ចដំណើរការត្រូវអនុវត្តជាប្រចាំ ឬមានចិរវេលាកំណត់ច្បាស់លាស់លើរាល់ការអនុវត្តសកម្មភាពនានាដែលបានកំណត់នៅក្នុងផ.ស.ថ.ប្រចាំឆ្នាំ។ គោលបំណងសំខាន់នៃការតាមដាន គឺសំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្ត និងការពិនិត្យកែសម្រួលសកម្មភាពនានានៃផ.ស.ថ.ប្រចាំឆ្នាំបានទាន់ពេលវេលា។

ក្នុងនាមក្រសួង ស្ថាប័នអនុវត្តនីមួយៗ គណៈកម្មាធិការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទទួលខុសត្រូវក្នុងការតាមដានលើការអនុវត្តផ.ស.ថ.ប្រចាំឆ្នាំរបស់ខ្លួន តាមរយៈកិច្ចប្រជុំប្រចាំខែ និងកិច្ចប្រជុំចាំបាច់នានា ព្រមទាំងរៀបចំរបាយការណ៍តាមការកំណត់អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តផ.ស.ថ.ប្រចាំឆ្នាំជូនគ.ជ.អ.ប.តាមរយៈលេខាធិការដ្ឋានគ.ជ.អ.ប.។ ជាមួយគ្នានេះដែរ ក្រសួង ស្ថាប័នក៏ត្រូវរៀបចំផែនការការងារសម្រាប់ការតាមដាន និងការគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិអំពីការអនុវត្តមុខងារ និងធនធានដែលបានផ្ទេរ។

ក្នុងនាមរដ្ឋបាលថ្នាក់ក្រោមជាតិ គណៈកម្មាធិការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទទួលខុសត្រូវក្នុងការតាមដានលើការអនុវត្តផ.ស.ថ.ប្រចាំឆ្នាំរបស់ខ្លួនតាមរយៈកិច្ចប្រជុំប្រចាំខែ និងកិច្ចប្រជុំចាំបាច់នានា ព្រមទាំងរៀបចំរបាយការណ៍អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តផ.ស.ថ.ប្រចាំឆ្នាំជូនគ.ជ.អ.ប.តាមរយៈលេខាធិការដ្ឋានគ.ជ.អ.ប.តាមការកំណត់។ ជាមួយគ្នានេះដែរ រដ្ឋបាលរាជធានី ខេត្តក៏ត្រូវរៀបចំផែនការការងារសម្រាប់ការតាមដាន និងគាំទ្ររដ្ឋបាលក្រុង ស្រុក ខណ្ឌ ហើយរដ្ឋបាលក្រុង ស្រុកក៏ត្រូវរៀបចំផែនការការងារសម្រាប់ការតាមដាន និងគាំទ្ររដ្ឋបាលឃុំ សង្កាត់ក្នុងការអនុវត្តមុខងារដែលបានផ្ទេរ និងមុខងារជាអាណត្តិទូទៅ។

លេខាធិការដ្ឋានគ.ជ.អ.ប. ទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និងបូកសរុបរៀបចំរបាយការណ៍អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តផ.ស.ថ.ប្រចាំឆ្នាំ ដើម្បីដាក់ជូនគ.ជ.អ.ប. ពិនិត្យ និងអនុម័ត។

គ.ជ.អ.ប. ត្រូវរៀបចំរបាយការណ៍ស្តីពីការអនុវត្តកម្មវិធីជាតិ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលយ៉ាងតិចរៀងរាល់៦ខែម្តង។

លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវរៀបចំកិច្ចប្រជុំជាទៀងទាត់ជាមួយស្ថាប័នអនុវត្តនានា ដើម្បីពិនិត្យមើលពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តផ.ស.ថ.ប្រចាំឆ្នាំ និងរៀបចំកិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍន៍នានាដូចជា កិច្ចប្រជុំក្រុមការងារបច្ចេកទេសស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកិច្ចប្រជុំគណៈកម្មការ ឬក្រុមប្រឹក្សាភិបាលដឹកនាំគម្រោង/កម្មវិធីនានា ដើម្បីធ្វើបច្ចុប្បន្នភាព

និងពិភាក្សាអំពីវឌ្ឍនភាព និងការដោះស្រាយបញ្ហាប្រឈមនានានៃការរៀបចំ និងការអនុវត្តផ.ស.ថ. ប្រចាំឆ្នាំ។

### ៩.១.២.៧. សវនកម្ម

ក្រុមសវនកម្មផ្ទៃក្នុងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលខុសត្រូវក្នុងការសម្របសម្រួល និងអនុវត្តសវនកម្មលើធនធាននានានៃកជទី២ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់លេខាធិការដ្ឋានគ.ជ.អ.ប.។ លេខាធិការដ្ឋានគ.ជ.អ.ប. ទទួលខុសត្រូវរៀបចំរបាយការណ៍ស្តីពីសវនកម្មផ្ទៃក្នុងជូនក្រុមការងារសវនកម្ម និងក្រុមសីលធម៌របស់គ.ជ.អ.ប. ដែលបានបង្កើតឡើងផ្អែកតាមការអនុម័តនៃកិច្ចប្រជុំលើកទី១៨របស់ គ.ជ.អ.ប.។

ការធ្វើសវនកម្មផ្ទៃក្នុងលើធនធានហិរញ្ញវត្ថុនានាគាំទ្រដោយដៃគូអភិវឌ្ឍន៍ដែលគ្រប់គ្រងដោយលេខាធិការដ្ឋានគ.ជ.អ.ប. រួមមាន ថវិកាគម្រោង/កម្មវិធីដាច់ដោយឡែកនានានឹងត្រូវអនុវត្តដោយក្រុមសវនកម្មផ្ទៃក្នុងរបស់លេខាធិការដ្ឋានគ.ជ.អ.ប.ស្របតាមបែបបទ និងនីតិវិធីរបស់គ.ជ.អ.ប. និងកិច្ចព្រមព្រៀងនានារវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយដៃគូអភិវឌ្ឍន៍ទាំងនោះ។ ចំពោះការធ្វើសវនកម្មផ្ទៃក្រៅ នឹងរៀបចំតាមរយៈការប្រកាសជ្រើសរើសក្រុមហ៊ុនឯកជនដើម្បីអនុវត្ត ផ្អែកតាមក្របខ័ណ្ឌពេលវេលា តម្រូវការ និងស្របតាមបែបបទ និងនីតិវិធីដែលបានឯកភាពគ្នារវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និងដៃគូអភិវឌ្ឍន៍។

ការធ្វើសវនកម្មលើធនធានហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលរួមមាន ថវិកាផ្ទេរពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងថវិការបស់ក្រសួង ស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានវិភាជសម្រាប់ការអនុវត្តសកម្មភាពនានានៃកម្មវិធីជាតិនឹងត្រូវអនុវត្តដោយស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលស្របតាមនីតិវិធីដែលបានកំណត់។

លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងពិនិត្យមើលលើរបកគំហើញ និងអនុសាសន៍ទាំងអស់នៃសវនកម្មលើធនធានហិរញ្ញវត្ថុស្ថិតក្រោមគ្រប់គ្រងរបស់ខ្លួន និងធានាចាត់វិធានការសមស្រប ដើម្បីទប់ស្កាត់ភាពមិនប្រក្រតីផ្នែកហិរញ្ញវត្ថុ និងនីតិវិធីនានាដែលអាចកើតមានឡើង។ ក្នុងន័យនេះ លេខាធិការដ្ឋានគ.ជ.អ.ប. នឹងរៀបចំការឆ្លើយតបចំពោះរបកគំហើញនានា និងរៀបចំរបាយការណ៍អំពីសកម្មភាពតាមដានសម្រាប់ គ.ជ.អ.ប. និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា។ របាយការណ៍សវនកម្ម និងឯកសារនានានឹងត្រូវផ្សព្វផ្សាយជាសាធារណៈ តាមរយៈគេហទំព័ររបស់គ.ជ.អ.ប. និងមធ្យោបាយផ្សេងទៀត បន្ទាប់ពីទទួលបានអនុលោមភាពពីគ.ជ.អ.ប. និងដៃគូអភិវឌ្ឍន៍នានា។

## ៤.២. ការតាមដាន និងការវាយតម្លៃកម្មវិធីជាតិដំណាក់កាលទី២

### ៤.២.១. វិសាលភាពនៃការតាមដាន និងការវាយតម្លៃកម្មវិធី

ជំពូកនេះរៀបរាប់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃដំណើរការវាស់វែងវឌ្ឍនភាពធៀបនឹងលទ្ធផលនានាដែលបានកំណត់នៅក្នុងក្របខ័ណ្ឌលទ្ធផលនៃកជទី២ និងលទ្ធផលរយៈពេលមធ្យមដែលបានកំណត់ក្នុងក្របខ័ណ្ឌលទ្ធផលនៃផអ៥។ ការតាមដាន និងការវាយតម្លៃកម្មវិធីនេះក៏ត្រូវវាស់វែងលទ្ធផលនានាដែលសម្រេចបានក្នុងរយៈពេលវែងផងដែរ។ គោលបំណងសំខាន់នៃការតាមដាន និងការវាយតម្លៃកម្មវិធីគឺ ដើម្បីផ្តល់ព័ត៌មានដល់ថ្នាក់ដឹកនាំ និងអ្នកពាក់ព័ន្ធនានាសម្រាប់ការពិភាក្សា និងការធ្វើសេចក្តីសម្រេចចិត្តអំពីគោលនយោបាយស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការតាមដាន និងការវាយតម្លៃកម្មវិធីគឺជាភារកិច្ច និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.។

ការអនុវត្តការតាមដាន ផ.ស.ថ.ប្រចាំឆ្នាំ នៃកជទី២ គឺជាកិច្ចការដាច់ដោយឡែកពីការតាមដាន និងការវាយតម្លៃកម្មវិធីដែលផ្តោតជាចម្បងលើការផ្តល់ព័ត៌មានឱ្យបានទាន់ពេលវេលាកំណត់ជូនថ្នាក់ដឹកនាំកម្មវិធី ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចាត់វិធានការឱ្យបានសមស្រប ទាន់ពេលវេលា និងតាមការចាំបាច់ចំពោះបញ្ហាប្រឈមនានា។ ការតាមដាន ផ.ស.ថ.ប្រចាំឆ្នាំ គឺជាភារកិច្ច និងការទទួលខុសត្រូវរបស់ស្ថាប័នអនុវត្តនានា និងលេខាធិការដ្ឋាន គ.ជ.អ.ប. ដែលបានបរិយាយនៅក្នុងផ្នែកខាងលើនៃការគ្រប់គ្រង និងអនុវត្តកម្មវិធី។

### ៤.២.២. សូចនាករ និងវិធីសាស្ត្រសម្រាប់ការវាស់វែងការផ្លាស់ប្តូរ

#### ៤.២.២.១. កម្រិតផ្លាស់ប្តូរទាំងបី

លទ្ធផលនានានៃកជទី២ត្រូវវាស់វែងការសម្រេចបាននូវការផ្លាស់ប្តូរនៅកម្រិតសំខាន់ៗចំនួន៣ដូចខាងក្រោម ៖

- **កម្រិតក្របខ័ណ្ឌច្បាប់ (គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត)៖** លទ្ធផលទាំងឡាយនៅក្នុងកម្រិតនេះរួមមាន គោលនយោបាយ និងលិខិតបទដ្ឋាននានាដែលរៀបចំ និងដាក់ឱ្យអនុវត្តសម្រាប់ការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរួមមានដូចជាលិខិតបទដ្ឋានពាក់ព័ន្ធនឹងការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលក្រុងមេត្រូប៉ូលីតែនរដ្ឋបាលតំបន់ ការគ្រប់គ្រងនិងការអភិវឌ្ឍបុគ្គលិក និងវិមជ្ឈការហិរញ្ញវត្ថុជាដើម។
- **កម្រិតស្ថាប័ន (រចនាសម្ព័ន្ធ និងប្រព័ន្ធ)៖** លទ្ធផលទាំងឡាយក្នុងកម្រិតនេះរួមមានដូចជាការផ្លាស់ ប្តូរនានាពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ ប្រព័ន្ធ សិទ្ធិអំណាច មុខងារ និងធនធាននានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ឧទាហរណ៍ រដ្ឋបាលរាជធានីភ្នំពេញក្លាយជារដ្ឋបាលក្រុងមេត្រូប៉ូលីតែន រដ្ឋបាលខេត្តក្លាយជារដ្ឋបាលតំបន់ ប្រព័ន្ធកសាងផែនការនិងថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែសម្រួលនិងដាក់ឱ្យអនុវត្ត ប្រព័ន្ធនៃការវាយតម្លៃលើការបំពេញ

ការងាររបស់ បុគ្គលិកនិងការលើកទឹកចិត្តបុគ្គលិកត្រូវបានអនុវត្ត សាលាជាតិរដ្ឋបាលមូលដ្ឋានត្រូវបានដំណើរការពេញលេញ។ល។

- **កម្រិតបុគ្គល (សេវា)៖** លទ្ធផលនានាក្នុងកម្រិតនេះរួមមានដូចជា ការផ្លាស់ប្តូរនានាពាក់ព័ន្ធនឹងការបំពេញការងាររបស់បុគ្គលិក និងការផ្តល់សេវា ឧទាហរណ៍ បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបានល្អប្រសើរ រដ្ឋបាលថ្នាក់ក្រោមជាតិផ្តល់សេវា និងអភិវឌ្ឍមូលដ្ឋានបានល្អប្រសើរ ប្រជាពលរដ្ឋទទួលបានសេវា និងផលប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែប្រសើរឡើង។

លទ្ធផលទាំង៣កម្រិតខាងលើនឹងត្រូវបានវាស់វែងតាមរយៈឧបករណ៍ត្រួតពិនិត្យចំនួន៣ប្រភេទ រួមមាន របាយការណ៍ ទិន្នន័យទូទៅ និងការអង្កេតដោយផ្អែកលើសំណាក។ សមិទ្ធផលផ្នែកគោលនយោបាយ (ដូចជា គោលនយោបាយ ឬលិខិតបទដ្ឋានថ្មីត្រូវបានអនុម័ត) ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងប្រព័ន្ធរបាយការណ៍នៃកម្មវិធី។ ការផ្លាស់ប្តូរផ្នែកស្ថាប័នត្រូវបានវាស់វែងតាមរយៈប្រព័ន្ធរបាយការណ៍នៃកម្មវិធី និងតាមរយៈការកត់ត្រាជាទិន្នន័យនៅក្នុងប្រព័ន្ធទិន្នន័យមូលដ្ឋាននានា ឧទាហរណ៍ អំពីចំនួនបុគ្គលិកក្នុងមុខតំណែងនានា ឬទំហំថវិកាដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានបែងចែកសម្រាប់មុខសញ្ញាចំណាយនីមួយៗរបស់ខ្លួន។ ជាទូទៅ ការវាស់វែងនៅកម្រិតបុគ្គលចាំបាច់ត្រូវធ្វើឡើងតាមរយៈការអង្កេតផ្អែកលើសំណាក។

សូចនាករនីមួយៗ វិធីសាស្ត្រនៃការវាស់វែង និងក្របខ័ណ្ឌពេលវេលា នៃការវាស់វែងមានបង្ហាញនៅក្នុងតារាងក្របខ័ណ្ឌលទ្ធផលរួមនៃកជ២។ បន្ថែមលើការវាស់វែងដោយផ្ទាល់ ផ្អែកលើសូចនាករនានាដែលបានកំណត់នៅក្នុងតារាងក្របខ័ណ្ឌលទ្ធផលរួមរបស់កជទី២ ការតាមដាន និងការវាយតម្លៃកម្មវិធីក៏ត្រូវអនុវត្តតាមរយៈការវាយតម្លៃដោយផ្អែកលើប្រធានបទជាក់លាក់មួយចំនួនផងដែរ។

### ៩.២.២.២. សន្ទស្សន៍ (បណ្តុំសូចនាករ) ជាយុទ្ធសាស្ត្រ

សូចនាករកម្រិតគោលបំណង និងគោលដៅនៃកជទី២រួមមាន សន្ទស្សន៍ជាយុទ្ធសាស្ត្រចំនួន៣គឺ៖

- **សន្ទស្សន៍ផ្នែកអភិបាលកិច្ច** (បណ្តុំសូចនាករកម្រិតគោលបំណងនៃកជទី២)
- **សន្ទស្សន៍ផ្នែកការផ្តល់សេវា** (បណ្តុំសូចនាករកម្រិតគោលដៅនៃកជទី២)
- **សន្ទស្សន៍ផ្នែកសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ** (បណ្តុំសូចនាករកម្រិតគោលដៅនៃកជទី២)

ការវាស់វែងសន្ទស្សន៍ជាយុទ្ធសាស្ត្រទាំង៣ខាងលើនេះឱ្យបានច្បាស់លាស់ ត្រឹមត្រូវ និងទាន់ពេលវេលាគឺជាកត្តាដ៏មានសារៈសំខាន់ក្នុងការវាស់វែងអំពីភាពជោគជ័យនៃកជទី២។ កន្លងមកនេះ សន្ទស្សន៍ជាយុទ្ធសាស្ត្រទាំង៣នេះ ត្រូវបានប្រើប្រាស់សម្រាប់កជទី១ ប៉ុន្តែសម្រាប់កជទី២ សន្ទស្សន៍ទាំងនេះចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពឡើងវិញ។ វិធីសាស្ត្រសម្រាប់ប្រើប្រាស់ក្នុងការវាស់វែងរួមមានដូចខាងក្រោម ៖

- សន្ទស្សន៍ផ្នែកអភិបាលកិច្ចដោយផ្អែកលើការធ្វើបច្ចុប្បន្នភាពលើការអង្កេតអំពីអភិបាលកិច្ច ដែលបានអនុវត្តនៅកជទី១
- សន្ទស្សន៍ផ្នែកការផ្តល់សេវាសំដៅលើការអង្កេតផ្អែកលើសំណាកអំពីការទទួលបាន ការប្រើប្រាស់ និងការពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សន្ទស្សន៍ផ្នែកសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកលើការវាយតម្លៃអំពីសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

និយមន័យនៃសន្ទស្សន៍ និងវិធីសាស្ត្រនៃការគណនាសន្ទស្សន៍នឹងត្រូវបានធ្វើបច្ចុប្បន្នភាព ព្រមទាំងត្រូវបានវាស់វែងដោយផ្អែកលើទិន្នន័យដើមគ្រាដែលបានរៀបចំនៅក្នុងឆ្នាំទី១នៃកជទី២។

### ៤.២.៣. ក្របខ័ណ្ឌលទ្ធផលកម្មវិធីជាតិ

ក្របខ័ណ្ឌលទ្ធផល គឺជាឧបករណ៍មួយដ៏មានសារៈសំខាន់សម្រាប់ ការគ្រប់គ្រង ការតាមដាន និងការវាយតម្លៃគម្រោង ឬកម្មវិធីនានា។ អាស្រ័យហេតុនេះ ក្របខ័ណ្ឌលទ្ធផលនៃកជទី២ ត្រូវបានរៀបចំឡើងសម្រាប់ប្រើប្រាស់ក្នុងការគ្រប់គ្រង ការតាមដាន និងការវាយតម្លៃកជទី២ ដើម្បីធានាការសម្រេចបាននូវលទ្ធផលនានាក្នុងរយៈពេលវែង (ចក្ខុវិស័យ) រយៈពេលមធ្យម (គោលបំណង និងគោលដៅកម្មវិធី) និងរយៈពេលខ្លី (សមិទ្ធផល និងលទ្ធផលរំពឹងទុកតាមសមាសភាគនីមួយៗ) ដែលបានកំណត់ក្នុងកម្មវិធីនេះ ស្របតាមសូចនាករ ចំណុចដៅ និងក្របខ័ណ្ឌពេលវេលាដែលបានគ្រោងទុក។

ក្របខ័ណ្ឌលទ្ធផលកជទី២ ក៏បង្ហាញពីលំដាប់ថ្នាក់នៃលទ្ធផលនានាដែលនឹងសម្រេចក្នុងអំឡុងពេល និងចុងបញ្ចប់នៃការអនុវត្ត កជទី២។ ជារួម ក្របខ័ណ្ឌលទ្ធផលនៃកជទី២ រួមមានធាតុសំខាន់ៗដូចខាងក្រោម ៖

- លទ្ធផលនានាតាមលំដាប់ថ្នាក់៖ ចក្ខុវិស័យ គោលបំណង គោលដៅ សមិទ្ធផលរំពឹងទុក និងលទ្ធផលរំពឹងទុក
- សូចនាករសំខាន់ៗនៃលទ្ធផលនានា
- ទិន្នន័យដើមគ្រា
- ចំណុចដៅ
- ក្របខ័ណ្ឌពេលវេលា និងការសន្មត
- តារាងលម្អិតអំពីក្របខ័ណ្ឌលទ្ធផលនៃកជទី២ មាននៅក្នុងឧបសម្ព័ន្ធ "ក"៖ ក្របខ័ណ្ឌលទ្ធផលនៃកជទី២។

### ៤.២.៤. ប្រព័ន្ធទិន្នន័យសម្រាប់ការតាមដាន និងការវាយតម្លៃ

ការតាមដាន និងការវាយតម្លៃ កជទី២ នឹងប្រើប្រាស់មូលដ្ឋានទិន្នន័យនានា ដែលបានបង្កើត និងគ្រប់គ្រងក្នុងកម្រិតជាលទ្ធផលរំពឹងទុកនានានៃកម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងមូលដ្ឋានទិន្នន័យនានាដែលបានបង្កើតក្នុងគោលបំណងផ្សេងទៀត។ មូលដ្ឋានទិន្នន័យផ្សេងទៀតទាំងនោះរួមមានដូចជា ប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងរបស់កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងនៃកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ។ កម្មវិធីជាតិត្រូវធានាថា លេខាធិការដ្ឋានគ.ជ.អ.ប. មានលទ្ធភាពអាចទទួល និងប្រើប្រាស់សំណុំទិន្នន័យទាំងនេះបាន។

មូលដ្ឋានទិន្នន័យដែលបង្កើតឡើងដោយកម្មវិធីកំណែទម្រង់ផ្សេងៗទៀត រួមមាន ៖

- ប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុនៃកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ
- ប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងធនធានមនុស្សនៃកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ
- ប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងការចុះបញ្ជីទ្រព្យរដ្ឋនៃកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ
- ប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៃកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ
- មូលដ្ឋានទិន្នន័យនៃការវិនិយោគសាធារណៈ (ដែលនឹងបង្កើតឡើងដោយកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ)
- ទិន្នន័យអង្កេតសេដ្ឋកិច្ច និងសង្គមកិច្ច។

មូលដ្ឋានទិន្នន័យ ដែលពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរួមមាន ៖

- ទិន្នន័យអំពីសេដ្ឋកិច្ច និងសង្គមកិច្ចនៃមូលដ្ឋានទិន្នន័យឃុំសង្កាត់ ដែលប្រើប្រាស់ជាសំខាន់សម្រាប់គាំទ្រការកសាងផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានប្រមូលជារៀងរាល់ឆ្នាំជាមួយនឹងទិន្នន័យតាមវិស័យដទៃទៀតនៃមូលដ្ឋានទិន្នន័យឃុំ សង្កាត់
- មូលដ្ឋានទិន្នន័យក្រុមប្រឹក្សាឃុំ សង្កាត់មានផ្ទុកទិន្នន័យអំពីសមាជិកក្រុមប្រឹក្សានានា
- មូលដ្ឋានទិន្នន័យនៃការតាមដាន និងការវាយតម្លៃរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបច្ចុប្បន្នកំពុងរៀបចំឱ្យក្លាយទៅជាប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងនៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- មូលដ្ឋានទិន្នន័យស្តីពីគម្រោងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- មូលដ្ឋានទិន្នន័យថ្នាក់ជាតិអំពីផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គ.ជ.អ.ប.។

#### ៤.២.៥. ផែនការសកម្មភាព និងថវិកាសម្រាប់ការតាមដាន និងការវាយតម្លៃ

ឯកសារ ផអ៥ នីមួយៗ ត្រូវបញ្ចូលសកម្មភាពជាអាទិភាពនានា សម្រាប់ការតាមដាន និងការវាយតម្លៃកម្មវិធី។ ក្នុងអំឡុងពេលចាប់ផ្តើមអនុវត្តផអ៥នីមួយៗ លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវរៀបចំ ផ.ស.ថ.ប្រចាំឆ្នាំលម្អិតសម្រាប់ការតាមដាន និងការវាយតម្លៃរយៈពេល៥ឆ្នាំ ផ្អែកលើសកម្មភាពជាអាទិភាពនានានៃការតាមដាន និងការវាយតម្លៃដែលបានកំណត់ក្នុងផអ៥។ ជារួម ផែនការសកម្មភាព និងថវិកាសម្រាប់ការតាមដាន និងការវាយតម្លៃបង្ហាញអំពី៖

- សកម្មភាពនិងថវិកានានានៃការតាមដាន និងការវាយតម្លៃកម្មវិធី ដែលត្រូវអនុវត្តក្នុងអំឡុងពេលផអ៥ រួមបញ្ចូលទាំងការពិនិត្យកែសម្រួល និងរៀបចំសៀវភៅណែនាំ និងសេចក្តីណែនាំនានាពាក់ព័ន្ធនឹងសកម្មភាពតាមដាន និងវាយតម្លៃ
- ជំហាននានាសម្រាប់អនុវត្តសកម្មភាពនីមួយៗ និងតម្រូវការពេលវេលា (ដូចជា ការរៀបចំការអង្កេត ការចុះកិច្ចសន្យាជាមួយទីប្រឹក្សា ។ល។)
- ក្របខ័ណ្ឌពេលវេលាសម្រាប់សកម្មភាពនីមួយៗ
- ស្ថាប័ន/អង្គភាពទទួលខុសត្រូវសម្រាប់សកម្មភាពនីមួយៗ
- ជំនាញដែលត្រូវការសម្រាប់អនុវត្តសកម្មភាពនីមួយៗរួមទាំងផែនការសម្រាប់ការអភិវឌ្ឍសមត្ថភាពបុគ្គលិក ឬការជ្រើសរើសបុគ្គលិកដែលមានជំនាញពាក់ព័ន្ធ។

ផែនការសកម្មភាព និងថវិកា សម្រាប់ការតាមដាន និងការវាយតម្លៃត្រូវដាក់ជូនប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីពិនិត្យ និងអនុម័ត។

#### ៤.២.៦. ការវាយតម្លៃការអនុវត្ត កជទី២

ដើម្បីឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព បញ្ហាប្រឈម និងផលប៉ះពាល់ នៃការអនុវត្តកជទី២ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវដឹកនាំ សម្របសម្រួល និងអនុវត្តការវាយតម្លៃ ដោយផ្តោតលើសកម្មភាពជាអាទិភាព ដូចខាងក្រោម ៖

##### ៤.២.៦.១. ការរៀបចំទិន្នន័យដើមគ្រាកម្មវិធី

ដើម្បីធានាការវាស់វែងវឌ្ឍនភាពនៃលទ្ធផលនានា ដែលបានកំណត់ក្នុងក្របខ័ណ្ឌលទ្ធផលនៃកជទី២ និងលទ្ធផលរយៈពេលមធ្យមដែលបានកំណត់ក្នុង ផអ៥ ឱ្យមានសុក្រឹត្យភាព និងភាពអាចជឿទុកចិត្តបាន លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវរៀបចំចងក្រងទិន្នន័យដើមគ្រាដោយផ្តោតលើសូចនាករចាំបាច់នានា តាមរយៈការប្រើប្រាស់មូលដ្ឋានទិន្នន័យ និងរបាយការណ៍ពាក់ព័ន្ធនានាដែលមានស្រាប់ រួមបញ្ចូលទាំងការប្រមូលទិន្នន័យដោយផ្ទាល់តាមការចាំបាច់។ ការរៀបចំទិន្នន័យដើមគ្រាត្រូវអនុវត្តនៅក្នុងអំឡុងឆ្នាំដំបូងនៃផអ៥ទី១។

### ៤.២.៦.២. ការវាយតម្លៃប្រចាំឆ្នាំ

លេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តផ.ស.ថ. ប្រចាំឆ្នាំរបស់គ.ជ.អ.ប.។ ជាមួយគ្នានេះដែរ លេខាធិការដ្ឋាន គ.ជ.អ.ប. ក៏ត្រូវរៀបចំធ្វើបច្ចុប្បន្នភាពនូវក្របខ័ណ្ឌលទ្ធផលនានា និងធ្វើការវាយតម្លៃដោយសង្ខេបអំពីវឌ្ឍនភាពធៀបទៅនឹងលទ្ធផលជាយុទ្ធសាស្ត្រនានានៃកជទី២។

### ៤.២.៦.៣. ការវាយតម្លៃពាក់កណ្តាលកម្មវិធី

ការវាយតម្លៃពាក់កណ្តាលកម្មវិធី ត្រូវអនុវត្តនៅក្នុងអំឡុងឆ្នាំទី៥នៃផអ៥ទី១។ គោលបំណងនៃការវាយតម្លៃនេះគឺសិក្សាវាយតម្លៃអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តផអ៥ ធៀបនឹងក្របខ័ណ្ឌលទ្ធផលរបស់ផអ៥នីមួយៗ។ លទ្ធផលនៃការវាយតម្លៃនេះនឹងត្រូវប្រើប្រាស់ ដើម្បីលើកកម្ពស់សមិទ្ធផល និងប្រសិទ្ធភាពនៃផអ៥ ក៏ដូចជារួមចំណែកក្នុងការសម្រេចបាននូវលទ្ធផលនានានៃកជទី២។ ជាមួយគ្នានេះដែរ ការវាយតម្លៃនេះក៏នឹងត្រូវប្រើប្រាស់សម្រាប់ធ្វើជាមូលដ្ឋានទិន្នន័យដើមគ្រារបស់ផអ៥ទី២។

### ៤.២.៦.៤. ការវាយតម្លៃបញ្ចប់កម្មវិធី

ការវាយតម្លៃបញ្ចប់កម្មវិធីត្រូវអនុវត្តនៅក្នុងអំឡុងឆ្នាំទី១០នៃកជទី២។ គោលបំណងនៃការវាយតម្លៃនេះគឺដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំតាក់តែងកម្មវិធីជាតិបន្តបន្ទាប់ទៀត។ ការវាយតម្លៃបញ្ចប់កម្មវិធីត្រូវសិក្សាវាយតម្លៃអំពីសមិទ្ធផលនានានៃផអ៥ទី២ និងកជទី២ ធៀបនឹងក្របខ័ណ្ឌលទ្ធផលនៃផអ៥ទី២ និងក្របខ័ណ្ឌលទ្ធផលនៃកជទី២។

### ៤.២.៦.៥. ការវាយតម្លៃផលប៉ះពាល់សំខាន់ៗ

ការវាយតម្លៃផលប៉ះពាល់សំខាន់ៗរួមមាន៣ប្រភេទដែលត្រូវអនុវត្ត ដើម្បីវាស់វែងលទ្ធផលជាយុទ្ធសាស្ត្រសំខាន់ៗនានានៅក្នុងក្របខ័ណ្ឌលទ្ធផលនៃកជទី២។ ការវាយតម្លៃផលប៉ះពាល់សំខាន់ៗទាំង៣នេះរួមមាន ការអង្កេតអភិបាលកិច្ច ការវាយតម្លៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ និងការវាយតម្លៃលើគោលនយោបាយ ៖

- **ការអង្កេតអភិបាលកិច្ច៖** ការអង្កេតសំណាក ដែលត្រូវអនុវត្តក្នុងអំឡុងពេលនៃកជទី២ គឺជាការអង្កេតអភិបាលកិច្ច។ ក្នុងការអង្កេតអភិបាលកិច្ច សំណាកនានាដែលតំណាងឱ្យប្រជាពលរដ្ឋ និងតំណាងឱ្យសមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានសួរការយល់ដឹងអំពីសិទ្ធិអំណាច និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការយល់ដឹងអំពីកិច្ចដំណើរការអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអំពីការប្រើប្រាស់សេវា និងការពេញចិត្តទៅលើគុណភាពនៃសេវាដែលប្រជាពលរដ្ឋបានទទួល។ ការអង្កេតអភិបាលកិច្ចត្រូវបានរៀបចំអនុវត្តក្នុងគោលបំណងតាមដានការផ្លាស់ប្តូរនៃសន្ទស្សន៍គន្លឹះៗមួយចំនួនពាក់ព័ន្ធនឹងអភិបាលកិច្ចដូចជា ការផ្តល់សេវា ការឆ្លើយតប ការចូលរួមរបស់ប្រជាពលរដ្ឋ តម្លាភាព និងគណនេយ្យភាព។ ការអង្កេតអភិបាលកិច្ចត្រូវអនុវត្តចំនួន៣ដងក្នុងអំឡុង

ពេលនៃកដទី២រួមមាន ការអង្កេតទិន្នន័យដើមគ្រា ការអង្កេតបន្តក្នុងឆ្នាំទី៥ និងការអង្កេតទិន្នន័យចុងគ្រាក្នុងឆ្នាំទី៩នៃកម្មវិធីជាតិ។

- **ការវាយតម្លៃការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖** ការវាយតម្លៃអំពីការអភិវឌ្ឍសមត្ថភាពគឺជាផ្នែកមួយនៃការអង្កេតអំពីសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលនឹងត្រូវអនុវត្តជារៀងរាល់៣ឆ្នាំម្តង។ គោលបំណងនៃការវាយតម្លៃអំពីការអភិវឌ្ឍសមត្ថភាពគឺដើម្បីកំណត់នូវគម្លាត និងឧបសគ្គនៃការបំពេញការងារ និងផ្តល់អនុសាសន៍សម្រាប់ការកែលម្អ សំដៅលើកកម្ពស់ប្រសិទ្ធភាពការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការវាយតម្លៃការអភិវឌ្ឍសមត្ថភាពត្រូវវាស់វែងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅ៣កម្រិត៖
  - **សមត្ថភាពក្របខ័ណ្ឌច្បាប់៖** រៀបរាប់អំពីការរៀបចំ និងការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋាននានាស្តីពីការបង្កបរិយាកាស និងការលើកទឹកចិត្តនានាដែលអនុវត្តនៅក្នុងស្ថាប័ន។
  - **សមត្ថភាពស្ថាប័ន៖** រៀបរាប់អំពីរចនាសម្ព័ន្ធ ប្រព័ន្ធ កិច្ចដំណើរការ នីតិវិធី និងការអនុវត្តនានាដែលស្ថាប័នប្រើប្រាស់រួមជាមួយនឹងការប្រាស្រ័យទាក់ទង និងភាពជាដៃគូក្នុងការអនុវត្តការងារ។
  - **សមត្ថភាពបុគ្គល៖** រៀបរាប់អំពីជំនាញ ចំណេះដឹង និងអាកប្បកិរិយារបស់បុគ្គលិកម្នាក់ៗក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។
- **ការវាយតម្លៃគោលនយោបាយ៖** ការវាយតម្លៃគោលនយោបាយគឺជាការទទួលខុសត្រូវស្នូលរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.។ អាស្រ័យហេតុនេះ ការវាយតម្លៃគោលនយោបាយត្រូវអនុវត្តឱ្យបានទៀងទាត់ជារៀងរាល់ឆ្នាំ ដើម្បីធានាថាគោលនយោបាយនានាដែលបានអនុម័តអាចអនុវត្តប្រកប ដោយប្រសិទ្ធភាព។ គោលនយោបាយនីមួយៗត្រូវបានវាយតម្លៃដោយត្រូវពិនិត្យមើលឡើងវិញពីការរៀបចំតាក់តែង រហូតដល់ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយនោះ។ ជារួមការវាយតម្លៃគោលនយោបាយផ្តោតលើផ្នែកសំខាន់ៗចំនួន៥ គឺ ៖
  - **កិច្ចដំណើរការរៀបចំតាក់តែងគោលនយោបាយ៖** ផ្នែកនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវពិនិត្យមើលឡើងវិញ និងវាយតម្លៃលើដំណើរការរៀបចំតាក់តែងគោលនយោបាយដើម្បីជាមូលដ្ឋានក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃដំណើរការតាក់តែងគោលនយោបាយនាពេលអនាគត។ ការវាយតម្លៃនេះផ្តោតជាសំខាន់លើរបៀបនៃការកំណត់គោល

នយោបាយដែលនឹងត្រូវរៀបចំតាក់តែង នីតិវិធីនៃការរៀបចំគោលនយោបាយ និងការចូលរួមរបស់អ្នកពាក់ព័ន្ធ។

- **លទ្ធផលនៃការរៀបចំតាក់តែងគោលនយោបាយ៖** ផ្នែកនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវតាមដានលទ្ធផលនៃការរៀបចំតាក់តែងគោលនយោបាយធៀបនឹងក្របខ័ណ្ឌពេលវេលាដែលបានគ្រោងទុក ដោយកំណត់ពីបញ្ហាប្រឈមនានាដែលបង្កឱ្យមានភាពយឺតយ៉ាវក្នុងការដាក់ចេញនូវគោលនយោបាយនោះ។
- **គុណភាពនៃគោលនយោបាយដែលបានដាក់ចេញ៖** ផ្នែកនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវវាយតម្លៃអំពីគុណភាពនៃគោលនយោបាយដោយផ្តោតលើខ្លឹមសារនៃគោលនយោបាយ (ភាពច្បាស់លាស់នៃការកំណត់នូវគោលដៅ គោលបំណងបទបញ្ញត្តិត្រូវអនុវត្ត ការកំណត់តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ស្ថាប័នអនុវត្ត ការកំណត់អំពីយន្តការនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃ) ការអង្កេតពីភាពពេញចិត្ត ការវាយតម្លៃសង្គតិភាពគោលនយោបាយជាមួយគោលការណ៍វិមជ្ឍការ និងវិសហមជ្ឈការ និងការកំណត់ចំណុចខ្វះខាតនៃគោលនយោបាយដែលបានដាក់ចេញ។
- **ការអនុវត្តគោលនយោបាយ៖** ផ្នែកនេះមានគោលបំណងពិនិត្យមើលលើការអនុវត្តគោលនយោបាយធៀបនឹងបទបញ្ញត្តិដែលបានដាក់ចេញ ព្រមទាំងវាស់វែងលើវឌ្ឍនភាព និងកំណត់បញ្ហាប្រឈមក្នុងការអនុវត្តគោលនយោបាយទាំងនោះ ដើម្បីធានាដល់ការសម្របសម្រួល និងកិច្ចអន្តរាគមន៍គាំទ្រនានាសំដៅពង្រឹងការអនុវត្តឱ្យកាន់តែប្រសើរឡើង។
- **ប្រសិទ្ធភាពនៃគោលនយោបាយ៖** ផ្នែកនេះ ផ្តោតជាសំខាន់លើការវាយតម្លៃទៅលើការសម្រេចបាននូវលទ្ធផលគ្រោងទុកកម្រិតខ្ពស់ ដែលរួមមានដូចជាសមិទ្ធផលរំពឹងទុក និងផលប៉ះពាល់នៃគោលនយោបាយ។ អាស្រ័យហេតុនេះ ក្នុងករណីដែលចាំបាច់ត្រូវវាយតម្លៃពីប្រសិទ្ធភាពនៃគោលនយោបាយណាមួយ លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវរៀបចំវិធីសាស្ត្រ មធ្យោបាយ លក្ខណៈវិនិច្ឆ័យ និងសូចនាករសម្រាប់ការវាយតម្លៃប្រសិទ្ធភាពនៃគោលនយោបាយនោះ។

### ៤.២.៧. ការសិក្សាដែលមានលក្ខណៈជាការវាយតម្លៃ និងការស្រាវជ្រាវ

ការសិក្សា និងការស្រាវជ្រាវត្រូវអនុវត្តក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីវឌ្ឍនភាព និងផលប៉ះពាល់នៃកជទី២។ ការសិក្សាមានលក្ខណៈខុសគ្នាពីការអង្កេត ដោយផ្តោតសំខាន់លើការប្រមូលទិន្នន័យបែបគុណភាព។ ការអង្កេតមានគោលបំណងវាស់វែងអំពីការផ្លាស់ប្តូរ ចំណែកការសិក្សាមានគោលបំណងស្វែងរកអំពីមូលហេតុដែលនាំឱ្យមានការផ្លាស់ប្តូរ។ ក្របខ័ណ្ឌលទ្ធផលនៃកម្មវិធីជាតិ

បានកំណត់នូវចំណុចដៅមួយចំនួនសម្រាប់វាស់វែងអំពីការផ្លាស់ប្តូរនេះ។ សូចនាករនានានៃក្របខ័ណ្ឌលទ្ធផលកម្មវិធីជាតិត្រូវបានវាស់វែងតាមរយៈការអង្កេត និងវិធីសាស្ត្របែបបរិមាណដទៃទៀត។

#### ៤.២.៧.១. ការសិក្សាដែលមានលក្ខណៈជាការវាយតម្លៃ

ការសិក្សាអាចអនុវត្តតាមវិធីសាស្ត្រខុសៗគ្នាអាស្រ័យលើប្រធានបទដែលត្រូវសិក្សា។ ឧទាហរណ៍នៃវិធីសាស្ត្រសម្រាប់ការសិក្សារួមមានដូចជា ករណីសិក្សា ការពិភាក្សាជាក្រុម ការសម្ភាសន៍អ្នកផ្តល់ព័ត៌មាន និងការអង្កេតសំណាក ដែលមានបំណងជាក់លាក់ (ក្នុងករណីនេះ សំណាកត្រូវបានជ្រើសរើសសម្រាប់គោលបំណងជាក់លាក់ណាមួយដោយមិនតំណាងឱ្យប្រជាពលរដ្ឋទាំងមូលដែលមិនអាចធ្វើសេចក្តីសន្និដ្ឋានមានលក្ខណៈជាទូទៅបានឡើយ)។

#### ៤.២.៧.២. ការស្រាវជ្រាវ

ការស្រាវជ្រាវត្រូវបានប្រើប្រាស់ក្នុងគោលបំណងបង្កើនការយល់ដឹងអំពីមូលហេតុ ទស្សនៈ និងឆន្ទៈបំពេញការងារពាក់ព័ន្ធនឹងកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការស្រាវជ្រាវនឹងរកឱ្យឃើញអំពីមូលហេតុនៃបញ្ហា ឬជួយអភិវឌ្ឍគំនិត ឬរៀបចំសកម្មភាពនានាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការស្រាវជ្រាវក៏មានគោលបំណងក្នុងការផ្តល់នូវសារៈតា និងអំណះអំណាងសម្រាប់អ្នកស្រាវជ្រាវ និងអ្នកធ្វើគោលនយោបាយនានានៅក្នុងការតាក់តែង និងការធ្វើសេចក្តីសម្រេចលើគោលនយោបាយ។

លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវរៀបចំអភិវឌ្ឍជំនាញស្តីពីការរៀបចំតាក់តែងនូវការសិក្សា និងការស្រាវជ្រាវដល់មន្ត្រីជំនាញរបស់ខ្លួន ព្រមទាំងត្រូវសម្របសម្រួល និងអនុវត្តការសិក្សានិងការស្រាវជ្រាវដោយផ្ទាល់ ឬដោយមានជំនួយបច្ចេកទេសពីខាងក្រៅ ផ្អែកលើគោលបំណង វិសាលភាព និងកម្រិតជំនាញដែលត្រូវការសម្រាប់ការសិក្សានិងការស្រាវជ្រាវនេះ។

### ៤.២.៨. ការរៀបចំរបាយការណ៍ស្តីពីការអនុវត្ត កជទី២

របាយការណ៍នានាដែលត្រូវរៀបចំស្តីពីការអនុវត្តកជទី២រួមមាន៖ របាយការណ៍នៃការវាយតម្លៃប្រចាំឆ្នាំ ពាក់កណ្តាល និងចុងបញ្ចប់នៃកជទី២ ការវាយតម្លៃផលប៉ះពាល់ ការអង្កេត ការសិក្សានិងការស្រាវជ្រាវ និងរបាយការណ៍ពាក់ព័ន្ធផ្សេងៗទៀត។ របាយការណ៍ទាំងនេះត្រូវរៀបចំ និងផ្សព្វផ្សាយយ៉ាងទូលំទូលាយជាសាធារណៈ តាមរយៈមធ្យោបាយផ្សេងៗដូចជា គេហទំព័រ និងបណ្ណាល័យរបស់ គ.ជ.អ.ប. និងបណ្តាញព័ត៌មានសង្គមផ្សេងទៀតស្របតាមគោលនយោបាយ និងលិខិតបទដ្ឋាននានាស្តីពីការផ្សព្វផ្សាយព័ត៌មានរបស់គ.ជ.អ.ប.។

## ៤.៣. ការគ្រប់គ្រងហានិភ័យ

ការអនុវត្តកជទី២ មានភាពសាំញ៉ាំ។ លទ្ធផលរំពឹងទុកនានាដែលទទួលខុសត្រូវអនុវត្តដោយក្រសួង ស្ថាប័នផ្សេងៗគ្នាមានទំនាក់ទំនង និងពឹងអាស្រ័យគ្នាទៅវិញទៅមក។ ជាមួយគ្នានេះដែរ នៅក្នុង

សមាសភាគនីមួយៗនៃកជទី២ រួមមាននូវការកំណត់អំពីហានិភ័យសំខាន់ៗពាក់ព័ន្ធនឹងយុទ្ធសាស្ត្រនៃការអនុវត្តសមាសភាគនោះ។ ហានិភ័យទាំងនេះត្រូវបានវាយតម្លៃពីកម្រិតរបស់វាតាមរយៈតារាងស្តីពីការគ្រប់គ្រងហានិភ័យនៃសមាសភាគនីមួយៗ។

អាស្រ័យហេតុនេះ កជទី២ ត្រូវយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងហានិភ័យទាំងនោះដោយប្រុងប្រយ័ត្ន ពោលគឺហានិភ័យនីមួយៗដែលបានកំណត់នៅក្នុងតារាងចាំបាច់ត្រូវត្រួតពិនិត្យតាមដានជាប្រចាំ។ ផ្អែកតាមនីតិវិធីដែលបានកំណត់នៅក្នុងសៀវភៅណែនាំស្តីពីការគ្រប់គ្រងគម្រោងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ហានិភ័យនីមួយៗត្រូវវាយតម្លៃដោយប្រើប្រាស់ប្រព័ន្ធកូដដែលមានកំណត់ពណ៌ក្រហម លឿង និងបៃតង។ ជាមួយគ្នានេះដែរ ចាំបាច់ត្រូវរៀបចំ និងអនុវត្តនូវផែនការសម្រាប់ដំណោះស្រាយឱ្យបានសមស្របសម្រាប់ហានិភ័យនានាដែលបានកំណត់ជាពណ៌ក្រហម។

ការអនុវត្តប្រព័ន្ធគ្រប់គ្រងហានិភ័យនៃកជទី២ ត្រូវទទួលខុសត្រូវរួមគ្នាដោយក្រសួង ស្ថាប័នអនុវត្តនានា និងលេខាធិការដ្ឋាន គ.ជ.អ.ប.។

**៤.៣.១. ចំណាត់ថ្នាក់ហានិភ័យនានា**

ការគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងហានិភ័យនានានៃព្រឹត្តិការណ៍ ឬស្ថានភាពនានាដែលនឹងអាចកើតមានឡើង និងធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់ភាពជោគជ័យនៃកជទី២។

ជាទូទៅ ចំណាត់ថ្នាក់របស់ហានិភ័យរួមមាន ហានិភ័យពាក់ព័ន្ធនឹងការអនុវត្ត ភាពជឿជាក់ក្នុងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ សុវត្ថិភាពបរិស្ថាននិងសង្គម និងនិរន្តរភាព។ ទោះបីជាយ៉ាងណាក៏ដោយ សម្រាប់កជទី២ ហានិភ័យដែលមានលក្ខណៈជាគន្លឹះគឺហានិភ័យពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។ ដោយឡែក ហានិភ័យពាក់ព័ន្ធនឹងភាពជឿជាក់ក្នុងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ សុវត្ថិភាពបរិស្ថាននិងសង្គម និងនិរន្តរភាពក៏មានសារៈសំខាន់ផងដែរ ប៉ុន្តែក្នុងក្របខ័ណ្ឌកជទី២ ផលប៉ះពាល់ដែលពាក់ព័ន្ធនឹងហានិភ័យទាំងនេះគឺ ការធ្វើឱ្យចុះខ្សោយកម្រិតនៃភាពជឿជាក់ក្នុងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ មានផលប៉ះពាល់ជាអវិជ្ជមានដល់សុវត្ថិភាពបរិស្ថាននិងសង្គម ឬការផ្តល់ធនធានមិនបានគ្រប់គ្រាន់ដល់ការគាំទ្រកម្មវិធីដែលធ្វើឱ្យប៉ះពាល់ដល់និរន្តរភាពនៃកំណែទម្រង់។

ហានិភ័យដែលបានកំណត់នីមួយៗរួមមានកម្រិតនៃផលប៉ះពាល់ដែលបានវាយតម្លៃមួយ (មានន័យថា ប្រសិនបើមានហានិភ័យណាមួយកើតមានឡើង តើផលប៉ះពាល់នោះមានកម្រិតណា?) និងលទ្ធភាពនៃហានិភ័យដែលអាចកើតឡើង ប្រសិនបើពុំមានវិធានការដោះស្រាយហានិភ័យនោះប្រកបដោយប្រសិទ្ធភាព។

ផលប៉ះពាល់នៃហានិភ័យនានាត្រូវបានកំណត់តាមមធ្យោបាយដូចខាងក្រោម ៖

- **ផលប៉ះពាល់កម្រិតខ្ពស់ ៖** ប្រសិនបើស្ថានភាព ឬព្រឹត្តិការណ៍បានកើតឡើង នោះវានឹងធ្វើឱ្យបរាជ័យនូវការអនុវត្តគោលដៅនានារបស់កជទី២។

- **ផលប៉ះពាល់កម្រិតមធ្យម** ៖ ប្រសិនបើស្ថានភាព ឬព្រឹត្តិការណ៍បានកើតឡើង នោះវានឹងធ្វើឱ្យអូសបន្លាយនូវការសម្រេចគោលដៅនានារបស់កជទី២ ឬសមិទ្ធផលរំពឹងទុកនៃសភាគមួយ។
- **ផលប៉ះពាល់កម្រិតទាប** ៖ ប្រសិនបើស្ថានភាព ឬព្រឹត្តិការណ៍បានកើតឡើង នោះវានឹងធ្វើឱ្យអូសបន្លាយដល់ការសម្រេចនូវលទ្ធផលរំពឹងទុកនានានៃកជទី២ ប៉ុន្តែវាពុំមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ការសម្រេចបាននូវសមិទ្ធផលរំពឹងទុក ឬគោលដៅរបស់កម្មវិធីឡើយ។

ភាពដែលអាចកើតមានឡើងនៃហានិភ័យ ត្រូវបានកំណត់តាមមធ្យោបាយដូចខាងក្រោម ៖

- **ភាពអាចកើតមានឡើងកម្រិតខ្ពស់** ៖ ប្រសិនបើពុំមានចាត់វិធានការដោះស្រាយហានិភ័យប្រកបដោយប្រសិទ្ធភាពទេ ព្រឹត្តិការណ៍ឬស្ថានភាពនៃហានិភ័យនោះនឹងអាចកើតឡើងយ៉ាងពិតប្រាកដ និងនាំឱ្យមានផលប៉ះពាល់ដូចកម្រិតដែលបានវាយតម្លៃ។
- **ភាពអាចកើតមានឡើងកម្រិតមធ្យម** ៖ ប្រសិនបើពុំមានចាត់វិធានការដោះស្រាយហានិភ័យប្រកបដោយប្រសិទ្ធភាពទេ ព្រឹត្តិការណ៍ឬស្ថានភាពនៃហានិភ័យនោះមានលទ្ធភាពអាចកើតឡើងយ៉ាងតិច៥០%។
- **ភាពអាចកើតមានឡើងកម្រិតទាប** ៖ ប្រសិនបើពុំមានចាត់វិធានការដោះស្រាយហានិភ័យប្រកបដោយប្រសិទ្ធភាពទេ ព្រឹត្តិការណ៍ឬស្ថានភាពនៃហានិភ័យនោះមានលទ្ធភាពអាចកើតឡើងតិចជាង៥០%។

តារាងស្តីពីការគ្រប់គ្រងហានិភ័យមានបរិយាយនៅក្នុងសមាសភាគនីមួយៗ និងផ្នែកកិច្ចការអន្តរវិស័យ។

ក្រៅពីបញ្ជីហានិភ័យដែលបានកំណត់នៅក្នុងសមាសភាគនីមួយៗ និងកិច្ចការអន្តរវិស័យ ក៏មានហានិភ័យមួយចំនួនទៀតដែលមានលក្ខណៈជាទូទៅសម្រាប់កម្មវិធីជាតិទាំងមូល។ ហានិភ័យដែលមានលក្ខណៈជាទូទៅទាំងនោះ អាចកើតឡើងដោយសារម្យ៉ាងពាក់ព័ន្ធទៅនឹងកត្តាខាងក្រៅដូចជា កំណើនសេដ្ឋកិច្ចទាបជាងការរំពឹងទុក ជំងឺកូវីដ-១៩ ឬម្យ៉ាងទៀតដោយសារហានិភ័យនោះមិនមានការពាក់ព័ន្ធទៅនឹងសកម្មភាពជាអាទិភាពជាក់លាក់ណាមួយនៃសមាភាគរបស់កជទី២។ ហានិភ័យដែលមានលក្ខណៈទូទៅ ឬលក្ខណៈជាម៉ាក្រូរួមមានក្នុងតារាងខាងក្រោម ៖

**តារាងទី ១២៖ ការគ្រប់គ្រងហានិភ័យដែលមានលក្ខណៈទូទៅ (កម្រិតកម្មវិធី)**

| ល.រ | ហានិភ័យ | ផលប៉ះពាល់ | លទ្ធភាពកើតមាន | វិធានការកាត់បន្ថយ |
|---|---|---|---|---|
| ១ | កំណើនសេដ្ឋកិច្ចទាបជាងការរំពឹងទុក ដែលនាំឱ្យខ្វះធានធានហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ | មធ្យម | ទាប | – បន្តផ្តោតការយកចិត្តទុកដាក់លើគោលបំណងដែលមានលក្ខណៈយុទ្ធសាស្ត្រនានានៃកំណែទម្រង់<br>– ចាត់អាទិភាពចំណាយសម្រាប់ការផ្តល់សេវាដែលមានផលប៉ះពាល់ខ្ពស់ |
| ២ | បញ្ហាបរិស្ថាន និងគ្រោះធម្មជាតិនាំឱ្យប៉ះពាល់ដល់កិច្ចប្រតិបត្តិការរបស់រាជរដ្ឋាភិបាល ឬបង្កឱ្យមានការកាត់បន្ថយអាទិភាពសម្រាប់ការងារកំណែទម្រង់ជាយុទ្ធសាស្ត្រនានា | មធ្យម | ទាប | – ពង្រឹងសមត្ថភាពការគ្រប់គ្រងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ជំងឺឆ្លងកាចសាហាវនានា និងភាពធន់នឹងការប្រែប្រួលអាកាសធាតុនៅរដ្ឋបាលគ្រប់កម្រិត |
| ៣ | ការបន្តការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលនាំឱ្យមានការពន្យារពេលក្នុងការចាប់ផ្តើមអនុវត្តសកម្មភាពនានានៃកម្មវិធី | មធ្យម | ខ្ពស់ | – ចាប់ផ្តើមអនុវត្តតែសកម្មភាពដែលមានលក្ខណៈជាយុទ្ធសាស្ត្រសមស្របមួយចំនួននៃកម្មវិធី |

តារាងគ្រប់គ្រងហានិភ័យដ៏ពេញលេញមួយនៃកម្មវិធីជាតិទាំងមូល ដែលរួមបញ្ចូលនូវហានិភ័យនានាពីគ្រប់សមាសភាគទាំងអស់ ដូចមានក្នុងឧបសម្ព័ន្ធ "ខ" ៖ ការគ្រប់គ្រងហានិភ័យនៃកជទី២ នឹងត្រូវដាក់បញ្ចូលនៅក្នុងឯកសារផអ៥ទី១ និងជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងហានិភ័យ។

**៤.៣.២. ការគ្រប់គ្រងហានិភ័យ**

ការគ្រប់គ្រងហានិភ័យ គឺជាការទទួលខុសត្រូវរបស់ គ.ជ.អ.ប. ក្នុងការសម្របសម្រួល និងដោះស្រាយនូវហានិភ័យទាំងនោះ។

តារាងស្តីពីការគ្រប់គ្រងហានិភ័យត្រូវពិនិត្យមើលឡើងវិញ និងធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំដោយលេខាធិការដ្ឋាន គ.ជ.អ.ប.ក្នុងអំឡុងពេលនៃការរៀបចំ ផ.ស.ថ.ប្រចាំឆ្នាំ នៃកម្មវិធីជាតិ។

លេខាធិការដ្ឋាន គ.ជ.អ.ប.ត្រូវវាយតម្លៃសម្រាប់ហានិភ័យនីមួយៗដូចខាងក្រោម ៖

- តើហានិភ័យនោះបានកើតឡើងនៅឆ្នាំមុនដែរឬទេ?
- តើលទ្ធភាពនៃការកើតឡើងនូវព្រឹត្តិការណ៍ឬស្ថានភាពនៃហានិភ័យនោះនៅឆ្នាំបន្ទាប់ មានការផ្លាស់ប្តូរដែរឬទេ បើប្រៀបធៀបនឹងកម្រិតនៃការកើតឡើងដែលបានកំណត់នៅក្នុងតារាងគ្រប់គ្រងហានិភ័យ?

– តើវិធានការនានាដោះស្រាយហានិភ័យនានានៅក្នុងតារាងគ្រប់គ្រងហានិភ័យបានដាក់បញ្ចូលក្នុង ផ.ស.ថ.ប្រចាំឆ្នាំ ដែរឬទេ?

កម្រិតផលប៉ះពាល់ជាទូទៅនៃហានិភ័យនីមួយៗ អាចត្រូវបានវាយតម្លៃបានដោយបូកសរុបផលប៉ះពាល់នៃហានិភ័យ និងលទ្ធភាពដែលអាចកើតឡើងនៃហានិភ័យ ដើម្បីកំណត់កម្រិតផលប៉ះពាល់នៃហានិភ័យនោះជាពណ៌ក្រហម ឬពណ៌ទឹកក្រូច ឬពណ៌បៃតង ស្របតាមតារាងដូចខាងក្រោម។

ជារួម ហានិភ័យទាំងអស់នៅក្នុងតារាងស្តីពីការគ្រប់គ្រងហានិភ័យសរុបមានចំនួន៣៩ ដែលក្នុងនោះ ហានិភ័យចំនួន២២ ត្រូវបានវាយតម្លៃជាពណ៌ក្រហម ចំនួន១៥ ជាពណ៌ទឹកក្រូច និងចំនួន២ ជាពណ៌បៃតង។

**តារាងទី ១៣៖ ការគ្រប់គ្រងហានិភ័យតាមការកំណត់ជាពណ៌**

| | លទ្ធភាពដែលអាចកើតមាននៃហានិភ័យ | | | |
|---|---|---|---|---|
| ផលប៉ះពាល់នៃហានិភ័យ | | ខ្ពស់ | មធ្យម | ទាប |
| | ខ្ពស់ | | | |
| | មធ្យម | | | |
| | ទាប | | | |



ក្នុងករណីដែលលេខាធិការដ្ឋាន គ.ជ.អ.ប.ពិនិត្យឃើញហានិភ័យមួយដែលបានកំណត់ជាពណ៌ "ក្រហម" ឬ "ទឹកក្រូច" ប៉ុន្តែពុំមានសកម្មភាពកាត់បន្ថយហានិភ័យនេះសមស្របនៅក្នុង ផ.ស.ថ.ប្រចាំឆ្នាំនោះទេ លេខាធិការដ្ឋាន គ.ជ.អ.ប.ត្រូវមានទំនាក់ទំនងជាមួយស្ថាប័នអនុវត្តពាក់ព័ន្ធ ដើម្បីផ្តល់ការបកស្រាយអំពីមូលហេតុដែលមិនបានដាក់បញ្ចូលនូវវិធានការកាត់បន្ថយហានិភ័យនេះឱ្យបានសមស្រប។

ក្នុងករណីដែលលេខាធិការដ្ឋាន គ.ជ.អ.ប.ពិនិត្យឃើញហានិភ័យមួយដែលបានកំណត់ជាពណ៌ "ក្រហម" ប៉ុន្តែពុំមានសកម្មភាពកាត់បន្ថយហានិភ័យនេះសមស្រប នៅក្នុងផ.ស.ថ.ប្រចាំឆ្នាំនោះទេ លេខាធិការដ្ឋាន គ.ជ.អ.ប.ត្រូវតែកត់សម្គាល់ហានិភ័យនេះឱ្យបានដាក់លាក់ក្នុងឯកសារ ផ.ស.ថ.ប្រចាំឆ្នាំ និងក្នុងរបាយការណ៍សង្ខេបមួយជូន គ.ជ.អ.ប.។

# ជំពូកទី ៥

## ការចំណាយនានា និងការផ្ដល់ហិរញ្ញប្បទាននៃកម្មវិធី

ចំណាយនានាសម្រាប់ការអនុវត្តកជទី២ រួមមាន ៖

- ចំណាយបន្ទុកបុគ្គលិករបស់លេខាធិការដ្ឋាន គ.ជ.អ.ប.
- ចំណាយការអនុវត្តសកម្មភាព និងលទ្ធផលរំពឹងទុកនានារបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ដែលមានកំណត់ក្នុងក្របខ័ណ្ឌលទ្ធផលនៃកជទី២ បន្ថែមជាមួយចំណាយសម្រាប់ការតាមដាន និងការវាយតម្លៃកម្មវិធី (ដែលចំណាយទាំងនេះចាត់ទុកជាចំណាយស្នូលនានារបស់កម្មវិធី)
- ចំណាយការអនុវត្តសកម្មភាព និងលទ្ធផលរំពឹងទុកនានារបស់ក្រសួង ស្ថាប័នអនុវត្តនានានៃការផ្ទេរធនធានហិរញ្ញវត្ថុគ្រប់ប្រភេទ (ការផ្ទេរធនធានមានជាប់លក្ខខណ្ឌ ការផ្ទេរធនធានគ្មានភ្ជាប់លក្ខខណ្ឌ ការផ្ដល់ហិរញ្ញប្បទានដល់គម្រោងវិនិយោគនានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោមក្របខ័ណ្ឌនៃការផ្ដល់ហិរញ្ញប្បទានដែលបានគាំទ្រដោយ កជទី២)
- ចំណាយសម្រាប់ការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី
- ចំណាយរបស់គម្រោង និងកម្មវិធីនានាដែលផ្ដល់ហិញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍នានាដើម្បីចូលរួមក្នុងការសម្រេចបាននូវលទ្ធផលរំពឹងទុកនានាក្នុងក្របខ័ណ្ឌលទ្ធផលនៃកជទី២ ដែលត្រូវបានចាត់ទុកជា គម្រោង/កម្មវិធីដាច់ដោយឡែកនានាដែលស្ថិតនៅក្នុងកជទី២។

ចំណាយប៉ាន់ស្មានប្រចាំឆ្នាំតាមប្រភេទចំណាយនីមួយៗមានបង្ហាញក្នុងតារាងខាងក្រោម ៖

**តារាងទី ១៤៖ ការប៉ាន់ស្មានតាមប្រភេទចំណាយនៃកម្មវិធីជាតិ**

| ប្រភេទចំណាយ | ចំណាយឆ្នាំ ២០២២ (គិតជាលានរៀល) |
|---|---|
| បន្ទុកបុគ្គលិករបស់លេខាធិការដ្ឋាន គ.ជ.អ.ប. | ២.១៥០ |
| ការអនុវត្តសកម្មភាព និងលទ្ធផលរំពឹងទុកនានារបស់លេខាធិការដ្ឋាន គ.ជ.អ.ប. និងការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី | ៩.៥០០ |
| ការអនុវត្តសកម្មភាព និងលទ្ធផលរំពឹងទុកនានារបស់ក្រសួង ស្ថាប័នអនុវត្តនានា | ១៧.៧២០ |

| | |
|---|---|
| ការផ្ទេរហិរញ្ញប្បទានពីថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ | ៣.៣៩៤.៨១៤ |
| គម្រោង/កម្មវិធីដាច់ដោយឡែក និងការគាំទ្រដទៃទៀតពីដៃគូអភិវឌ្ឍន៍ | ១៩០.០០០ |
| **សរុប** | **៣.៦១៤.១៨៤** |

ដូច្នេះ ចំណាយប៉ាន់ស្មានឆ្នាំ២០២២សម្រាប់ការអនុវត្តកម្មវិធីជាតិពីឆ្នាំ២០២១-២០៣០ មានចំនួនប្រមាណ ៣.៦១៤.១៨៤លានរៀល។

ភាគច្រើននៃចំណាយប៉ាន់ស្មានសរុប ត្រូវបានផ្តល់ហិរញ្ញប្បទានដោយរាជរដ្ឋាភិបាល តាមរយៈថវិការបស់ក្រសួង ស្ថាប័នអនុវត្តនានា និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ស្ថាប័នអនុវត្តទាំងអស់នឹងបញ្ចូលលទ្ធផលរំពឹងទុក និងសកម្មភាពនានានៃកជទី២ ទៅក្នុងផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន និងត្រូវបានផ្តល់ហិរញ្ញប្បទានជាអាទិភាពដល់លទ្ធផលរំពឹងទុក និងសកម្មភាពទាំងនេះ។

កជទី២ ក៏នឹងកៀរគរស្វែងរកការគាំទ្រផ្នែកហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍នានាផងដែរ។ ការគាំទ្រពីដៃគូអភិវឌ្ឍន៍នានា អាចចូលរួមចំណែកដោយផ្ទាល់ចំពោះចំណាយនានានៃលទ្ធផលរំពឹងទុក និងសកម្មភាពក្នុងក្របខ័ណ្ឌលទ្ធផលនៃកម្មវិធីជាតិ ឬអាចគាំទ្រដោយផ្តល់ហិរញ្ញប្បទានលើគម្រោង/កម្មវិធីដាច់ដោយឡែកនានាដែលមានការកំណត់ពីលទ្ធផលរំពឹងទុករបស់ខ្លួន ប៉ុន្តែលទ្ធផលរំពឹងទាំងនោះបានចូលរួមចំណែកក្នុងកម្រិតសមិទ្ធផលរំពឹងទុក និងគោលដៅនៃកជទី២។

គម្រោង/កម្មវិធីដាច់ដោយឡែកនានាដែលស្ថិតក្នុងក្របខ័ណ្ឌនៃកជទី២ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងផ.ស.ថ.ប្រចាំឆ្នាំរបស់កជទី២។ គម្រោង/កម្មវិធីដាច់ដោយឡែកនានាអាចអនុវត្តដោយក្រសួង ស្ថាប័នអនុវត្ត និង/ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ឬដោយអង្គការសង្គមស៊ីវិលនានា (ដែលចាត់ទុកជាប្រភេទនៃការចូលរួមគាំទ្រហិរញ្ញប្បទានរួមគ្នា)។

រាជរដ្ឋាភិបាលបានកំណត់ចំណុចដៅចំនួន១០% នៃចំណាយនានារបស់កម្មវិធីជាតិដែលត្រូវកៀរគរធនធានពីដៃគូអភិវឌ្ឍន៍នានា។ ប៉ុន្តែយោងតាមគម្រោងដោយឡែករបស់ដៃគូអភិវឌ្ឍន៍ដែលកំពុងអនុវត្តរួមមានថវិកាចូលរួមចំណែកពីគម្រោងទាំងនេះមានចំនួនជាង ៥% ប៉ុណ្ណោះ អាស្រ័យហេតុនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. ចាំបាច់ត្រូវខិតខំបន្តកៀរគរការចូលរួមចំណែកពីដៃគូអភិវឌ្ឍន៍ក្នុងការអនុវត្តផ.ស.ថ.ប្រចាំឆ្នាំនីមួយៗរបស់កជទី២ឱ្យបានតាមចំនួនដែលបានកំណត់ជាចំណុចដៅខាងលើនេះ។

# ជំពូកទី ៦

## សេចក្តីសន្និដ្ឋាន

ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ចក្នុងវិស័យសាធារណៈ គឺជាស្នូលនៃយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល ដែលជាមគ្គទេសក៍សម្រាប់ប្រទេសកម្ពុជាក្នុងការប្រែក្លាយឋានៈរបស់ខ្លួនទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០។ ការគួបផ្សំគ្នារវាងកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ច្បាប់ និងយុត្តិធម៌ក្នុងការបង្កើត នូវប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈទំនើប ស្វ័យភាព តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងមានការឆ្លើយតប គឺជាផ្នែកជាគន្លឹះមួយនៃកិច្ចខិតខំប្រឹងប្រែងនេះ។ កជទី២ នឹងកសាងបន្ថែមផ្អែកលើសមិទ្ធផលនានានៃកជទី១ និងដាក់ចេញនូវរបៀបវារៈនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិសម្រាប់រយៈពេលពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០។

ផ្អែកលើលទ្ធផល និងមេរៀនបទពិសោធន៍នៃកជទី១ បានបង្ហាញយ៉ាងច្បាស់ថា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការត្រូវអនុវត្តជាជំហានៗប្រកបដោយការប្រុងប្រយ័ត្ន ប៉ុន្តែក៏ត្រូវមានភាពច្បាស់លាស់ និងមានការតាំងចិត្តយ៉ាងមោះមុតពីថ្នាក់ដឹកនាំនៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិព្រមទាំងត្រូវអនុវត្ត ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធពីកម្មវិធីកំណែទម្រង់អភិបាលកិច្ចដទៃទៀត។ អាស្រ័យហេតុនេះ កជទី២នឹងផ្តោតការយកចិត្តទុកដាក់លើការពង្រឹងការដឹកនាំ និងការគ្រប់គ្រងការងារកំណែទម្រង់ ដើម្បីធានាដល់ការសម្រេចបាននូវលទ្ធផល និងសមិទ្ធផលរំពឹងទុកនានាដែលបានកំណត់។ ជាមួយគ្នានេះដែរ កជទី២ ក៏បានសង្កត់ធ្ងន់អំពីការផ្លាស់ប្តូរដែលបានរំពឹងទុកថានឹងកើតមានឡើងនាពេលអនាគតក្នុងអំឡុងពេលនៃការអនុវត្តកម្មវិធី ដើម្បីត្រៀមរៀបចំជាមុនក្នុងការសម្របសម្រួលការដោះស្រាយបញ្ហាប្រឈម និងហានិភ័យនានាដែលអាចកើតមានឡើងដោយសារការផ្លាស់ប្តូរចម្បងៗទាំងនោះ។

ជារួម តក្កភាពនៃការតាក់តែង កជទី២ គឺ ៖

- រចនាសម្ព័ន្ធ មុខងារ និងសិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រភេទផ្សេងៗគ្នានឹងត្រូវបានកំណត់យ៉ាងច្បាស់លាស់
- រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានផ្តល់នូវសិទ្ធិអំណាច សមត្ថភាព ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុនិងសម្ភារៈគ្រប់គ្រាន់ក្នុងការអនុវត្តមុខងារនានា ដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

- រដ្ឋបាលថ្នាក់ក្រោមជាតិនឹងផ្តល់នូវសេវាសាធារណៈនានា និងការអភិវឌ្ឍមូលដ្ឋានប្រកបដោយគុណភាពខ្ពស់ក្នុងការឆ្លើយតបនឹងតម្រូវការជាក់ស្តែង និងអាទិភាពរបស់ប្រជាពលរដ្ឋមូលដ្ឋានក្រោមការត្រួតពិនិត្យមើលពីលើរបស់ក្រុមប្រឹក្សា
- ការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមប្រកបដោយលក្ខណៈប្រជាធិបតេយ្យ បរិយាប័ន្ន និងសមធម៌សង្គម ការកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋទាំងអស់។

កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមានការពាក់ព័ន្ធ និងត្រូវចូលរួមដោយស្ថាប័ទាំងឡាយរបស់រាជរដ្ឋាភិបាល។ នៅពេលដែលការទទួលខុសត្រូវលើការផ្តល់សេវានានា និងការអភិវឌ្ឍមូលដ្ឋានត្រូវបានផ្ទេរពីក្រសួង ស្ថាប័នទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ឬផ្ទេរពីរដ្ឋបាលថ្នាក់ក្រោមជាតិដែលស្ថិតនៅកម្រិតខ្ពស់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្ថិតនៅកម្រិតទាបជាង នោះនឹងធ្វើឱ្យតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នដែលនៅកម្រិតខ្ពស់ត្រូវផ្លាស់ប្តូរពីការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានដោយផ្ទាល់ទៅជាតួនាទី និងការទទួលខុសត្រូវក្នុងការរៀបចំគោលនយោបាយ ការត្រួតពិនិត្យមើលពីលើ ការកំណត់ស្តង់ដារ ការកសាងសមត្ថភាព និងការត្រួតពិនិត្យតាមដាន។ ការផ្ទេរមុខងារនានាចាំបាច់ត្រូវផ្ទេរភ្ជាប់ទៅជាមួយនូវធនធានហិរញ្ញវត្ថុ បុគ្គលិក និងទ្រព្យសម្បត្តិពាក់ព័ន្ធនានា។ ដើម្បីជានាភាពជោគជ័យ កជទី២ ទាមទារនូវការចូលរួម និងការគាំទ្រយ៉ាងសកម្មពីគ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល។ ការអនុវត្ត កជទី២ ក៏ចាំបាច់ត្រូវរៀបចំឱ្យមានកិច្ចសហការ ការសម្របសម្រួល និងការគាំទ្រពីកម្មវិធីកំណែទម្រង់ផ្សេងទៀតដូចជា កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកំណែទម្រង់ច្បាប់ និងយុត្តិធម៌ និងកម្មវិធីកំណែទម្រង់វិស័យជាក់លាក់នានា ព្រមទាំងការបន្តពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានាដើម្បីជានាដល់ការសម្រេចបាននូវលទ្ធផល និងសមិទ្ធផលរំពឹងទុកនានា។

រាជរដ្ឋាភិបាលមានជំនឿជឿជាក់ថា កជទី២ នឹងនាំមកនូវសមិទ្ធផលជាច្រើនបន្ថែមទៀតសម្រាប់កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងការបង្វិតការផ្តល់សេវាសាធារណៈចាំបាច់នានា និងការអភិវឌ្ឍមូលដ្ឋានឱ្យកាន់តែកៀកជិតជាមួយប្រជាពលរដ្ឋ និងប្រកបដោយសមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម សំដៅរួមចំណែកក្នុងការសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ដើម្បីប្រែក្លាយប្រទេសកម្ពុជាជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅក្នុងឆ្នាំ២០៣០។

# សន្ទានុក្រម

| វាក្យស័ព្ទ | និយមន័យ |
|---|---|
| គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ | សំដៅលើវិធានការ យន្តការ និងនីតិវិធីនានាដែលប្រជាពលរដ្ឋ អាចទាមទារឱ្យរដ្ឋបាលរបស់ខ្លួនទទួលខុសត្រូវក្នុងប្រព័ន្ធប្រជាធិបតេយ្យ គឺការបោះឆ្នោត និងមានសភាពហុបក្ស។ គណនេយ្យភាពនយោបាយគឺជាគណនេយ្យភាពរបស់រដ្ឋាភិបាល មន្ត្រីរាជការស៊ីវិល និងអ្នកនយោបាយចំពោះសាធារណៈជនតាមរយៈស្ថាប័ននីតិបញ្ញត្តិ ដូចជារដ្ឋសភា។ គណនេយ្យភាពនយោបាយសំដៅលើប្រព័ន្ធប្រតិតុល្យការនៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋដែលធានានូវការទទួលខុសត្រូវរបស់មន្ត្រីសាធារណៈ និងស្ថាប័នរដ្ឋាភិបាល។គណនេយ្យភាពតាមបែបប្រជាធិបតេយ្យពាក់ព័ន្ធនឹងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការផ្តល់សេវានានាជូនប្រជាជន និងធានានូវសិទ្ធិមនុស្សនិងយុត្តិធម៌សង្គម។ ហើយនៅក្នុងបរិបទវិមជ្ឈការ មានន័យថា គឺជាការទទួលខុសត្រូវរបស់រដ្ឋបាល មន្ត្រីរាជការ និងអ្នកនយោបាយចំពោះសាធារណៈជនតាមរយៈក្រុមប្រឹក្សាដែលជាប់ឆ្នោត។ |
| គណនេយ្យភាពសង្គម | សំដៅទៅលើសកម្មភាព និងយន្តការនានាដែលប្រជាពលរដ្ឋអាចប្រើប្រាស់ ដើម្បីទាមទារឱ្យរដ្ឋបាលមានគណនេយ្យភាពចំពោះខ្លួន ព្រមទាំងសកម្មភាពនានារបស់រដ្ឋាភិបាល សង្គមស៊ីវិល និងតួអង្គដទៃទៀតក្នុងការលើកកម្ពស់ការអនុវត្តសកម្មភាព និងយន្តការទាំងនោះ។ |
| គណនេយ្យភាពខ្សែទទឹង | សំដៅទៅលើខ្សែគណនេយ្យភាពរវាងមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលខ្លួនកំពុងប្រតិបត្តិការនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនោះ។ |
| គណនេយ្យភាពខ្សែបណ្តោយ | សំដៅទៅលើខ្សែគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយក្រសួង ស្ថាប័នថ្នាក់ជាតិ ឬរវាងមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ន ដែលកំពុងប្រតិបត្តិការនៅថ្នាក់ក្រោមជាតិ ជាមួយក្រសួង ស្ថាប័នសាមី។ |
| គណនេយ្យភាពពីលើទៅក្រោម | សំដៅទៅលើខ្សែគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ឧទាហរណ៍៖<br>• រដ្ឋបាលថ្នាក់ក្រោមជាតិឆ្លើយតបទៅនឹងតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋជាពិសេសស្ត្រី កុមារ ក្រុមជនងាយរងគ្រោះ និងជនជាតិដើមភាគតិច និងផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាពជូនប្រជាពលរដ្ឋ |

| វាក្យស័ព្ទ | និយមន័យ |
|---|---|
| | • រដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំឱ្យមានយន្តការសម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំ និងអនុវត្តផែនការនិងថវិកា និងសេចក្ដីសម្រេចចិត្តនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• រដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំឱ្យមានយន្តការសម្រាប់ការពារសិទ្ធិនិងផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងផ្ដល់ព័ត៌មានដល់ប្រជាពលរដ្ឋ។ |
| គណនេយ្យភាពផ្ទៃក្នុង | សំដៅទៅលើគណនេយ្យភាពនៅក្នុងអង្គភាពចាត់តាំងមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនៅក្នុងរង្វង់រដ្ឋបាលមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ឧទាហរណ៍៖<br>• គណនេយ្យភាពរវាងគណៈអភិបាល និងទីចាត់ការនានារបស់រដ្ឋបាលខេត្ត "ក" ជាមួយក្រុមប្រឹក្សាខេត្ត "ក"<br>• គណនេយ្យភាពនៅក្នុងគណៈអភិបាលខេត្ត "ក"<br>• គណនេយ្យភាពនៅក្នុងទីចាត់ការនីមួយៗនៃរដ្ឋបាលខេត្ត "ក" ។ |
| គណនេយ្យភាពផ្នែកនយោបាយ | សំដៅទៅលើគណនេយ្យភាពរបស់អ្នកជាប់ឆ្នោតចំពោះប្រជាពលរដ្ឋ ឬអ្នកបោះឆ្នោតតាមរយៈការបំពេញតួនាទីក្នុងអាណត្តិរបស់ខ្លួន។ |
| គណនេយ្យភាពផ្នែកច្បាប់ | សំដៅទៅលើគណនេយ្យភាពចំពោះមុខច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។ |
| គណនេយ្យភាពផ្នែករដ្ឋបាល | សំដៅទៅលើគណនេយ្យភាពពាក់ព័ន្ធនឹងការរៀបចំប្រព័ន្ធគ្រប់គ្រងនីតិវិធីប្រតិបត្តិការ ស្តង់ដារ និងនិយាមការងាររបស់បុគ្គល និងអង្គការចាត់តាំងទៅតាមឋានានុក្រម។ |
| គណនេយ្យភាពផ្នែកហិរញ្ញវត្ថុ | សំដៅទៅលើគណនេយ្យភាពដែលពាក់ព័ន្ធនឹងការរៀបចំប្រព័ន្ធ និងនីតិវិធីគ្រប់គ្រងថវិកា និងហិរញ្ញវត្ថុស្របតាមច្បាប់ និងគោលការណ៍ហិរញ្ញវត្ថុសាធារណៈ។ |
| គណនេយ្យភាពអន្តររដ្ឋបាល | សំដៅទៅលើគណនេយ្យភាពរវាងក្រសួង ស្ថាប័ន មន្ទីរ ទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ជាមួយរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ឧទាហរណ៍៖<br>• គណនេយ្យភាពរវាងក្រសួង ស្ថាប័ន ជាមួយរដ្ឋបាលរាជធានី ខេត្ត ឬរដ្ឋបាលក្រុងស្រុក ខណ្ឌ ឬរដ្ឋបាលឃុំសង្កាត់<br>• គណនេយ្យភាពរវាងមន្ទីរ ទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ជាមួយរដ្ឋបាលរាជធានី ខេត្ត ឬរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬរដ្ឋបាលឃុំ សង្កាត់។ |

| វាក្យស័ព្ទ | និយមន័យ |
|---|---|
| គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ | សំដៅទៅលើគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ឬរវាងអង្គការចាត់តាំងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានប្រភេទដូចគ្នាឬប្រភេទផ្សេង។ ឧទាហរណ៍៖<br>• គណនេយ្យភាពរវាងរដ្ឋបាលខេត្ត "ក" និងខេត្ត "ខ"<br>• គណនេយ្យភាពរវាងរដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់<br>• គណនេយ្យភាពរវាងក្រុមប្រឹក្សាខេត្ត "ក" និងក្រុមប្រឹក្សាខេត្ត "ខ"<br>• គណនេយ្យភាពរវាងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់<br>• គណនេយ្យភាពរវាងគណៈអភិបាលខេត្ត "ក" និងគណៈអភិបាលខេត្ត "ខ"<br>• គណនេយ្យភាពរវាងគណៈអភិបាលរាជធានី ខេត្ត គណៈអភិបាលក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់។ |
| វិមជ្ឈការផ្នែករដ្ឋបាល | សំដៅលើការរៀបចំឡើងវិញ និងការប្រគល់ភារកិច្ចនិងមុខងារច្បាស់លាស់រវាងថ្នាក់រដ្ឋបាលនីមួយៗ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងតម្លាភាពរបស់រដ្ឋបាលនៅទូទាំងប្រទេស។ |
| រដ្ឋបាលមូលដ្ឋាន | សំដៅទៅលើថ្នាក់រដ្ឋបាលសាធារណៈទាបបំផុត។ |
| រដ្ឋបាលតំបន់ | សំដៅទៅលើថ្នាក់រដ្ឋបាលដែលកើតពីការប្រមូលផ្តុំនូវរដ្ឋបាលមូលដ្ឋានមួយចំនួនដែលស្ថិតនៅក្នុងភូមិសាស្ត្រជាមួយគ្នា។ |
| រដ្ឋបាលក្រុងម៉េត្រូលីតែន | សំដៅទៅលើរដ្ឋបាលនៅក្នុងទីក្រុងធំៗ ដែលមានចំនួនប្រជាជន និងលក្ខខណ្ឌភូមិសាស្ត្រតាមការកំណត់ជាក់លាក់ដែលត្រូវបានបង្កើតឡើង ដើម្បីផ្តល់ការសម្របសម្រួលរវាងរដ្ឋបាលចំណុះនានា ហើយដែលមានស្ថាប័នធ្វើសេចក្តីសម្រេចចិត្តត្រូវបានបង្កើតឡើងតាមរយៈការបោះឆ្នោត ព្រមទាំងជានីតិបុគ្គលមានស្វ័យភាពផ្នែកហិរញ្ញវត្ថុ និងផ្នែករដ្ឋបាលរបស់ខ្លួន។ |
| ការប្រគល់មុខងារ | សំដៅទៅលើការផ្ទេរភាពជាម្ចាស់លើមុខងារ ការទទួលខុសត្រូវ សិទ្ធិអំណាច និងធនធានុសិទ្ធិចាំបាច់ទាំងអស់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដើម្បីគ្រប់គ្រង និងអនុវត្តមុខងាររបស់ខ្លួន។ |
| សវនកម្មផ្ទៃក្នុងផ្នែកហិរញ្ញវត្ថុ | គឺជាដំណើរការនៃការត្រួតពិនិត្យទៅលើប្រតិបត្តិការ និងកិច្ចបញ្ជីការហិរញ្ញវត្ថុដែលធ្វើឡើងដោយសវនករផ្ទៃក្នុងដែលជាមន្ត្រី បុគ្គលិកនៅក្នុងអង្គភាព ស្ថាប័នរបស់ |

| វាក្យស័ព្ទ | និយមន័យ |
|---|---|
| | ខ្លួនផ្ទាល់ដើម្បីធានាដល់ភាពត្រឹមត្រូវនៃការអនុវត្តថវិកាទៅតាមគោលការណ៍ និងនីតិវិធីដែលបានកំណត់។ |
| សវនកម្មផ្ទៃក្រៅផ្នែកហិរញ្ញវត្ថុ | គឺជាដំណើរការនៃការត្រួតពិនិត្យទៅលើប្រតិបត្តិការ និងកិច្ចបញ្ជីការហិរញ្ញវត្ថុដែលធ្វើឡើងដោយសវនករឯករាជ្យ ដើម្បីធានាដល់ភាពត្រឹមត្រូវនៃការអនុវត្តថវិកាទៅតាមគោលការណ៍ និងនីតិវិធីដែលបានកំណត់។ |
| សវនកម្មផ្នែកសង្គម | សំដៅទៅលើដំណើរការដែលប្រជាពលរដ្ឋចូលរួមជាមួយរដ្ឋាភិបាល ស្ថាប័នឯករាជ្យ ឬអង្គការសង្គមស៊ីវិលក្នុងការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់ទៅលើការអនុវត្តសកម្មភាព ការផ្តល់សេវាសាធារណៈ កម្មវិធីឬគម្រោងជាក់លាក់ណាមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| សវនកម្មយេនឌ័រ | សំដៅទៅលើវិធីសាស្ត្រ និងដំណើរការសម្រាប់ធ្វើការប៉ាន់ប្រមាណ ដើម្បីឱ្យស្ថាប័ននានាមើលឃើញពីទំហំ និងកម្រិតនៃការប្តេជ្ញាចិត្ត ការគាំទ្រ និងការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំ និងបុគ្គលិកក្នុងការដោះស្រាយ និងឆ្លើយតបទៅនឹងបញ្ហាយេនឌ័រនៅក្នុងកម្មវិធី និងដំណើរការផ្ទៃក្នុងរបស់ស្ថាប័ននោះ និងដើម្បីកំណត់បាននូវដំណោះស្រាយ ឬកិច្ចអន្តរាគមន៍សមស្របឈានឆ្ពោះទៅលើកកម្ពស់សមភាពយេនឌ័រ។ |
| សិទ្ធិអំណាច | សំដៅលើលទ្ធភាពតាមផ្លូវច្បាប់ក្នុងការអនុវត្តនូវការទទួលខុសត្រូវដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដើម្បីកំណត់ និងដោះស្រាយតម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ |
| ការអភិវឌ្ឍសមត្ថភាព | សំដៅទៅលើការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ផ្តល់ឱកាសសិក្សារៀនសូត្រ និងការផ្តល់ព័ត៌មាន ទិន្នន័យ ឧបករណ៍ ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីចាំបាច់នានាដែលអនុញ្ញាតឱ្យបុគ្គលនិងស្ថាប័នសម្រេចបាននូវលទ្ធផលរំពឹងទុក និងគោលដៅដែលបានកំណត់។ |
| ការចូលរួមរបស់ប្រជាពលរដ្ឋ | សំដៅទៅលើដំណើរការនានា ដែលប្រជាពលរដ្ឋនៅតាមសហគមន៍រួមគ្នារៀបចំឡើង ដើម្បីចូលរួមផ្តល់យោបល់ ផ្តល់គំនិតនៅក្នុងដំណើរការរៀបចំ និងការធ្វើសេចក្តីសម្រេចចិត្តនានារបស់រដ្ឋបាលពាក់ព័ន្ធនឹងគោលនយោបាយ ដីកា និងលិខិតបទដ្ឋាននានា។ |
| ការប្រែប្រួលអាកាសធាតុ | សំដៅទៅលើការប្រែប្រួលសីតុណ្ហភាពនៃបរិយាកាសនៅជុំវិញផែនដី ជាពិសេសការកើនឡើងនៃកម្តៅ (ដែលអាចនាំឱ្យមានការប្រែប្រួលដល់របបទឹកភ្លៀង មានទឹកជំនន់ មានព្យុះ និងគ្រោះមហន្តរាយផ្សេងៗទៀត) ដែលបណ្តាលមកពីការកើន |

| វាក្យស័ព្ទ | និយមន័យ |
| --- | --- |
| | ឡើងនូវកំហាប់ឧស្ម័នផ្ទះកញ្ចក់។ ឧស្ម័នផ្ទះកញ្ចក់គឺជាស្រទាប់បរិយាកាសជុំវិញផែនដី ដែលផ្សំឡើងដោយសារចំហាយទឹក ឧស្ម័នកាបូនិច មេតាន ឌីអាសូតម៉ូណូអុកស៊ីត និងអូហ្សូន ហើយបើឧស្ម័នទាំងនោះកើតឡើងដោយធម្មជាតិ នោះឧស្ម័នផ្ទះកញ្ចក់នេះមានតួនាទីថែរក្សាសីតុណ្ហភាពបរិយាកាសសមស្របសម្រាប់ទ្រទ្រង់ជីវិតរុក្ខជាតិ និងសត្វនៅលើភពផែនដី។ |
| ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ | សំដៅទៅលើសមត្ថភាពរបស់មនុស្ស សត្វ រុក្ខជាតិ និងប្រព័ន្ធអេកូឡូស៊ីក្នុងការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ព្រមទាំងទាញយកលានុវត្តភាព ឬដោះស្រាយផលវិបាកនានាបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ ការបន្សាំអាចកើតឡើងដោយឯកឯង ឬដោយការគ្រោងទុកជាមុន។ |
| វិមជ្ឈការ | សំដៅទៅលើដំណើរការ ដែលរាជរដ្ឋាភិបាលប្រគល់ឱ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធាន ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់មូលដ្ឋាន។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋមូលដ្ឋានលើបញ្ហាទាំងនេះ។ |
| វិសហមជ្ឈការ | សំដៅទៅលើដំណើរការដែលរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន ធ្វើប្រតិភូកម្មមុខងារ សិទ្ធិអំណាច និងធនធានទៅអង្គភាពក្រោមបង្គាប់ ឬទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តក្នុងនាមរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន។ អង្គភាព ឬក្រុមប្រឹក្សានោះ ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នស្របទៅតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។ |
| ការធ្វើប្រតិភូកម្ម | សំដៅទៅលើដំណើការដែលរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន ផ្ទេរនូវការទទួលខុសត្រូវសិទ្ធិអំណាច និងឆន្ទានុសិទ្ធិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការធ្វើសេចក្តីសម្រេចចិត្ត ការអនុវត្ត និងការគ្រប់គ្រងកិច្ចការនិងធនធាននានា ហើយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នដែលបានធ្វើប្រតិភូកម្ម។ |
| ការធ្វើប្រតិភូកម្មមុខងារ | សំដៅទៅលើការផ្ទេរនូវមុខងារ ការទទួលខុសត្រូវ សិទ្ធិអំណាច និងឆន្ទានុសិទ្ធិ ទៅឱ្យរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគ្រប់គ្រង និងអនុវត្តមុខងារក្នុងនាមអាជ្ញាធរដែលធ្វើប្រតិភូកម្ម ដោយផ្អែកតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។ អាជ្ញាធរដែលបានធ្វើប្រតិភូកម្ម នៅតែរក្សាភាពជាម្ចាស់លើកិច្ចការ ឬមុខងារដែលបានធ្វើប្រតិភូកម្ម។ |

| វាក្យស័ព្ទ | និយមន័យ |
|---|---|
| ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ | សំដៅលើការអភិវឌ្ឍដែលដំណើរការដោយមានលក្ខណៈ៖ (១) ភាពជាតំណាងសាធារណៈ (២) ស្វ័យភាពរបស់មូលដ្ឋាន (៣) ការពិគ្រោះយោបល់និងការចូលរួម (៤) ការឆ្លើយតបនិងគណនេយ្យភាព (៥) ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន (៦) ការលើកស្ទួយសមធម៌ (៧) តម្លាភាពនិងសុចរិតភាព និង (៨) វិធានការប្រឆាំងអំពើពុករលួយនិងការរំលោភអំណាច។ |
| អភិបាលកិច្ចឌីជីថល | សំដៅទៅលើប្រព័ន្ធការងារដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដែលរដ្ឋបាលថ្នាក់ក្រោមជាតិប្រើប្រាស់ក្នុងការបំពេញការងាររបស់ខ្លួន រួមទាំងការងាររដ្ឋបាលផ្ទៃក្នុងរវាងអង្គភាពមួយទៅអង្គភាពមួយទៀត ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ ឧបករណ៍ឌីជីថល រួមមានគេហទំព័រ ប្រព័ន្ធផ្សព្វផ្សាយសង្គម អ៊ីនធឺណិត ហើយព័ត៌មាន ទិន្នន័យ និងសេវានានារបស់រដ្ឋបាលត្រូវបានផ្សព្វផ្សាយនៅលើអ៊ីនធឺណិត។ |
| រដ្ឋាភិបាលឌីជីថល | សំដៅទៅលើដំណើរការធ្វើទំនើបកម្មលើប្រព័ន្ធគ្រប់គ្រងរដ្ឋបាល និងសេវាសាធារណៈតាមរយៈការប្រើប្រាស់នូវបច្ចេកវិទ្យាឌីជីថល ដូចជាកុំព្យូទ័រ ឧបករណ៍ឆ្លាតវៃ និងប្រព័ន្ធអ៊ីនធឺណិត ដើម្បីជួយសម្រួលដល់ការគ្រប់គ្រងកិច្ចការរដ្ឋបាល ការសម្រេចចិត្ត និងការផ្តល់សេវាជូនប្រជាពលរដ្ឋ វិស័យឯកជន និងស្ថាប័នពាក់ព័ន្ធនានាប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងបរិយាប័ន្ន។ |
| ថ្នាលឌីជីថល | កម្មវិធីបច្ចេកវិទ្យាព័ត៌មានបង្កើតបានជាពិភពឌីជីថលបម្រើក្នុងគោលបំណងជាក់លាក់មួយ និងសម្រាប់សម្របសម្រួលអ្នកប្រើប្រាស់ធ្វើអន្តរសកម្ម និងអន្តរប្រតិបត្តិការជាមួយនឹងអ្នកពាក់ព័ន្ធនានា។ |
| អភិបាលកិច្ចតាមប្រព័ន្ធអេឡិចត្រូនិច | សំដៅទៅលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ (ICT) ដោយរដ្ឋបាលពិសេសប្រព័ន្ធអ៊ីនធឺណិត ក្នុងការផ្តល់ និងសម្រួលដល់ការផ្តល់សេវាសាធារណៈនានារបស់រដ្ឋាភិបាល ការផ្លាស់ប្តូរព័ត៌មាន និងការប្រាស្រ័យទាក់ទងផ្សេងៗ ដើម្បីធ្វើឱ្យការងាររបស់រដ្ឋបាលកាន់តែបានល្អប្រសើរ។ |
| ប្រជាធិបតេយ្យតាមប្រព័ន្ធអេឡិចត្រូនិក | សំដៅលើការលើកកម្ពស់ការចូលរួមឱ្យបានកាន់តែច្រើន និងយ៉ាងសកម្មរបស់ប្រជាជន តាមរយៈបច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យទាក់ទងក្នុងកិច្ចដំណើរការនានានៃការធ្វើសេចក្តីសម្រេចចិត្ត។ |

| វាក្យស័ព្ទ | និយមន័យ |
|---|---|
| សេវាតាមប្រព័ន្ធអេឡិចត្រូនិច | សំដៅលើការផ្តល់សេវានានាដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យទាក់ទងជូនប្រជាជន។ សេវាតាមប្រព័ន្ធអេឡិចត្រូនិចមានសមាសភាគសំខាន់ចំនួន៣ គឺអ្នកផ្តល់សេវា អ្នកទទួលសេវា និងមធ្យោបាយក្នុងការផ្តល់សេវា។ |
| វិមជ្ឈការសារពើពន្ធ | សំដៅលើការវិភាជថវិកាសម្រាប់ការចំណាយសាធារណៈ និងការប្រគល់ចំណូលនានាទៅឱ្យអាជ្ញាធរមូលដ្ឋាន ដើម្បីឱ្យអាជ្ញាធរមូលដ្ឋាន មានលទ្ធភាពក្នុងការប្រមូលចំណូលដោយខ្លួនឯងស្របតាមតួនាទី ភារកិច្ចដែលបានប្រគល់។ |
| មុខងារ | សំដៅទៅលើសកម្មភាពរបស់រដ្ឋាភិបាលក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សហគមន៍ តាមរយៈសកម្មភាពប្រកបដោយនិរន្តរភាព ហើយផ្តល់ផលប្រយោជន៍ដល់សហគមន៍។ ឧទាហរណ៍៖ សហគមន៍មួយត្រូវការទឹកស្អាតសម្រាប់ជីវភាពប្រចាំថ្ងៃរបស់ខ្លួន។ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលយកនូវមុខងារក្នុងការផ្តល់ទឹកស្អាតដល់សហគមន៍សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ តាមរយៈការបង្កើតហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត ព្រមទាំងយន្តការសម្រាប់គ្រប់គ្រង ថែទាំ និងត្រួតពិនិត្យគុណភាពទឹក។ ល។ |
| មុខងារជាកាតព្វកិច្ច | សំដៅទៅលើមុខងារត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាសតាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ដើម្បីសម្រេចបាននូវគោលបំណងជាកាតព្វកិច្ចមួយឬច្រើន ដែលបានកំណត់ដោយក្រសួង ស្ថាប័នថ្នាក់ជាតិ។ |
| មុខងារជាជម្រើស | សំដៅទៅលើមុខងារដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានឆន្ទានុសិទ្ធិ ក្នុងការបង្កើតការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដើម្បីឆ្លើយតបដោយផ្ទាល់ទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមិនមានការរំលោភ ឬផ្ទុយនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់ជាតិ។ |
| មុខងារជាអាណត្តិទូទៅ | ការយល់អំពីពាក្យនេះ គឺផ្អែកលើមាត្រា២៩នៃច្បាប់រៀបចំអង្គការ (ឆ្នាំ២០០៨) ដែលចែងថា៖ "ក្រុមប្រឹក្សាមានតួនាទីក្នុងការចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវ គោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្មតាមច្បាប់នេះ ឬដែលស្របតាមច្បាប់នេះ។ "មុខងារអាណត្តិទូទៅ" មានន័យថារដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុញ្ញាតឱ្យអនុវត្ត |

| វាក្យស័ព្ទ | និយមន័យ |
| --- | --- |
| | នូវមុខងារដែលពួកគេយល់ថាជាផលប្រយោជន៍របស់ប្រជាពលរដ្ឋមូលដ្ឋាន ដរាបណាមិនមានច្បាប់ហាមឃាត់”។ |
| អភិបាលកិច្ច | សំដៅទៅលើវិធីសាស្ត្រ ឬដំណើរដែលក្រសួង ស្ថាប័ន អង្គភាព ប្រើប្រាស់នូវសិទ្ធិ អំណាច មុខងារ និងធនធានក្នុងការគ្រប់គ្រង និងអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និង ការងារសន្តិសុខសណ្តាប់ធ្នាប់ ដោយមានការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធ ដើម្បី បម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ។ |
| មូលនិធិគ្មានភ្ជាប់ លក្ខខណ្ឌ | សំដៅទៅលើមូលនិធិដែលក្រុមប្រឹក្សាត្រូវប្រើប្រាស់ដើម្បី៖<br>• បំពេញភារកិច្ចតាមផ្លូវច្បាប់<br>• បំពេញមុខងារ ភារកិច្ចក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ<br>• ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន និង<br>• ជ្រើសរើស គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសនានា។ |
| មូលនិធិមាន លក្ខខណ្ឌ | សំដៅទៅលើមូលនិធិដែលក្រុមប្រឹក្សាត្រូវប្រើប្រាស់ដើម្បី៖<br>• គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាកាតព្វកិច្ចមួយឬច្រើនដែលត្រូវបាន ផ្ទេរទៅឱ្យក្រុមប្រឹក្សាតាមរយៈការប្រគល់មុខងារ ឬការធ្វើប្រតិភូកម្មមុខងារ<br>• បន្តគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសមួយឬច្រើនដែលក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលធ្លាប់បានអនុវត្ត ឬសម្រេចបាននូវគោលបំណង កាតព្វកិច្ចមួយឬច្រើនដែលបានកំណត់។ |
| ទំនាក់ទំនង អន្តររដ្ឋបាល | សំដៅទៅលើទំនាក់ទំនងរវាងក្រសួង ស្ថាប័ន មន្ទីរ និងទីភ្នាក់ងាររបស់ក្រសួង ស្ថាប័នជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិមួយទៅ រដ្ឋបាលថ្នាក់ក្រោមជាតិទៀត។ |
| ទំនាក់ទំនងអន្តររដ្ឋ បាលថ្នាក់ក្រោមជាតិ | សំដៅទៅលើទំនាក់ទំនងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ឬរវាងអង្គការចាត់តាំងនៃ រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានប្រភេទដូចគ្នា ឬប្រភេទផ្សេងគ្នា។ |
| ស្វ័យភាពមូលដ្ឋាន | សំដៅទៅលើស្ថានភាពដែលក្រុមប្រឹក្សាអាចម្ចាស់ការចាត់ចែង គ្រប់គ្រងនូវកិច្ចការ ដែលបានប្រគល់ ឬធ្វើប្រតិភូកម្មដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រកបដោយប្រសិទ្ធភាព។ |

| វាក្យស័ព្ទ | និយមន័យ |
|---|---|
| អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅមូលដ្ឋាន | សំដៅទៅលើវិធីសាស្ត្រ ឬដំណើរដែលក្រុមប្រឹក្សារដ្ឋបាលមូលដ្ឋានជាប់ឆ្នោតប្រើប្រាស់នូវសិទ្ធិអំណាច មុខងារ និងធនធានក្នុងការគ្រប់គ្រង និងអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងការងារសន្តិសុខសណ្តាប់ធ្នាប់ ដោយមានការចូលរួមស្មើភាពគ្នាពីគ្រប់តួអង្គពាក់ព័ន្ធមូលដ្ឋាន (ដូចជារដ្ឋបាលថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ សង្គមស៊ីវិល និងវិស័យឯកជន) ដើម្បីលើកកម្ពស់គណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ |
| គោលនយោបាយ (គោលនយោបាយសាធារណៈ) | សំដៅទៅលើឯកសារគោល សកម្មភាព គោលការណ៍ ឬសេចក្តីសម្រេចនានា ដែលមានគោលបំណងដើម្បី៖ (១) ឆ្លើយតបទៅនឹងបញ្ហានានាដែលសាធារណៈជនជួបប្រទះ (២) សម្របសម្រួលដំណើរការនយោបាយជាក់លាក់ណាមួយ និង (៣) ផ្តល់ជាក្របខ័ណ្ឌផ្លូវច្បាប់សម្រាប់ក្រសួង ស្ថាប័ន អង្គភាពនានាអនុវត្តតួនាទីភារកិច្ច ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច។ |
| កម្មវិធី | សំដៅទៅលើកិច្ចអន្តរាគមន៍ ឬសកម្មភាពនានាតាមពេលវេលាកំណត់ណាមួយ ដែលមានលក្ខណៈខុសពីគម្រោង ដែលជាទូទៅកម្មវិធីមានការពាក់ព័ន្ធជាមួយស្ថាប័នអនុវត្ត វិស័យជំនាញ និងតំបន់ភូមិសាស្ត្រមួយចំនួន ហើយការអនុវត្តកម្មវិធីត្រូវបានប្រើប្រាស់នូវវិធីសាស្ត្រ និងស្ថាប័នមួយចំនួន ព្រមទាំងមានការគាំទ្រថវិកាពីប្រភពផ្សេងៗគ្នា។ |
| តំណាងសាធារណៈ | មានន័យថាក្រុមប្រឹក្សាជាប់ឆ្នោតអនុវត្តការងាររបស់ខ្លួនក្នុងនាម និងធ្វើជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ |
| សេវាសាធារណៈ | សំដៅទៅលើរាល់សកម្មភាពទាំងឡាយ ដែលធ្វើឡើងដោយស្ថាប័នមានសមត្ថកិច្ច និងស្ថាប័នទទួលសមត្ថកិច្ច ក្នុងគោលបំណងបម្រើផលប្រយោជន៍សាធារណៈ។ ស្ថាប័នមានសមត្ថកិច្ច ក្នុងន័យនេះសំដៅលើស្ថាប័នរដ្ឋ ឬភ្នាក់ងាររដ្ឋ ឬអាជ្ញាធររដ្ឋគ្រប់ជាន់ថ្នាក់ដែលកំពុងបំពេញការងារតាមដែនសមត្ថកិច្ចរបស់ខ្លួន។ ស្ថាប័នទទួលសមត្ថកិច្ច ក្នុងន័យនេះ សំដៅលើផ្នែកឯកជន ឬសង្គមស៊ីវិលដែលទទួលបានសិទ្ធិ និងភារកិច្ចពីរដ្ឋ ហើយស្ថិតនៅក្រោមការគ្រប់គ្រងត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋ។ |
| ការឆ្លើយតប និងការទទួលខុសត្រូវ | មានន័យថាក្នុងនាមជាតំណាងប្រជាពលរដ្ឋក្នុងមូលដ្ឋាន ក្រុមប្រឹក្សាត្រូវឆ្លើយតបចំពោះប្រជាពលរដ្ឋរបស់ខ្លួន ក្នុងការធ្វើគោលនយោបាយ សេចក្តីសម្រេចចិត្ត សកម្មភាព និងការបំពេញភារកិច្ចរបស់ខ្លួន ប្រកបដោយការទទួលខុសត្រូវចំពោះ |

| វាក្យស័ព្ទ | និយមន័យ |
|---|---|
| | អ្វីដែលខ្លួនបានអនុវត្ត។ ក្រុមប្រឹក្សាក៏ទទួលខុសត្រូវចំពោះរាជរដ្ឋាភិបាលក្នុងការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានា។ |
| ការទទួលខុសត្រូវ | សំដៅទៅលើតួនាទី និងកាតព្វកិច្ចដែលបានប្រគល់ឱ្យដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តទៅឱ្យបុគ្គល អង្គការចាត់តាំងនៃរដ្ឋបាលណាមួយ ឬរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| យេនឌ័រ | សំដៅទៅលើផ្នត់គំនិត ឬការប្រព្រឹត្តរបស់គ្រួសារ សហគមន៍ និងសង្គមដែលពាក់ព័ន្ធនឹងការបែងចែកការងារ ពលកម្ម ការអប់រំ សិទ្ធិអំណាច លំដាប់ថ្នាក់ ឋានៈ និងតួនាទីដល់កូនស្រីនិងកូនប្រុស ឬស្ត្រីនិងបុរស។ ដូចជាការកំណត់របស់គ្រួសារលើការសិក្សារបស់កូនស្រី កូនប្រុស ការកំណត់ការងារសម្រាប់ក្មេងស្រី ក្មេងប្រុសរួមទាំងការងារផ្ទះសម្បែងជាដើម។ |
| ការបញ្ជ្រាបយេនឌ័រ | សំដៅទៅលើវិធីសាស្ត្រនៃការដាក់បញ្ចូលកង្វល់ពាក់ព័ន្ធនឹងយេនឌ័រទៅក្នុងការវិភាគ ការរៀបចំ និងការតាមដានត្រួតពិនិត្យគោលនយោបាយ កម្មវិធី និងគម្រោងអភិវឌ្ឍនានា ដើម្បីជានាដល់ការកាត់បន្ថយវិសមភាព និងគម្លាតយេនឌ័រ។ |
| បញ្ហាយេនឌ័រ | សំដៅទៅលើផលប៉ះពាល់ជាអវិជ្ជមានដែលកើតមកពីផ្នត់គំនិត ឬការប្រព្រឹត្តមកលើ បុរស ស្ត្រី ឬក្មេងប្រុស ក្មេងស្រីរបស់គ្រួសារ សហគមន៍ និងសង្គមតាមរយៈការចែកការងារ ពលកម្ម ការអប់រំ សិទ្ធិអំណាច លំដាប់ថ្នាក់ ឋានៈ និងតួនាទី។ ដូចជាការកំណត់ថា ក្មេងស្រីមិនគួររៀនច្រើនបានបណ្ដាលឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់ស្ត្រី និងក្មេងស្រី ពុំសូវមានចំណេះដឹងខ្ពស់ មានការលំបាកក្នុងការចូលរួមក្នុងការងារ សង្គម និងការទទួលបានព័ត៌មានជាដើម។ |
| សមភាពយេនឌ័រ | សំដៅទៅលើភាពគ្មានការរើសអើង ដែលប្រកាន់លើភេទណាមួយនៅក្នុងការបែងចែកធនធានផលប្រយោជន៍ ឬនៅក្នុងការទទួលបានសេវានានា។ សមភាពយេនឌ័រអាច វាស់វែងបានដោយការពិនិត្យមើលអំពីការមានកាលានុវត្តភាពស្មើគ្នា ឬការទទួលបាននូវលទ្ធផលដូចគ្នារបស់ស្ត្រី និងបុរស។ ក្នុងនោះសំដៅលើភាពស្មើគ្នាលើការចូលរួម ការទទួលបានការគ្រប់គ្រង និងការធ្វើសេចក្ដីសម្រេចរវាងបុរសនិងស្ត្រីទៅលើធនធានទ្រព្យសម្បត្តិ និងសកម្មភាពផ្សេងៗក្នុងវិស័យសាធារណៈ និងឯកជន។ |
| សមធម៌យេនឌ័រ | ជាដំណើរការនៃការប្រព្រឹត្តដោយយុត្តិធម៌ទៅលើស្ត្រី និងបុរសសំដៅឆ្ពោះទៅសមភាព យេនឌ័រតាមរយៈគោលនយោបាយច្បាប់ និងវិធានការនានា ដើម្បីកែ |

| វាក្យស័ព្ទ | និយមន័យ |
|---|---|
| | សម្រួលនូវភាពលម្អៀងដែលមាននៅក្នុងសង្គមចំពោះស្ត្រី និងបុរស។ ក្នុងនោះ សំដៅលើវិធានការ ឬសកម្មភាពពិសេសដាក់លាក់ក្នុងការបង្កឱកាស ការលើកទឹកចិត្តការជំរុញ ដើម្បីឈានទៅរកភាពស្មើគ្នារវាងបុរស និងស្ត្រីនៅក្នុងការងារសង្គម និងនៅក្នុងគ្រួសារ (សមភាពយេនឌ័រ)។ |
| សមធម៌សង្គម | សំដៅទៅលើសិទ្ធិប្រើប្រាស់ និងទទួលបានផលប្រយោជន៍ប្រកបដោយភាពយុត្តិធម៌នៃការផ្តល់សេវា ការអភិវឌ្ឍមូលដ្ឋាន ស្របតាមស្ថានភាពរូបរាងកាយ ស្ថានភាពសង្គម នយោបាយ ព្រមទាំងសិទ្ធិចូលរួមយ៉ាងពេញលេញនៅក្នុងកិច្ចការនយោបាយ និងវប្បធម៌នៅក្នុងសង្គម។ |
| បរិយាប័ន្ន | សំដៅលើការលើកកម្ពស់ការចូលរួម និងទទួលផលពេញលេញរបស់ប្រជាពលរដ្ឋគ្រប់រូប គ្រប់ក្រុម និងសហគមន៍សកម្មភាពនានារបស់សង្គមដោយគ្មានការរើសអើង។ |
| ការផ្ទេរមុខងារ | សំដៅទៅលើការប្រគល់ ឬការធ្វើប្រតិភូកម្មនូវមុខងារទៅឱ្យរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់ជាមួយនូវធនធាន និងសមត្ថភាព។ |
| តម្លាភាព | ការផ្តល់ព័ត៌មានទាន់ពេលវេលាពាក់ព័ន្ធ និងអាចជឿទុកចិត្តបានអាចចូលទៅដល់គ្រប់ភាគីពាក់ព័ន្ធ។ |
| តម្លាភាព និង សុចរិតភាព | សំដៅទៅលើការចាត់ចែង និងគ្រប់គ្រងកិច្ចការនានា រាប់បញ្ចូលទាំងកិច្ចការហិរញ្ញវត្ថុ ដោយអនុលោមតាមបទដ្ឋានខ្ពស់បំផុតនៃសុចរិតភាព និងច្បាប់ក្នុងលក្ខណៈបើកចំហ ប្រកបដោយតម្លាភាព ការចូលរួម និងការឆ្លើយតប។ |
| រដ្ឋបាលឯកភាព | សំដៅទៅលើការរៀបចំឱ្យមានក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិមួយ ដែលអាចម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារនិងធនធាន រួមទាំងហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ហើយក្រុមប្រឹក្សានីមួយៗនោះ មានសមត្ថភាពសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពនៃការផ្តល់សេវា និងការអភិវឌ្ឍផ្សេងៗទៀតដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រួមទាំងការផ្តល់សេវា និងការអភិវឌ្ឍដែលធ្វើឡើងដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល សំដៅឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ |
| ការបង្កើនភាពអង់អាចដល់ស្ត្រី | សំដៅទៅលើដំណើរការក្នុងការជួយស្ត្រីផ្នែកសង្គមកិច្ច សេដ្ឋកិច្ច នយោបាយ និង ច្បាប់ ដើម្បីឱ្យស្ត្រីអាចធ្វើសកម្មភាពក្នុងការពង្រឹងសិទ្ធិ សមត្ថភាព ការទទួលបាន |

| វាក្យស័ព្ទ | និយមន័យ |
|---|---|
| | នូវសេវាសាធារណៈ ការគ្រប់គ្រងធនធាន និងការចូលរួមដោយស្មើភាពនៅក្នុងកិច្ចការដែលពីមុនគេហាមឃាត់ ឬកម្រិតស្ត្រីមិនឱ្យចូលរួម។ |
| សាប់ស៊ីឌែរីធី | ជាគោលការណ៍នៃការធ្វើសេចក្តីសម្រេចចិត្តនានាដែលចែងថា សេចក្តីសម្រេចចិត្តទាំងឡាយត្រូវធ្វើឡើងដោយស្ថាប័ននៅកម្រិតទាបបំផុត ឬនៅកៀកជិតបំផុតជាមួយនឹងអ្នកទទួលសេវា ឬអ្នកទទួលផល ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តសេចក្តីសម្រេចចិត្តទាំងនោះដូចជា ការធ្វើសេចក្តីសម្រេចចិត្តដោយរដ្ឋបាលមូលដ្ឋានក្នុងទីតាំងភូមិសាស្ត្រជាក់លាក់ណាមួយ នឹងមានប្រសិទ្ធភាព ជាងការធ្វើសេចក្តីសម្រេចចិត្តទូលំទូលាយទូទាំងតំបន់ ឬទូទាំងប្រទេស។ |
| កម្មវិធីបណ្តុះបណ្តាល | ជាសំណុំនៃសកម្មភាពបណ្តុះបណ្តាលដែលបានរៀបចំឡើង តាមរយៈការវាយតម្លៃអំពីតម្រូវការបណ្តុះបណ្តាលក្នុងគោលបំណងលើកកម្ពស់សមត្ថភាពបុគ្គលិកសំដៅសម្រេចបាននូវបេសកកម្ម និងគោលដៅរបស់ស្ថាប័ន។ |
| កម្មវិធីសិក្សា | ជាកញ្ចប់សកម្មភាពនៃការសិក្សារៀនសូត្រដែលត្រូវបានរៀបចំឡើង ដើម្បីសម្រេចបាននូវគោលបំណងនានានៃកម្មវិធីបណ្តុះបណ្តាល។ |
| វគ្គជាកាតព្វកិច្ច | ជាវគ្គបណ្តុះបណ្តាលដែលតម្រូវឱ្យបុគ្គលិកទាំងអស់នៃស្ថាប័នមួយសិក្សារៀនសូត្រដើម្បីធានាសម្រេចបាននូវគោលនយោបាយ និងស្តង់ដានានារបស់ស្ថាប័ននោះ។ |
| មូលនិធិភាតរភាព | ជាមូលនិធិដែលបានមកពីការកាត់ចំណូលមួយចំណែកពីរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានចំណូលខ្ពស់ ដើម្បីបែងចែកទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងប្រភេទតែមួយដែលមានចំណូលតិចតួច ដើម្បីធានាកាត់បន្ថយនូវគម្លាតធនធាន និងការអភិវឌ្ឍរវាងតំបន់នានា។ |
| កញ្ចប់ថវិកាពិសេស | ជាកញ្ចប់ថវិកាពិសេសនៃថវិកាជាតិសម្រាប់ជួយគាំទ្រដោយឡែកដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសក្តានុពលតិចតួច ក៏ដូចជាការអភិវឌ្ឍបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនានាដែលជាតំបន់ប៉ូលសេដ្ឋកិច្ចសំខាន់ៗរបស់ជាតិ ដើម្បីធានាដល់ការកាត់បន្ថយនូវគម្លាតនៃការអភិវឌ្ឍរវាងតំបន់នានា និងការចូលរួមចំណែកដ៏មានប្រសិទ្ធភាពក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ។ |


កម្មវិធីជាតិ
ដំណាក់កាលទី២
ប្រជាពលរដ្ឋទទួលបានសេវាសាធារណៈ
និងផលប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ដោយ
រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គម
សមាសភាគ ទី១
ការដឹកនាំ និង ការសម្របសម្រួល ការងារ កំណែទម្រង់
សមាសភាគ ទី២
រចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រង រដ្ឋបាលថ្នាក់ក្រោមជាតិ
សមាសភាគ ទី៣
ការគ្រប់គ្រង និង ការអភិវឌ្ឍ ធនធានមនុស្ស
សមាសភាគ ទី៤
វិមជ្ឈការ ហិរញ្ញវត្ថុ និង ប្រព័ន្ធផែនការ និងថវិការបស់ រដ្ឋបាលថ្នាក់ក្រោមជាតិ
សមាសភាគ ទី៥
ការផ្តល់សេវាសាធារណៈ និង ការអភិវឌ្ឍ មូលដ្ឋាន
ការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម
ការគ្រប់គ្រងការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ
ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា